ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- បុណ្យនៃសេចក្តីស្រឡាញ់ ៖ សេចក្តីដឹងគុណចំពោះម្តាយ
- ការពិនិត្យលលាដ៍ក្បាល ៖ ការវិភាគឆ្អឹងសាកសពនៅជើងឯក

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២០៦ ខែកុម្ភៈ ឆ្នាំ២០១៧

# ស្វែងរកការពិត

លេខ២០៦ ខែកុម្ភៈ ឆ្នាំ២០១៧

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ បុណ្យនៃសេចក្តីស្រឡាញ់ ៖ សេចក្តីដឹងគុណចំពោះម្តាយ ....................១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាព អ៊ីវ អ៊ាង (អតីតគ្រូបង្រៀន) ប្រធានកង ....................២

◆ ចម្លើយសារភាពរបស់ ស៊ុន ហឿន ហៅ អ៊ឹម ប្រធានក្រសួង ..................៦

◆ ចម្លើយសារភាពរបស់ ហង់ បូ ប្រធានពេទ្យ កងពល១៧៤....................៩

◆ ទន្ទឹមនឹងចលនាធ្វើស្រែ យើងត្រូវសម្រុកដាំដំណាំផ្សេងៗទៀត................១៣

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ រួចជីវិតព្រោះចេះធ្វើស្រែចម្ការ ...................................................១៨

◆ ការចែករំលែកបទពិសោធន៍ពីរបបខ្មែរក្រហម ពីលោក លឹម ហម ...........២២

◆ ខួត ខន ៖ អតីតយោធាខ្មែរក្រហម ................................................២៤

◆ ខ្មែរក្រហមសម្លាប់ឪពុក និងតារបស់ខ្ញុំ ...........................................២៥

◆ ជីវិតជាទាហានក្នុងរបបខ្មែរក្រហម ..................................................២៦

◆ មិនដឹងសោះថា ខ្លួនឯងជាខ្មែរក្រហម............................................២៨

◆ ការចងចាំរបស់ មាស ពៅ.........................................................២៩

◆ ស៊ាយ សំបួរ អតីតអនុលេខាស្រុកសំរោងទង.................................៣១

◆ កងទ័ពវៀតកុង បានផ្តាច់ស្ពាន "មិត្តភាព កម្ពុជា-ជប៉ុន" .....................៣៤

**ផ្នែកច្បាប់**

◆ ដើមបណ្តឹងរដ្ឋប្បវេណី និង សាក្សីផ្តល់សក្ខីកម្ម ...............................៣៧

◆ សក្ខីកម្មរបស់សាក្សី ស៊ិន អ៊ីង...................................................៤៣

◆ ការពិនិត្យលលាដ៏ក្បាល ៖ ការវិភាគឆ្អឹងសាកសពនៅជើងឯក ............៤៧

**វេទិកាពិភាក្សាសាធារណៈ**

◆ ចំណាប់អារម្មណ៍របស់សិស្សវិទ្យាល័យព្រះយុគន្ធរចំពោះប្រវត្តិ............៥០

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ គេរង់ចាំណែលដេះផង់សល់ពីរបបខ្មែរក្រហម.....................................៥២

◆ សល់មួយគ្រាប់ .......................................................................៥៧



គ្រួសារប្រជាជនក្នុងរបបខ្មែរក្រហម

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ*** ៖ *ហេង សុរីតា, សេង ស្រីលក្ខណ៍, កង ធី, កុយ សៅសូយ៉ាន, សន ឆវីវតី, គិត ស្រីពៅ, សុខ វណ្ណៈ, លីអូនី គីដេស្តី, សៀវ សុផុន, ហែម សុវណ្ណារិទ្ធិ* ***អ្នកនិពន្ធនិងស្រាវជ្រាវ*** ៖ *ទាវ សារៈមុនិន្ទ* ***អ្នកបកប្រែ*** ៖ *ឈឹម អមរ័ត្ន និង ឯម សីលា* ***និពន្ធនាយកទូទៅ*** ៖ *ឆាំង យុ* ***ជំនួយការនិពន្ធនាយក*** ៖ *សោម ប៊ុនថន* ***ក្រាហ្វិកកុំព្យូទ័រ*** ៖ *សោម ប៊ុនថន* ***គ្រប់គ្រងការចែកផ្សាយ*** ៖ *ឆេង វើង* **Email: dccam@online.com.kh, Homepage: www. d.dccam.org, www.cambodiatribunal.org, www.cambodiasri.org, www.truthcambodia.com**

# បុណ្យនៃសេចក្ដីស្រឡាញ់ ៖
# សេចក្ដីដឹងគុណចំពោះម្ដាយនៅថ្ងៃបុណ្យនៃសេចក្ដីស្រឡាញ់

ថ្ងៃបុណ្យនៃសេចក្ដីស្រឡាញ់ គឺជាថ្ងៃបង្ហាញនូវមនោសញ្ចេតនាចំពោះអ្នកដែលជាទីស្រឡាញ់ ។ ក្នុងឱកាសនេះ ខ្ញុំចង់រំឭកអំពីសេចក្ដីស្រឡាញ់ដែលម្ដាយខ្ញុំមានចំពោះរូបខ្ញុំក្នុងអំឡុងពេលដ៏សែនវេទនា ។ វាជាការពិតដែលនិយាយថា សេចក្ដីស្រឡាញ់ និងការសណ្ដោសប្រណី គឺជាពន្លឺដ៏ចែងចាំងក្នុងភាពងងឹត និងភាពអស់សង្ឃឹម ហើយការចងចាំដែលនៅជិតជាប់ក្នុងអារម្មណ៍ខ្ញុំបំផុត គឺពាក្យសម្ដីរបស់ម្ដាយខ្ញុំដែលនិយាយមកកាន់ខ្ញុំក្នុងសម័យសុបិន្ដដ៏អាក្រក់ខ្មែរក្រហម ។

នាសម័យនោះ ខ្ញុំគ្រាន់តែជាក្មេងប្រុសម្នាក់ ហើយខ្ញុំមិនដឹងពីវិធីរស់នៅគឺជាអ្វីនោះទេ ។ អាហារ គឺជាទេវតា ហើយការដេកស្កប់ស្កល់ គឺជាអ្វីដែលពិសេសបំផុតក្នុងជីវិត ។ ខ្ញុំរៀនរស់ព្រោះការស្រេកឃ្លាន គឺជាគ្រូដ៏មានអំណាច ។ ខ្ញុំបង្រៀនខ្លួនឯងឲ្យចេះហែលទឹក និងកាប់អំពៅដុះក្នុងស្រែដែលពេញដោយទឹកជំនន់ ។ ខ្ញុំរៀនលួច ហើយហូបអាហារគ្រប់ប្រភេទ មានជាស្លឹកឈើ, សត្វកណ្ដុរ និងពស់ ។ ប៉ុន្ដែមានចំណុចមួយដែលខ្ញុំមិនបានរៀន គឺខ្ញុំមិនដឹងធ្វើយ៉ាងណាដើម្បីរកក្ដីសង្ឃឹមនោះទេ ។ ម្ដាយខ្ញុំបានឲ្យមេរៀននៃក្ដីសង្ឃឹមនេះមកខ្ញុំ ។ គាត់ប្រាប់ខ្ញុំថា គាត់យល់សប្ដិឃើញខ្ញុំអង្គុយលើភ្នំព្រះនេត្រព្រះ ហើយសម្លឹងមើលទៅឆ្ងាយ ។ គាត់ប្រាប់ខ្ញុំថា នេះគឺជាសញ្ញាដែលខ្ញុំអាចមានជីវិតរស់នៅ ។ សម្ដីរបស់គាត់ បានឲ្យក្ដីសង្ឃឹមមកខ្ញុំ ហើយខ្ញុំមិនដែលភ្លេចពីតម្លៃអំណោយនេះមកទល់សព្វថ្ងៃ ។

សុបិន្ដម្ដាយខ្ញុំបានជួយឲ្យខ្ញុំរស់រានមានជីវិតពីរបបខ្មែរក្រហម ហើយនៅថ្ងៃនេះ ដើម្បីបង្ហាញពីសេចក្ដីស្រឡាញ់ដល់អ្នកដែលជាទីស្រឡាញ់ ខ្ញុំអរគុណដល់ម្ដាយខ្ញុំ ហើយប្រាប់គាត់ថា គាត់មានសារសំខាន់ណាស់នៅក្នុងជីវិតរបស់ខ្ញុំ ។

**ឆាំង យុ**



រូបថតជួរខាងមុខ រាប់ពីឆ្វេង ៖ យាយ កែវ ណាន (ម្ដាយលោក ឆាំង យុ) លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងលោក ហួ ហ៊ុយ អតីតមេឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយ នៅក្នុងពិធីបណ្ដុះបណ្ដាលគ្រូ ស្ដីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅសាលប្រជុំព្រឹទ្ធសភា កាលពីថ្ងៃ២ ខែតុលា ឆ្នាំ២០១០ ។

# ចម្លើយសារភាព អ៊ីវ អ៊ាង (អតីតគ្រូបង្រៀន) ប្រធានកងធំកងចល័ត ឃុំឱម៉ាល់ ស្រុកភ្នំសំពៅ តំបន់៣ ពាយ័ព្យ

*សង្ខេបចេញពីឯកសារចម្លើយសារភាពលេខ D៤១២៧៤*

អ៊ីវ អ៊ាងភេទប្រុស មានអាយុ៤១ឆ្នាំ កើតនៅឃុំឱម៉ាល់ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ជាអតីតគ្រូបង្រៀននៅសាលាបឋមសិក្សាបឹងរាំង ។ មុនចាប់ខ្លួន (ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ) គាត់មានតួនាទីជាប្រធានកងធំ កងចល័តឃុំ ផ្នែកនារីចូលថ្មី នៅឃុំឱម៉ាល់ ស្រុកភ្នំសំពៅ តំបន់៣ ។ មានបងប្អូនបង្កើតចំនួន៤នាក់ (ប្រុស៣នាក់ និង ស្រីម្នាក់) ។ អ៊ាង ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៧៧ ។ ចម្លើយសារភាពរបស់ អ៊ាង សរសេរដោយដៃមានចំនួន២៩ទំព័រ និងមានបញ្ជីរាយឈ្មោះកម្លាំងក្បត់ចំនួន៧ទំព័រផ្សេងទៀត សរុបកម្លាំងក្បត់ចំនួន៦៨នាក់ ។ យើងមិនដឹងថា ចម្លើយសារភាពរបស់ អ៊ាង ជាចម្លើយពិត ឬយ៉ាងណានោះទេ ។ ខាងក្រោមនេះជាសេចក្តីសង្ខេបស្រង់ចេញមកពីចម្លើយរបស់ អ៊ាង៖

តាំងពីតូចមក អ៊ាង រស់នៅក្នុងបន្ទុកឪពុកម្តាយ ។ នៅឆ្នាំ១៩៥០-១៩៥២ បានចូលរៀននៅសាលាបឋមសិក្សាបឹងរាំងពីថ្នាក់ទី១២ ដល់ថ្នាក់ទី១០ ។ ឆ្នាំ១៩៥៣-៥៥ អ៊ាង បានចូលរៀននៅមជ្ឈមសាលា ក្រុងបាត់ដំបងពីថ្នាក់ទី៩ ដល់ថ្នាក់ទី៧ ។ ឆ្នាំ១៩៥៦ បានបន្តចូលរៀននៅវិទ្យាល័យព្រះមុនីវង្សរហូតដល់ថ្នាក់ទី៣ទំនើប ។ នៅក្នុងថ្នាក់រៀន អ៊ាង បានរាប់អានមិត្តភក្តិស្និទ្ធស្នាលចំនួនប្រាំនាក់មានឈ្មោះ ១) ហួ ហូយ (ឆ្នាំ១៩៦១ ធ្វើការនៅសាលាខេត្តបាត់ដំបង), ២) កែវ ហែល (ឆ្នាំ១៩៦១ ធ្វើគ្រូបង្រៀន) បច្ចុប្បន្នស្លាប់, ៣) គី សារី (ឆ្នាំ១៩៦១ ធ្វើគ្រូបង្រៀន) បច្ចុប្បន្ន ស្លាប់, ៤) ស៊ីន សុវណ្ណ (ឆ្នាំ១៩៦១ ធ្វើគ្រូបង្រៀន) បច្ចុប្បន្ន ស្លាប់ និងទី៥) ជា សុវណ្ណ (ឆ្នាំ១៩៦១ ធ្វើគ្រូបង្រៀន) បច្ចុប្បន្នស្លាប់ ។ ឆ្នាំ១៩៥៧ អ៊ាង និងមិត្តភក្តិទាំងបួន បានឯកភាពគ្នាទៅសុំចម្លងសំបុត្រកំណើតទុកសម្រាប់ប្រើប្រាស់ពេលប្រឡងឌីប្លូម ពេលនោះបានទាក់ទងជាមួយឈ្មោះ អ៊ុក វ៉ា ដែលជាចៅហ្វាយស្រុកបាត់ដំបង ។ បន្ទាប់មក អ្នកទាំងប្រាំត្រូវបាន អ៊ុក វ៉ា



រូបថតរណ្តៅសាកសព និងឆ្អឹងរបស់ជនរងគ្រោះ ។ រណ្តៅទាំងនេះត្រូវបានគាស់ ហើយឆ្អឹង និងលលាដ៏ក្បាលរបស់ជនរងគ្រោះត្រូវបានរាប់ក្រោយរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩ ។

អូសទាញឲ្យធ្វើគិញ ដើម្បីចាប់អ្នកលេងល្បែងស៊ីសងតាមភូមិ តាមផ្ទះ រៀងរាល់ថ្ងៃព្រហស្បតិ៍ ថ្ងៃអាទិត្យ និងថ្ងៃឈប់សម្រាក ផ្សេងៗ ហើយត្រូវរាយការណ៍ឲ្យគាត់ (អ៊ុក វ៉ា) វិញ គាត់នឹងឲ្យជាប្រាក់ខែ ។ ពេលនោះអ្នកទាំងប្រាំក៏បានយល់ព្រមចូលធ្វើគិញឲ្យឈ្មោះ អ៊ុក វ៉ា ចាប់ពីពេលនោះមក ។

អ៊ាង និងមិត្តទាំងបួននាក់ បានធ្វើសកម្មភាពដើរចាប់អ្នកលេងល្បែងស៊ីសង ហើយបានរាយការណ៍ជូន អ៊ុក វ៉ា ជាបន្តបន្ទាប់ ។ បន្ទាប់មក វ៉ា ក៏បានបញ្ចុះបញ្ចូលអ្នកទាំងប្រាំជាសមាជិក សេ.អ៊ី.អា ។ មួយខែក្រោយមក វ៉ា បាននាំអ្នកទាំងប្រាំឲ្យទៅជួបឈ្មោះ ទឹម ផ្លូន ជាចៅហ្វាយខេត្តបាត់ដំបង ឲ្យទទួលស្គាល់អ្នកទាំងប្រាំជាសមាជិក សេ.អ៊ី.អា ។ ពេលនោះកម្មវិធីបញ្ចូលសមាជិក សេ.អ៊ី.អា ក៏បានរៀបចំឡើង ដោយមាន ១) ទឹម ផ្លូន ចៅហ្វាយខេត្តបាត់ដំបង ជាប្រធាន, ២) នូ គាល់ ចាងហ្វាងសាលាដំបូងខេត្តបាត់ដំបង ជាអនុប្រធាន, ៣) អ៊ុក វ៉ា ចៅហ្វាយស្រុកបាត់ដំបង ជាសមាជិក, ៤) ហ៊ិច ជនជាតិអាមេរិក និង៥) អ្នកបកប្រែភាសាខ្មែរ (មិនស្គាល់ឈ្មោះ) ។ បន្ទាប់ពីពិធីគោរពទង់ជាតិខ្មែរ និងទង់ជាតិអាមេរិកាំង ចប់សព្វគ្រប់រួចមក វ៉ា បានឡើងធ្វើការធានាអះអាងទទួលខុសត្រូវចំពោះអ្នកទាំងប្រាំនៅចំពោះមុខអង្គប្រជុំ ពេលនោះ ទឹម ផ្លូន ដែលជាប្រធាន ក៏បានប្រកាសទទួលស្គាល់អ្នកទាំងប្រាំជាសមាជិក សេ.អ៊ី.អា ជាផ្លូវការ រួចហើយអ្នកទាំងប្រាំក៏បានឡើងប្ដេជ្ញាចិត្តម្នាក់ម្ដងៗ ដោយនិយាយថា មិនក្បត់ វៀចវេរពីអង្គការ សេ.អ៊ី.អា នេះឡើយ បើក្បត់ សូមឲ្យអង្គការនេះផ្ដន្ទាទោសចុះ ។ ពេលចប់ពិធីបញ្ចូលសមាជិក សេ.អ៊ី.អា ហើយ ទឹម ផ្លូន បានដាក់ផែនការឲ្យអនុវត្តគឺ ៖ ១) ស្មោះត្រង់នឹងអង្គការ សេ.អ៊ី.អា ជារៀងរហូត ២) ខិតខំកសាងកម្លាំង សេ.អ៊ី.អា ឲ្យបានច្រើន ៣) អប់រំប្រជាជនឲ្យប្រឆាំងនឹងពួកកុម្មុយនីស្ត ។

នៅឆ្នាំ១៩៥៨-ឆ្នាំ១៩៥៩ វ៉ា បានចាត់ អ៊ាង និងបក្ខពួក ឲ្យទៅតាមដានសិស្សនៅអនុវិទ្យាល័យមោង និងអនុវិទ្យាល័យស៊ីសុផុន តែការតាមដាននៅពេលនោះ មិនបានទទួលលទ្ធផលអ្វីទេ ។ ដល់ឆ្នាំ១៩៦០ វ៉ា បានខទ្មេសនាមឲ្យ អ៊ាង មកជួបទាក់ទងជាមួយឈ្មោះ ឌិម ណាគ្រី (អតីតគ្រូបង្រៀនសាលាឯកជន និងជាអ្នកនិពន្ធសៀវភៅ) ដើម្បីរកបក្ខពួកខ្មែរក្រហមនៅភ្នំពេញ ។ ពេលនោះ ណាគ្រី បានណែនាំឲ្យ អ៊ាង ឲ្យស្គាល់ខ្មែរពីរនាក់មានឈ្មោះ អ៊ិក ឃិន (គ្រូបង្រៀនសាលាឯកជននៅកំពត) និងឈ្មោះ នូ ផុន (អតីតគរុសិស្សនៅសាលាគរុកោសល្យ) ។ បន្ទាប់ពីបានស្គាល់គ្នាហើយ អ៊ាង និងបក្ខពួកទាំងអស់ បានដើរអប់រំប្រជាជនឲ្យប្រឆាំងនឹងបក្សកុម្មុយនីស្ត និងតាមដានរកមេដឹកនាំ និងដៃជើងដែលជាបរិវាររបស់ខ្មែរក្រហម ។

ឆ្នាំ១៩៦១ អ៊ាង និងបក្ខពួក បានវិលត្រឡប់ទៅធ្វើការនៅឯខេត្តបាត់ដំបងវិញ និងបានទៅបង្រៀននៅសាលាស៊ីសុផុន ។ នៅពេលនោះ វ៉ា បានខទ្មេសនាមឲ្យ អ៊ាង ធ្វើការទាក់ទងជាមួយឈ្មោះ ខាំ ឈឿក ជាចាងហ្វាងសាលាស៊ីសុផុន នៅពេលនោះដែរ ឈឿក បានណែនាំឲ្យស្គាល់ខ្មែរពីរនាក់ផ្សេងទៀតឈ្មោះ ត្រៃ ភឿយ និង សៀង ប៉ៃ ជាគ្រូបង្រៀននៅសាលាស៊ីសុផុន ។ អ៊ាង បានធ្វើសកម្មភាពនៅក្នុងសាលាដោយបានអប់រំសិស្សឲ្យយល់ពីការលំបាកនៃការរស់នៅរបស់ប្រជាជនដែលជាជនកុម្មុយនីស្ត និងអប់រំសិស្សឲ្យប្រឆាំងនឹងបក្សកុម្មុយនីស្ត ។ ក្រៅពីនេះ អ៊ាង បានកសាងកម្លាំងបានម្នាក់ ដែលជាមិត្តធ្លាប់រៀនជាមួយគ្នាឈ្មោះ សុស ស៊ីមឿង (អតីតគ្រូបង្រៀននៅសាលាមង្គលបូរី) ដោយបានអប់រំពន្យល់ និងធ្វើការប្រៀបធៀបពីការរស់នៅក្នុងរបបកុម្មុយនីស្តទៅនឹងប្រទេសសេរី ។ បន្ទាប់ពីកសាងបានហើយ អ៊ាង ក៏បានរាយការណ៍ឲ្យ វ៉ា បានដឹង ។

ឆ្នាំ១៩៦២-១៩៦៦ អ៊ាង បានប្ដូរមកបង្រៀនសិស្សនៅសាលាបឹងរាំង ហើយបានរាយការណ៍ប្រាប់ វ៉ា ឲ្យបានដឹងពីទីកន្លែងធ្វើការថ្មីរបស់ខ្លួន ។ ពេលនោះ វ៉ា បានខទ្មេសនាមឲ្យ អ៊ាង ធ្វើការទាក់ទងឈ្មោះ អ៊ឹម ឃឹន (អតីតចាងហ្វាងសាលាបឹងរាំង ស្លាប់ឆ្នាំ១៩៧៧) ជាខ្សែចាត់តាំងចាស់ ឲ្យបន្តធ្វើសកម្មភាពអប់រំសិស្ស និងប្រជាជនឲ្យប្រឆាំងនឹងកុម្មុយនីស្ត ។ បន្ទាប់មក អ៊ាង រួមជាមួយ ឃឹន និងបក្ខពួកចំនួនប្រាំនាក់ទៀត បានដើរតាមភូមិពន្យល់អប់រំប្រជាជនឲ្យស្គាល់ពីជីវភាពរស់នៅប្រកបដោយទុក្ខលំបាកក្នុងការរស់នៅជាមួយពួកកុម្មុយនីស្ត គឺបង្ខំឲ្យធ្វើការ ហើយពេលបានផលប្រមូលយកអស់ ការហូបចុកក៏មានរបបកំណត់ ចង់ដើរហើរក៏មិនបាន រស់នៅគ្មានសេរីភាពជាដើម ។ ក្រោយមក អ៊ាង បានកសាងកម្លាំងបានម្នាក់ទៀតឈ្មោះ ណុំ វ៉ាន់ ជាអតីតគ្រូ

បង្រៀននៅថ្មគោល ធ្លាប់រាប់អាន និងរៀនជាមួយគ្នា ។

ដើមឆ្នាំ១៩៦៧ អ៊ាង បានចូលរួមប្រជុំនៅមជ្ឈិមសាលាបាត់ដំបងក្រុង ជាមួយគ្រប់ប្រធានក្រសួងក្នុងខេត្ត គ្រប់ចៅហ្វាយស្រុក អ្នកមុខអ្នកការ នាយទាហាន និងភ្នាក់ងារ សេ.អ៊ី.អា ទាំងអស់ ក្រោមការដឹកនាំរបស់ សេក សំអៀត អតីតចៅហ្វាយខេត្តបាត់ដំបង ។ ក្នុងឱកាសនោះ សំអៀត បានធ្វើការអំពាវនាវដល់ប្រជាជនទាំងអស់ក្នុងខេត្តឲ្យចេះសាមគ្គីគ្នា ពួតដៃទៅវាយកម្ទេច បោសសម្អាតខ្មែរក្រហមឲ្យអស់ពីតំបន់នេះ ។ ឆ្លើយតបទៅនឹងសេចក្តីប្រកាសរបស់ចៅហ្វាយខេត្ត ឱ អ៊ុក តំណាងឲ្យគ្រូក្នុងខេត្តបាត់ដំបង បាននិយាយថា គ្រូទាំងអស់ស្ម័គ្រចិត្តទៅវាយបោសសម្អាតខ្មែរក្រហមឲ្យអស់ ។ ថ្ងៃបន្ទាប់ វ៉ា បានហៅភ្នាក់ងារ សេ.អ៊ី.អា ប្រជុំដែលមានសមាជិកចូលរួម ជាទាហានស័ក្តិមួយ ស័ក្តិ២ ស័ក្តិ៣ ប៉ូលីស បុគ្គលិកសាលាខេត្ត ចាងហ្វាងសាលារៀន និងគ្រូបង្រៀនចំនួន៣២នាក់ ។ ពេលនោះ វ៉ា បានដាក់ផែនការមុនចេញទៅដេញខ្មែរក្រហម ដោយបានធ្វើការពន្យល់ និងណែនាំយ៉ាងលម្អិតពីគម្រោងការគឺ ៖ ១) យាមផ្លូវជាតិ ស្ពាន រោងចក្រ ការិយាល័យ អគារសិក្សា និងទីក្រុង ។ ២) ផែកពិនិត្យអ្នកធ្វើដំណើរគ្រប់ប្រភេទមនុស្សមកសំណាក់តាមភូមិ ជាយក្រុង ក្នុងក្រុង ផែកឆែករកលិខិតសម្គាល់ខ្លួន ។ ៣) ផែកមនុស្សដែលមានការសង្ស័យធ្វើដំណើរតាមឡាន ម៉ូតូ រកថ្នាំពេទ្យ សំពត់ភ្លៀង អង្រឹង សំពត់ខ្មៅ ជាដើម ។ បន្ទាប់មក អ៊ាង និង ឃឹន បានទៅស្និទ្ធស្នាលជាមួយមេឃុំ ជំទប់ឃុំ និងស្មៀននៃឃុំឪម៉ាល់ ដើម្បីធ្វើការអូសទាញឲ្យចូលជាខ្សែ ជាកម្លាំងស្នូលក្នុងឃុំ ដោយបានពន្យល់ពីសកម្មភាពខ្មែរក្រហម និងពួកកុម្មុយនីស្តដែលចូលមកក្នុងទឹកដីខ្មែរ ធ្វើបាបប្រជាជនខ្មែរ ប្លន់ទឹកដីខ្មែរ ។ ជាលទ្ធផលក្នុងបេសកកម្ម គឺចាប់បានថ្នាំពេទ្យមួយបាវ សំពត់ភ្លៀង សំពត់ខ្មៅ អង្រឹង និងសម្ភារផ្សេងៗពីរបាវពីខ្មែរក្រហមពីរនាក់ ។

ឆ្នាំ១៩៦៨-៧០ អ៊ាង និងបក្ខពួក បានធ្វើសកម្មភាពដើរអប់រំប្រជាជន ឲ្យចូលបម្រើទាហាន ដោយសហការជាមួយឃុំ រៀបចំជាក្រុមកុម្មង់ដូ ជាស្វ័យត្រាណ ជួយយាមល្បាត និងបានអង្កេតរកមេដឹកនាំខ្មែរក្រហម និងខ្សែរយៈទាក់ទងរបស់ខ្មែរក្រហមដែលចេញចូលក្នុងភូមិឃុំ ។ ក្រោយពីធ្វើសកម្មភាព អ៊ាង និងបក្ខពួករួមជាមួយសមាជិកឃុំ បានចាប់បានសមាជិកខ្មែរក្រហមចំនួន៦នាក់ ចាប់បានថ្នាំពេទ្យពីរបាវ ចាប់បានសំពត់ភ្លៀង អង្រឹង និងសម្ភារផ្សេងៗចំនួនបួនបាវ ហើយបានបញ្ជូនឲ្យទៅ វ៉ា ។

ក្រោយរដ្ឋប្រហារ ១៨ មីនា ឆ្នាំ១៩៧០ សមាជិកឃុំបានផ្លាស់ប្តូរថ្មីទាំងអស់ ។ ពេលនោះ អ៊ាង បានទាក់ទងសមាជិកឃុំថ្មីឡើងវិញ ដើម្បីឯកភាពគ្នាធ្វើការប្រឆាំងខ្មែរក្រហម ។ ក្នុងពេលនោះ អ៊ាង ជ្រើសរើសទាហានបានចំនួន១៥នាក់ ប្រគល់ឲ្យទៅឈ្មោះ ទូច ឈឿម (អតីតមេកងកុម្មង់ដូ) និង ឡាយ យួង (អតីតស្មៀនឃុំ) ជាអ្នកមើលការខុសត្រូវ ។ ក្រោយពីការអប់រំ ពន្យល់នៃក្រុមភ្នាក់ងារ សេ.អ៊ី.អា ប្រជាជន បានស្ម័គ្រចិត្តចូលមកចុះឈ្មោះបានចំនួនមួយកងធំ ក្នុងឃុំឪម៉ាល់ ។ អ៊ាង បានបង្កប់បក្ខពួកចំនួនប្រាំនាក់ ឈ្មោះ ឈុត នួត, ង៉ិម ចន, សឿន ប្រិ, ចក់ ជុត, រិត សុត នៅក្នុងភូមិ ដើម្បីធ្វើការតាមដានខ្មែរក្រហមដែលលួចចូលមករកស្បៀង និងសម្ភារផ្សេងៗ និងបានអប់រំ បំផុសប្រជាជនឲ្យទិញកាំភ្លើង (ចំពោះអ្នកដែលមិនបានចូលជាទាហាន) ដើម្បីការពារភូមិ ។ ក្រោយមក ក្រោមការស៊ើបអង្កេតផ្ទាល់របស់មេឃុំ ក៏ចាប់បានខ្មែរក្រហមពីរនាក់ឈ្មោះ កែវ និង គឿ ។ ក្រៅពីសកម្មភាពខាងលើ អ៊ាង បានចូលធ្វើកុម្មង់ដូជួយយាមកាមទីក្រុងដែរ ។

ឆ្នាំ១៩៧៥ មុនរំដោះ វ៉ា បានហៅភ្នាក់ងារ សេ.អ៊ី.អា មកប្រជុំនៅមជ្ឈិមសាលាបាត់ដំបងក្រុង មានភ្នាក់ងារមកចូលរួមចំនួន៨នាក់ ។ ពេលនោះ វ៉ា បានរាយការណ៍ថា ខ្មែរក្រហមបានវាយបុកចូលមកកៀកទីក្រុង និងបានវាយយកទីតាំងសំខាន់ៗជាច្រើនកន្លែង ។ សមរភូមិធំៗ ត្រូវបរាជ័យ វ៉ា និយាយទាំងអស់សង្ឃឹម ។ បន្ទាប់មក វ៉ា បានដាក់ផែនការដើម្បីត្រៀមលក្ខណៈ (ចាញ់សង្គ្រាម) ៖ ១) បំផុសប្រជាជនឲ្យរត់ទៅសៀម, ២) កសាងកម្លាំងបង្កប់ក្នុងជួរប្រជាជន, ៣) ប្រឆាំងគ្រប់សកម្មភាពនូវចលនាដែលកុម្មុយនីស្តឈ្នះ, ៤) ប្រឆាំងរបបកុម្មុយនីស្ត, ៥) កម្ទេចក្បាលម៉ាស៊ីនជាមេដឹកនាំ, ៦) កសាងកម្លាំងប្រឆាំងបង្កប់ក្នុងកងទ័ពក្នុងក្រសួងមន្ទីរ និងរោងចក្រ ។

ក្រោយរំដោះឆ្នាំ១៩៧៥ ភ្នាក់ងាររបស់ក្រុម សេ.អ៊ី.អា ដាច់ការទាក់ទង ។ ប្រធាន និងភ្នាក់ងារភាគច្រើនក្តាប់មិនបាន ។ ដោយឡែក អ៊ាង ក្រោយពីបានជួប ឃឹន មក គណៈឃុំឪម៉ាល់បានហៅ អ៊ាង ឲ្យទៅជួយធ្វើការចែកដី និងរៀបចំប្រជាជនឲ្យមាន

របៀបរៀបរយ ។ ក្រោយមក អ៊ាង បានជួបខ្សែរយៈចាស់ឡើងវិញចំនួន១៣នាក់ ហើយក៏បានអប់រំអ្នកទាំងអស់គ្នាឲ្យទាក់ទងទាហានដែលធ្លាប់មានបុណ្យស័ក្តិ និងទាក់ទងអ្នកដែលធ្លាប់ដើរស៊ីចាយ សប្បាយហ៊ឺហា ដើម្បីចលនាអ្នកទាំងអស់នោះឲ្យរត់ទៅសៀម ។ ជាក់ស្តែង ក្នុងឆ្នាំ១៩៧៥ យុវជន និងអតីតទាហានបានរត់ទៅសៀមចំនួន១៥នាក់ ។ ចំណែកខ្សែរយៈរបស់ អ៊ាង នៅសល់មួយចំនួនទៀត បានធ្វើការនៅក្នុងឃុំឪម៉ាល់ បានចលនាអតីតទាហានដែលធ្លាប់មានបុណ្យស័ក្តិ ធ្លាប់ដើរហើរសប្បាយហ៊ឺហា ឲ្យប្រឆាំងចលនាសហករណ៍ ប្រឆាំងចលនាពលកម្ម និងប្រឆាំងចលនាសមូហភាព និងនិយាយវាយប្រហារអ្នកបដិវត្តន៍ ។

ឆ្នាំ១៩៧៦ អ៊ាង បានមករស់នៅការដ្ឋានអណ្តូងព្រីង ដោយឈ្មោះ ឆាំ អតីតគណៈកម្មាធិការយោធាទទួលខុសត្រូវខាងផ្នែកកសិកម្មប្រចាំស្រុកភ្នំសំពៅ យកមកនៅជាមួយឲ្យជួយធ្វើការឆែរមើលការខុសត្រូវឃ្លាំងសម្ភារផ្សេងៗ និងចាត់ចែងឲ្យកម្មករធ្វើការក្នុងការដ្ឋានអណ្តូងព្រីង ប៉ុន្តែក្រោយមក ឆាំ ក៏បានអប់រំ អ៊ាង, ចិន (អតីតយោធាទទួលខុសត្រូវឃ្លាំង) និងនារី ហាន (អតីតស័ក្តិ២ប៉េអឹម) ឲ្យប្រឆាំងបដិវត្តន៍ ដោយបំផុសវាយប្រហារទៅលើបដិវត្តន៍ ហើយបាននិយាយថា "អ្នកដឹកនាំនិយាយភូតកុហក កាលនៅព្រៃថា គស៊ូយកផ្ទះថ្មនៅ សប្បាយស៊ីចុក ស្លៀកពាក់ហ៊ឺហាដល់ពេលរំដោះបាន មើលឃើញតែកំហុស ហើយថែមទាំងចោទថាក្បត់សីលធម៌ទៀត" ។ ឆាំ នៅបានពន្យល់ណែនាំទៀតថា "ធ្វើការតស៊ូប្រឆាំងបដិវត្តន៍ ត្រូវចេះលាក់ការណ៍ មិនមែនធ្វើមួយថ្ងៃ ឬពីរថ្ងៃ មួយឆ្នាំ ឬពីរឆ្នាំនោះទេ គឺតស៊ូយូរអង្វែង គ្មានថ្ងៃកំណត់ទេ ។ គេកសាងកម្លាំងប្រឆាំងបង្កប់លាក់ទុកគ្រប់ក្រសួង មន្ទីរ យោធា និងនៅក្នុងចំណោមប្រជាជន ។ ពេលមានកម្លាំងគ្រប់គ្រាន់ មធ្យោបាយមានសព្វគ្រប់ការទាក់ទងបានគ្រប់ទីកន្លែង មានសមត្ថភាពគ្រប់គ្រាន់ហើយ ទើបចេញមុខប្រឆាំងពេញទី" ។ បន្ទាប់មក ឆាំ បានដាក់ផែនការឲ្យអ្នកទាំងបីធ្វើគឺ៖ ១) កសាងកម្លាំងឲ្យបានច្រើន ប្រឆាំងនឹងចលនាបដិវត្តន៍តស៊ូយូរអង្វែង, ២) កម្ទេចក្បាលម៉ាស៊ីនដែលជាអ្នកដឹកនាំ, ៣) និយាយវាយប្រហារអ្នកបដិវត្តន៍ និងប្រឆាំងចលនាសហករណ៍ និងចលនាពលកម្ម ។ បន្ទាប់មក អ៊ាង បានចុះដាប់ចលនាពលកម្មនៅការដ្ឋានអណ្តូងព្រីង ហើយក៏បានចលនាកម្មករទាំងនោះ ឲ្យប្រឆាំងបដិវត្តន៍ដើម្បីជាកម្លាំងបង្កប់ក្នុងជួរកម្មករ ដោយបានអប់រំពន្យល់ណែនាំពីរបៀបរបបរស់នៅរបស់ប្រទេសសេរី ទៅនឹងការរស់នៅបែបកុម្មុយនីស្ត ។ បន្ទាប់ពីកម្មករយល់ព្រមចូលរួមក្នុងចលនាប្រឆាំងនឹងបដិវត្តន៍ហើយ អ៊ាង បានយកផែនការដែល ឆាំ បានប្រគល់ឲ្យដាក់ឲ្យកម្មករអនុវត្តជាហូរហែ ។

ឆ្នាំ១៩៧៧ អ៊ាង បានវិលត្រឡប់ទៅរស់នៅសហករណ៍ក្នុងឃុំឪម៉ាល់ ស្រុកភ្នំសំពៅវិញ នៅពេលនោះ គណៈឃុំឪម៉ាល់ បានប្រគល់ភារកិច្ចឲ្យ អ៊ាង ទទួលខុសត្រូវគឺ ចល័តផ្នែកនារី ដែលទើបចេញពីមន្ទីរពេទ្យ និងចល័តថ្មីដែលសហករណ៍ទើបបញ្ជូនមកដល់ប្រគល់ឲ្យទៅឃុំ ។ នៅពេលនោះដែរ អ៊ាង បានជួបខ្សែចាស់របស់ខ្លួនទាំងអស់ (ចំនួន៩នាក់) ដែលធ្វើការនៅក្នុងឃុំឪម៉ាល់ ។ បន្ទាប់មក អ៊ាង បានខទ្មេសនាម ឆាំ ដែលជាអ្នកដឹកនាំថ្មី និងជាបង្អែកដ៏រឹងមាំក្នុងការប្រឆាំងនឹងបដិវត្តន៍ ឲ្យខ្សែរយៈរបស់ខ្លួនទទួលស្គាល់ និងបានអប់រំណែនាំសមាជិកក្នុងក្រុមទាំងអស់ពីសកម្មភាពដែលត្រូវអនុវត្តប្រឆាំងនឹងចលនាបដិវត្តន៍ជាបន្តទៅទៀតគឺ៖ ១) ត្រូវកសាងកម្លាំងឲ្យបានច្រើនដើម្បីប្រឆាំងនឹងចលនាបដិវត្តន៍ ត្រៀមកម្ទេចក្បាលម៉ាស៊ីនដឹកនាំ, ២) និយាយវាយប្រហារអ្នកបដិវត្តន៍, ៣) ប្រឆាំងចលនាសហករណ៍ និងចលនាពលកម្ម ។ ក្រោយពេលបានទទួលការណែនាំហើយ បក្ខពួករបស់ អ៊ាង បានឯកភាពគ្នាបន្តធ្វើសកម្មភាពប្រឆាំងចលនាបដិវត្តន៍ ដោយត្រៀមលក្ខណៈកសាងកម្លាំងឲ្យបានច្រើនជាបណ្តើរៗ និងបំផុសដល់អតីតទាហានដែលមានបុណ្យស័ក្តិ និងអ្នកធ្លាប់ដើរហើរស៊ីចាយ សប្បាយហ៊ឺហា ឲ្យនិយាយវាយប្រហារអ្នកបដិវត្តន៍ ប្រឆាំងចលនាសហករណ៍ និងចលនាពលកម្ម ។ ជាបន្តបន្ទាប់ អ៊ាង, ឈុត ឆួត និង ឈិត ផុនឈៀត បានរួមគ្នាធ្វើសកម្មភាពប្រឆាំងពលកម្ម ធ្វើឲ្យខាតការឆែររំខានដល់អ្នកទទួលខុសត្រូវផ្នែកសម្ភារ ធ្វើការបន្តិចឈប់ បន្តិចឈឺ ហើយបាននាំគ្នាកាប់គាស់ ធ្វើឲ្យបាក់ដងចប បាក់ផ្លែចប បោកប្រាស់បង្គីធ្វើឲ្យឆាប់ខូច ។ បើបានរែកដីម្តងៗ រែកឲ្យបាក់ដងរែក ចុះធ្វើការក្រោយគេពេលឈប់ៗមុនគេជាដើម អ៊ាង បានធ្វើសកម្មភាពទាំងនេះរហូតដល់ថ្ងៃអង្គការចាប់ខ្លួនតែម្តង ។

**ឆេង ង៉េង**

# ចម្លើយសារភាពរបស់ ស៊ុន ហឿន ហៅ អ៊ឹម ប្រធានក្រសួងសន្តិសុខរបស់ភូមិភាគកណ្តាល

*សង្ខេបចេញពីឯកសារចម្លើយសារភាពលេខ D៤១២៦៥*

ស៊ុន ហឿន ហៅ អ៊ឹម ភេទប្រុស អាយុ៣២ឆ្នាំ (គិតត្រឹមឆ្នាំ១៩៧៨) មានស្រុកកំណើតនៅភូមិត្រពាំងធំ ឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អ៊ឹម ជាប្រធានក្រសួងសន្តិសុខរបស់ភូមិភាគកណ្តាល ហើយត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ១៩៧៨ ។ ក្រោយពីចាប់ខ្លួនរួចហើយ អ៊ឹម ត្រូវបានបញ្ជូនមកមន្ទីរសន្តិសុខស-២១ ។ នៅក្នុងឆ្លើយសារភាព អ៊ឹម បានឆ្លើយរៀបរាប់ពីសកម្មភាពដែលខ្លួនរួមជាមួយបក្ខពួកបានធ្វើដើម្បីប្រឆាំងនឹងបដិវត្តន៍ ។ យើងមិនដឹងថា ការឆ្លើយសារភាពរបស់ អ៊ឹម ពិតប្រាកដយ៉ាងណានោះទេ ។ ខាងក្រោមនេះជាសេចក្តីដកស្រង់ដោយសង្ខេបចេញពីចម្លើយសារភាពរបស់ អ៊ឹម ៖

ឆ្នាំ១៩៦៥ អ៊ឹម រៀនថ្នាក់ទី៦ នៃវិទ្យាល័យអង្គតាសោម រហូតដល់ថ្នាក់ទី៣ ។ ក្នុងអំឡុងពេលសិក្សា អ៊ឹម បានស្គាល់គ្រូ ងី គ្រូ សារីម និងគ្រូ វុទ្ធ ដែលជាសាស្រ្តាចារ្យបង្រៀននៅវិទ្យាល័យអង្គតាសោម ។ រាល់ពេលថ្ងៃសៅរ៍ គ្រូងី តែងនាំសិស្សទៅលេងកែបទឹកឈូ ភ្នំជីសូរ អង្គបង្គរ ជាដើម ហើយឆ្លៀតឱកាសនោះ ក៏អប់រំថានឹងរកអនាគតឲ្យសិស្សទាំងអស់ឲ្យបានភ្លឺស្វាងដោយមានតំណែងតួនាទី មុខមាត់ ប្រាក់ខែ ហើយជម្រើសតែមួយគត់ គឺចូលជាសមាជិក សេ.អ៊ី.អា ។ ពេលនោះ អ៊ឹម ក៏បានយល់ព្រមចូលជាសមាជិក សេ.អ៊ី.អា តាមការអូសទាញនេះ ។

ឆ្នាំ១៩៦៦ អ៊ឹម ត្រូវបានគ្រូងី បញ្ចូលជាសមាជិក សេ.អ៊ី.អា នៅផ្ទះរបស់គាត់ ជិតសាលារៀន ដែលនៅពេលនោះមានរៀបចំពិធីបញ្ចូលជាសមាជិក មានគោរពទង់ រូបផ្កាយ ដែលមានគ្រូ វុទ្ធ ជាអ្នកទទួលស្គាល់ និងគ្រូ សារីម ជាសាក្សី ដោយទទួលបានប្រាក់ខែចំនួនមួយពាន់រៀលក្នុងមួយខែ ។ បន្ទាប់ពីបញ្ចូលរួចរាល់ហើយ គ្រូ វុទ្ធ បានប្រគល់ភារកិច្ចឲ្យ អ៊ឹម ធ្វើគឺ៖ ១) ខិតខំរក្សាការសម្ងាត់ឲ្យបានដាច់ខាត ២) ខិតខំកសាងកម្លាំងឲ្យបានច្រើនថែមទៀត និងទី៣) តាមដានមូលដ្ឋានបដិវត្តន៍ និងធ្វើសកម្មភាពបំផ្លិចបំផ្លាញកម្លាំងបដិវត្តន៍ ។ បន្ទាប់មក គ្រូ ងី ក៏បានណែនាំ អ៊ឹម ឲ្យស្គាល់ខ្សែរយៈ សេ.អ៊ី.អា ចំនួនប្រាំបីនាក់ ដែលអ្នកទាំងនោះគឺជាអតីតសិស្សរៀននៅថ្នាក់ទី៣ នៃវិទ្យាល័យអង្គតាសោម ។ ក្រោយពីក្តាប់បាននូវភារកិច្ចដែល គ្រូ ងី បានប្រគល់ឲ្យមក អ៊ឹម បានតាមដានសកម្មភាពបដិវត្តន៍ជាបន្តបន្ទាប់ ។

នៅឆ្នាំ១៩៦៧ អ៊ឹម បានដាច់ខ្សែរយៈ បន្ទាប់ពី គ្រូ ងី, គ្រូ វុទ្ធ និងគ្រូ សារីម រត់ចូលព្រៃ ។ លុះដល់ឆ្នាំ១៩៦៨ អ៊ឹម បានទៅរកស៊ីនៅខេត្តសៀមរាប ដោយធ្វើជាជាងថតរូបនៅអង្គរវត្តឲ្យថៅកែម្នាក់ឈ្មោះ ទ្រី ។ មួយឆ្នាំក្រោយមក ទ្រី បានអប់រំ អ៊ឹម ឲ្យចូល សេ.អ៊ី.អា ជាលើកទីពីរ ហើយបានណែនាំឲ្យស្គាល់ខ្សែរយៈទាក់ទងចំនួនដប់នាក់ និងបានដាក់ផែនការឲ្យធ្វើសកម្មភាពបំផ្លាញអង្គរវត្ត ។ លុះដល់ឆ្នាំ១៩៧០ ពេលមានព្រឹត្តិការណ៍រដ្ឋប្រហារ អ៊ឹម បានរត់ទៅស្រែណូយជាមួយឪពុកធម៌ឈ្មោះ កែវ បានពីរខែ ហើយក៏បានចូលបដិវត្តន៍នៅមន្ទីរឃុំជាមួយឈ្មោះ ង៉ា, ឈ្មោះ ខែម និងឈ្មោះគន់ ដែលជាខ្សែ សេ.អ៊ី.អា ជាមួយគ្នា ។ បន្ទាប់មក ខែម បានណែនាំ អ៊ឹម ឲ្យស្គាល់ខ្សែ សេ.អ៊ី.អា របស់ខ្លួនចំនួនបីនាក់ទៀត ដើម្បីទាក់ទងគ្នាធ្វើសកម្មភាពទៅថ្ងៃមុខ ។

ឆ្នាំ១៩៧១ អ៊ឹម នៅមន្ទីរតំបន់ក្នុងនាមជាអ្នកថតរូប ។ ពីរខែក្រោយមក សុត បានណែនាំឲ្យស្គាល់ខ្សែរយៈចំនួនប្រាំនាក់ទៀតមានឈ្មោះ លាត, អឿន, រឿត, សែត និង អ៊ុយ ដើម្បីជាកម្លាំងសម្រាប់ទាក់ទងតាមស្រុកមួយៗ នៅក្នុងតំបន់១០៦ ។ ថ្ងៃមួយ សុត បានហៅ ខឿន និង អ៊ឹម ឲ្យមកជួប ហើយបានចាត់ឲ្យអ្នក

ទាំងពីរទទួលកិច្ចការផ្នែកទទួលភ្ញៀវជំនួស ព្រោះគាត់ត្រូវទៅធ្វើការងារថ្មីនៅស្រុកបន្ទាយស្រី ហើយ សុត បានសរសេរសំបុត្រមួយច្បាប់ដែលក្នុងសំបុត្របានហៅសមាជិកគ្រប់មូលដ្ឋានមកជួបប្រជុំគ្នានៅមន្ទីរស្រុកបន្ទាយស្រី និងបានណែនាំ អ៊ឹម ឲ្យថតរូបអ្នកទាំងអស់គ្នាទុក ព្រោះអ្នកទាំងនោះសុទ្ធតែជាខ្មែរ សេ.អ៊ី.អា (អ្នកដែលមកប្រជុំនៅពេលនោះ ត្រូវបានអង្គការចាប់ខ្លួនអស់ហើយ) ។

នៅឆ្នាំ១៩៧២-១៩៧៤ សុត បានណែនាំឲ្យ អ៊ឹម ស្គាល់ខ្មែររយៈរបស់ខ្លួនជាបន្តបន្ទាប់ ដែលខ្មែររយៈខ្លះពីមុននៅក្នុងអង្គភាព តែត្រូវបាន សុត ដកឲ្យមកនៅតាមមូលដ្ឋាននានា ។ ក្រោយមក អ៊ឹម ត្រូវបាន សុត ដកពីមន្ទីរតំបន់ ឲ្យមកនៅបន្ទាយក្ដីវិញ ។ នៅបន្ទាយក្ដី អ៊ឹម បានធ្វើការទាក់ទងជាមួយឈ្មោះ សៀន វរសេនាតូចរបស់តំបន់១០៦ (សៀន ត្រូវអង្គការចាប់ខ្លួនហើយ) និងឈ្មោះ ឈឿន, យ៉េ និង ឆន ដើម្បីជាកម្លាំងក្នុងការស្ទាក់ចាំបាញ់កម្មាភិបាលបដិវត្តន៍ ។ បន្ទាប់ពីបានទៅរស់នៅក្នុងមន្ទីរតំបន់១០៦ បានមួយរយៈជាមួយប្រធានមន្ទីរតំបន់ ឈ្មោះ យាន, លន និង លាត (សុត បានប្រាប់ អ៊ឹម ឲ្យដឹងថា អ្នកទាំងបីខាងលើ ក៏ជាខ្មែររយៈ សេ.អ៊ី.អា ដែរ) ឈ្មោះ លន បានហៅ អ៊ឹម ទៅណែនាំថា (មិត្តខំធ្វើការងារទៅ បើមានខុសត្រូវអ្វីយ៉ាងណា យើងត្រូវអធ្យាស្រ័យឲ្យគ្នា ព្រោះនៅកន្លែងនេះសុទ្ធតែជាខ្មែរ សេ.អ៊ី.អា របស់យើងទេ ។ បើមានការបែកបាក់គ្នា ប្រយ័ត្នមានការអន្តរាយដល់កម្លាំងយើង និងអាយុជីវិតយើងថែមទៀត) ។ នៅពេលនោះ លន បានខទ្មេសនាមខ្មែររបស់ខ្លួនមួយចំនួនឲ្យ អ៊ឹម បានស្គាល់ ។ លន មានផែនការចាំបាច់មួយ គឺក្នុងខែមិថុនា ឆ្នាំ១៩៧៤ នេះ ត្រូវធ្វើសកម្មភាពចាំបាញ់កម្មាភិបាលដែលធ្វើដំណើរទៅមកនៅពេលយប់ ក្នុងគោលបំណងអុកឡុកឲ្យកើតមានអសន្តិសុខក្នុងតំបន់រំដោះ ។ បន្ទាប់មក លន បានចាត់ឲ្យ អ៊ឹម ទៅទាក់ទងខ្មែររបស់គាត់នៅមន្ទីរនេសាទត្រីឈ្មោះ ជាតិ ធ្វើយ៉ាងណាឲ្យអ្នកនៅទីនោះខិតខំពង្រឹងកម្លាំងក្នុងឡូនេសាទឲ្យបានច្រើនថែមទៀត ។

មុនពេលរំដោះទីក្រុងសៀមរាប លន បានចាត់ឲ្យ អ៊ឹម ប្រមូលកម្លាំង សេ.អ៊ី.អា នៅក្នុងមន្ទីរតំបន់១០៦ ឲ្យមកនៅមន្ទីរដ-១ ។ ក្នុងខែធ្នូ ឆ្នាំ១៩៧៤ លន បានចាត់ឲ្យ អ៊ឹម រៀបចំកសាងកម្លាំងនៅក្នុងមន្ទីរតំបន់១០៦ ថែមទៀត ពេលនោះ អ៊ឹម បានកសាងកម្លាំងបានពីរនាក់មានឈ្មោះ គត់ និងឈ្មោះ វី អ្នកទាំងពីរគឺជាយុទ្ធជននៅក្រសួងសាធារណការភាគឧត្តរ ។ បន្ទាប់ពីអង្គការបានវាយរំដោះទីក្រុងសៀមរាបមក លន បានធ្វើជាប្រធានមន្ទីរតំបន់១០៦ នៅសៀមរាប ហើយស្របពេលជាមួយគ្នានោះដែរ ទីក្រុងកំពង់ចាម ក៏ត្រូវបានរំដោះដែរ ហេតុនេះ អង្គការបានដក លន ឲ្យមកនៅក្រុងកំពង់ចាម ។ តែមុននឹងមក លន បានដកកម្លាំង សេ.អ៊ី.អា ពីមន្ទីរតំបន់១០៦ មកនៅក្រុងកំពង់ចាមដែរ ហើយនៅពេលនោះ ឈ្មោះ ស្រេង បានចាត់តាំង លន ឲ្យធ្វើជាប្រធានមន្ទីរកណ្ដាល ចំណែក អ៊ឹម បាននៅជាប់ជាមួយឈ្មោះ ឌឹម និង សួរ ។

នៅឆ្នាំ១៩៧៥ ឈ្មោះ សួរ បានបើកការប្រជុំមួយ ដែលមានសមាជិក សេ.អ៊ី.អា ចំនួន១៣នាក់ចូលរួម ។ នៅក្នុងអង្គប្រជុំ សួរ បានជំរុញឲ្យសមាជិកទាំងអស់យល់អំពីការកិច្ចរបស់ខ្លួនដែលត្រូវអនុវត្ត ហើយត្រូវខិតខំកសាងកម្លាំង សេ.អ៊ី.អា ឲ្យបានច្រើនថែមទៀតនៅតាមក្រសួងរៀងៗខ្លួន ។ បន្ទាប់មក សួរ បានចាត់ អ៊ឹម ឲ្យទៅទាក់ទងជាមួយឈ្មោះ វ៉េង អនុកងពលភាគឧត្តរ ដើម្បីប្រាប់ពីផែនការកសាងកម្លាំងនៅក្នុងអង្គភាពរបស់ខ្លួនដើម្បីត្រៀមធ្វើរដ្ឋប្រហារវាយរំលំបដិវត្តន៍នៅពេលខាងមុខ ។ ក្នុងពេលនោះដែរ ឈ្មោះ ហុន បានខទ្មេសនាមខ្មែររយៈរបស់ខ្លួនចំនួនបីនាក់ឲ្យ អ៊ឹម បានស្គាល់ (ទាំងបីនាក់ត្រូវបានអង្គការចាប់ខ្លួនហើយ) ។

ឆ្នាំ១៩៧៦ អង្គការបានបើកវគ្គរៀនសូត្រមួយរបស់ភាគ ។ ពេលនោះ អ៊ឹម ក៏បានចូលរួមរៀនសូត្រក្នុងវគ្គនេះដែរ ហើយក្នុងអំឡុងពេលរៀនសូត្រនោះ អ៊ឹម បានជួបខ្មែររយៈ សេ.អ៊ី.អា ចាស់របស់ខ្លួនបីនាក់ ។ ក្រោយពេលសម្រាកពីការរៀនសូត្រ អ៊ឹម បានទៅជួបអ្នកទាំងបីដើម្បីពិភាក្សាគ្នាអំពីសកម្មភាពដែលបានអនុវត្តកន្លងមក ដូចជាសកម្មភាពបំផ្លាញ សកម្មភាពទាក់ទងខ្មែររយៈ ហើយពិសេសទៀតនោះគឺ សកម្មភាពពង្រីកកម្លាំងនៅតាមមុខសញ្ញារបស់ម្នាក់ៗ ។ នៅក្នុងខែមេសា បន្ទាប់ពីអង្គការធ្វើការបោសសម្អាតខ្មែររយៈរបស់ សួរ រួចមក អ៊ឹម បានដាច់ខ្សែអស់មួយរយៈកាល រហូតដល់ខែឧសភា ទើបអង្គការចាប់ផ្ដើមរៀបចំគណៈមន្ទីរថ្មី ដែលមានឈ្មោះ ញាន ជាប្រធានភូមិភាគ រីឯ អ៊ឹម បាននៅជាប់ជាមួយ ញាន (គណៈមន្ទីរថ្មី) និង ភោគ ប្រធានសន្តិសុខភាគ ។

ខែមករា ឆ្នាំ១៩៧៧ ញ៉ាន បានប្រមូលកម្លាំងដែលនៅសេសសល់ ក្រោយពីអង្គការចាប់ខ្លួន មកប្រជុំដើម្បីធ្វើការអប់រំនៅមន្ទីរកណ្តាល ផ្ទះលេខ៣ ។ ក្នុងឱកាសនោះ ញ៉ាន បាននិយាយថា «យើងទាំងអស់គ្នាត្រូវខិតខំពង្រឹងនិងពង្រីកកម្លាំងតទៅទៀត ចំពោះមេកើយរបស់យើងដែលត្រូវបានអង្គការបោសសម្អាតនោះ មិនទាន់អស់នៅឡើយទេ ដូចជាឈ្មោះ អាន ដែលមកពីភូមិភាគនិរតីជាដើម ។ យល់បែបនេះ ទើបយើងមានកម្លាំងធ្វើការបន្តទៀត ហើយត្រូវសង្ឃឹមលើមេដឹកនាំថ្មីរបស់យើង ម៉្យាងទៀតត្រូវខិតខំលាក់ការណ៍ឲ្យបានជាសម្ងាត់» ។ ការប្រជុំត្រូវបានរំសាយបន្ទាប់ពី ញ៉ាន ណែនាំចប់ ។ ក្រោយមក ញ៉ាន បានហៅ អ៊ីម ឲ្យមកជួបនៅមន្ទីរកណ្តាល ហើយបានធ្វើការណែនាំឲ្យខិតខំទាក់ទងខ្មែរខាងក្រៅឲ្យបានច្រើន ព្រោះកម្លាំងនៅខាងក្នុងត្រូវអង្គការចាប់អស់ច្រើនណាស់ ដូច្នេះត្រូវខំកសាងកម្លាំងនៅខាងក្រៅឲ្យបានច្រើន ។ នៅខែកញ្ញា ញ៉ាន ត្រូវបានអង្គការចាប់ខ្លួន ហើយបានបញ្ជូនឈ្មោះ នឿន (នឿន ជាខ្មែរ សេ.អ៊ី.អា) ឲ្យមកធ្វើជាប្រធានមន្ទីរភូមិភាគជំនួស ញ៉ាន វិញ ។ ពេលនោះ អ៊ីម ក៏បាននៅជាប់ជាមួយ នឿន រហូតមក ។ បន្ទាប់មក នឿន បាននិយាយប្រាប់ អ៊ីម ថា «ខ្ញុំបានឡើងធ្វើជាប្រធានមន្ទីរភូមិភាគហើយ ខ្ញុំមានសង្ឃឹមច្រើនណាស់ថា អាចវាយរំលំបដិវត្តន៍បាន ព្រោះខ្ញុំមានកម្លាំងនៅគ្រប់កន្លែង ហើយមានមេដឹកនាំនៅខាងលើខ្ពស់ទៀតផង គឺបងអាន ជាអនុលេខាភូមិភាគកណ្តាល ។ តែផែនការវាយរំលំបក្សកុម្មុយនីស្តកម្ពុជានោះ មិនបានសម្រេចទេ ព្រោះអង្គការបានធ្វើការបោសសម្អាតខ្មែររបស់យើងអស់មួយចំនួនហើយ» ។ ឈ្មោះ នឿន និង ប៉េង ត្រូវបានអង្គការចាប់ខ្លួនជាបន្តបន្ទាប់នៅខែតុលា ។ ចំណែក អ៊ីម ក៏បានមកនៅជាមួយឈ្មោះ យាន នៅក្រសួងសាធារណការ ។ លុះដល់ខែធ្នូ ឆ្នាំ១៩៧៧ អ៊ីម ក៏បានទទួលតំណែងជាប្រធានសន្តិសុខភូមិភាគកណ្តាល ។ នៅក្នុងកងសន្តិសុខ អ៊ីម បានធ្វើការទាក់ទងខ្មែរបីនាក់មានឈ្មោះ ស័យ, អឿន និង ដា ដែលជាប់ខ្សែរយៈជាមួយឈ្មោះ ឈី ។

ឆ្នាំ១៩៧៨ ខែមេសា ឈ្មោះ ឈី បានហៅខ្មែរក្បត់មកធ្វើការនៅផ្ទះលេខ៥ ជិតមន្ទីរកណ្តាល ដើម្បីរៀបចំដឹកប្រហុកចំនួន៥០ពាង និងត្រីងៀតនៅឃ្លាំងពាណិជ្ជកម្ម យកទៅឲ្យ បងភឹម លេខាភូមិភាគបូព៌ា ដោយលាក់ការណ៍សម្ងាត់បំផុត ។ មួយខែក្រោយមក ឈ្មោះដន បានមកយកសម្ភារនៅមន្ទីរភូមិភាគកណ្តាល ហើយបានជួបជាមួយ អ៊ីម ។ អ៊ីម បានសួរទៅ ដន ពីខ្សែរយៈនៅភាគនិរតីតើមាននរណាខ្លះ? ដន បាននិយាយប្រាប់ អ៊ីម ថា មានមេដឹកនាំចំនួន៩នាក់ គឺ ១) ឈ្មោះ សែរ លេខាភូមិភាគឧត្តរ ២) ឈ្មោះ អាន លេខាតំបន់៤១ ៣) ឈ្មោះ ផែន លេខាតំបន់៤៣ ៤) ស៊ុន លេខាស្រុកសន្ទុក តំបន់៤៣ ៥) នារី យុត លេខាស្រុកកំពង់សៀម តំបន់៤១ ៦) ឈ្មោះ ដុន ប្រធានយោធាស្រុកកំពង់សៀម តំបន់៤១ ៧) ឈ្មោះ ឆាយ ប្រធានមន្ទីរតំបន់៤៣ ៨) ឈ្មោះ ភោគ ប្រធានក្រសួងសន្តិសុខ ចម្ការកៅស៊ូភូមិភាគកណ្តាល និង ៩) ឈ្មោះ ឆាយ ប្រធានកងពលភូមិភាគកណ្តាល ។ ដន បាននិយាយប្រាប់បន្តថា «បើមិត្តបានស្គាល់ហើយ សូមមិត្តរក្សាការសម្ងាត់ឲ្យបាន មិនត្រូវឲ្យអ្នកណាដឹងក្រៅពីខ្លួនយើង និងខ្មែររបស់យើងទេ» ។

នៅក្នុងក្រសួងសន្តិសុខ អ៊ីម ចេះតែមានអារម្មណ៍ភិតភ័យ ព្រោះដឹងខ្លួនថា អង្គការចាប់អារម្មណ៍ចំពោះខ្លួនហើយ ។ ថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៧៨ ឈ្មោះ មឿន បានមកណែនាំ អ៊ីម ថា ឥឡូវនេះ បក្សថា មិត្តបានជាប់នៅក្នុងចម្លើយខ្លាំងហើយ គឺបក្សសុំដកមិត្តឲ្យទៅនៅតំបន់៤២សិន ហើយឲ្យមិត្តរៀបចំអីវ៉ាន់ទៅថ្ងៃនេះ ។ មឿន និយាយចប់ អ៊ីម បានរៀបចំអីវ៉ាន់ ហើយឡើងឡានធ្វើដំណើរទៅតំបន់៤២ ។ ពេលទៅដល់មន្ទីរតំបន់ភ្លាម អ៊ីម បានសរសេរសំបុត្រមួយច្បាប់ផ្ញើឲ្យទៅឈ្មោះ ដន នៅចម្ការកៅស៊ូភូមិភាគកណ្តាល ដើម្បីណាត់ឲ្យឈ្មោះ ដន ឲ្យមកជួបខ្លួននៅដើមចំបក់ នៅមន្ទីរតំបន់៤២ ។ ពេលបានជួប ដន ហើយ អ៊ីម បាននិយាយថា «មិត្តសិទ្ធិ បាននិយាយថា បងឯងបានយកអង្ករទៅឲ្យចោរព្រៃ» ។

អ៊ីម បានបន្ថែមថា ខ្លួនសរសេរសំបុត្រនេះ គឺគោលបំណងចង់ប្រាប់ទៅឲ្យមេៗនៅខាងលើ និងខ្មែរក្បត់ទាំងអស់បានដឹង ហើយប្រឆាំងតបនឹងបក្សវិញ ដោយបង្កើតតំបន់និយម បក្ខពួកនិយម ។ តែកិច្ចការនេះមិនបានសម្រេចទេ លុះដល់ថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៧៨ អ៊ីម ត្រូវបានអង្គការចាប់ខ្លួនតែម្តង ។

**ឆេង ទ៉េង**

# ចម្លើយសារភាពរបស់ ហង់ បូ ប្រធានពេទ្យ កងពល១៧៤ ភាគកណ្តាល

*ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ D៤១២៦៦*

ហង់ បូ ភេទប្រុស អាយុ៣៦ឆ្នាំ (គិតត្រឹមឆ្នាំ១៩៧៧) មានស្រុកកំណើតនៅភូមិកំពង់គោ ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ តំបន់៤៣ ភូមិភាគកណ្តាល ។ ឪពុកឈ្មោះ ហង់ អាយុ៦០ឆ្នាំ (រស់) ម្តាយឈ្មោះ ស៊ាន អាយុ៥៥ឆ្នាំ (រស់) ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (មុនពេលចាប់ខ្លួន) បូ ជាប្រធានពេទ្យកងពល១៧៤ ភាគកណ្តាល ។ បូ ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៧ បន្ទាប់ពីបំផ្ទុះមីន រៀបចំគម្រោងការវាយដណ្តើមយកទីក្រុងកំពង់ចាមតែប៉ុន្មានម៉ោងប៉ុណ្ណោះ ហើយបានបញ្ជូនមកមន្ទីរស-២១ ដើម្បីសួរចម្លើយ ។ នៅក្នុងឆ្លើយសារភាព បូ បានរៀបរាប់ពីសកម្មភាពដែលខ្លួនរួមជាមួយបក្ខពួកបានធ្វើដើម្បីប្រឆាំងនឹងបដិវត្តន៍ ។ យើងមិនដឹងថា ការឆ្លើយសារភាពរបស់ បូ ពិតឬក៏យ៉ាងណានោះទេ ។ ខាងក្រោម នេះជាសេចក្តីដកស្រង់ដោយសង្ខេបចេញពីចម្លើយសារភាពរបស់ ហង់ បូ៖

បូ រស់នៅជាមួយឪពុកម្តាយតាំងពីតូចមក លុះដល់ពេលមានអាយុ១០ឆ្នាំ បានចេញទៅរៀននៅសាលាវត្តកំពង់គោរយៈពេលបីឆ្នាំ ហើយបានបន្តទៅរៀននៅសាលាពាមគ្រែងរហូតដល់ថ្នាក់ទី៨ ។ លុះដល់អាយុ១៧ឆ្នាំ ក៏បានឈប់រៀន ហើយវិលត្រឡប់មកជួយធ្វើការងារឪពុកម្តាយនៅផ្ទះវិញ គឺធ្វើស្រែ និងនេសាទត្រី ។ បួនឆ្នាំក្រោយមកទៀត គឺពេលដែល បូ មានអាយុ២១ឆ្នាំ ក៏បានរៀបការប្រពន្ធឈ្មោះ ឡោ ស៊ុម ហើយនៅជួយរកស៊ីឪពុកម្តាយ រហូតដល់ឆ្នាំ១៩៧០ ទើបចេញទៅរស់នៅខាងស្រុកកំណើតរបស់ប្រពន្ធនៅភូមិតាំងក្រូច ឃុំសាន់គរ ស្រុកកំពង់ស្វាយ តំបន់៤៣ ភូមិភាគកណ្តាល ។

ឆ្នាំ១៩៧១ បូ បានចូលបដិវត្តន៍នៅភូមិតាំងក្រូច ឃុំ



អតីតផ្ទះរបស់ប្រជាជននៅក្នុងភូមិមួយ ក្នុងខេត្តកណ្តាល ត្រូវបានខ្មែរក្រហមយកធ្វើជាមន្ទីរសន្តិសុខសម្រាប់ឃុំឃាំងអ្នកទោស ។ រូបថតនេះ ថតក្រោយពេលរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩ ។

*សាន់គរ ស្រុកកំពង់ស្វាយ តំបន់៤៣ ដែលមានឈ្មោះ កែវ ហៅ ថូ (នារី) ជាគណៈអប់រំនៅក្នុងស្រុកកំពង់ស្វាយ ជាអ្នកអប់រំឲ្យចូល ។ ក្រោយពេលចូលបដិវត្តន៍មក បូ និង ថូ កាន់តែមានការជិតស្និទ្ធនឹងគ្នាខ្លាំងឡើងៗ ។ បន្ទាប់មក ថូ បានចាត់ឲ្យ បូ ធ្វើជាប្រធានភូមិក្រសាំង ។ ពេលដែល បូ បានធ្វើជាប្រធានភូមិភ្លាម បូ បានបើកឲ្យឈ្លើញយកជ្រូកទៅលក់ឲ្យខ្មាំងជារៀងរាល់ថ្ងៃ ឯល្បែងស៊ីសងបើកឲ្យលេងពេញទាំងភូមិ ពេលភូមិមានចោរលួច ចោរប្លន់ ក៏មិនរវល់ចាប់ចោរដែរ ។*

*ខែឧសភា ឆ្នាំ១៩៧២ ថូ បានផ្លាស់ចេញពីគណៈអប់រំស្រុក ទៅធ្វើជាយោធានៅសមរភូមិកំពង់ធំ ហើយឈ្មោះ ដេត ជាអនុប្រធានស្រុកកំពង់ស្វាយ មកទទួលដំណែងជំនួស ថូ ។ ពេលនោះ បូ ត្រូវបាន ដេត ដកចេញពីភូមិក្រសាំង ហើយប្រើអស់រយៈពេលប្រាំខែដើម្បីអប់រំ បញ្ចុះបញ្ចូល បូ ដោយបាននិយាយថា សព្វថ្ងៃនេះ សភាពការណ៍កាន់តែតឹងតែងម្តងបន្តិចៗហើយ ពីព្រោះរបបសមូហភាពកាន់តែរីកធំឡើងៗ ចំណែកឯរបបឯកជនកាន់តែបាត់ទៅៗ ។ ម្យ៉ាងទៀត របបឯកជន និងរបបសមូហភាពមានការខុសគ្នាឆ្ងាយណាស់ ។ របបឯកជនជារបបសេរី ចង់ធ្វើអីធ្វើហ្នឹងបានតាមចិត្ត ឯរបបសមូហភាពវិញ តឹងណាស់ មានអង្គការវិន័យសេរីមិនបាន ។ ពេលអប់រំ បូ រួចហើយ ដេត ក៏បានចាត់ បូ ឲ្យទៅធ្វើជាប្រធានភូមិព្រៃតាង៉ោល ក្នុងសង្កាត់ដីរីស្វាប់ ស្រុកកំពង់ស្វាយ ហើយនៅក្នុងខែកញ្ញា ដេត ក៏បានបញ្ចូល បូ ជាខ្មែរ សេ.អ៊ី.អា ។ ការបញ្ចូល បូ ជាខ្មែរ សេ.អ៊ី.អា នេះ អ្នកដែលបានចូលរួមមានឈ្មោះ ទុន ប្រធានពាណិជ្ជកម្មស្រុកកំពង់ស្វាយ ឈ្មោះ ផាត ប្រធានសង្កាត់ក្រសាំង ឈ្មោះ លាន ប្រធានសង្កាត់សាន់គរ ឈ្មោះ គីន ប្រធានសន្តិសុខ ស្រុកកំពង់ស្វាយ ។ ចំណែក ដេត មិនបានចូលរួមទេ ដោយបានចាត់ឲ្យឈ្មោះ ទុន ជាអ្នកចាត់ចែងការងារនេះជំនួសខ្លួន ។ ពេលនោះ ទុន ក៏បានមានមតិផ្តាំផ្ញើថា សេ.អ៊ី.អា មានភារកិច្ចអប់រំ ប្រមូលកម្លាំងជាខ្មែរសង្ការ៉ាក់ សេ.អ៊ី.អា ឲ្យបានច្រើនដើម្បីប្រឆាំងនឹងបដិវត្តន៍វិញ ធ្វើយ៉ាងណាកុំឲ្យប្រជាជន មានជំនឿទៅលើបដិវត្តន៍ ។ ពិធីបញ្ចូល សេ.អ៊ី.អា បានបញ្ចប់ ហើយអ្នកចូលរួមក៏បានបំបែកគ្នាទៅកន្លែងរៀងៗខ្លួនវិញ ។ បូ បានបន្តធ្វើការគាបសង្កត់ប្រជាជនមិនឲ្យចេញទៅរកស្រូវខាងក្រៅសង្កាត់ ហើយចាប់ពីពេលនោះមកក៏កើតមានចោរលួចពេញទាំងភូមិ ។*

*ឆ្នាំ១៩៧៣ ខែតុលា បូ, គឿន ប្រធានសង្កាត់ដីរីស្វាប់ និងនារីឈ្មោះ ផា ជាអនុប្រធានសង្កាត់ទួលគ្រើលក្នុងស្រុកកំពង់ស្វាយ ត្រូវបាន ដេត បញ្ចូលជាសមាជិកបក្សនៅភូមិសាន់គរ ។ ឆ្លៀតក្នុងឱកាសនោះ ដេក បាននិយាយថា រយៈកាលកន្លងមក យើងមិនបានទាក់ទងគ្នា តែនៅពេលនេះ យើងបានស្គាល់គ្នាហើយ ហេតុនេះ យើងទាំងអស់គ្នាត្រូវយកភារកិច្ច សេ.អ៊ី.អា នេះទៅអនុវត្តឲ្យបាន ដូចជា ប្រមូលកម្លាំងឲ្យបានជាខ្មែរសង្ការ៉ាក់ បំផុសទំនាក់ធ្វើឲ្យប្រជាជនលែងមានទំនុកចិត្តលើបដិវត្តន៍ ហើយខ្លួនយើងផ្ទាល់ ត្រូវតែដាច់ខាតកុំស្ទាក់ស្ទើរឲ្យសោះក្នុងការប្រឆាំងជាមួយនឹងបដិវត្តន៍ជារៀងរហូត ។ ចប់កម្មវិធី ដេត ក៏បានចាត់ បូ ឲ្យទទួលពាណិជ្ជកម្មសង្កាត់ដីរីស្វាប់ ហើយ បូ ក៏បានបន្តដំឡើងថ្លៃអីវ៉ាន់ឲ្យហួសពីតម្លៃអង្គការបានកំណត់ ធ្វើឲ្យប្រជាជនរកលុយទិញមិនបាន ហើយប្រាក់ចំណេញត្រូវ ដេត ដកយកជារៀងរាល់ថ្ងៃ ។ ដេត ត្រូវបានអង្គការដកចេញពីស្រុកកំពង់ស្វាយដោយសារធ្វើខុស ប៉ះពាល់សីលធម៌ ។*

*ក្រោយមកឈ្មោះ គឿន បានប្រមូលខ្មែរ សេ.អ៊ី.អា ចំនួនប្រាំនាក់នៅសង្កាត់ដីរីស្វាប់មកប្រជុំ ។ គឿន បាននិយាយថា មួយរយៈកាលកន្លងមកនេះ យើងទាំងអស់គ្នាមិនបានចាត់តាំងកម្លាំងឲ្យចូលជាខ្មែរ សេ.អ៊ី.អា បានម្នាក់នៅឡើយទេ តែក្រោយពីនេះទៅ យើងម្នាក់ៗត្រូវយកភារកិច្ច សេ.អ៊ី.អា ទៅអនុវត្តនៅតាមភូមិដើម្បីអប់រំប្រជាជន ជាពិសេសអប់រំប្រធានភូមិ ឬអនុប្រធានភូមិឲ្យចូលជាខ្មែរ សេ.អ៊ី.អា ដើម្បីងាយស្រួលធ្វើការទៅថ្ងៃក្រោយ ។ តែការអនុវត្តតាមផែនការអប់រំនេះ មិនបានសម្រេចទេ រហូតដល់ខែកុម្ភៈ ឆ្នាំ១៩៧៤ មានទាហានចេញមកពីកំពង់ធំបានកៀរប្រជាជននៅខាងលិចតាមបណ្តោយផ្លូវជាតិលេខ៦ យកទៅអស់មួយចំនួន ដែលក្នុងនោះក៏មានគ្រួសាររបស់ បូ ដែរ ។ ចំណែក បូ នៅធ្វើការរកស៊ីលក់នៅក្នុងពាណិជ្ជកម្មដដែល រហូតដល់ខែមិថុនា ទើបអង្គការដក់ឲ្យទៅនៅក្នុងមន្ទីរភ័ស្តុភារ ។ ដល់ខែកញ្ញា បូ បានផ្លាស់ទៅនៅខាងភ័ស្តុភារយោធាតំបន់៤៣ ភូមិភាគកណ្តាល ដែលមានអ្នកទទួលខុសត្រូវឈ្មោះ យ៉ាង និងមិត្តនារីឈ្មោះ វីន ។ បន្ទាប់មកទៀត បូ ត្រូវបានឈ្មោះ យ៉ាង ចាត់តាំងឲ្យ*

ទៅធ្វើនៅមន្ទីរភូមិស្រឡៅពក សង្កាត់ស្វាយទាប ស្រុកចម្ការលើ ។

ឆ្នាំ១៩៧៥ ខែកុម្ភៈ ឈ្មោះ លាន បានមកជួប បូ ពីរដង ។ លើកទីមួយ មកជំរុញឲ្យ បូ ខិតខំកសាងខ្សែរយៈ សេ.អ៊ី.អា ហើយមកជួបលើកទីពីរគឺណែនាំឲ្យ បូ ស្គាល់ខ្សែរបស់ខ្លួនឈ្មោះ វ៉ែន ឈ្មោះ ហោះ និងឈ្មោះ គុជ ដើម្បីងាយស្រួលទាក់ទងគ្នាធ្វើសកម្មភាព ។ ជាបន្តបន្ទាប់ បូ បានធ្វើសកម្មភាពនៅខាងចម្ការរបស់អង្គភាពគឺ ប្រើគោ មិនយកចិត្តទុកដាក់ ធ្វើឲ្យគោស្គមនៅសល់តែឆ្អឹង ធ្វើឲ្យបាក់រទេះ ធ្វើឲ្យពោតខូចអស់៣បាវ សណ្តែកបាយខូចអស់២បាវ សណ្តែកសៀងខូចអស់២បាវ សណ្តែកដីខូចអស់២បាវកន្ទះ រីឯបេកទុកឲ្យទុំចោលពេញចម្ការមិនកាប់យកផ្លែបញ្ជូនទៅតាមអង្គភាពទេ ។ បន្ទាប់មកទៀត បូ បានផ្លាស់ពីកស្តុភារតំបន់៤៣ មកនៅកស្តុភាយោធាកងពល១៧៤ ភូមិភាគកណ្តាលវិញ មានអ្នកទទួលខុសត្រូវឈ្មោះ លី ។ ក្រោយពីបានដឹងថា បូ និង យ៉ាង គឺជា សេ.អ៊ី.អា មក លី ក៏បានភ្ជាប់ខ្សែ សេ.អ៊ី.អា ជាមួយ បូ ហើយបន្តបំពេញភារកិច្ចរបស់ សេ.អ៊ី.អា បន្តទៀត ដើម្បីកសាងកម្លាំងថែមទៀតឲ្យបានកាន់តែច្រើន ។ មួយរយៈក្រោយមក យ៉ាង បានធ្វើខុសខាងសីលធម៌ ពេលនោះ លី ក៏បានដក យ៉ាង ឲ្យទៅនៅក្នុងសហករណ៍ទៅ ។

ឆ្នាំ១៩៧៦ បូ បានទៅធ្វើការនៅឯកំពង់ចាម ហើយក៏បានជួប លី ។ ពេលនោះ លី ក៏បានណែនាំឲ្យ បូ ស្គាល់ខ្សែ សេ.អ៊ី.អា របស់ខ្លួនដែលកសាងបាននៅក្នុងអង្គភាពកស្តុភារ កងពល១៧៤ មានឈ្មោះ ថា, បឿន, ចក់, នារីដា, នារីហន, យឹន, យឿន, ដែន, អែម, សល់, ប៉ុល, និង ម៉ាត់ ងាយទាក់ទងគ្នាទៅថ្ងៃក្រោយ ។ ខែមិថុនា បូ និង លី អប់រំបានសមាជិកចំនួន ៩នាក់នៅក្នុងអង្គភាពយោធាកស្តុភារ កងពល១៧៤ បញ្ចូលជាខ្សែ សេ.អ៊ី.អា ។ ការអប់រំនេះ បូ បានលើកឡើងពីការធ្វើបដិវត្តន៍សព្វថ្ងៃមានការតឹងតែង មានភារកិច្ចកាន់តែច្រើន មានអង្គការវិន័យកាន់តែតឹងតែងឡើងៗ ហើយត្រូវធ្វើការទាំងយប់ទាំងថ្ងៃ គ្មានពេលទំនេរ ហើយការហូបចុកមិនបានហូបឆ្អែតទៀតផង ។

ឆ្នាំ១៩៧៧ លី បានប្រមូលខ្សែ សេ.អ៊ី.អា ទាំងអស់ដែលកសាងបានចំនួន២១នាក់នៅក្នុងអង្គភាពកស្តុភារ មកប្រជុំនៅវត្តបឹងកុក ។ ពេលនោះ លី បាននិយាយថា “ថ្ងៃនេះ យើងបានមកជួបជុំគ្នា ដោយខ្ញុំចង់ពង្រឹងបន្ថែម ឲ្យយល់កាន់តែច្បាស់ថែមទៀតពីភារកិច្ចរបស់ សេ.អ៊ី.អា គឺត្រូវបម្រើចលនាប្រឆាំងនឹងបដិវត្តន៍ ដើម្បីទាមទារយកមកវិញនូវរបបឯកជន ពីព្រោះរបបឯកជននេះ វាងាយអនុវត្តតាម ។ ហេតុនេះ យើងទាំងអស់គ្នា ត្រូវត្រៀមលក្ខណៈសម្បត្តិឲ្យបានខ្ពស់ និងរួមកម្លាំងជាមួយយោធាយើង ដែលមានឈ្មោះ រាប ជាប្រធានដឹកនាំខ្សែ សេ.អ៊ី.អា នៅក្នុងវរសេនាធំទី១ យើងនេះ” ។ ខែកុម្ភៈ រាប និង លី បានប្រមូលកម្លាំងខ្សែ សេ.អ៊ី.អា មកប្រជុំគ្នានៅខាងលិចមន្ទីរនីរសារយោធា មានសមាជិកចូលរួមចំនួន២២នាក់ ។ នៅក្នុងអង្គប្រជុំ រាប បានលើកឡើងថា “ពេលនេះ យើងបានមកជួបជុំគ្នា ខ្ញុំសូមឲ្យអ្នកទាំងអស់គ្នាស្គាល់គ្នាឲ្យបានច្បាស់ ដើម្បីយើងប្រមូលកម្លាំង សេ.អ៊ី.អា ឲ្យបានកាន់តែច្រើន ហើយយើងនឹងដាក់ផែនការវាយយកកំពង់ចាមនៅពេលខាងមុខនេះ” ។ លី ក៏បានបន្ថែមដែរថា “មុនដាក់ផែនការ ទាល់តែយើងទាំងអស់គ្នាដាច់ខាតទើបបាន ហើយម្យ៉ាងទៀត យើងទាំងអស់គ្នាត្រូវលាក់ការណ៍ឲ្យជិតកុំឲ្យអ្នកណាដឹងទៀតក្រៅពីគ្នាយើង” ។ នៅពេលស្រុះស្រួលមតិគ្នាហើយ អង្គប្រជុំក៏បានរំសាយ ។ ខែមេសា បូ ត្រូវបាន លី ផ្លាស់ ឲ្យមកនៅកំពង់ចាម និងឲ្យទទួលខុសត្រូវពេទ្យយោធាកងពល ១៧៤ ។

មួយខែក្រោយមក រាប និង លី បានបើកការប្រជុំមួយ ដែលមានសមាជិកចូលរួមចំនួន១១នាក់ មានឈ្មោះ រាប, លី, រឿន, ខា, អិន, នីន, បូ, វ៉ន, ប៉ុន, នារី ដា និងនារី ហន ។ នៅក្នុងអង្គប្រជុំ រាប បាននិយាយថា “មូលហេតុដែលយើងប្រជុំគ្នាលើកនេះ គឺខ្ញុំចង់ឲ្យ លី ធ្វើស្ថិតិកាំភ្លើង និងគ្រាប់រំសេវទាំងអស់ដែលមាននៅក្នុងឃ្លាំង ថាតើមានចំនួនប៉ុន្មាន? ដើម្បីយើងត្រៀមឲ្យហើយ កុំឲ្យពិបាកទៅថ្ងៃក្រោយ ។ ហេតុនេះ យើងទាំងអស់គ្នាត្រូវតាំងចិត្តឲ្យរឹងមាំ ទើបយើងវាយយកទីក្រុងកំពង់ចាមបាន នៅពេលត្រឡប់ទៅវិញ យើងត្រូវរៀបចំកម្លាំងត្រៀមទុកឲ្យស្រេច ហើយអប់រំតាមរយៈខ្សែ សេ.អ៊ី.អា របស់យើងនៅតាមអង្គភាពនីមួយៗ ឲ្យបានច្បាស់ថែមទៀត” ។ ក្រោយពេលប្រជុំរួច បូ និង លី កសាងកម្លាំង សេ.អ៊ី.អា បានពីរនាក់មានឈ្មោះ អន អនុប្រធានពេទ្យយោធាកងពល១៧៤ ភូមិភាគកណ្តាល និងនារី ឆួ សមាជិកពេទ្យយោធាកងពល១៧៤ ភូមិភាគកណ្តាល ពីព្រោះ

អ្នកទាំងពីរជាមនុស្សចូលចិត្តចង់បានមុខមាត់ និងបុណ្យស័ក្តិ ចូលចិត្តលក្ខណៈស៊ីចុកឯកជន និងមិនសូវគិតគូរពីការងារទេ ហើយអ្នកទាំងពីរបានធ្វើសកម្មភាពក្នុងមន្ទីរពេទ្យគឺ ចាក់ថ្នាំឲ្យអ្នកជំងឺតែមិនបានដោះស្រាយការហូបចុកឲ្យបានស្រួលបួលដល់អ្នកជំងឺ មានជំនាស់ជាមួយបុគ្គលិកពេទ្យមិនឈប់ឈរ មិនយកចិត្តទុកដាក់មើលថែអ្នកជំងឺធ្ងន់ៗជាដើម ។

ខែសីហា ឆ្នាំដដែល រាប និង លី បានប្រមូលខ្សែ សេ.អ៊ី.អា ក្នុងកស្តុភារយោធាទៅប្រជុំនៅភ្នំប្រុសភ្នំស្រី ។ ពេលដែលសមាជិកមកជួបជុំគ្នាហើយ រាប បានលើកឡើងពីផែនការវាយយកទីក្រុងកំពង់ចាមនៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៧ ប្រាប់ទៅសមាជិកនៅក្នុងអង្គប្រជុំៗក៏បានឯកភាពចំពោះផែនការនេះ ។ ពេលនោះ លី បានបន្ថែមថា បើយើងឯកភាពគ្នាហើយ យើងត្រូវបែងចែកមុខព្រួញគ្នាឲ្យបានច្បាស់លាស់ បើមិនអ៊ីចឹងទេ មុខជាប្រឡូកប្រឡល់មិនខាននៅក្នុងទីក្រុងនេះ ។ បន្ទាប់មក រាប បានបែងចែកមុខព្រួញឲ្យសមាជិកម្នាក់ៗទទួលមុខព្រួញរៀងៗខ្លួនគឺ ៖ ១) ឈ្មោះ ឈាន ទទួលវរសេនាតូច៧០១ ឡើងពីជំរំភ្នំប្រុសភ្នំស្រីតាមផ្លូវជាតិលេខ៧ សំដៅទៅឃ្លាំង ដើម្បីបញ្ចេញអាវុធមកក្រៅបែកទ័ព ។ ២) ឈ្មោះ អិន ទទួលវរសេនាតូច៧០៥ ឡើងពីជំរំវាលវង់ សំដៅទៅវត្តបឹងឆ្នូងទៅខាងកើតសាធារណការ ហើយវាយកម្លាំងមកលិចវិញ ។ ៣) ឈ្មោះ នីនទទួលវរសេនាតូច៧០៣ ឡើងពីវត្តថ្មគោលសំដៅចូលផ្សារតែម្តង ។ ៤) វឿន ទទួលវរសេនាតូច៧០២ ឡើងពីព្រែកដើមចាន់សំដៅទៅខាងត្បូងផ្សារ ។ ៥) ខា ទទួលវរសេនាតូច៧០៤ ឡើងពីជំរំវត្តថ្មី សំដៅទៅខាងលិចសាលាខេត្តចាស់ ។ ៦) វ៉ែន ទទួលវរសេនាតូច៧០៩ ឡើងពីជំរំស្រឹប សំដៅទៅខាងលិចសាលាខេត្តចាស់ ។ ៧) ប៉ុន ទទួលវរសេនាតូច៩០១ ឡើងពីជំរំវត្តអង្គរ សំដៅទៅឃ្លាំង ដើម្បីបញ្ចេញកាំភ្លើងធំមកក្រៅ ។ កាលណាយើងវាយយកក្រុងកំពង់ចាមបានហើយ យើងត្រូវដកទ័ពមកការពារក្រុងវិញភ្លាម ។ ៦ ការការពារក្រុងវិញ ១) ឈ្មោះ នីន ទទួលវរសេនាតូច៧០៣ ការពារខាងជើងក្រុងកំពង់ចាម ពីវត្តថ្មគោលសំដៅទៅវាលយន្តហោះ ។ ២) ឈ្មោះ អិន ទទួលវរសេនាតូច៧០៥ ការពារខាងជើងឈាងខាងលិចក្រុងកំពង់ចាម ពីវាលវង់ទៅទួលដូនជី ផ្លូវចម្ការលើ ។ ៣) ឈ្មោះ ឈាន ទទួលវរសេនាតូច៧០១ ការពារខាងលិចក្រុងកំពង់ចាម ពីទួលដូនជីមកត្រើង ។ ៤) ឈ្មោះ វ៉ែន ទទួលវរសេនាតូច៧០៩ ការពារខាងលិចក្រុងកំពង់ចាម ពីត្រើងទៅភូមិត្រពាំងថ្ម ។ ៥) ឈ្មោះ វឿន ទទួលវរសេនាតូច៧០២ និងឈ្មោះ ខា ទទួលវរសេនាតូច៧០៤ រួមគ្នាការពារខាងត្បូងក្រុងកំពង់ចាម ពីភូមិត្រពាំងថ្មសំដៅទៅព្រែកជីក ។ ៦) ឈ្មោះ ប៉ុន ទទួលវរសេនាតូច៩០១ នៅការពារកាំភ្លើងធំ ។ លុះពេលប្រជុំរៀបចំដាក់ផែនការចប់ លី និង បូ បានវិលមកកន្លែងវិញ ហើយបានប្រជុំខ្សែ សេ.អ៊ី.អា នៅអង្គភាពភ័ស្តុភារ ដើម្បីប្រាប់ឲ្យដឹងពីផែនការវាយក្រុងកំពង់ចាមនៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៧ ហើយប្រាប់ឲ្យត្រៀមលក្ខណៈសម្បត្តិឲ្យហើយ ហើយត្រូវលាក់ការណ៍សម្ងាត់ឲ្យជិតដាច់ខាត ។

លុះដល់ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៧៧ រាប និង លី បានប្រមូលកម្លាំង សេ.អ៊ី.អា មកប្រជុំម្តងទៀតនៅផ្ទះរបស់ លី ដែលអ្នកបានចូលរួមនាពេលនោះមានឈ្មោះ បូ, វឿន, ខា, អិន, រាប, និង លី ។ រាប ក៏បាននិយាយថា យើងបានឯកភាពគ្នាដាក់ផែនការវាយយកទីក្រុងកំពង់ចាមរួចហើយ តែយើងត្រូវមានផែនការមួយទៀត គឺយើងត្រូវដាក់មីនឲ្យផ្ទុះមុនយើងវាយទីក្រុងកំពង់ចាម ហើយយើងកំណត់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៧ ឲ្យផ្ទុះតែម្តង ។ បន្ទាប់មក លី ក៏បានហៅឈ្មោះ មឿន ដែលជាអ្នកទទួលខុសត្រូវមកប្រាប់ពីផែនការទីពីរ គឺត្រូវដាក់មីនឲ្យផ្ទុះឃ្លាំងនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៧នេះ ។ ក្រោយពីបានទទួលផែនការពី លី ហើយ មឿន បានចាត់តាំងបក្ខពួកមួយចំនួនដើម្បីអនុវត្តផែនការនេះ ។ ពេលវេលាចេះតែទៅមុខជានិច្ច ការកំណត់បំផ្ទុះមីនដើម្បីបំផ្លាញឃ្លាំងក៏បានមកដល់ ។ នៅវេលាម៉ោង៤រសៀល មីនក៏បានផ្ទុះឡើង ។ ឈ្មោះ វុធ, ខុន, មឿន, ប៊ុត និងម្នាក់ទៀត មិនស្គាល់ឈ្មោះ ដែលជាអ្នកទទួលខុសត្រូវក្នុងការដាក់បំផ្ទុះមីន នេះត្រូវបានពលីទាំងអស់ ។ បន្ទាប់ពីផ្ទុះមីនបំផ្លាញឃ្លាំងបានប្រមាណម៉ោងកន្លងមក ពោលគឺនៅពេលយប់ដដែល (ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៧) បូ ក៏ត្រូវបានអង្គការចាប់ខ្លួនតែម្តង ។

**ឆេង ខេង**

# ទន្ទឹមនឹងចលនាធ្វើស្រែ យើងត្រូវសម្រុកដាំដំណាំផ្សេងៗទៀត និងបន្លែបន្ការ ឱ្យពាសពេញស្នេកស្ទះ

*ដកស្រង់ចេញពីឯកសារទង់បដិវត្តន៍លេខ៦ ខែមិថុនា ឆ្នាំ១៩៧៦ D២១៤១៥*

**ភារកិច្ចជាយុទ្ធសាស្ត្រប្រចាំឆ្នាំនេះ គឺធ្វើស្រែឲ្យបាន ៣តោន ១ហិកតា**

ដើម្បីឈានទៅសម្រេចយុទ្ធសាស្ត្រ ៣តោន ១ហិកតាក្នុងរដូវវស្សានេះ លុះត្រាតែយើងមានកម្លាំងគ្រប់គ្រាន់ ដើម្បីវាយសម្រុក ។ ដូច្នេះ យើងត្រូវដោះស្រាយជីវភាពប្រជាជនក្នុងរយៈឆ្នងកាត់នេះឲ្យបានជាអតិបរមា ។ បើដោះស្រាយជីវភាពប្រជាជនមិនបានក្នុងខែ៦ ខែ៧ ខែ៨ ខែ៩ និងខែ១០ គឺប៉ះពាល់ដល់កម្លាំងប្រយុទ្ធធំ ។ យើងខ្វះកម្លាំងដើម្បីវាយសម្រុក ។ បញ្ហានេះ វាចោទយ៉ាងនេះ ។

បក្សបានកំណត់ជាយូរខែហើយថា ដើម្បីដោះស្រាយជីវភាពប្រជាជន យើងត្រូវវាយដោយយុទ្ធវិធី គឺវាយដោយស្រូវស្រាល ស្រូវកណ្ដាល ពោត សណ្ដែក ដំឡូង បន្លែបន្ការផ្សេងៗ ។ យើងត្រូវសម្រុកដាំដំណាំរួមផ្សំ និងបន្លែបន្ការឲ្យខ្លាំង ឲ្យពាសពេញឲ្យស្នេកស្ទះ ។ យើងត្រូវវាយជាយុទ្ធវិធីយ៉ាងនេះ ដើម្បីឈ្នះជាយុទ្ធវិធីក្នុងរយៈឆ្លងកាត់រដូវវស្សានេះ ។ យើងត្រូវវាយជាបន្តបន្ទាប់តាមគ្រប់រូបភាព វាយកុំឈប់ វាយទាំងធំ វាយទាំងតូច ។ ពាក្យស្លោករបស់បក្ស គឺ ដាំ ដាំ ដាំ គឺដាំឲ្យពាសពេញ ដាំឲ្យស្នេកស្ទះ ដាំកុំឲ្យសល់ដី ដាំទាំងយុវជន ដាំទាំងយុវនារី ដាំទាំងចាស់ ដាំទាំងកុមារ ដាំទាំងអ្នកពេញកម្លាំង ដាំទាំងអ្នកខ្សោយកម្លាំង ដាំជាសមូហភាព ដាំជាបុគ្គល ដាំជាចម្ការ ដាំមួយគុម្ព ពីរគុម្ព ជុំវិញផ្ទះ ជុំវិញមន្ទីរ ជុំវិញការដ្ឋាន ។ល ។ បើដាំយ៉ាងនេះ យើងដោះស្រាយរយៈឆ្លងកាត់នេះ បានពេញទី ។ បើដោះស្រាយរយៈឆ្លងកាត់នេះបាន យើងពិតជាសម្រេចយុទ្ធសាស្ត្រឆ្នាំ៧៦ នេះបាន ។

**យើងត្រូវជំរុញចលនាដាំដំណាំរួមផ្សំ និងដាំបន្លែបន្ការនៅមូលដ្ឋានឲ្យពាសពេញ ស្នេកស្ទះថែមទៀត**

ជាទូទៅ ប្រជាជនយើង យុទ្ធជន-យុទ្ធនារី និងកម្មាភិបាលយើង ក្ដាប់បានយុទ្ធសាស្ត្រ និងយុទ្ធវិធីបង្កបង្កើនផលរបស់បក្ស ហើយអនុវត្តយុទ្ធសាស្ត្រ និងយុទ្ធវិធីនេះ បានល្អត្រឹមត្រូវតាមទិសរបស់បក្ស ។ ដូច្នេះ នៅកន្លែងជាច្រើន ទន្ទឹមនឹងចលនាវាយសម្រុកខ្លាំងក្លា ក្លួររាស់ ដកស្ទូងធ្វើស្រែវស្សា ចលនាដាំដំណាំរួមផ្សំ និងដាំបន្លែបន្ការគ្រប់មុខ ក៏ដុលផុស សស្រោកសស្រាំ ខុសប្លែកពីឆ្នាំមុនៗ បម្រើសមរភូមិមុខបានល្អផង ធ្វើឲ្យភូមិសហករណ៍យើង លេចចេញទិដ្ឋភាពថ្មី ស្រស់ប្លែកផង ។ ជុំវិញផ្ទះក៏មានដំណាំ ជុំវិញស្រែក៏មានដំណាំ តាមមាត់ប្រឡាយក៏មានដំណាំ ។ ស្អីក៏ដាំ ។ ដូច្នេះ វាយធំក៏វាយ វាយតូចក៏វាយ ។ អនុវត្តមាគ៌ាប្រយុទ្ធរបស់បក្ស បានរស់រវើកតាមសភាពការណ៍ដី សភាពការណ៍ទឹក និងសភាពការណ៍កម្លាំង ជាកម្លាំងធំ កម្លាំងតូច កម្លាំងរាយរង គឺប្រើទាំងអស់ មិនទុកឲ្យទំនេរ ។ ចាត់ចែងកម្លាំង ប្រើប្រាស់កម្លាំងដោយប្រសិទ្ធភាពខ្ពស់ ។

ទិដ្ឋភាពដែលប្លែកខ្លាំង ដែលគួរឲ្យរំភើប គឺទិដ្ឋភាពប្រែប្រួលនៅតំបន់ខាងលើៗមួយចំនួន ។ ពីដើមធ្លាប់តែក្រៀមក្រោះស្ងួតហែងទាំងប្រាំងទាំងវស្សា ។ ឥឡូវ ទៅជាមានព្រែកជីកធំៗ រាប់ច្រើនសិបគីឡូម៉ែត្រ ។ កន្លែងខ្លះ៤០គីឡូម៉ែត្រ កន្លែងខ្លះ៦០គីឡូម៉ែត្រ ។ មានទឹកពេញព្រែក តំបន់ជុំវិញព្រែក ទៅជាមានជីវិតរស់រវើកស្រស់បំព្រង ប្រហាក់ប្រហែលនឹងតំបន់មាត់ទន្លេ ។ ដូច្នេះ ប្រែប្រួលសម្បើម ។ ប្រជាជនសប្បាយចិត្ត រីករាយ មានពន្លឺភ្លឺស្វាង ហើយប្រយុទ្ធកាន់តែខ្លាំងក្លាថែមទៀត ។

ទន្ទឹមនឹងនេះ ក៏នៅមានកន្លែងខ្លះទៀត ក្ដាប់យុទ្ធសាស្ត្រយុទ្ធវិធី បង្កបង្កើនផលរបស់បក្ស មិនទាន់ណែន អនុវត្តមាគ៌ានេះមិនទាន់បានល្អនៅឡើយ ។ ចលនាបង្កបង្កើនផលខ្លាំងក្លាដែរ តែអនុវត្តមាគ៌ាប្រយុទ្ធមិនទាន់រស់រវើក ។ ឧទាហរណ៍ ៖ កន្លែងខ្លះជា

ដីកោះ ជាដីមាត់ទន្លេ ជាដីមានដីជាតិ ជាកន្លែងដែលធ្លាប់តែមានបន្លែបង្ការ ។ តែឆ្នាំនេះអត់ ព្រោះប្រមូលកម្លាំងទៅខាងមុខអស់ ។ ចាស់ក៏ទៅ ក្មេងក៏ទៅ ទៅពពាក់ពពូននៅខាងមុខ ។ ឯនៅខាងក្រោយគ្មានកម្លាំង បោលដីទទេ ។ នេះមិនមែនមកពីដីទេ ។ គឺមកពីការដឹកនាំមកពីការចាត់ចែងកម្លាំងមិនរស់រវើក មិនសមស្រប ។ យើងត្រូវចាត់ចែងកម្លាំង ប្រើប្រាស់កម្លាំងឲ្យសមស្រប ឲ្យមានប្រសិទ្ធភាពថែមទៀត ។ កម្លាំងណាឲ្យទៅខាងមុខ កម្លាំងណាទុកឲ្យនៅខាងក្រោយ ដាំដំណាំរួមផ្សំ និងបន្លែបង្ការរួមផ្សំ ។

ដូច្នេះ កន្លែងណាដែលចលនាដាំដំណាំរួមផ្សំ និងដាំបន្លែបង្ការផុសផុលហើយ ត្រូវជំរុញចលនាថែមទៀត ឲ្យកាន់តែខ្លាំងក្លាទ្វេមួយជាដប់ ជាម្ភៃដងឡើង ។

កន្លែងណាដែលចលនាដាំដំណាំរួមផ្សំ និងបន្លែបង្ការនៅខ្សោយ ត្រូវដកពិសោធ រៀនសូត្រពិសោធ ពីកន្លែងផ្សេង ហើយបំផុសចលនាឲ្យផុសផុលឡើង ។ យើងត្រូវដាំ តែកុំឲ្យប៉ះពាល់កម្លាំង ។ កម្លាំងចាស់ កម្លាំងកុមារ ក៏ដាំបាន ។ ដាំពោត ដាំដំឡូង ដាំបន្លែបង្ការ ដាំត្រឡាច ដាំល្ពៅ ។ ស្អីក៏ដាំ ដាំឲ្យច្រើន ឲ្យកន្លែងមួយទៅជាសួន ។ ក្រៅពីនេះ នៅសមរភូមិខាងមុខក៏ឆ្លៀតដាំបានដែរ ។ ម្នាក់ដាំបាន២-៣-៤-៥គុម្ព ។ ដីខាងក្រោមដាំស្រូវ ដីទួលដាំបន្លែបង្ការ ។ ដាំតាមមាត់ប្រឡាយ ដាំតាមភ្លឺស្រែ ។ បើយើងដាំយ៉ាងនេះ យើងមិនខ្វះទេស្បៀង បន្លែបង្ការ ។ យើងម្ចាស់ការពេញទីក្នុងរយៈឆ្លងកាត់រដូវវស្សានេះ ហើយយើងមានកម្លាំងវាយសម្រុកសម្រេចយុទ្ធសាស្ត្រ បីគោន មួយហិកតា ។

**ជំរុញចលនាបង្កបង្កើនផល នៅគ្រប់មន្ទីរ គ្រប់ក្រសួង ឲ្យកាន់តែមមាញឹក និងឲ្យកាន់តែខ្លាំងក្លាថែមទៀត**

នៅតាមមន្ទីរ តាមក្រសួង តាមរោងចក្រ ក៏កម្មាភិបាលយើងយុទ្ធជន-យុទ្ធនារីយើង បានឆ្លៀតបង្កបង្កើនផល ធ្វើស្រែ ធ្វើចម្ការដាំបន្លែបង្ការខបត្ថម្ភខ្លួន ។ មន្ទីរខ្លះខបត្ថម្ភខ្លួន ខាងបន្លែបង្ការបានទាំងស្រុង ខបត្ថម្ភខ្លួនខាងស្រូវអង្ករ បាន៦០-៧០ភាគរយ ។ ប្រយុទ្ធបំពេញភារកិច្ចស្នូលរបស់ខ្លួនក៏ខ្លាំងក្លា បង្កបង្កើនផល ខបត្ថម្ភខ្លួន ក៏មមាញឹកសកម្ម ។ ដូច្នេះ បរិយាកាសក្នុងមន្ទីរ ក្នុងក្រសួង គឺបរិយាកាស ជាប់ពលកម្ម ជាប់មូលដ្ឋាន ជាប់នឹងសហករណ៍ ។ ជាបរិយាកាសបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម ។

ប៉ុន្តែ មន្ទីរ ក្រសួងជាច្រើនទៀត ក៏នៅខ្សោយខាងបង្កបង្កើនផលនៅឡើយដែរ ។ នៅពឹងផ្អែកលើអង្គការ លើរដ្ឋទាំងស្រុង ឬស្ទើរតែទាំងស្រុង ។ មិនត្រឹមតែពឹងផ្អែកលើរដ្ឋ ឲ្យខបត្ថម្ភខោអាវ ស្បៀកពាក់ អង្ករ អំបិល ប្រហុក ត្រីសាច់ទេ ពឹងពាក់រហូតដល់បន្លែបង្ការថែមទៀត ។ ដូច្នេះ ជាបន្ទុកធ្ងន់ដល់មូលដ្ឋាន ដល់ប្រជាជនដល់សហករណ៍យើង គឺរស់នៅធ្វើការផាវជាច់ពីមូលដ្ឋាន ដាច់ពីប្រជាជន ។ ពេលទំនេរ ពេលសម្រាកពីការងារ ជួនណាមានទាត់សីវាយពីងប៉ុង ឬអង្គុយដិកផ្ជដែកគ្នាលេងឥតប្រយោជន៍ ។ តាមរយៈនេះ ទស្សនៈ និងគោលជំហរនាយទុន នាម៉ឺន វាជ្រៀតចូលក្នុងមន្ទីរ ក្នុងក្រសួងជាបណ្តើរៗ ។ ចំណុចនេះ ដែលយើងត្រូវចាប់អារម្មណ៍ ហើយកែប្រែឲ្យឆាប់រហ័ស ។

ពេលទំនេរពីការងារ ពេលសម្រាកពីការងារ កុំនៅស្ងៀម ។ ត្រូវឆ្លៀតបង្កបង្កើនផល រែកទឹកស្រោចដំណាំ ថែទាំដំណាំ ។

បើប្រៀបធៀបទៅនឹងការប្រយុទ្ធបង្កបង្កើនផលរបស់ប្រជាជនយើងនៅតាមមូលដ្ឋាន មន្ទីរ និងក្រសួងយើង នៅចាញ់ប្រជាជនឆ្ងាយណាស់ ។ សូម្បីតែប្រជាជនថ្មីដែលចេញពីភ្នំពេញទៅ ក៏មន្ទីរ ក្រសួង នៅចាញ់គេដែរ ។

ប្រជាជនយើងយ៉ាងម៉េច? ប្រជាជនយើងគឺអធន ។ ដូច្នេះ ប្រជាជនយើងប្រយុទ្ធនឹងជីវភាពជាប់ ។ ឯនៅមន្ទីរ នៅក្រសួងយ៉ាងម៉េច? ពិតមែនតែគ្មានប្រាក់ខែ តែមានរបបស៊ីចុក ស្លៀកពាក់ ។ ធ្វើឬមិនធ្វើ ក៏មានរបបគ្រប់គ្រាន់ ។ ដូច្នោះ គឺមានទុន ។ ទុននេះ គឺយកមកពីមូលដ្ឋាន យកមកពីប្រជាជន ។ ដូច្នេះ បើមិនប្រុងប្រយ័ត្នគោលជំហរនាម៉ឺន គោលជំហរនាយទុន វាពង្រីង ពង្រីកបាន ។ ជាបណ្តើរៗទៅ មន្ទីរ ក្រសួង វាប្រែធាតុវា ទៅជានាយទុនការិយាល័យកម្ម ។ យើងត្រូវមើលឃើញយ៉ាងនេះ ដើម្បីរៀនសូត្រពីប្រជាជន ដើម្បីបង្កបង្កើនផលឲ្យជាប់ បង្កបង្កើនផលឲ្យមមាញឹកថែមទៀត ។ ទន្ទឹមនេះ ក៏ខិតខំសន្សំសំចៃថែមទៀត ។ សន្សំសំចៃអង្ករ អំបិល ខោអាវស្លៀកពាក់ ។ល ។ សន្សំសំចៃ និងបង្កបង្កើនផល ដើម្បីផ្សារភ្ជាប់មន្ទីរ ក្រសួងយើង ជាមួយមូលដ្ឋាន ជាមួយសហករណ៍ ។

ដូច្នេះ មន្ទីរ និងក្រសួងយើងបង្កបង្កើនផលនេះ មិនមែនដើម្បីបម្រើសំណូមពរចំពោះមុខ កែប្រែជីវភាពរបស់ខ្លួន និងខបត្ថម្ភខ្លួនតែប៉ុណ្ណោះទេ គឺដើម្បីធ្វើបដិវត្តន៍សង្គមនិយម កម្ចាត់

*គោលជំហរនាម៉ឺន កម្ចាត់គោលជំហរនាយទុន កសាងគោលជំហរសង្គមនិយម គោលជំហរសមូហភាព ជាប់នឹងប្រជាជន ជាប់នឹងមូលដ្ឋាន ជាប់នឹងសហករណ៍ ។ បណ្តុះនិស្ស័យ ពង្រឹង ពង្រីកនិស្ស័យស្រឡាញ់ពលកម្ម និងរួមវិភាគទានកសាងសង្គមនិយម ។*

*ជំរុញចលនាបង្កបង្កើនផល ក្នុងកងទ័ពបដិវត្តន៍ រួមចំណែកកសាងប្រទេស ភារកិច្ចស្នូល ភារកិច្ចសំខាន់របស់កងទ័ពបដិវត្តន៍ គឺការពារប្រទេស និងការពារសន្តិសុខលើផ្ទៃប្រទេស ។*

*ទន្ទឹមនេះ កងទ័ពបដិវត្តន៍យើង ក៏ត្រូវរួមកសាងប្រទេសក្នុងក្របខណ្ឌបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម ។*

*កន្លងមក រហូតដល់ថ្ងៃនេះ កងទ័ពបដិវត្តន៍យើងក៏បានរួមយ៉ាងសកម្មគ្មានលក្ខខណ្ឌក្នុងកិច្ចកសាងប្រទេស ។ យុទ្ធជន-យុទ្ធនារី និងកម្មាភិបាលយើង មានស្មារតីវាយសម្រុក ខំធ្វើស្រែ ខំធ្វើដី ។ ពេញចិត្តពេញថ្លើមនឹងចលនាធ្វើស្រែ ធ្វើដី ហើយចលនាមានសន្ទុះខ្លាំងក្លា ។ កងទ័ពបដិវត្តន៍យើង ត្រូវជំរុញចលនានេះថែមទៀត ទាំងចលនាធ្វើស្រែ ទាំងចលនាធ្វើដី ទាំងចលនាដាំដំណាំរួមផ្សំផ្សេងៗ និងដាំបន្លែបង្ការគ្រប់មុខ ។ ពិសេស ជំរុញចលនាធ្វើស្រែឲ្យខ្លាំងក្លាទ្វេមួយជាពីរថែមទៀត ។ កម្លាំងកងទ័ពបដិវត្តន៍ភាគច្រើន ជាកម្លាំងយុវ័ន ហើយជាកម្លាំងពិសេស ខ្លាំងជាងកម្លាំងនៅជនបទឆ្ងាយណាស់ ។ ដូច្នេះ កម្លាំងនេះ មានលទ្ធភាពវាយសម្រុកបង្កបង្កើនផលខ្លាំងក្លាជាងប្រជាជនយើងនៅមូលដ្ឋានឆ្ងាយណាស់ ។ ពិសេសអង្គភាពដែលបោះនៅក្នុងផ្ទៃប្រទេស មានលក្ខណៈសម្បត្តិល្អជាងគេ ពីព្រោះមិនមែនជាប់នឹងសមរភូមិផ្ទាល់ជាប្រចាំ ដូចអង្គភាពនៅតាមព្រំដែន ឬតាមសមុទ្រទេ ។*

*ដូច្នេះ កងទ័ពបដិវត្តន៍ដែលបោះនៅក្នុងផ្ទៃប្រទេស ត្រូវផ្គត់ផ្គង់ខ្លួនឯង ឲ្យបានមួយរយភាគរយ ក្នុងរបប១៣ថាំង ស្មើទាំងបុរសទាំងនារី ។ ទន្ទឹមនេះ ក៏ត្រូវមានផលិផលជាបម្រុងប្រចាំឆ្នាំមួយចំនួនដែរ ។ យ៉ាងតិច២០ភាគរយ នៃសេចក្តីត្រូវការរបស់ខ្លួន ។ ត្រៀមដើម្បីមានការអើយកចំណែកនេះ ទៅថែមបំពេញសេចក្តីត្រូវការបាន ។ ក្រៅពីនេះ ត្រូវផ្តល់ឲ្យរដ្ឋ សម្រាប់កសាងប្រទេស ។*

*ដូច្នេះ កងទ័ពបដិវត្តន៍យើងធ្វើស្រែនេះ មិនមែនត្រឹមតែឲ្យរួចខ្លួនទេ ។ ត្រូវធ្វើឲ្យបានផលច្រើន ។ ទស្សនៈ និងគោលជំហរធ្វើស្រែនេះ ត្រូវពង្រឹង ពង្រីកឲ្យខ្លាំងក្លា ក្នុងន័យនេះ ។ កងទ័ពបដិវត្តន៍នេះ ពីមុន ជាកូនចៅកសិករនៅវាត់វាយ ។ តែឥឡូវទៅជាកងទ័ពបដិវត្តន៍របស់បក្ស ទៅជាកម្មកររបស់បក្ស មានការចាត់តាំងខ្ពស់ និងមានវិទ្យាសាស្ត្រ ។ ពេលសង្គ្រាម ក៏វាយឈ្នះខ្លាំង ។ ដល់បង្កបង្កើនផលក៏ខ្លាំងក្លា ។*

*ថ្ងៃណាមួយ មានសង្គ្រាមទៀត កងទ័ពបដិវត្តន៍យើង ត្រូវច្បាំងការពារប្រទេស ។ ដីស្រែ និងដំណាំដាំដុះនេះ កងទ័ពបដិវត្តន៍ប្រគល់ឲ្យប្រជាជនឲ្យសហករណ៍ ។ ដូច្នេះ កងទ័ពបដិវត្តន៍យើងធ្វើស្រែនេះ និងដាំដំណាំទាំងអស់នេះ គឺដើម្បីកសាងប្រទេស ដើម្បីធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម មិនមែនដើម្បីធ្វើជាកម្មសិទ្ធិឯកជន ឬជាកម្មសិទ្ធិអង្គភាពរបស់ខ្លួនទេ ។ គោលជំហរនេះ ក៏កងទ័ពបដិវត្តន៍យើងត្រូវថែបំប៉នឲ្យជាប់ ដើម្បីរួមចំណែកកសាងប្រទេស និងការពារប្រទេសឲ្យបានខ្លាំងក្លា ក្នុងក្របខណ្ឌបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម ។*

*សរុបមក កសិករសហករណ៍យើងទូទាំងប្រទេស កម្មាភិបាលយុទ្ធជន-យុទ្ធនារីយើងគ្រប់ក្រសួង គ្រប់មន្ទីរ កម្មករយើងគ្រប់រោងចក្រ កងទ័ពបដិវត្តន៍យើងគ្រប់អង្គភាព មានភារកិច្ចវាយសម្រុកសម្រេចទិសដៅយុទ្ធសាស្ត្ររបស់បក្សឆ្នាំនេះ សម្រេចផលស្រូវឲ្យបានបីតោនមួយហិកតា ។ ទាំងអស់គ្នា មានភារកិច្ចរួមកម្លាំងដោះស្រាយជីវភាពប្រជាជនក្នុងរយៈឆ្ងកាត់ ។ បក្សបានកំណត់មាគ៌ាជាយុទ្ធសាស្ត្រ និងមាគ៌ាជាយុទ្ធវិធីត្រឹមត្រូវច្បាស់លាស់ហើយ ។ មាគ៌ានេះកំពុងតែលេចចេញជាលទ្ធផលជាសាច់ការជាប្រព័ន្ធភ្លឺ ជាប្រឡាយទឹក ជាស្រែ ជាសំណាប ជាសន្ទូង ជាសួនដំណាំនៅគ្រប់កន្លែងជាបណ្តើរៗហើយ ។ ឧបសគ្គ និងការលំបាកនៅមាន ។ តែមិនមែនជាឧបសគ្គធំទេ ។ បញ្ហានៅតែយើងទាំងអស់គ្នាវាយសម្រុកឲ្យខ្លាំងក្លាថែមទៀត ឲ្យស័ក្តិសិទ្ធិថែមទៀតដើម្បីឈ្នះ ។ ឈ្នះជាយុទ្ធវិធីផង ហើយឈានទៅឈ្នះជាយុទ្ធសាស្ត្រទៀត ។ យើងត្រូវវាយសម្រុកដាំជាបន្តបន្ទាប់តាមគ្រប់រូបភាពដាំកុំឈប់ ។ យើងចេះតែដាំ ។ បើយើងដាំយ៉ាងនេះ យើងពិតជាដោះស្រាយរយៈឆ្ងកាត់នេះបាន ។ យើងដោះស្រាយរយៈឆ្ងកាត់នេះបាន យើងពិតជាសម្រេចយុទ្ធសាស្ត្រ បីតោន មួយហិកតាឆ្នាំ១៩៧៦នេះ បានជាដាច់ខាត ។ ពាក្យស្លោកយើងគឺ ៖ «ក្មេងចាស់ប្រុសស្រី ដាំ ដាំ ដាំ ដាំកុំឲ្យសល់ដីទំនេរមួយចង្អាម» ។* **ឆេង ខេង**

# ការិយាល័យព័ត៌មានសាធារណៈ

*“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។*

*មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។*

*តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។*

*ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អ៊ុន សុដាវី តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthsodavy.u@dccam.org ។*





















# កាលវិភាគបញ្ចាំងខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា
















*រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង ១០ : ០០ ព្រឹក*

*ទីតាំង : អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង : ម៉ែន ពិចិត្រ ទូរសព្ទលេខ : ០២៣ ២១៨ ០០៩ អ៊ីម៉ែល : truthmpechet@dccam.org*

# រួចជីវិតព្រោះចេះធ្វើស្រែចម្ការ

ឌុច យន ស្រុកកំណើតនៅភូមិបឹងតាព្រាម សង្កាត់កំពត ក្រុងកំពត ខេត្តកំពត (បច្ចុប្បន្នភូមិបឹងតាព្រាម សង្កាត់ត្រើយកោះ ក្រុងកំពត ខេត្តកំពត) ។ យន មានបងប្អូនប្រាំបួននាក់ (ស្រី៣នាក់ ប្រុស៦នាក់) ។ យន ជាកូនទីពីរក្នុងគ្រួសារដែលមានឪពុកជាជាងឈើ និងម្ដាយជាកសិករ នៅភូមិបឹងតាព្រាម ។

យន បានរៀនសូត្រត្រឹមថ្នាក់ទី៨ ក្នុងសម័យសង្គមរាស្ត្រនិយម ។ នៅឆ្នាំ១៩៦៦ យន មានវ័យ១៨ឆ្នាំ និងបានចុះឈ្មោះចូលបម្រើការងារជាកងយុទ្ធពលខេមរភូមិន្ទរបស់សម្ដេចព្រះនរោត្តម សីហនុ ។ យន ត្រូវទៅស្នាក់ និងរស់នៅក្នុងបន្ទាយ និងធ្វើការងារមួយចំនួនទៀត ។ ជាទូទៅ ទាហាននៅបន្ទាយត្រូវបានថ្នាក់លើចាត់តាំងឲ្យដាំដុះដំណាំសម្រាប់ផ្គត់ផ្គង់អង្គភាព ។ ប៉ុន្តែ យន បានរៀនសូត្រចេះដឹងគ្រាន់បើ ទើបថ្នាក់លើចាត់ឲ្យគាត់ធ្វើការនៅក្នុងការិយាល័យ ដោយមានឋានន្តរស័ក្តិពលទោ ។ ក្រោយរដ្ឋប្រហារទម្លាក់សម្ដេច សីហនុ ឆ្នាំ១៩៧០ យន នៅតែបន្តការងាររបស់ខ្លួនជាទាហានដដែល ដោយគ្រប់គ្រងខាងភ័ស្តុភារវរសេនាតូច ។

ក្រោយជ័យជម្នះរបស់ចលនាតស៊ូខ្មែរក្រហម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជននៅក្នុងភូមិបឹងតាព្រាម ត្រូវបានខ្មែរក្រហមជម្លៀសចេញពីភូមិទាំងអស់ ។ មុននឹងជម្លៀស ខ្មែរក្រហមប្រកាសប្រាប់ប្រជាជនគ្រប់គ្នាថា អ្នកដែលជាអតីតអ្នករដ្ឋការចាស់ ទាហាន ប៉ូលីស ត្រូវនៅម្ខុំ និងប្រជាជនធម្មតាត្រូវនៅម្ខុំ ព្រោះត្រូវធ្វើដំណើរទៅកាន់ទិសដៅផ្សេងគ្នា ។ ពេលនោះ យន និងអ្នកឯទៀត ដែលជាអតីតទាហាននៅពាក់ឯកសណ្ឋាននៅឡើយ ប៉ុន្តែ ខ្មែរក្រហមក៏មិនបានធ្វើអ្វីដែរ គឺគ្រាន់តែដឹកអ្នកទាំងអស់គ្នាទៅកាន់វត្តដងទង់ថ្មី ។ យន និងប្រពន្ធត្រូវដឹកទៅកាន់វត្តនោះតែពីរនាក់ប៉ុណ្ណោះ ព្រោះគ្រួសាររបស់គាត់ត្រូវបានខ្មែរក្រហមជម្លៀសទៅកាន់កន្លែងផ្សេងមុនគាត់ទាំងពីរ ។

ដោយនៅវត្តដងទង់ថ្មីមានមនុស្សច្រើនពេក យន និងប្រពន្ធត្រូវបានអង្គការបញ្ជូនបន្តទៅកាន់វត្តក្រាំងលាវ ដែលនៅក្បែរៗវត្តដងទង់ថ្មីដែរ ។ មួយរយៈក្រោយមក យន និងប្រពន្ធ ក៏ដូចជាមនុស្សមួយចំនួនទៀត ត្រូវបានអង្គការយកទៅផ្ញើឲ្យរស់នៅជាមួយប្រជាជនក្នុងភូមិ ។ យន បានឲ្យដឹងថា អំឡុងពេលនោះ មិនទាន់មានការចាប់អតីតទាហាន ឬអ្នករដ្ឋការទៅសម្លាប់នោះទេ ហើយអ្នកដែលត្រូវខ្មែរក្រហមយកទៅសម្លាប់ ភាគច្រើន គឺផ្ដើមចេញពីគំនុំបុគ្គលផ្ទាល់ខ្លួនតាំងពីដើមមក ហើយឆ្លៀតក្នុងឱកាសនេះ ក៏ធ្វើការសងសឹកតែម្ដង ។

យន រស់នៅភូមិមួយនៅខាងត្បូងស្ពានគ្រើង និងធ្វើស្រែនៅទីនោះបានមួយវស្សា ។ ក្រោយមក យន បានដឹងថា ឪពុកម្ដាយក្មេករបស់គាត់រស់នៅឃុំបានាវ ខាងត្បូងផ្សារឈូក ទើបគាត់ និងប្រពន្ធស្នើអង្គការដើម្បីទៅនៅឃុំបានាវវិញ ។ ពេលនោះ អ្នកដែលជាអតីតទាហានជាមួយគាត់សុំគាត់ទៅជាមួយ ហើយអង្គការក៏អនុញ្ញាត ។ ប៉ុន្តែ គាត់ក៏មិនបានរស់នៅភូមិជាមួយឪពុកម្ដាយក្មេកដែរ គ្រាន់តែនៅភូមិក្បែរគ្នា (មិនចាំឈ្មោះ) ដែលស្ថិតក្នុងឃុំជាមួយគ្នា ។

ទៅដល់ភូមិដំបូង យន ត្រូវបានអង្គការចាត់តាំងកាប់ដីដាំពោតដំឡូង ធ្វើស្រែ និងឡើងត្នោត ។ អំឡុងពេលនោះ យន បានឲ្យដឹងថា អង្គការបានធ្វើប្រវត្តិរូបគាត់ជាច្រើនលើកច្រើនសា ដោយសួរគាត់ពីការរៀនសូត្រ ការងារជាដើម ។ យន បានសរសេរប្រាប់អង្គការទាំងអស់ពីអតីតភាពរបស់គាត់ ដោយមិនបានលាក់បាំងអ្វីឡើយ ។ ទោះបីជាដឹងថា យន មានអតីតភាពជាទាហាន ក៏ដោយ អង្គការក៏មិនបានធ្វើទុក្ខម្នេញអ្វីដល់ យន ដែរ ។ អង្គការទុកឱកាសចុងក្រោយឲ្យ យន ធ្វើស្រែចម្ការ និងឡើងត្នោតជាការសាកល្បង ។ ប្រសិនបើគាត់មិនចេះធ្វើការងារទាំងអស់នេះទេ អង្គការនឹងយកគាត់ទៅកម្ទេចជាមិនខាន ។

ដោយសារតែ យន អាចធ្វើការងារស្រែចម្ការ និងឡើងត្នោតបានយ៉ាងស្ទាត់ជំនាញ ទើបអាចរួចរស់ជីវិតនៅពេលនោះ ។ អ្នកដទៃទៀតមិនមានវាសនាដូចគាត់នោះទេ អ្នកខ្លះមិនចេះភ្ជួរស្រែ ឡើងត្នោត គឺត្រូវអង្គការយកទៅកម្ទេចទាំងអស់ ។ យន រម្លឹកថា ពេលសាកល្បងនោះ ពិបាកសម្រាប់គាត់ ព្រោះអង្គការដាក់ផែនការឲ្យគាត់ធ្វើ និងតាមដានជាប់ជានិច្ច ។ យន ត្រូវធ្វើចម្ការភ្ជួរស្រែ ហើយជាពិសេស អង្គការបានដាក់ផែនការឲ្យ យន និងក្រុមគាត់ពីរនាក់ទៀត ឡើងត្នោតបីដើម ធ្វើយ៉ាងណាឲ្យបានទឹកត្នោតមួយខ្ទះ ដើម្បីរំងាស់ជាស្ករ ។ យន និងសមាជិកក្រុម ធ្វើបានគ្រប់ផែនការដែលអង្គការបានសាកល្បង ហើយរួចជីវិតតាំងពីពេលនោះមក ។

បន្ទាប់ពីឆ្លងកាត់ការសាកល្បងហើយ យន និងប្រពន្ធរស់នៅក្នុងភូមិដូចជាប្រជាជនជម្លៀសដទៃទៀតធម្មតា ហើយអង្គការក៏ឈប់ប្រកាន់ទោសពីអតីតភាពរបស់គាត់ដែរ ព្រោះគិតថា ទុកគាត់គឺមានប្រយោជន៍សម្រាប់សហករណ៍ ។ សហករណ៍ដែល យន រស់នៅឈ្មោះសហករណ៍ទី១ (ក្នុងមួយឃុំមាន៣សហករណ៍ ដោយឲ្យឈ្មោះជាលេខ) ។ អំឡុងពេលនោះ ប្រជាជនម្នាក់មានសិទ្ធិរកម្ហូបហូបជាឯកជនបាន ហើយរហូតមកដល់ចុងឆ្នាំ១៩៧៦ ទើបអង្គការឲ្យហូបបាយរួម ។ ពេលហូបបាយរួម របបអាហារមិនគ្រប់គ្រាន់នោះទេ គឺមានតែបបរ ។ ដោយសារតែអ្នកមូលដ្ឋានឃើញផលស្រូវដែលធ្វើបានច្រើន ហើយអង្គការចែកតែបបររាវឲ្យហូប ក៏ធ្វើការតវ៉ាពីបញ្ហានេះ ។ ក្រោយមក អង្គការក៏សម្រេចចែកបបរខាប់ជាងមុន (បបរឈ្នោល) សម្រាប់បីពេលក្នុងមួយថ្ងៃ ។ យន បានឲ្យដឹងថា ទោះយ៉ាងណាសហករណ៍របស់គាត់មិនសូវខ្វះខាតរបបហូបចុកទេ បើប្រៀបនឹងសហករណ៍ដទៃដែលគាត់បានដឹង ។ នៅសហករណ៍ អង្គការមិនអនុញ្ញាតឲ្យរកអាហារហូបជាឯកជនទេ ហើយអ្នកដែលល្មើសនឹងបទបញ្ជានេះ អង្គការនឹងយកមកអប់រំមួយលើកពីរលើក និងបើនៅតែហ៊ានប្រព្រឹត្តខុសទៀត នោះនឹងត្រូវយកទៅរៀនសូត្រ ។ ចំពោះ អ្នកដែលធ្វើការមិនគ្រប់ផែនការ គឺអង្គការតម្រូវឲ្យធ្វើរហូតទាល់តែគ្រប់ផែនការទើបឲ្យសម្រាក និងហូបអាហារ ។

ទោះបីជាមានបបរខាប់ហូប ក៏មិនស័ក្តិសមទៅនឹងកម្លាំងពលកម្មដែលប្រជាជនបានបញ្ចេញរៀងរាល់ថ្ងៃដែរ ។ យន និងប្រពន្ធធ្វើការនៅឃុំបានាវ ដោយមិនត្រូវបានជម្លៀសទៅកន្លែងផ្សេងទេ ។ ក្រោយបញ្ចប់ការងារអ្នកគ្រប់គ្នាអាចត្រឡប់មកសម្រាកនៅផ្ទះជុំគ្រួសារបាន ។ យន បានឲ្យដឹងថា ទោះបីជាគាត់មិនបានឃើញខ្មែរក្រហមសម្លាប់មនុស្សដោយផ្ទាល់ ក៏ដឹងថា មនុស្សនៅក្នុងឃុំមួយចំនួនបានបាត់ខ្លួន ហើយអ្នកទាំងនោះ ត្រូវឈ្លបខ្មែរក្រហមមកហៅនៅពេលយប់ ។ សាសនាទាំងប៉ុន្មានត្រូវបានខ្មែរក្រហមលុបបំបាត់ទាំងស្រុង ហើយក៏គ្មាននរណាម្នាក់ហ៊ានគោរពប្រណិប័តន៍ដែរ ។ អ្នកដែលចេះធម៌អាថ៌ប្ញភាសាបរទេស ក៏អង្គការមិនទុកដែរ ។

នៅឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានិងកងទ័ពស្ម័គ្រចិត្តវៀតណាមបានវាយចូលមកដល់ ។ កម្មាភិបាលខ្មែរក្រហម បានកៀរប្រជាជនទាំងអស់ទៅតាមខ្លួន ដោយបានឃោសនាថា កងទ័ពវៀតណាមចូលមកហើយ ប្រសិនបើចាប់បាននឹងអារកនឹងធាងត្នោតមិនខាន ។ ដោយមានការភ័យខ្លាចប្រជាជនទាំងអស់ក៏ភៀសខ្លួនទៅតាមការឃោសនារបស់កម្មាភិបាលខ្មែរក្រហម ។ ពេលនោះខ្មែរក្រហមបានកៀរប្រជាជនទៅដល់វត្តចក ហើយក៏ស្នាក់នៅទីនោះមួយយប់ ។ យប់នោះ យនបានដើរទៅខាងក្រោយវត្តដើម្បីរកចំបើងឲ្យក្របីស៊ី ក៏ឮការជជែកគ្នារបស់កម្មាភិបាលខ្មែរក្រហមអំពីសភាពការណ៍ទូទៅថាមិនស្រួលទេ និងត្រៀមភៀសខ្លួនបន្តទៀត ។ អំឡុងពេលធ្វើដំណើរតាមផ្លូវជាមួយនឹងយោធាខ្មែរក្រហម ក៏ពើបប្រទះនឹងកងទ័ពវៀតណាម ។ ប្រយុទ្ធគ្នាបានបន្តិច កម្លាំងខ្មែរក្រហមបានគេចខ្លួនចោលប្រជាជនអស់ ។ បន្ទាប់មក យន និងប្រពន្ធក៏ដូចជាអ្នកឯទៀតត្រូវបានកងទ័ពវៀតណាមឲ្យធ្វើដំណើរត្រឡប់មកភូមិកំណើតវិញ ។ យន បានចំណាយពេលធ្វើដំណើរជាង៥ថ្ងៃទើបមកដល់ភូមិតាព្រាមវិញ ។

ក្រោយរបបខ្មែរក្រហមបានដួលរលំ យន បានជួបជុំគ្រួសារជាថ្មីវិញ ប៉ុន្តែគាត់បានបាត់បង់ប្អូនប្រុសម្នាក់ ដោយខ្មែរក្រហមយកទៅសម្លាប់ ព្រោះតែមានជាប់និន្នាការនឹងរបបចាស់ ។ យនបានចាប់ផ្តើមជីវិតជាថ្មី ដោយប្រកបរបបរធ្វើស្រែចម្ការ និងឡើងត្នោត ។ បច្ចុប្បន្ន គាត់ និងប្រពន្ធនៅផ្ទះមើលថែរក្សាចៅៗ ហើយជីវភាពគ្រួសារ គឺកូនទាំងប្រាំរបស់គាត់ជាអ្នករ៉ាប់រង ។

**ឆាង សារៈមុនិន្ទ**

# វេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការបង្រៀន ប្រ
# នៅវិទ្យាល័យ ហ៊ុន សែន ប៊ុន រ៉ា ផ្សារ









# វត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)
# ដើមថ្កូវ កាលពីថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦









# ការចែករំលែកបទពិសោធន៍ពីរបបខ្មែរក្រហម ពីលោក លឹម ហម នាយករងវិទ្យាល័យ ហ៊ុន សែន ប៊ុន រ៉ានី ផ្សារដើមថ្កូវ



លោក លឹម ហម នាយករងវិទ្យាល័យ ហ៊ុន សែន ប៊ុន រ៉ានី ផ្សារដើមថ្កូវ បាន រៀបរាប់ពីរឿងរ៉ាវដែលគាត់បានឆ្លងកាត់របបខ្មែរក្រហម ប្រាប់ដល់បុគ្គលិកទស្សនាវដ្តីស្វែងរកការពិត នៅការិយាល័យរបស់គាត់ ។

កាលពីថ្ងៃសុក្រទី ៣ កុម្ភៈ ឆ្នាំ២០១៧ កន្លងទៅនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំវេទិកាថ្នាក់រៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដល់សិស្សថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុន សែនប៊ុនរ៉ានីផ្សារដើមថ្កូវ ក្នុងគោលបំណងអប់រំសិស្សានុសិស្សឲ្យយល់ដឹងបន្ថែមពីរបបខ្មែរក្រហម ក៏ដូចជាជំនួយដល់ការប្រលងថ្នាក់ជាតិនាពេលខាងមុខ ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំ និងមិត្តរួមការងារបានចូលជួបសំណេះសំណាលជាមួយលោកនាយករង លឹម ហម ដើម្បីសាកសួរអំពីមតិយោបល់របស់លោកនាយករងទាក់ទងនឹងវេទិកាថ្នាក់រៀននេះ ក៏ដូចជាប្រវត្តិផ្ទាល់ខ្លួនខ្លះៗរបស់លោក ជាពិសេសការចងចាំរបស់លោកក្នុងសម័យខ្មែរក្រហម ។

លឹម ហម កើតនៅឆ្នាំ១៩៦៧ ។ នៅក្នុងសម័យ លន់ នល់ គ្រួសាររបស់គាត់រស់នៅក្នុងស្រុកអង្គស្នួល ខេត្តកណ្ដាល ។ ឪពុករបស់លោកជាអ្នករត់រ៉ឺម៉កម៉ូតូពីពេទ្យលោកសង្ឃ ទៅស្រុកអង្គស្នួល ។ នៅក្នុងឆ្នាំ១៩៧៤ គាត់ និងឪពុកម្ដាយបានធ្វើដំណើរតាមរ៉ឺម៉កម៉ូតូមកក្រុងភ្នំពេញដើម្បីរត់គេចពីសង្គ្រាម និងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ។ ជាអកុសលនៅពេលដែលក្រុមគ្រួសាររបស់ ហម កំពុងធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញ យន្តហោះអាមេរិកបានទម្លាក់គ្រាប់បែកចំផ្ទះរបស់គាត់ បណ្ដាលឲ្យជីតាវ័យ ៧០ឆ្នាំរបស់គាត់បានបាត់បង់ជីវិត ។ គ្រួសាររបស់ ហម បានដឹកសពជីតាមកបញ្ចុះនៅកំបូលជ្រាយក្រុងភ្នំពេញ ដោយសារតែពេលនោះរដ្ឋាភិបាលមិនអនុញ្ញាតឲ្យដឹកសពចូលក្នុងក្រុង ។

ពេលខ្មែរក្រហមវាយចូលទីក្រុងភ្នំពេញនាឆ្នាំ១៩៧៥ ហម និងគ្រួសារត្រូវបានខ្មែរក្រហមជម្លៀសទៅកាន់ភូមិណាំតាវ ស្រុកថ្មពួក ខេត្តបាត់ដំបង ដែលនៅជិតព្រំដែនខ្មែរ-ថៃ ។ ពេលទៅដល់ទីនោះ គាត់មិនត្រូវបានខ្មែរក្រហមបំបែកចេញពីឪពុកម្ដាយ ដូចយុវជន យុវនារីផ្សេងទៀតនោះទេ ។ ប៉ុន្តែ ហម ត្រូវបានអង្គការចាត់ឲ្យធ្វើការនៅក្នុងកងកុមារ ដូចជា ដើររើសក្ដួរស្រូវ ជញ្ជូនអាចម៍គោ កាប់ទន្រ្ទានខេត្តជាដើម ។ ហម បានបន្តទៀតថា ត្បិតតែគាត់នៅតូចមែន ប៉ុន្តែគាត់បានឆ្លងទុក្ខលំបាក និងការអត់ឃ្លានគ្រប់បែបយ៉ាងនាពេលនោះ ។ ជារឿយៗ ហម ដើរដឹកដំឡូង រកបន្លែ ខ្ចង ក្ដាម ឬសត្វល្អិតផ្សេងៗទៀតមកហូបទាំងឆៅ ដើម្បីបំបាត់ភាពស្រេកឃ្លាន ។ ហម នៅចាំបានថា មានម្ដងនោះ ដោយ

សារតែការហេវហត់ពេលដើររើសក្ដួរស្រូវ គាត់ក៏បានបេះផ្លែចំបក់ហូប ស្រាប់តែពុលប្រកាច់នៅក្រោមដើមចំបក ។

គាត់បានរស់នៅក្នុងភាពជូរចត់បែបនេះរហូតដល់ថ្ងៃរំដោះ ៧ មករា ១៩៧៩ ។ បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្ដួលរំលំ ហម និងគ្រួសារបានធ្វើដំណើរត្រឡប់ទៅស្រុកកំណើតវិញ ។ តាមផ្លូវធ្វើដំណើរ ហម បានឃើញសាកសពមនុស្សស្លាប់ពេញផ្លូវ ដែលធ្វើឲ្យគាត់មានការរន្ធត់ចិត្តយ៉ាងខ្លាំង រាល់ពេលរំលឹកពីរឿងនេះម្ដងៗ ។ អ្វីដែលគាត់ចាំមិនភ្លេចនោះគឺ ហម បានឃើញប្រជាជនព្រួតវាយសម្លាប់អតីតកម្មាភិបាលខ្មែរក្រហមដែលពួកគេធ្លាប់ស្គាល់ ដើម្បីជាការសងសឹក បញ្ចេញកំហឹង ចំពោះទុក្ខវេទនាដែលអ្នកទាំងនោះទទួលបានក្នុងរយៈពេលជាង៣ឆ្នាំ ។

ថ្វីត្បិតតែ ក្នុងសម័យខ្មែរក្រហម ហម ស្ថិតក្នុងវ័យកុមារ និងពុំបានហែលឆ្លងទុកលំបាកខ្លាំងដូចប្រជាជនវ័យជំទង់ និងវ័យចំណាស់ ប៉ុន្តែការរំលោភសិទ្ធិមនុស្ស អំពើសាហាវយង់ឃ្នងទាំងនោះពុំគួរកើតមានលើប្រជាជនគ្រប់វ័យ និងគ្រប់វណ្ណៈនោះទេ ។ គាត់បានបន្ថែមថា ការអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហមនាពេលបច្ចុប្បន្ននេះ ពិតជាមានសារសំខាន់ខ្លាំងណាស់សម្រាប់ក្មេងជំនាន់ក្រោយ ពីព្រោះការអប់រំនេះបានបង្ហាញអ្នកទាំងនោះឃើញពីភាពសាហាវឃោរឃៅដែលក្រោមការដឹកនាំរបស់មេដឹកនាំសម័យនោះ និងនយោបាយកុម្មុយនីស្តផ្ដាច់ការរបស់ប៉ុល ពត ។ ផលអវិជ្ជមាននៃការសិក្សាប្រវត្តិសាស្ត្រគឺអាចធ្វើឲ្យក្មេងជំនាន់ក្រោយដែលពុំធ្លាប់ឆ្លងកាត់មានការប៉ះពាល់ដល់សតិអារម្មណ៍ដែរ ប៉ុន្តែក្នុងផលវិជ្ជមាន គឺក្មេងៗដែលជាអ្នកជំនាន់ក្រោយទាំងនេះអាចរៀនសូត្រពីរឿងរ៉ាវ និងជៀសវៀងនូវទង្វើឃោរឃៅគ្រប់រូបភាពដែលបានកើតឡើងនាពេលនោះ ។

**ឈឹម អមរ័ត្ន និង ឯម សីលា**




*ការតាំងពិព័រណ៍ស្ដីពី «ការជម្លៀសប្រជាជនដោយបង្ខំ» នៅក្នុងរបបខ្មែរក្រហម នៅវិទ្យាល័យ ហ៊ុន សែន-ប៊ុន រ៉ានី ផ្សារដើមថ្កូវ*

# ឡូត ខន : អតីតយោធាខ្មែរក្រហម

ឡូត ខន ជាអ្នកដែលមានស្រុកកំណើតនៅខេត្តសៀមរាប ។ បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេច សីហនុ នៅឆ្នាំ១៩៧០ ខន បានស្ម័គ្រចិត្តចូលរួមចលនាតស៊ូបដិវត្តន៍របស់ខ្មែរក្រហម ។ គាត់ចូលបដិវត្តន៍ដំបូងមាននាទីជាយោធា ។ ខន បានប្រយុទ្ធជាមួយទាហាន លន់ នល់ នៅសមរភូមិស្រុកក្រឡាញ់ ខេត្តសៀមរាប ហើយនៅឆ្នាំ១៩៧៣ និងឆ្នាំ១៩៧៤ គាត់បានផ្លាស់មកឈរជើងការពារនៅសមរភូមិស្រុកពួកវិញ ។

ក្រោយជ័យជម្នះឆ្នាំ១៩៧៥ ខន បានឈប់ពីយោធា ហើយស្នើសុំថ្នាក់លើធ្វើជាប្រជាជនធម្មតាវិញ ។ បន្ទាប់មក គាត់ និងគ្រួសារត្រូវបានអង្គការជម្លៀសឲ្យទៅរស់នៅស្រុកសូទ្រនិគម ខេត្តសៀមរាប ។ នៅទីនោះ ម្តាយរបស់គាត់បានស្លាប់ដោយសារជំងឺនៅឆ្នាំ១៩៧៦ (ឪពុកបានស្លាប់នៅឆ្នាំ១៩៧៣) ។ ខន និងបងប្អូន៤នាក់ទៀតបានរស់នៅ និងធ្វើស្រែនៅសូទ្រនិគម រហូតដល់ឆ្នាំ១៩៧៧ ទើបអង្គការចាត់តាំង ខន ឲ្យចូលធ្វើជាយោធាម្តងទៀត និងបញ្ជូនឲ្យទៅឈរជើងការពារនៅព្រំដែនថៃ ម្តុំតំបន់ប្រាសាទព្រះវិហារ ។



ហេង សុរីតា និស្សិតស្ម័គ្រចិត្ត កំពុងចាំងជម្រះស្មៅនៅបរិវេណមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ស្ថិតនៅខួងភ្នំដងរែក ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

ខន បានឲ្យដឹងថា រៀងរាល់ព្រឹកវេលាម៉ោង៤ មានកងដឹកជញ្ជូនបានយកមកចែកឲ្យកងរបស់គាត់ ហើយបើនរណាម្នាក់មានជំងឺ ត្រូវបានអង្គការបញ្ជូនមកព្យាបាល នៅមន្ទីរពេទ្យភ្លាមៗដែរ ។ យូរៗម្តង ទើប ខន បានច្បាប់មកលេងភូមិ ហើយបើទោះបីជាគាត់ឮថាមានការកាប់សម្លាប់ប្រជាជនក្តី ក៏កម្មាភិបាលនៅមូលដ្ឋានប្រាប់គាត់ថា អ្នកទាំងនោះសុទ្ធតែជាខ្មាំង ដែលដាច់ខាតត្រូវតែកម្ទេច ។

ខន ឈរជើងការពារនៅតំបន់ប្រាសាទព្រះវិហាររហូតដល់របបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ទើបគាត់ផ្លាស់មកឈរជើងការពារនៅតំបន់អន្លង់វែងបណ្តោះអាសន្នជាមួយកម្លាំងខ្មែរក្រហមដែលនៅសេសសល់ ។ បន្ទាប់ពីប្រយុទ្ធជាមួយនឹងកងទ័ពរដ្ឋាភិបាលជាច្រើនលើក កងទ័ពរដ្ឋាភិបាលដកថយពីតំបន់អន្លង់វែង ទើប ខន និងគ្រួសារផ្លាស់មករស់នៅអន្លង់វែង ។ ប៉ុន្តែ ទោះបីជាកងទ័ពរដ្ឋាភិបាលដកថយក៏ដោយ រៀងរាល់យប់ ខន មិនបានដេកស្រួលនោះទេ ព្រោះគាត់ត្រូវយាមប្រចាំការ និងចាំស្តាប់សភាពការណ៍ខ្លាចមានការលបវាយឆ្មក់ជាយថាហេតុពីរដ្ឋាភិបាល ។

ខន បានឲ្យដឹងថា នៅតំបន់អន្លង់វែង ដែលស្ថិតក្រោមការគ្រប់គ្រងរបស់តា ម៉ុក គឺប្រសើរជាងការរស់នៅក្នុងរបបខ្មែរក្រហម ។ តាម៉ុក បានសាងសង់អគារមួយចំនួន ដូចជា សាលារៀន មន្ទីរពេទ្យ ទំនប់ជាដើម ។ ខន បានចូលរួមជីក "ទំនប់អូរជីក" បានបីថ្ងៃ ។ គាត់ក៏ បានចូលរួមជីកទំនប់ធំមួយហៅថា "ទំនប់ថ្មី" ដែលជាអាងស្តុកទឹកធំមួយ និងជារនាំងសម្រាប់ការពារខ្មាំងសត្រូវដែរ ។

បន្ទាប់ពីតំបន់អន្លង់វែងធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាល ប្រជាជននៅក្នុងតំបន់នេះ បានរស់នៅដោយសុខសន្តិភាព ។ ខន បានចាប់ផ្តើមជីវិតជាថ្មីជាមួយនឹងរបរជាកសិករ ហើយបងប្អូនទាំង៤របស់គាត់ក៏មានគ្រួសារ និងផ្លាស់ទៅរស់នៅភូមិផ្សេងៗពីគាត់ដែរ ។ ខន មានក្តីរីករាយ ដែលបានដឹងថា តំបន់អន្លង់វែង ត្រូវបានចាត់ទុកជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ ហើយការរស់នៅប្រកបដោយសន្តិភាពដូចសព្វថ្ងៃគឺគ្រប់គ្រាន់ហើយសម្រាប់គាត់ ។

**ហេង សុរីតា**

# ខ្មែរក្រហមសម្លាប់ឪពុក និងតារបស់ខ្ញុំ

ឈឹម ណារី មានអាយុ៥២ឆ្នាំ និងមានកូនបីនាក់ ។ ណារី មានស្រុកកំណើតនៅភូមិព្រៃយ៉ាវ ឃុំស្រែក្នុង ស្រុកជុំគិរី ខេត្តកំពត ហើយសព្វថ្ងៃរស់នៅឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

នៅពេលដែលខ្មែរក្រហមបានកាន់កាប់អំណាចទាំងស្រុង នៅខែមេសា ឆ្នាំ១៩៧៥ ណារី ទើបមានអាយុប្រហែលជាង១០ ឆ្នាំប៉ុណ្ណោះ ។ គាត់បានរស់នៅជាមួយឪពុកម្តាយនៅភូមិព្រៃយ៉ាវ ឃុំស្រែក្នុង ស្រុកជុំគិរី ខេត្តកំពត ។ គាត់បានរៀបរាប់បន្តថា ពេលនោះ ខ្មែរក្រហមបានបែងចែកការងារឲ្យប្រជាជន ដោយមិនឲ្យនរណាម្នាក់នៅទំនេរឡើយ ។ ឪពុកម្តាយរបស់ ណារី ត្រូវបានខ្មែរក្រហមបញ្ជូនឲ្យទៅកាប់គាស់គល់ឈើដើម្បីវាទយកដីធ្វើស្រែ ។ ការងារត្រូវធ្វើចាប់ពីព្រលឹមទល់ព្រលប់ រីឯរបបអាហារវិញ ប្រជាជនទទួលបានពីរពេលក្នុងមួយថ្ងៃ គឺពេលថ្ងៃត្រង់ និងពេលល្ងាច តែហូបមិនបានឆ្អែតទេ ព្រោះអ្នកទាំងនោះទទួលបានតែបបររាវៗលាយជាមួយពោត និងសណ្តែកមួយកូនចានចង្កឹះប៉ុណ្ណោះ ។ ចំណែក ណារី ត្រូវបានអង្គការបញ្ជូនឲ្យទៅធ្វើការនៅកងកុមារ ដោយតម្រូវឲ្យរែកដីដំបូក និងរើសអាចម៍គោយកមកទុកធ្វើជី ។ ក្មេងៗដែលនៅក្នុងកងកុមារជាមួយ ណារី ត្រូវបានអង្គការឲ្យធ្វើការជារៀងរាល់ថ្ងៃ ប៉ុន្តែ ណារី ក៏មានឱកាសចូលរៀនជាមួយក្រុមកុមារផ្សេងៗទៀតដែរ ដោយក្នុងមួយថ្ងៃរៀនមួយម៉ោងកន្លះ ។ នៅពេលរៀនចប់ ណារី ត្រូវទៅរែកដី និងរើសអាចម៍គោធ្វើជីវិញ ។ កាលនោះរបបអាហារហូបចុកពុំបានហូបគ្រប់គ្រាន់ទេ ណារី និងកុមារឯទៀត ត្រូវស៊ូទ្រាំអត់ឃ្លាន តែមិនហ៊ានត្អូញត្អែរថាហូបមិនឆ្អែតទេ ព្រោះខ្លាចអង្គការធ្វើបាប ។ ដោយសារការខ្វះខាតអាហារ និងហូបមិនបានឆ្អែត ទាំង ណារី និងឪពុកម្តាយ ត្រូវលួចយកគល់ចេក គល់ល្ហុង ហូបនៅពេលយប់ដើម្បីបំបាត់នូវសេចក្តីស្រេកឃ្លាន ដោយមិនឲ្យអង្គការដឹងឡើយ ព្រោះម្តាយខ្ញុំបានប្រាប់ថា បើអង្គការបានដឹង នឹងយកយើងទាំងអស់គ្នា ទៅសម្លាប់ចោលជាមិនខាន ។ ចំណែកសម្លៀកបំពាក់ គាត់មានតែខោអាវមួយកំប្លេរពាក់ជាប់នឹងខ្លួនដែលអង្គការបានចែកឲ្យស្លៀកពាក់ពេញមួយឆ្នាំម្តង ។ រីឯអ្នកខ្វះទៀត ដោយសារមានការខ្វះខាតសម្លៀកបំពាក់ ខ្វះបានយកការុងសម្រាប់ដាក់អំបិលស្តើងៗមកស្លៀកលេចមុខលេចក្រោយ ដែលមើលទៅគឺវេទនាខ្លាំងណាស់ ។ ចំណែកអ្នកឈឺល្មមៗ មិនអាចសុំច្បាប់អង្គការឈប់សម្រាកបានទេ តែពេលឈឺធ្ងន់ ធ្វើការងារលែងកើត និងដើរលែងរួច ទើបអង្គការអនុញ្ញាតឲ្យឈប់សម្រាកព្យាបាល ។

មានរឿងដែលធ្វើឲ្យ ណារី តក់ស្លុតនោះគឺ ឪពុក និងជីតារបស់គាត់ត្រូវអង្គការចាប់យកទៅសម្លាប់ ព្រោះគាត់ធ្លាប់ជាអតីតមេឃុំសង្គមចាស់ ។ ណារី និងម្តាយ រួមទាំងសាច់ញាតិទាំងអស់បានត្រឹមតែនាំគ្នាលួចយំ មិនហ៊ានឲ្យអង្គការដឹងឡើយ ព្រោះខ្លាចអង្គការចាប់យកទៅសម្លាប់ទៀត ។ មិនតែប៉ុណ្ណោះ ណារី ត្រូវបានអង្គការបញ្ជូនឲ្យទៅដើររើសអាចម៍គោ រែកដី រហូតដល់គ្រុនក្តៅរងាស្ទើរស្លាប់ស្ទើររស់ ចំណែកការហូបចុកក៏មិនមានគ្រប់គ្រាន់ ។

កាលនោះ អ្នកដែលត្រូវបានអង្គការទុកចិត្ត និងជ្រើសរើសយកមកឲ្យដឹកនាំធ្វើជា មេក្រុម មេកង សុទ្ធតែជាមនុស្សមិនចេះលេខអក្សរ និង គ្មានការយោគយល់ដល់មនុស្សដូចគ្នាឡើយ ។ មានពេលមួយនោះ ណារី បានឃើញមនុស្សជាច្រើននាក់ ត្រូវបានខ្មែរក្រហមយកទៅសម្លាប់នៅក្បែរវត្តអង្គ ក្នុងខេត្តកំពត ប៉ុន្តែ ណារី មិនបានដឹងថា អ្នកដែលត្រូវអង្គការយកទៅសម្លាប់នោះ បានធ្វើអីខុសនោះទេ ។ ណារី ធ្លាប់បានឃើញការធ្វើបាបកើតមានឡើងសឹងរាល់ថ្ងៃ ដូចជា ការធ្វើទារុណកម្មដោយវាយដំ ការបាញ់សម្លាប់ វាយនឹងត្បូងចប អ្នកខ្វះត្រូវខ្មែរក្រហមចងទុកចោល ដើម្បីបង្អត់អាហារក៏មាន ។ ចំពោះអ្នកដែលមានទ្រព្យសម្បត្តិ ហើយមិនព្រមយកទៅដាក់ធ្វើជាទ្រព្យសម្បត្តិរួម នៅពេលឈ្លប ស៊ើបដឹង ក៏ត្រូវចោទថាក្បត់ ជានាយទុន ហើយត្រូវយកទៅកសាង ។ អ្នកដែលត្រូវអង្គការយកទៅកសាង ឬយកទៅឲ្យរៀនសូត្រ ភាគច្រើនមិនឃើញវិលត្រឡប់មកវិញទេ ។ **សេង ស្រីលក្ខណ៍**

# ជីវិតជាទាហានក្នុងរបបខ្មែរក្រហម

ញែម ជៀង អាយុ៦៥ឆ្នាំ មានស្រុកកំណើតនៅខេត្តកំពង់ធំ សព្វថ្ងៃរស់នៅក្នុងភូមិអូរគគីរក្រោម ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ ប្រពន្ធឈ្មោះ អឿន ញ ជាអតីតនាយទាហានក្នុងរបបខ្មែរក្រហម ។ ជៀង ជាកូនទី៦ ស្ថិតក្នុងគ្រួសារដែលមានបងប្អូនចំនួន៦នាក់ ប្រុស៣ ស្រី៣នាក់ (បងប្អូនចំនួន៥នាក់ បានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ដោយមិនដឹងមូលហេតុ) ។

នៅមុនឆ្នាំ១៩៧០ ជៀង រស់នៅក្នុងបន្ទុកឪពុកម្តាយ និងបានចូលរៀននៅសាលាក្នុងភូមិ ។ ឆ្នាំ១៩៧០ ពេលដែលស្រុកកើតចលាចល ហើយត្រូវការទាហានការពារជាតិផង មនុស្សជាច្រើន ត្រូវបានចាប់បញ្ជូនឲ្យធ្វើជាទាហាន ជាពិសេសបុរសភេទដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ដែលនៅក្នុងនោះ ក៏មាន ជៀង ម្នាក់ដែរ ។ ជៀង បានចូលបម្រើការងារជាទាហាននៅឆ្នាំ១៩៧០ ក្នុងរបបសាធារណរដ្ឋខ្មែរ ដែលគ្រប់គ្រងដោយ លន់ នល់ ។ កាលនោះ ជៀងមានអាយុទើបតែ១៥ឆ្នាំប៉ុណ្ណោះ ។



ញែម ជាង កំពុងធ្វើទ្រូសម្រាប់ដាក់យកត្រីនៅខាងក្រោមផ្ទះ ។ ជាង បានផ្តល់បទសម្ភាសន៍ពីជីវិតរបស់គាត់ដែលឆ្លងកាត់របបខ្មែរក្រហមប្រាប់ដល់ កង ធី និស្សិតស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅផ្ទះរបស់គាត់ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៣ ថ្នាក់លើបានផ្លាស់ ជៀង ពីស្រុកកំណើត (ខេត្តកំពង់ធំ) ឲ្យទៅនៅខេត្តកំពង់ចាម ។ នៅពេលដែលឪពុកម្តាយរបស់ ជៀង ស្លាប់ ជៀង បានសុំច្បាប់ដើម្បីបានទៅចូលរួមធ្វើបុណ្យសពឪពុកម្តាយ តែត្រូវបានអ្នកគ្រប់គ្រងអង្គភាពបដិសេធ និងឲ្យគាត់នៅធ្វើការដដែល ។ ជៀង និងយុទ្ធជនដទៃទៀត ត្រូវបានថ្នាក់លើបញ្ជូនទៅលត់ដំ ព្រមទាំងឲ្យរៀនក្បួនយុទ្ធសាស្ត្រសម្រាប់ទៅធ្វើសឹកសង្គ្រាម ។ ចាប់តាំងពេលនោះមក ជៀង មិនដែលបានទៅលេងស្រុកកំណើតរបស់ខ្លួនទេ តែគាត់បានទទួលដំណឹងពីក្រុមគ្រួសារតាមរយៈអ្នកភូមិនិយាយប្រាប់ថា បងរបស់គាត់ពីរនាក់ ត្រូវជ្រើសរើសឲ្យចូលធ្វើជាទាហាន ។

នៅឆ្នាំ១៩៧៥ ជៀង ត្រូវបានផ្លាស់មកនៅស្រុកអន្លង់វែង ស្ថិតនៅលើកំពូលភ្នំដងរែក ក្នុងទឹកដីនៃខេត្តឧត្តរមានជ័យ ។ ជីវភាពរស់នៅទីនោះ គឺមានបាយហូប តែមិនគ្រប់គ្រាន់ទេ ។ ម្យ៉ាងទៀត ពេលចេញទៅបំពេញភារកិច្ចយាមល្បាតម្តងៗ គាត់ត្រូវដេកក្នុងព្រៃ ហាលថ្ងៃហាលខ្យល់ គ្មានកន្លែងស្នាក់នៅសមរម្យ គ្មានមុង ឬភួយសម្រាប់ដណ្តប់ឡើយ ។ មានពេលខ្លះយុទ្ធជននៅទីនោះ បានពើបប្រយុទ្ធជាមួយសត្រូវ និងត្រូវរត់ទាំងយប់ក៏មាន ដើម្បីគេចចេញពីសត្រូវ ។ មានយុទ្ធជនខ្លះទៀត ត្រូវស្លាប់ដោយសារតែការហូបចុកមិន

*គ្រប់គ្រាន់ ។ ដោយសារតែភាពស្រេកឃ្លាននេះហើយ ទើបបណ្តាលឲ្យមានយុទ្ធជនមួយចំនួនរួមទាំង ជៀង បានធ្វើសកម្មភាពល្មើសនឹងវិន័យរបស់អង្គការ ទៅលួចជីកដំឡូងមកហូបដើម្បីបំបាត់ការស្រេចឃ្លាន ។*

*វិន័យរបស់អង្គការពិតជាតឹងតែងណាស់ គឺបានហាមដាច់ខាតមិនឲ្យប៉ះពាល់ទ្រព្យសម្បត្តិរបស់សមូហភាព (អ្វីៗទាំងអស់ជារបស់អង្គការមាន ផ្ទះ គោ ក្របី ស្រែចម្ការ ។ល ។) ។ ជៀង បានប្រាប់ឲ្យដឹងថា ពេលមួយនោះ គាត់ចុះទៅប្រយុទ្ធនៅសមរភូមិ គាត់មិនបានហូបបាយពេញមួយថ្ងៃ ព្រោះជាប់ដៃប្រយុទ្ធតទល់ជាមួយសត្រូវ ដៃកាន់អាវុធមែនពិត តែចំពោះកម្លាំងកាយ គឺរត់ចេញបាត់ពីក្នុងខ្លួនស្ទើរអស់ សឹងតែដើរដួលទៅហើយ ។ ពេលវាយប្រយុទ្ធគ្នាម្តងៗ តែងមានអ្នករៀបចំបាយទឹកសម្រាប់ទាហានជានិច្ច តែមានមួយលើកនោះ គ្មាននរណាហ៊ានយកបាយទឹកមកឲ្យកងទ័ពទាល់តែសោះ ព្រោះការវាយប្រយុទ្ធគ្នានៅគ្រានោះ គឺពិតជាខ្លាំងក្លាណាស់ មានទាំងយន្តហោះមកទម្លាក់គ្រាប់បែក ហេតុនេះកងទ័ពទាំងអស់ត្រូវដាច់បាយដាច់ទឹក ។*

*រៀងរាល់ពេលប្រយុទ្ធនៅសមរភូមិម្តងៗ ជៀង ឮតែសំឡេងយុទ្ធជនត្រូវរបួស ស្រែកអង្វរឲ្យជួយ មានខ្លះក៏ស្លាប់ ត្រូវបានគេសែងចេញពីសមរភូមិ ។ គាត់បានត្រឹមតែឈរមើល និងនឹកអាណិតនៅក្នុងចិត្តតែប៉ុណ្ណោះ ហើយត្រូវបោះជំហានបន្តដំណើរទៅមុខទៀត ទោះជាដឹងខ្លួនយ៉ាងច្បាស់ថា នឹងអាចមានសភាពដូចពួកគេក៏ដោយ ។ ពេលចេញទៅសមរភូមិម្តងៗ ជៀង បានត្រឹមប្រើខ្សែភ្នែករបស់គាត់ ដើម្បីសម្លឹងមើលទៅទាហានដែលនៅក្នុងអង្គភាពជាមួយគ្នា ដោយមិនហ៊ាននិយាយស្តី ឬសួរនាំអ្វីច្រើននោះទេ ។ ការប្រយុទ្ធ គឺរង់ចាំតែបញ្ជាពីថ្នាក់លើតែប៉ុណ្ណោះ ។ បើនិយាយវិន័យរបស់ទាហានវិញ គឺមានភាពតឹងតែងណាស់ មិនឲ្យដើរហើរទៅណាសេរីទេ បើគ្មានការអនុញ្ញាតពីថ្នាក់លើ ។ បើនរណាម្នាក់មិនគោរពតាមវិន័យរបស់អង្គភាព ត្រូវទទួលទោស ឬដាក់ពិន័យពីប្រធានអង្គភាព ។ បើមានកំហុសធ្ងន់ ត្រូវបានផ្លាស់ចេញពីអង្គភាពរបស់ខ្លួន ទៅអង្គភាពមួយផ្សេងទៀត តែមិនត្រូវបានយកទៅសម្លាប់ទេ ។ បើមានទោសស្រាល ត្រូវពិន័យដោយវាយនឹងដំបងតែមិនវាយដំធ្ងន់ធ្ងររហូតដល់ស្លាប់នោះទេ ។ ជៀង ជាយុទ្ធជននៅសមរភូមិមុខ ដូចនេះគាត់មិនសូវដឹងពីស្ថានការណ៍នៅសមរភូមិក្រោយប៉ុន្មានទេ ។ កាលនោះ ចុងភៅរបស់អង្គភាព សុទ្ធតែជាបុរសទាំងអស់ ។ ជៀង បានបន្តថា គាត់មិនដែលឃើញឃើញចុងភៅជាមនុស្សស្រីទេ នៅក្នុងអង្គភាពរបស់គាត់ ។ កាលនោះ អង្គការបានបែងចែកដាច់ដោយឡែកពីគ្នារវាងបុរស និងនារី មិនអនុញ្ញាតឲ្យរស់នៅជាមួយគ្នាទេ ។*

*នៅឆ្នាំ១៩៨២ ជៀង បានរៀបការជាមួយប្រពន្ធរបស់គាត់ឈ្មោះ អឿន ញ ដែលជាការចាត់ចែងរបស់អង្គការ ។ ក្នុងអំឡុងពេលដែល ជៀង មានប្រពន្ធហើយនោះ គឺគាត់អាចសុំច្បាប់ពីអ្នកគ្រប់គ្រងអង្គភាពឈប់សម្រាករយៈពេលមួយខែ ឬពីរខែបាន ដើម្បីទៅលេងប្រពន្ធកូន ។ អង្គភាពរបស់ ជៀង នៅពេលនោះស្ថិតនៅក្រោយការគ្រប់គ្រងផ្ទាល់របស់ តាម៉ុក ។ ទោះបីជាតាម៉ុក ជាអ្នកគ្រប់គ្រងអង្គភាពរបស់ ជៀង ផ្ទាល់ក៏ដោយ តែ ជៀង មិនដែលបានជួប ឬឃើញ តាម៉ុក ដោយផ្ទាល់នោះទេ ។ គាត់បានត្រឹមតែដឹងតាមអ្នកឯទៀតនិយាយថា តាម៉ុក ជាមនុស្សល្អ ដែលបានចែក អង្ករ ខោអាវ និងសម្ភារផ្សេងៗ ដល់ប្រជាជនដែលមកសុំគាត់ ។*

*ជៀង បាននិយាយឲ្យដឹងទៀតថា នៅក្នុងរបបខ្មែរក្រហម គាត់មិនដែលបានឃើញគេយកមនុស្សទៅសម្លាប់ដោយផ្ទាល់ភ្នែកទេ តែធ្លាប់បានឮថាមានមនុស្សជាច្រើនត្រូវបានគេយកទៅសម្លាប់ តែមិនដឹងថានរណាជាអ្នកសម្លាប់ទេ ហើយក៏មិនដឹងសម្លាប់ដើម្បីអ្វីដែរ ។ បន្ទាប់ពីខ្មែរក្រហមបានធ្វើសមាហរណកម្ម ចុះចូលជាមួយរាជរដ្ឋាភិបាលក្នុងឆ្នាំ១៩៩៩ មក គាត់ក៏បានសម្រេចចិត្តឈប់ធ្វើជាទាហាន ដោយវិលត្រឡប់មករួមរស់ជាមួយក្រុមគ្រួសារប្រពន្ធកូនវិញ ។*

*ជៀង នៅតែចងចាំពីដំណើរជីវិតរបស់គាត់ ដែលធ្លាប់បានឆ្លងកាត់ធ្វើជាទាហានរហូតមក ។ គាត់ចង់រស់នៅក្នុងភាពស្ងប់ស្ងាត់ ចង់រស់នៅដោយសុខសន្តិភាព និងមានជីវភាពសមល្មមដូចសព្វថ្ងៃនេះ គឺគ្រប់គ្រាន់ហើយសម្រាប់រូបគាត់ ហើយគាត់ក៏មិនចង់ឲ្យរបបខ្មែរក្រហម កើតមានឡើងសាជាថ្មីម្តងទៀតនៅប្រទេសកម្ពុជាដែរ ។*

**ភខ ធី**

# មិនដឹងសោះថា ខ្លួនឯងជាខ្មែរក្រហម

ទូច វ៉ាន ភេទស្រី អាយុ៥៩ឆ្នាំ សព្វថ្ងៃរស់នៅភូមិអូរគគីរក្រោម ឃុំលំទោង ស្រុកអន្លង់វែង ខេត្ត ឧត្តរមានជ័យ ។ វ៉ាន មានស្រុកកំណើតនៅស្រុកស្ទួល ខេត្តក្រចេះ និងមានកូនចំនួន៤នាក់ ។

សព្វថ្ងៃ វ៉ាន បម្រើការងារផ្នែកទទួលបន្ទុកការងាររដ្ឋបាលស្ត្រី និងជនក្រីក្រនៅក្នុងតំបន់នៃស្រុកអន្លង់វែងដែលគាត់កំពុងរស់នៅ ។ វ៉ាន បានឲ្យដឹងពីខ្សែជីវិតខ្លះៗ ដែលគាត់ធ្លាប់បានឆ្លងកាត់កន្លងមកនៅក្នុងរបបខ្មែរក្រហម ។

កាលណោះ ប្រហែលជាក្នុងអំឡុងឆ្នាំ ១៩៧៥ វ៉ាន ត្រូវបានខ្មែរក្រហមបញ្ជូនឲ្យទៅធ្វើការនៅក្នុងរោងបាយ ដោយមាននាទីជាអ្នកដាំបាយឲ្យសហករណ៍ ។ រហូតមកដល់ឆ្នាំ១៩៧៦ គាត់ក៏ត្រូវបានអង្គការបញ្ជូនបន្តឲ្យទៅចៀរជ័រនៅស្រុកស្ទួល ខេត្តក្រចេះ ។

ទីនោះ ការរស់នៅរបស់ វ៉ាន ជួបការលំបាកខ្លាំង ដោយសារការគ្រប់គ្រងពីសំណាក់ខ្មែរក្រហមមានការតឹងរ៉ឹង និងមិនឲ្យគាត់វិលត្រឡប់មករស់នៅជួបជុំក្រុមគ្រួសារវិញ ។ វ៉ាន បានឲ្យដឹងទៀតថា នៅទីនោះមានប្រជាជនជាច្រើន ត្រូវបានអង្គការចាត់ឲ្យមកធ្វើការងារជាអ្នកចៀរជ័រ ។

ឆ្នាំ១៩៧៩ សង្គ្រាមរវាងកម្លាំងខ្មែរក្រហមជាមួយនឹងកងទ័ពវៀតណាម បានកើតមានឡើងនៅក្នុងស្រុកស្ទួល ។ ពេលនោះពួកគាត់ក៏ត្រូវបានយោធាខ្មែរក្រហមជម្លៀសជាក្រុមបន្តឲ្យមករស់នៅលើភ្នំដងរែក ក្នុងទឹកដីខេត្តឧត្តរមានជ័យ ។ នៅពេលដែលគាត់មកដល់តំបន់នេះដំបូង អង្គការតម្រូវឲ្យគាត់ធ្វើកាងារស្រែចម្ការដូចជាអ្នកចំណូលថ្មីឯទៀតដែរ ។

លុះមកដល់ឆ្នាំ១៩៨០ ពួកគាត់ បានភៀសខ្លួនទៅរស់នៅឯតំបន់ភូណយ ក្នុងទឹកដីថៃ ។ គាត់រស់នៅទីនោះបាន ប្រមាណជាងមួយឆ្នាំ ទើបគាត់វិលត្រលប់មករស់នៅលើភ្នំក្នុងទឹកដីខ្មែរវិញ ដោយទទួលតួនាទីជាអ្នកដាំបាយផង ជាអ្នករៀបចំទទួលភ្ញៀវផង ហើយត្រូវឡើងទៅរាយការណ៍ក្នុងអង្គប្រជុំ ។ ប្រហែលជាមួយសប្តាហ៍ ឬពីរសប្តាហ៍ មានការជួបប្រជុំម្តង (វ៉ាន មិនបានបញ្ជាក់ពីការប្រជុំនោះក្នុងគោលបំណងអ្វីទេ ហើយក៏មិនបានបញ្ជាក់ថាមានអ្នកណាខ្លះ ដែលបានចូលរួមប្រជុំដែរ) ។ ពេលខ្លះគាត់ក៏បានចេញទៅជួយជញ្ជូនគ្រាប់រំសេវយកទៅឲ្យកងទ័ពខាងសមរភូមិមុខដើម្បីទុកប្រើប្រាស់ការពារជាមួយកងទ័ពវៀតណាមដែរ ។

ទោះបីជាការរស់នៅរបស់គាត់មានការផ្លាស់ប្តូរពីមួយកន្លែងទៅមួយកន្លែងក៏ពិតមែន ប៉ុន្តែ ជីវិតរបស់គាត់ហាក់ដូចជាមិនមានជួបការលំបាកខ្លាំងក្លានោះទេក៏ព្រោះតែកន្លែងដែលគាត់រស់នៅនោះមានការគ្រប់គ្រងល្អពីសំណាក់ តាម៉ុក ហើយគ្រប់ពេលដែលប្រជាជននៅក្នុងតំបន់ជួប ការខ្វះខាតក្នុងការហូបចុក គឺពួកគាត់តែងតែស្នើសុំជំនួយពីតាម៉ុកៗ ក៏បានផ្តល់ជាស្បៀងអាហារ ថ្នាំសង្កូវ និងសម្ភារប្រើប្រាស់ផ្សេងៗមកពួកគាត់ជានិច្ច ។

នៅឆ្នាំ១៩៩៨ នៅពេលដែលខ្មែរក្រហមធ្វើសមាហរណកម្មចុះចូលជាមួយរដ្ឋាភិបាល ទើប វ៉ានដឹងខ្លួនថា គាត់ជាក្រុមខ្មែរក្រហម ព្រោះរយៈកាលកន្លងមកដែលគាត់រស់នៅទីនោះ គាត់មិនបានដឹងថា ខ្លួនគាត់ស្ថិតនៅក្នុងក្រុមខ្មែរក្រហមសោះឡើយ ។ ក្រោយពីបានដឹងថាខ្លួនស្ថិតនៅក្នុងក្រុមខ្មែរក្រហមមក គាត់មានអារម្មណ៍អន់ចិត្តបន្តិចបន្តួច ។

ទាក់ទងទៅនឹងការកាត់ទោសមេដឹកនាំខ្មែរក្រហម វ៉ាន បានបញ្ចេញចំណាប់អារម្មណ៍ផ្ទាល់ខ្លួនថា «ការកាត់ទោសរបស់តុលាការលើមេដឹកនាំខ្មែរក្រហម គាត់មិនមានអ្វីទាមទារច្រើននោះទេ គឺគ្រាន់តែចង់ឲ្យតុលាការបញ្ចប់រឿងនេះទៅ ព្រោះបើសិនជាគាត់ក្តីបន្តទៀត ក៏មិនមានទទួលបានអ្វីលើសពីនេះទៀតដែរ ហើយមានបុគ្គលជាច្រើនបានចូលរួមក្នុងរឿងនេះ បើកាត់ទោសតែម្នាក់ៗដូច្នេះក៏មិនកើតដែរ» ។

**កុយ សៅសុយ៉ាន**

# ការចងចាំរបស់ មាស ពៅ

ការផ្លាស់ប្តូរនៃរបបដឹកនាំក្នុងប្រទេសមួយ ក៏អាចធ្វើឲ្យការរស់នៅរបស់ប្រជាជនមានការផ្លាស់ប្តូរទៅតាមនោះដែរ ។ ធ្លាប់បានហែលឆ្លងកាត់ច្រើនសម័យកាល ស្ត្រីវ័យ៦១ឆ្នាំមួយរូប ហាក់បានជួបនូវព្រេងសំណាងច្រើនជាងអ្នកឯទៀតដែលឆ្លងកាត់ពេលវេលាដូចគ្នា តែមានវាសនាខុសគ្នា ។

មានស្រុកកំណើតនៅខេត្តកំពង់ស្ពឺ អ្នកស្រី មាស ពៅ បានរៀនត្រឹមថ្នាក់ទី៩ (សង្គមចាស់) ប៉ុណ្ណោះ ។ គាត់ធំដឹងក្តីក្នុងគ្រួសារជាកសិករ និងមានបងប្អូន៨នាក់ ។ រៀបរាប់ដោយសំឡេងមួយៗ និងគិតទៅរឿងអតីតកាល ពៅ ឲ្យដឹងថា ជីវិតរបស់គាត់ដែលបានឆ្លងកាត់សម័យសង្គ្រាម គឺជាការចងចាំដែលមិនអាចបំភ្លេចបាន ជាពិសេសគឺភាពខុសប្លែកនៃការរស់នៅស្រណុកស្រួលជាងមនុស្សមួយចំនួនធំ ដែលស្ថិតនៅក្នុងពេលវេលាដូចគ្នា និងប្រទេសជាតិមួយដូចគ្នា ។

ពៅ បានរម្លឹកអំពីប្រវត្តិតស៊ូដែលបានឆ្លងកាត់ថា ក្រោយរដ្ឋប្រហារថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០ គាត់បានស្ម័គ្រចិត្តចូលតស៊ូបដិវត្តន៍ ។ ពេលនោះ គាត់ធ្វើជាយោធា ដោយមានភារកិច្ចដឹកជញ្ជូនគ្រាប់ ។ ចុងឆ្នាំ១៩៧៤ ពៅ បានផ្លាស់ពីការងារយោធា មកធ្វើការនៅរោងចក្រស្ករស តំបន់១៥ ខាងលិចភ្នំពេញ ដែលស្ថិតនៅភូមិអណ្តូងចម្រុះ ស្រុកពញាឮ ខេត្តកណ្តាល ។

បន្ទាប់ពីជ័យជម្នះថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ពៅ ត្រូវបានផ្ទាក់លើផ្លាស់ឲ្យមកធ្វើការនៅទីក្រុងភ្នំពេញ ។ គាត់ត្រូវបានអង្គការចាត់តាំងឲ្យធ្វើជាប្រធានក្រុមកម្មករនៅរោងចក្រតម្បាញមួយក្បែរផ្សារអូរឫស្សី ។ និយាយមកដល់ចំណុចនេះ ពៅ ញញឹម និងបន្តថា ជីវិតរបស់គាត់ពេញមួយរបបខ្មែរក្រហម មិនបានជួបទុក្ខលំបាកខ្លាំងដូចប្រជាជនទូទៅ ដែលបានជួបប្រទះឡើយ ហើយបញ្ហាកង្វះខាតអាហារ ក៏មិនមែនជាបញ្ហាដែលគាត់ជួបប្រទះដែរ ។

ពៅ បានឲ្យដឹងថា នៅរោងចក្រតម្បាញ គាត់ទទួលរបបអាហារ៣ពេល ។ បាយ និងម្ហូបចម្អិនដោយចុងភៅដែលធ្លាប់ធ្វើការនៅហាងបារាំងកាលពីជំនាន់មុន ។ ពេលព្រឹកមានបបរ ហើយពេលថ្ងៃ និងល្ងាច មានបាយ ។ ចំពោះការងារក៏មិនលំបាកខ្លាំងដែរ គឺបែងចែកទៅតាមផ្នែក និងតួនាទីរៀងៗខ្លួន ។

ពៅ តែងតែចងចាំនូវអំពើល្អរបស់ប្រធានរោងចក្រតម្បាញរបស់គាត់ឈ្មោះ តាទុង ។ ពៅ បានឲ្យដឹងថា តាទុង តែងតែសណ្តោសប្រណីដល់កម្មករគ្រប់គ្នា ដែលជាហេតុធ្វើឲ្យកម្មករស្រឡាញ់ចូលចិត្ត និងមានភាពកក់ក្តៅក្នុងការធ្វើការងារ ។ ប៉ុន្តែ អ្វីដែលគួរឲ្យសោកស្តាយ តាទុង ត្រូវបានដកចេញពីតំណែង និងផ្លាស់ចេញពីរោងចក្រ ។ ពៅ គ្រាន់តែដឹងថា ការដែលអង្គការដក តាទុង ព្រោះគាត់មានប្រពន្ធជាអ្នកភូមិភាគបូព៌ា ទើបជាប់និន្នាការក្បត់ ។

ការស្នាក់នៅរបស់ ពៅ នៅរោងចក្រតម្បាញ មានការបែកចែកជាក្រុម ដោយមួយក្រុមៗមានគ្នា១២នាក់ នៅក្នុងផ្ទះល្វែងជាន់លើមួយនៅម្តុំផ្សារអូរឫស្សី ។ រៀងរាល់មួយអាទិត្យម្តង គាត់តែងតែទៅផ្សារធំថ្មីដើម្បីបើកម្ហូបអាហារ ដោយពេលនោះត្រូវប្រើបណ្ណ ហើយការធ្វើដំណើរ ខាងអង្គភាពចាត់ឲ្យមានឡានជូនទៅទៀតផង ។ បន្ថែមពីលើនេះ ភាពស៊ីវិល័យនៃការរស់នៅរបស់គាត់នៅរបបខ្មែរក្រហម ហាក់មានភាពគួរឲ្យកត់សម្គាល់ ។ ជាក់ស្តែង នៅក្នុងរោងចក្រតម្បាញរបស់ ពៅ មានទូទឹកកកសម្រាប់ក្លាស្សេត្រី សាច់ បន្លែ ទុកសម្រាប់ធ្វើម្ហូបថែមទៀតផង ។ ចំណែកឯឯកសណ្ឋានធ្វើការក្នុងរោងចក្រតម្បាញនេះ គឺសំពត់ពណ៌ខ្មៅ និងអាវពណ៌ខៀវ ។

ថ្វីត្បិតតែ មានការរស់នៅក្នុងជីវភាពល្អប្រសើរ មានហូបចុកគ្រប់គ្រាន់ មានសម្លៀកបំពាក់ស្លៀកពាក់ និងមិនត្រូវបានបង្ខិតបង្ខំឲ្យធ្វើការងារធ្ងន់ក្តី ក៏ ពៅ នៅតែបង្ហាញពីក្តីកង្វល់ដោយមានការភ័យខ្លាចថ្នាក់លើចាប់កំហុស ឬខ្លាចមានអង្គការចោទប្រកាន់អំពីរឿងខ្សែផ្ទៃក្នុងដែលម្តាយគាត់តែងតែផ្តាំផ្ញើ និងប្រាប់ឲ្យ

គាត់ប្រុងប្រយ័ត្ន ។ អ្វីដែលគួរឲ្យកត់សម្គាល់មួយទៀតគឺ ច្បាប់ធ្វើការក្នុងរោងចក្រនៅក្នុងក្រុងភ្នំពេញនៅសម័យខ្មែរក្រហម មិនបានរឹតបន្តឹងនោះឡើយ ។ ជាក់ស្ដែង ពៅ បានឲ្យដឹងថា គាត់អាចមានសិទ្ធិសុំច្បាប់ទៅលេងស្រុកកំណើត ឬសុំអនុញ្ញាតនាំម្ដាយមកលេងភ្នំពេញបាន ។

ឆ្លើយតបនឹងសំណួរខ្ញុំថា តើគាត់ធ្លាប់បានឃើញការសម្លាប់មនុស្សដោយផ្ទាល់ដែរទេ? ពៅ បញ្ជាក់ថាមិនធ្លាប់ទេ ប៉ុន្តែគាត់ធ្លាប់ឮ និងដឹងអំពីការរស់នៅលំបាកវេទនារបស់ប្រជាជននៅជនបទ ។ មកដល់ចំណុចនេះ ពៅ បានបង្ហាញភាពអាណិតអាសូរដល់អ្នកដែលទទួលរងនូវការលំបាកទាំងអស់នោះ ហើយគាត់ក៏មិនចង់ឲ្យរបបខ្មែរក្រហមកើតឡើងសាជាថ្មីម្ដងទៀតដែរ បើទោះបីជាគាត់មិនបានរស់នៅលំបាកក៏ពិតមែន តែមានមនុស្សជាច្រើនដែលមិនមានវាសនាដូចគាត់ ។

ទោះបីជាយ៉ាងណា ពៅ មិនបានស្អប់ ឬមិនពេញចិត្តនូវរបបកម្ពុជាប្រជាធិបតេយ្យដែលគាត់ធ្លាប់បានឆ្លងកាត់មួយនេះឡើយ ដោយអះអាងថា ការដឹកនាំនៃរបបនេះគឺអាស្រ័យទៅលើអ្នកអនុវត្តផ្ទាល់នៅថ្នាក់ក្រោម ដែលអនុវត្តលើសកម្រិត ហើយសំខាន់បំផុតក៏អាស្រ័យទៅលើមនុស្សដែរ ។

ចំពោះថា តើការកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមឲ្យជាប់គុកអស់មួយជីវិត សម្រាប់ ពៅ យល់ថាជារឿងយុត្តិធម៌ដែរឬទេ គាត់បានឲ្យដឹងថា ដោយសារតែមានការស្លាប់ប្រជាជនក្រោមការដឹកនាំរបស់អ្នកទាំងនោះ អ៊ីចឹងទោះចង់ ឬមិនចង់ នេះជាការទទួលខុសត្រូវរបស់ពួកគាត់ បើទោះជាពួកគាត់មិនមែនជាអ្នកសម្លាប់ដោយផ្ទាល់ក៏ពិតមែន ប៉ុន្តែពេលនោះស្ថិតក្នុងជំនាន់ដែលពួកគាត់ដឹកនាំ ។

ពៅ បានរៀបការជាមួយប្ដីឈ្មោះ ដួន ណាក់ នៅឆ្នាំ១៩៨០ ពេលដែលគាត់ត្រូវបានជម្លៀសមកនៅលើភ្នំដងរែក ក្នុងស្រុកអន្លង់វែង ។ ពេលនោះ ប្ដីរបស់គាត់ជាយោធាក្រោមការដឹកនាំរបស់តាម៉ុក ។

ការរៀបការនេះ ក៏មិនមានការបង្ខិតបង្ខំឡើយ គឺជាការស្ម័គ្រចិត្តស្រលាញ់គ្នាទាំងសងខាងក្រោយពេលស៊ើបសួរពីប្រវត្តិគ្នារួចស្រេច ។ ក្រោយពីរស់នៅលើភ្នំដងរែកដោយមានតួនាទីជាអ្នកបើកអាហារឲ្យកងទ័ពក្រោមការគ្រប់គ្រងរបស់តាម៉ុកអស់រយៈពេលជិត១០ឆ្នាំ ពៅ និងគ្រួសារបានចុះមកតាំងទីលំនៅនៅខាងក្រោមភ្នំវិញដូចគ្រួសារយោធាឯទៀតដែរ រហូតដល់បច្ចុប្បន្ន ។

**សន ឆវីចរិតី**



និស្សិតស្ម័គ្រចិត្តនៃគម្រោងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានចុះធ្វើទស្សនកិច្ចសិក្សារយៈពេលបីថ្ងៃ នៅតំបន់ប្រវត្តិសាស្ត្រអន្លង់វែង ខេត្តឧត្តរមានជ័យ ។ និស្សិតស្ម័គ្រចិត្តទាំងអស់ កំពុងស្ដាប់ការធ្វើបទបង្ហាញរបស់លោក លី សុខឃាង (រូបឈរ) ជាប្រធានគម្រោង ទាក់ទងនឹងប្រធានបទ សង្គ្រាម ជម្លោះ អំពើហិង្សា និងស្ថានភាពក្នុងតំបន់អន្លង់វែង មុននឹងសិស្សនិស្សិតទាំងនេះចុះទៅជួបប្រជាជននៅក្នុងសហគមន៍ ។

# ស្វាយ សំបួរ អតីតអនុលេខាស្រុកសំរោងទង

នៅអំឡុងពេលសង្គ្រាមស៊ីវិលរវាងពួកខ្មែរក្រហម និងទាហាននៃរបបសាធារណរដ្ឋខ្មែរពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ស្រុកកណ្តាលស្ទឹងស្ថិតក្នុងភូមិភាគពិសេស ។ លក្ខណៈភូមិសាស្ត្រស្រុកកណ្តាលស្ទឹងនៅពេលនោះ គឺរួមទាំងស្រុកកណ្តាលស្ទឹងពេលបច្ចុប្បន្ន និងតំបន់មួយចំនួនរបស់ស្រុកអង្គស្នួល ស្រុកសំរោងទង និងស្រុកគងពិសី ។ នៅខណៈពេលនោះ ក៏មានភូមិឃុំមួយចំនួនរបស់ស្រុកកណ្តាលស្ទឹងបានក្លាយទៅជាតំបន់ប្រទាញប្រទង់រវាងកងទ័ពខ្មែរក្រហម និងទាហាននៃរបបសាធារណរដ្ឋខ្មែរ ។

ព្រំ ទូច ហៅ ស្វាយ សំបួរ មានស្រុកកំណើតនៅខេត្តកណ្តាល បានរៀបរាប់ប្រាប់ថា បន្ទាប់ពី លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ នៅឆ្នាំ១៩៧០ ដោយសារមានចិត្តស្រលាញ់ព្រះមហាក្សត្រ សំបួរ បានបំផុសបំផុលអ្នកស្រុកដែលមានចិត្តចង់ជួយសម្តេចព្រះសីហនុដូចគ្នាឲ្យចូលព្រៃ ដើម្បីធ្វើការតស៊ូ ។ នៅចុងឆ្នាំ១៩៧០ សកម្មភាពរបស់ សំបួរ ត្រូវបានបែកការណ៍ ហើយទាហាន លន់ នល់ បានដេញចាប់គាត់ ។ សំបួរ បានរត់ចូលព្រៃខាងត្រពាំងល្ពាជាមួយបក្ខពួកចំនួន៥ នាក់ទៀត ដែលមានឈ្មោះ នៅ, ចាប, ជុន, សំបុក និង កែវ ។ ពេលដែល សំបួរ រត់ចូលព្រៃដំបូងមានក្រុមចលនាតស៊ូរបស់ខ្មែរក្រហមឈ្មោះ គុណ ហៅ១០១ ចេញមកទទួលក្រុមរបស់គាត់ និងបានយកទៅផ្ញើជាមួយប្រជាជនរយៈពេលប្រមាណ ១-២ខែ ទើបយកទៅកន្លែងកងទ័ពបដិវត្តន៍ ។

ដោយសារតែ សំបួរ មានវ័យចំណាស់ ទើបខ្មែរក្រហមចាត់ឲ្យគាត់នៅក្នុងកងទ័ពមូលដ្ឋាន ដែលមាន សារិន ជាអ្នកគ្រប់គ្រង ។ សំបួរ បានហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រធ្វើសង្គ្រាមនៅក្នុងព្រៃប្រហែលមួយឆ្នាំ ទើបកងរបស់ សារិន និង សំបួរ ដែលមានគ្នាប្រមាណជាង ៣០ នាក់ចុះមកស្រុកកណ្តាលស្ទឹង ដើម្បីវាយឆ្មក់ទាហាន លន់ នល់ និងឃោសនាស្វែងរកកម្លាំងចូលរួមបដិវត្តន៍ ។ សំបួរ ឃោសនាបណ្តើរវាយជាមួយទាហាន លន់ នល់ បណ្តើរ ពេលណាដែលទាហាន លន់ នល់ វាយសម្រុកខ្លាំងខាងកម្លាំង សំបួរ ដកថយទៅខាងក្រោយជាមួយប្រជាជន ហើយទើបចាប់ផ្តើមវាយជាថ្មីទៀត ។

តាមរយៈការឃោសនារបស់ សំបួរ និង សារិន មានប្រជាជនជាច្រើនបានចូលរួមធ្វើបដិវត្តន៍ជាហូរហែ ហើយក្នុងនោះយុវជនក្មេងៗ ដែលស្ម័គ្រចិត្តចូលជាកងទ័ពបដិវត្តន៍នៅស្រុកកណ្តាលស្ទឹង សំបួរ រៀបចំជាកងស្រួច និងបញ្ជូនទៅអង្គការថ្នាក់លើ ។ ចំណែកអ្នកដែលមានវ័យចំណាស់ សំបួរ ចាត់ចូលជាកងទ័ពស្រុកកណ្តាលស្ទឹង ដែលគ្រប់គ្រងដោយគាត់ផ្ទាល់ ។ នៅក្នុងស្រុកកណ្តាលស្ទឹងមានការប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លារវាងយោធាខ្មែរក្រហមជាមួយនឹងទាហាន លន់ នល់ ដូច្នេះ កងទ័ពមូលដ្ឋានរបស់ សំបួរ បានសហការជាច្រើនលើកជាមួយនឹងកងទ័ពស្រួច ដូចជាកងរបស់ តាសារឿន, តាសោម ជាដើម ដើម្បីច្បាំងជាមួយទាហាន លន់ នល់ ។

ក្នុងអំឡុងពេលធ្វើសង្គ្រាមជាមួយ លន់ នល់ ខ្មែរក្រហមបានចាប់ផ្តើមរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងដោយបានបង្កើតតំបន់ភូមិភាគពិសេសមួយទៀត ដែលរួមមានតំបន់ ១៥ និង ២៥ ដើម្បីជាការងាយស្រួលក្នុងការវាយដណ្តើមយកទីក្រុងភ្នំពេញ ។ ភូមិភាគពិសេសនេះ មាន វន វេត ជាប្រធាន និង សុន សេន ជាអនុប្រធាន ។ ចំណែកឈ្មោះ គុណ ហៅ ១០១ ទទួលជាលេខាស្រុកកណ្តាលស្ទឹង ។ បន្ទាប់ពី ១០១ ត្រូវផ្លាស់ទៅគ្រប់គ្រងខាងពាណិជ្ជកម្មនៅតំបន់២៥ នៃភូមិភាគពិសេស ។ នៅអំឡុងឆ្នាំ១៩៧២ ខ្មែរក្រហមបានបញ្ជូន តាអាន ឲ្យមកធ្វើជាលេខាស្រុកកណ្តាលស្ទឹងជំនួស១០១ ។ នៅឆ្នាំដដែល តាអាន បានគ្រប់គ្រង និងធ្វើការឃោសនាប្រជាជននៅស្រុកកណ្តាលស្ទឹងឲ្យចូលរួមជាមួយចលនាខ្មែរក្រហម ។

ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ រចនាសម្ព័ន្ធភូមិសាស្ត្រត្រូវបានផ្លាស់ប្តូរ ។ ភូមិភាគពិសេស ត្រូវបានរំលាយចោល

ហើយខ្មែរក្រហមបានបង្កើតភូមិភាគបស្ចិមជំនួសវិញ ។ ភូមិឃុំមួយចំនួនរបស់ ស្រុកកណ្តាលស្ទឹង ដែលស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៣ត្រូវបានខ្មែរក្រហមកាត់ទៅឲ្យស្រុកសំរោងទង តំបន់៣៣ ភូមិភាគនិរតី ។ ពេលនោះមន្ទីរតំបន់៣៣ស្ថិតនៅត្រាំខ្នារដែលមានលេខា ឈ្មោះ អុន ។ នៅពេលនោះ តាសាត់ ត្រូវបានតែងតាំងជាលេខាស្រុកសំរោងទង ហើយ សំបួរ ក៏ត្រូវបានដំឡើងជាអនុលេខាស្រុកសំរោងទងដែរ ។ តាសាត់ បានចាត់តាំងឈ្មោះ ខន ធ្វើជាប្រធានកងទ័ពសម្រាប់ការពារសន្តិសុខ ដូចជារាយការណ៍ពីការចាប់ខ្មាំងសត្រូវ កិច្ចការកងទ័ព និងការថែរក្សាសន្តិសុខជាដើម ។ រីឯ សំបួរ ដែលជាអនុលេខាស្រុកសំរោងទងរួមទាំងសមាជិកចំនួនពីរនាក់ទៀត ឈ្មោះ តាសួន និង តាប៉ែន ជាអ្នកទទួលបន្ទុកខាងផ្នែកកសាង ។ ក្នុងកិច្ចការកសាង សំបួរ ទទួលបន្ទុកមើលការខុសត្រូវលើការកសាងលំនៅដ្ឋាន, ប្រព័ន្ធធារាសាស្ត្រ និងកសិកម្ម ។ ក្រោយមក តាសាត់ ផ្លាស់ទៅគ្រប់គ្រងនៅស្រុកគងពិសី ទើបអង្គការចាត់តាំង តាសៀង ឲ្យមកធ្វើជាលេខាស្រុកសំរោងទង ។

បន្ទាប់ពីដណ្តើមបានភ្នំពេញភ្លាម ខ្មែរក្រហមបានចាប់ផ្តើមអនុវត្តផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញមកកាន់ស្រុកសំរោងទង និងបណ្តាខេត្តផ្សេងៗទៀត ។ ការទទួលប្រជាជនថ្មី ដែលជម្លៀសពីភ្នំពេញមានតាមលំដាប់ ។ កាលដំបូងខ្មែរក្រហមបញ្ជូនប្រជាជនទីក្រុងទៅតាមភូមិឃុំ ហើយកម្មាភិបាលភូមិឃុំធ្វើការថ្លឹងថ្លែងថា តើអាចទទួលបានប្រជាជនប៉ុន្មាន និងបញ្ជូនប្រជាជនដែលនៅសល់ប៉ុន្មានទៅឲ្យស្រុកវិញ ។ ថ្នាក់ស្រុកបញ្ជូនប្រជាជនដែលនៅសល់បន្តទៅខាងតំបន់ ដើម្បីចាត់ចែងបន្តទៀត ។ នៅក្នុងស្រុកសំរោងទងពេលនោះមានប្រជាជនទាំងថ្មីទាំងចាស់ខ្ទង់រាប់សែននាក់ ។ ប្រជាជនទាំងថ្មីទាំងចាស់ត្រូវបានខ្មែរក្រហមចាត់ឲ្យរស់នៅ ហូបចុក និងធ្វើការងាររួមគ្នា គ្រាន់តែប្រជាជនចាស់ជាអ្នកដឹកនាំធ្វើការងារផ្សេងៗដូចជាការងារស្រែចម្ការជាដើម ។ ដោយសារតែខ្មែរក្រហមយល់ថា ប្រជាជនថ្មីជាមនុស្សទន់ខ្សោយ ដូចនេះប្រជាជនចាស់ហាក់បីដូចមានសិទ្ធិជាងប្រជាជនថ្មី ហើយម្យ៉ាងទៀតដោយសារតែប្រជាជនចាស់ជាម្ចាស់ស្រុក ។ បន្ទាប់ពីចាត់ចែងប្រជាជនទៅតាមតំបន់ភូមិស្រុករួច ខាងតំបន់បានចាត់ឲ្យភូមិឃុំធ្វើប្រវត្តិរូបប្រជាជន ទាំងចាស់ទាំងថ្មី ។ ប្រជាជនថ្មីខ្លះប្រាប់ពីប្រវត្តិរបស់ខ្លួនតាមត្រង់ តែមានប្រជាជនថ្មីខ្លះមិនបានប្រាប់ដោយត្រង់ទេ ។ អ្នកធ្វើប្រវត្តិរូបគ្រាន់តែកត់ត្រាទុកនូវអ្វីដែលសាមីខ្លួនបានរៀបរាប់រួចបញ្ជូនទៅថ្នាក់លើតែប៉ុណ្ណោះ ពុំមានការបង្ខិតបង្ខំសួរចម្លើយឡើយ ។

ចំពោះការហូបចុករបស់ប្រជាជននៅស្រុកសំរោងទងក្នុងឆ្នាំ១៩៧៥ មានការខ្វះខាតខ្លាំងដោយសារតែនៅក្នុងមូលដ្ឋានគ្មានស្បៀងអាហារគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ប្រជាជន និងមកពីសង្គ្រាមទើបតែចប់ហើយកំណើនប្រជាជនកើនឡើងដោយសារតែការជម្លៀសប្រជាជនមកពីភ្នំពេញបន្ថែមទៀត ។ ប្រការទាំងអស់នេះធ្វើឲ្យមូលដ្ឋានគ្មានស្រូវគ្រប់គ្រាន់សម្រាប់ប្រជាជន ហេតុនេះ ខាងអង្គការថ្នាក់លើបានដឹកស្រូវសាឡី រួមទាំងពោតមកជួយផ្គត់ផ្គង់ប្រជាជននៅស្រុកសំរោងទងបន្ថែម ។ តែទោះបីជាយ៉ាងណានៅក្នុងឆ្នាំ១៩៧៥ ប្រជាជននៅស្រុកសំរោងទងនៅតែមានការខ្វះខាតស្បៀងអាហារដដែល ។ លុះដល់ឆ្នាំ១៩៧៦ ការហូបចុកមានភាពល្អប្រសើរជាងមុន ហើយចាប់ពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ ប្រជាជនមានការហូបចុកគ្រប់គ្រាន់មួយថ្ងៃបីពេល ព្រឹកបបរ ថ្ងៃត្រង់បាយ និងល្ងាចបាយ ។ នៅថ្ងៃទី១០ និងថ្ងៃទី២០ ដែលខ្មែរក្រហមចាត់ទុកថាជាថ្ងៃពិសេស នៅខាងស្រុកសំរោងទងមានធ្វើបង្អែម និងចាប់មាន់ ទា ដែលប្រជាជនចិញ្ចឹមមកធ្វើម្ហូបចែកគ្នាហូប ។

ជារៀងរាល់ខែ ភូមិ ឃុំ តែងតែត្រូវទៅប្រជុំជាមួយស្រុកដែលមន្ទីរស្រុកនៅក្នុងភូមិកំពង់ត្រាំ ។ ស្រុកក៏ត្រូវទៅប្រជុំជាមួយនឹងថ្នាក់តំបន់នៅរៀងរាល់មួយខែម្តងដែរ ។ ចំពោះករណីបន្ទាន់ ភូមិ ឃុំ ស្រុក ត្រូវធ្វើការប្រជុំភ្លាមមិនចាំបាច់តាមទម្លាប់នោះទេ ។ ការប្រជុំនេះទៀតសោត គឺមានភាពខុសគ្នារវាងផ្នែកកសាង និងផ្នែកការពារ ។ ផ្នែកកសាងខ្មែរក្រហមធ្វើការប្រជុំជាទូទៅ ចំណែកឯផ្នែកការពារវិញការប្រជុំមានលក្ខណៈសម្ងាត់ និងលាក់ការណ៍ខ្ពស់ មានតែអ្នកដែលមានតួនាទីខាងផ្នែកការពារប៉ុណ្ណោះទើបអាចចូលប្រជុំបាន ។

សំបួរ ទទួលបន្ទុកក្នុងកិច្ចការកសាង ដូច្នេះគាត់តែងតែដើរតាមការដ្ឋានដឹកប្រឡាយ សាងសង់លំនៅដ្ឋាន និងមើលលើកិច្ចការធ្វើស្រែចម្ការ ហើយជួនកាល១០ ទៅ ២០ថ្ងៃ សំបួរ

ឆ្លៀតមកផ្ទះលេងក្រុមគ្រួសារម្តង ។ ចំពោះផែនការធ្វើស្រែចម្ការនៅស្រុកសំរោងទង គឺ សំបួរ បានធ្វើផែនការគ្រោងទុកជាមុន ថាចំនួនដីប៉ុន្មានដែលអាចធ្វើស្រែលើសពី៣តោន ចំនួនដីប៉ុន្មានដែលអាចធ្វើបានត្រឹម៣តោន និងចំនួនដីប៉ុន្មានដែលពុំសូវមានជីវជាតិ ហើយមិនអាចធ្វើគ្រប់ផែនការ៣តោនក្នុងមួយហិកតា ។ សំបួរ និងកម្មាភិបាលផ្សេងទៀតបានធ្វើការព្យាករណ៍ទុកជាមុនពីចំនួនផលស្រូវនៅពេលប្រមូលដែរ ថាតើផលស្រូវប៉ុន្មានសម្រាប់ទុកឲ្យប្រជាជនបរិភោគ និងប៉ុន្មានសម្រាប់បែងចែកទៅឲ្យអង្គការថ្នាក់លើ ។ ប៉ុន្តែនៅពេលប្រមូលផលពិតប្រាកដ គឺ សំបួរ ត្រូវបែងចែកទៅតាមផលស្រូវជាក់ស្តែងថាតើប៉ុន្មានត្រូវទុកផ្គត់ផ្គង់ប្រជាជន និង ផលស្រូវចំនួនប៉ុន្មានសម្រាប់ផ្តល់ជូនអង្គការលើ ។

សំបួរ ធ្លាប់បានចូលរួមក្នុងមហាសន្និបាតទូទាំងប្រទេសនៅឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ នៅឯបុរីកីឡា ក្នុងទីក្រុងភ្នំពេញ ។ មហាសន្និបាតនេះមានការឧទ្ទេសនាមពីសំណាក់ នួន ជា ហៅតានួន នៅក្នុងពិធីប្រារព្ធមហាសន្និបាតប្រចាំឆ្នាំរបស់កម្មាភិបាលខ្មែរក្រហម ។ អំឡុងពេលចូលរួមក្នុងមហាសន្និបាតទាំង២លើកនោះ សំបួរ បានជួបជាមួយ តាអាន និងបានសំណេះសំណាលសួរសុខទុក្ខគ្នា ។ បន្ទាប់ពីបែកភ្នំពេញឆ្នាំ១៩៧៥ តាអាន ត្រូវផ្លាស់ទៅធ្វើជាគណៈតំបន់នៅខេត្តកំពត ។ ក្រោយមក អង្គការបានដកតាអាន ឲ្យទៅធ្វើជាគណៈតំបន់នៅក្នុងខេត្តកំពង់ចាមវិញ ។ បន្ទាប់ពីមហាសន្និបាតចប់ ថ្នាក់មជ្ឈិមបានដឹកនាំកម្មាភិបាលខ្មែរក្រហមដែលចូលរួមក្នុងមហាសន្និបាទចុះធ្វើទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍អំពីកិច្ចការងារកសាងប្រព័ន្ធធារសាស្ត្រ, ការធ្វើស្រែចម្ការនិងការគ្រប់គ្រងនៅតាមតំបន់ផ្សេងៗ ។ សំបួរ ធ្លាប់បានធ្វើទស្សនកិច្ចស្ទើរគ្រប់ខេត្តនៃប្រទេសកម្ពុជា លើកលែងតែខេត្តស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ព្រៃវែង និងស្វាយរៀង ។ ក្នុងដំណើរទស្សនកិច្ចម្តងៗ មានរយៈពេល៣ថ្ងៃ ហើយចំនួនកម្មាភិបាលដែលចុះទស្សនកិច្ចមានដល់ទៅរាប់ពាន់នាក់ ដែលត្រូវប្រើរថយន្តជាច្រើនរយគ្រឿង ។

ក្នុងឆ្នាំ១៩៧៧ និង ១៩៧៨ សំបួរ មិនបានចូលរួមក្នុងមហាសន្និបាតប្រចាំឆ្នាំនៅភ្នំពេញទេ ដោយសារតែមានការវឹកវរនៅតាមព្រំដែន ។ នៅមុនពេលវៀតណាមចូលភ្នំពេញបន្តិច តាសាត់ក៏ត្រូវផ្លាស់ពីស្រុកសំរោងទង ទៅស្រុកគងពិសី ។ តាសៀង បានក្លាយជាលេខាស្រុកសំរោងទង ។ ក្រោយមក តាសាត់ និង តាសៀង ត្រូវបានខាងគណៈមជ្ឈិមចាប់ខ្លួនដោយចោទប្រកាន់ថាក្បត់នឹងអង្គការ ។ លេខាស្រុកសំរោងទងចុងក្រោយ មានឈ្មោះតាយ៉ាន ។

ពេលបែកភ្នំពេញឆ្នាំ១៩៧៩ យ៉ាន ដែលជាលេខាស្រុកសំរោងទងត្រូវបានវៀតណាមចាប់ខ្លួន ។ ចំណែក សំបួរ បានរត់គេចទៅជួបកម្មាភិបាលខ្មែរក្រហមដូចគ្នានៅក្នុងព្រៃ ។ កម្មាភិបាលខ្មែរក្រហម ដែលបានជួបបញ្ចុះបញ្ចូល សំបួរ ឲ្យទៅសារភាព ។ ដូច្នេះ២ ឬ ៣ ខែក្រោយវៀតណាមវាយ បែកភ្នំពេញ សំបួរ បានចូលទៅសារភាពនៅភូមិមហាសាំង ក្នុងខេត្តកំពង់ស្ពឺ ។ បន្ទាប់ពីសារភាពហើយ ខាងភូមិឃុំបានបញ្ជូន សំបួរ ទៅឃុំឃាំងនៅគិរីចុងកោះ ក្នុងស្រុកកោះអណ្តែត ខេត្តតាកែវ ។ អ្នកដែលជាប់ឃុំនៅគិរីចុងកោះមានចំនួនរាប់ពាន់នាក់ ដែលអ្នកទាំងនោះមានមុខងារចាប់តាំងពីកម្មាភិបាលធំៗ រហូតដល់អ្នកដឹកអុសក្នុងរបបខ្មែរក្រហម ។ មន្ទីរឃុំឃាំងនៅគិរីចុងកោះពេលនោះ គ្រប់គ្រងដោយវៀតណាម ។ សំបួរ និងអ្នកជាប់ឃុំឃាំងផ្សេងៗទៀត ត្រូវបានវៀតណាមបែងចែកជាក្រុមៗដាំបន្លែ ដូចជា ស្ពៃ ឆៃថាវជាដើម ហើយចំពោះការហូបចុកវិញពុំបានគ្រប់គ្រាន់ឡើយ នៅមន្ទីរឃុំឃាំងនេះ វៀតណាមជួលរបបអាហារត្រឹមតែ២ពេលក្នុង១ថ្ងៃដល់អ្នកជាប់ឃុំ ដែលមួយពេលអ្នកជាប់ឃុំ អាចទទួលបានបាយត្រឹមតែមួយចានតូចប៉ុណ្ណោះ ។ នៅក្នុងពេលជាប់ឃុំ សំបួរ ត្រូវបានវៀតណាមធ្វើប្រវត្តិរូបជាច្រើនសា ទៅតាមផែនការរបស់វៀតណាម ។ ប្រពន្ធកូនឬក៏សាច់ញាតិអាចទៅសួរសុខទុក្ខអ្នកជាប់ឃុំឃាំងបាននៅកន្លែងជួបសួរសុខទុក្ខ ដោយមានការឃ្លាំមើលពីសំណាក់ឆ្មាំគុក ។

សំបួរ ជាប់ឃុំឃាំងចាប់តាំងពីឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ១៩៨៦ ទើបវៀតណាមដោះលែងគាត់ឲ្យមានសេរីភាព ។ បន្ទាប់ពីចេញពីមន្ទីរឃុំឃាំងភ្លាម សំបួរ បានវិលត្រឡប់មកជួបជុំគ្រួសារ ប្រពន្ធកូន នៅស្រុកកំណើត និងចាប់ផ្តើមប្រកបរបរធ្វើស្រែចម្ការ និងឡើងត្នោត ដោយបានប្តូរឈ្មោះពី ស្វាយ សំបួរ មកព្រំ ទូច វិញ ។

**គិត ស្រីពៅ**

# កងទ័ពវៀតកុងបានផ្តាច់ស្ពានមិត្តភាព កម្ពុជា-ជប៉ុន «ស្ពានជ្រោយចង្វារ នៅអំឡុងឆ្នាំ១៩៧៣»

ប៉ែន វី មានអាយុ៦១ឆ្នាំ ជាអតីតយោធាខ្មែរក្រហមមានឋានៈប្រធានអនុសេនាតូចមួយ នៅក្នុងកងវរៈសេនាធំប្រចាំតំបន់២២ភូមិភាគបូព៌ា បានរៀបរាប់ឲ្យដឹងថា នៅក្នុងឆ្នាំ១៩៧៣ កងវរៈសេនាធំតំបន់២២ បានសហការជាមួយកងទ័ពវៀតកុង ដើម្បីផ្តាច់ស្ពានជ្រោយចង្វារ ។ ប៉ុន្តែកងវរសេនាធំតំបន់២២ ដែលស្គាល់ភូមិសាស្ត្រនោះបានត្រឹមតែជាអ្នកនាំផ្លូវ ចំណែកកងទ័ពវៀតកុងទទួលភារកិច្ចជាអ្នករៀបចំដាក់គ្រឿងបំផ្ទុះដើម្បីផ្តាច់ស្ពានដោយផ្ទាល់ ។ បើតាមការចាំស្មានរបស់ វី ការផ្តាច់ស្ពានជ្រោយចង្វារនេះ គឺក្នុងគោលបំណងកាត់ផ្តាច់កាដឹកជញ្ជូនស្បៀង និងអាវុធយុទ្ធភណ្ឌរបស់ ទាហាន លន់ នល់ ពីទីក្រុងភ្នំពេញតាមផ្លូវជាតិលេខ៦ ទៅកាន់បន្ទាយមួយចំនួនដូចជា បន្ទាយព្រែកលៀប បន្ទាយព្រែកអញ្ចាញ បន្ទាយព្រែកតាមាក់ជាដើម ។ វី បានឲ្យដឹងទៀតថា មុនពេលផ្តាច់ស្ពាននេះ កងកម្លាំងខ្មែរក្រហមមិនងាយវាយចូលដល់បន្ទាយទាហាន លន់ នល់ នៅព្រែកលៀប ព្រែកអញ្ចាញ ព្រែកតាមាក់ឡើយ ហើយពេលវាយចូលបន្ទាយទាំងនោះម្តងៗមានយោធាខ្មែរក្រហមស្លាប់រាប់សិបនាក់ ពីព្រោះបន្ទាយទាំងនេះមានលក្ខណៈរឹងមាំមានរាយលួសបន្លាពទ័ជុំវិញ ដឹកប្រឡាយ ដាក់សុទ្ធតែចម្រូង និងមានមីនរាយពេញដីជុំវិញបន្ទាយ ។ ម្យ៉ាងទៀតទាហាន លន់ នល់ មានស្បៀង និងអាវុធយុទ្ធភណ្ឌគ្រប់គ្រាន់ ។ ដូច្នេះខ្មែរក្រហមមានវិធីតែមួយគត់ គឺផ្តាច់ស្ពាន ផ្តាច់ផ្លូវថ្នល់ ដើម្បីរារាំងកុំឲ្យទាហាន លន់ នល់ យកស្បៀង និងគ្រាប់រំសេវចូលមកបន្ទាយបានដោយងាយស្រួល ។

ប៉ែន វី បានបន្ថែមថា កងវរសេនាធំប្រចាំតំបន់២២ ភូមិភាគបូព៌ា មានមេបញ្ជាការឈ្មោះ ឌឹម និង ស៊ុម ជាអនុប្រធាន ។ វី មានតួនាទីជាប្រធានអនុសេនាតូចមួយ ដែលទទួលមុខសញ្ញាម្តុំស្ពានជ្រោយចង្វារ ចាប់ពីមាត់ទន្លេមេគង្គទៅទល់នឹងទន្លេបួនមុខចាំស្ទាក់បាញ់កប៉ាល់ចម្បាំងទាហាន លន់ នល់ ដែលធ្វើដំណើរដឹកស្បៀង និងគ្រាប់រំសេវឆ្លងកាត់តំបន់នេះ ។

នៅថ្ងៃទី១៧មេសា ឆ្នាំ១៩៧៥ យោធាភូមិភាគបូព៌ាមិនបានចូលទៅរៀបចំទីក្រុងទេ មានតែកម្លាំងយោធាភូមិភាគឧត្តរ និងភូមិផ្សេងៗចូលទៅដល់មុន ។ អង្គភាពរបស់ វី បានចូលត្រឹមស្ពានជ្រោយចង្វារប៉ែកខាងកើត ចាំការពារក្រវ៉ាត់ទីក្រុង ។ វី ឈរជើងនៅគល់ស្ពានជ្រោយចង្វារ ក៏បានឃើញប្រជាជនត្រូវអង្គការជម្លៀសចេញពីទីក្រុងជាហូរហែដែរ ។

ពេលខ្មែរក្រហមបានឡើងកាន់អំណាច អង្គការបានរៀបចំរចនាសម្ព័ន្ធកងទ័ពថ្មីដូចជាឈ្មោះ ឌឹម ត្រូវបានផ្លាស់ទៅទទួលជាអនុកងពល១៦៤ ដែលជាកងពលជើងទឹកប្រចាំនៅក្រុងកំពង់សោម ដែលមានឈ្មោះ មាស មុត ជាប្រធានកងពល ។ ចំណែកឈ្មោះ ស៊ុម ត្រូវបានអង្គការដំឡើងជាប្រធានវរសេនាធំឯករាជ្យ១៥២ របស់មជ្ឈិមទទួលបន្ទុកជើងទឹកទន្លេមេគង្គ ។ អង្គភាពវរសេនាធំឯករាជ្យ១៥២ ស្ថិតនៅព្រែកលៀបម្តុំគៀនឃ្លាំង ។ នៅអំឡុងឆ្នាំ១៩៧៥-៧៦ មានគណៈប្រតិភូកូរ៉េខាងជើង និងចិនបានមកទស្សនកិច្ចនៅអង្គភាពវរសេនាធំ១៥២នៅព្រែកលៀប ។ បន្ទាប់ពីមានដំណើរទស្សនកិច្ចនោះ ក៏មានជំនួយជារថយន្តធំៗសម្រាប់ដឹកកងទ័ព និងសម្ភារមួយចំនួនផ្សេងទៀតមកដល់អង្គភាពវរសេនាធំ១៥២ ។

នៅឆ្នាំ១៩៧៧ ប្រធានកងសេនាធំឯករាជ្យ១៥២ និងកម្មាភិបាលខ្មែរក្រហមមួយចំនួន ត្រូវបានអង្គការចាប់ខ្លួនជាបន្ត

បន្ទាប់ ។ វី មានឋានៈត្រឹមប្រធានអនុសេនាតូចនោះ ក៏ត្រូវបានអង្គការចោទថាជាប់និន្នាការក្បត់ និងបញ្ជូនទៅលត់ដំនៅគុកព្រៃសជិតមួយឆ្នាំ ។ វី គិតថាគ្មានជីវិតរស់ផង ព្រោះគ្មានអាហារគ្រប់គ្រាន់ធ្វើការងារក្នុងមួយថ្ងៃដឹកប្រឡាយឲ្យបានពីរម៉ែត្របួនជ្រុងដីសុទ្ធតែគ្រួស ។ វី និង មិត្តរួមអាវុធក្នុងសម័យសង្គ្រាម៩ឆ្នាំជាមួយគ្នាចំនួន៦នាក់ទៀត ត្រូវបានអង្គការចាប់បញ្ជូនទៅលត់ដំនៅគុកព្រៃសនោះ មានតែពីរនាក់ទេដែលមានជីវិតរួចត្រឡប់មកវិញ គឺ វី និងម្នាក់ទៀតឈ្មោះ សុខ ។ ចំណែក៥នាក់ផ្សេងទៀតបានបាត់ខ្លួន នៅខណៈពេលដែលអង្គការហៅទៅសួរចម្លើយ ។

នៅឆ្នាំ១៩៧៨ សង្គ្រាមជាមួយប្រទេសវៀតណាមចាប់កើតមានឡើង ហើយកម្លាំងយោធាខ្មែរក្រហមដើងចាស់មួយចំនួនដែលជាប់នៅកន្លែងលត់ដំត្រូវបានដោះឲ្យធូរស្រាលមួយកម្រិតពីព្រោះ អង្គការត្រូវការកម្លាំងយោធាមួយចំនួនទៅការពារព្រំដែន និងធ្វើសង្គ្រាមជាមួយប្រទេសវៀតណាម ។ នៅឆ្នាំ១៩៧៨ នេះដែរ វី និង សុខ បានរួចចេញពីគុកព្រៃសវិញ និងត្រូវបានចាត់តាំងបញ្ចូលទៅក្នុងកងកម្លាំងយោធាវរសេតូចមួយដែលមានសមាជិកចំនួន៣០០នាក់ ដើម្បីជួសជុលផ្លូវជាតិឆ្ពោះទៅខេត្តមណ្ឌលគិរី និងខេត្តរតនគិរីដែលមានសភាពខូចខាតខ្លាំង ។ វរសេនាតូចរបស់ វី បានកំពុងធ្វើការជួសជុលផ្លូវដល់ត្រឹមអូរពងមាន់ អូរគ្រៀល អូរព្រះស្រាប់តែកម្លាំងកងទ័ពវៀតណាមបានវាយចូលមកដល់ប្រទេសកម្ពុជានៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

នៅឆ្នាំ១៩៧៩ វី មិនបានរត់សំដៅមកស្រុកកំណើតវិញទេ វី និងយោធាខ្មែរក្រហមផ្សេងទៀត បាននាំគ្នារត់ចូលព្រៃចុះឡើងគ្មានទីកន្លែងច្បាស់លាស់ គ្មានអាហារហូបចុកគ្រប់គ្រាន់ស្ទើររស់ស្ទើរស្លាប់ ចំពោះអ្នកដែលស្លាប់គឺចោលនៅក្នុងព្រៃដូចសត្វគ្មានអ្នកណាជួយអ្នកណាទេ ម្នាក់ៗរត់យកតែរស់រៀងខ្លួន ។ វី និងយោធាមួយចំនួននៅសេសសល់ពីការស្លាប់បាននាំគ្នារត់មកដល់ខេត្តកំពង់ធំ ។ កាលនោះដោយសារតែខ្លាចវត្តមានកងទ័ពវៀតណាមសម្លាប់បាននាំគ្នាដើរកាត់ព្រៃឡង់ រហូតបានទៅដល់ភ្នំដងរែក និងបានរួបរួមជាមួយកងកម្លាំងខ្មែរក្រហមដទៃទៀតបន្តធ្វើសង្គ្រាមជាមួយកងកម្លាំងរដ្ឋាភិបាលរយៈពេលជិត២០ឆ្នាំទៀត ។

**សុខ ខណ្ណៈ**



ស្ពានមិត្តភាពកម្ពុជា-ជប៉ុន "ស្ពានជ្រោយចង្វារ" ដែលត្រូវបានផ្តាច់ដោយកងទ័ពវៀតកុង នៅក្នុងអំឡុងឆ្នាំ១៩៧៣

# គេហទំព័រទស្សនាវដ្តីស្វែងរកការពិតជាភាសាខ្មែរ

## www.truthcambodia.com

*ទស្សនាវដ្តីស្វែងរកការពិត បង្កើតគេហទំព័រ www.truthcambodia.com ក្នុងគោលបំណងផ្សព្វផ្សាយ និងអប់រំឲ្យបានកាន់តែទូលំទូលាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) ដើម្បីសម្រេចឲ្យបាននូវការចងចាំ យុត្តិធម៌ និងការផ្សះផ្សាជាតិក្នុងសង្គមដែលទទួលរងនូវការបែកបាក់ និង សង្គ្រាមជាច្រើនទសវត្សរ៍ ។*

*គេហទំព័រ www.truthcambodia.com ក៏នឹងដើរតួនាទីដ៏សំខាន់ផងដែរក្នុងការចែករំលែកព័ត៌មានអំពីដំណើរការសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាមួយសាធារណជន និងជួយសាលាក្តីក្នុងការរំលែកព័ត៌មានទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហម នៅខណៈពេលអត្ថបទមួយចំនួននៅក្នុងគេហទំព័រនេះត្រូវបានយកទៅប្រើប្រាស់ជាភស្តុតាងដើម្បីដាក់បន្ទុកមេដឹកនាំខ្មែរក្រហម ។*

*គេហទំព័រ www.truthcambodia.com បែងចែកជា៥ផ្នែកសំខាន់ គឺ១) ផ្នែកឯកសារ ២) ផ្នែកប្រវត្តិសាស្ត្រ ៣) ផ្នែកច្បាប់ ៤) ផ្នែកវេទិកាពិភាក្សាជាសាធារណៈ និង ៥) ផ្នែកស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬបាត់ខ្លួនក្នុងរបបខ្មែរក្រហម ។ នៅក្នុងគេទំព័រ www.truthcambodia.com ក៏មានផ្ទុកនូវឯកសារជាវីដេអូ, សំឡេង, រូបថត និងឯកសារដើមរបស់ខ្មែរក្រហមដែរ ។*

*អត្ថបទសម្រាប់ផ្នែកទី១) នឹងរៀបរៀងឡើងដោយស្មេរមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយផ្អែកលើឯកសារដើមទាំងស្រុង ។ សរសេរឲ្យស្រួលអាន គឺការសង្ខេបចេញពីឯកសារដើមមកជាអត្ថបទ ។ គោលបំណងនៃផ្នែកនេះ គឺចង់ជម្រាបជូនសាធារណជនថាតើមានឯកសារអ្វីខ្លះដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ផ្នែកទី២) គឺជាអត្ថបទវិភាគលើប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម ។ អត្ថបទផ្នែកនេះគឺជាអត្ថបទចូលរួមមកពីអ្នកជំនាញជាន់ខ្ពស់លើប្រវត្តិសាស្ត្រខ្មែរក្រហម ហើយមានទិសដៅសម្រិតសម្រាំងប្រវត្តិសាស្ត្រនេះឲ្យមានភាពកាន់តែសុក្រឹតទ្បើងទៀត ។ ផ្នែកទី៣) គឺជាផ្នែកច្បាប់ដែលផ្តើការវិភាគដោយមេធាវី ឬចៅក្រម ឬអ្នកជំនាញការច្បាប់អន្តរជាតិ ។ ការវិភាគនេះនឹងជួយជាគំនិតលើផ្នែកច្បាប់ថា តើឧក្រិដ្ឋកម្មអ្វីខ្លះដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ហើយថា តើឧក្រិដ្ឋកម្មនីមួយៗត្រូវតែដោះស្រាយតាមនីតិវិធីបែបណា ដើម្បីរកឲ្យបាននូវយុត្តិធម៌ពិតប្រាកដមួយដល់ជនរងគ្រោះ ។ ផ្នែកទី៤) គឺជាវេទិកាពិភាក្សា និង ផ្តល់គំនិតនានាលើបញ្ហាខ្មែរក្រហម ។ អត្ថបទទីនេះ គឺជាវិភាគទានចូលរួមពីសំណាក់អង្គការក្រៅរដ្ឋាភិបាលនានា សមាជិករាជរដ្ឋាភិបាល គ្រូ សិស្ស និស្សិត ជាដើម ។ល ។ ផ្នែកទី៥) គឺជាទំព័រស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬ បាត់ខ្លួនក្នុងរបបខ្មែរក្រហម ឬការសាកសួររកព័ត៌មានអំពីមិត្តភក្តិ សាច់សារលោហិតដែលបានស្លាប់ដោយសាររបបខ្មែរក្រហម ។ ជាទំព័រឈឺចាប់ អាណោចអាធ័ម ប៉ុន្តែក៏ជាទំព័ររម្ងាប់ការមន្ទិលសង្ស័យដើម្បីសេចក្តីសុខក្នុងខ្លួនជាអមតៈដែរ ។*

*សរុបសេចក្តីទៅផ្នែកទាំង៥ខាងលើនៃគេហទំព័រ www.truthcambodia.com នឹងបើកចំហជូនដល់ការចូលរួមស្វែងរកការពិតពីសាធារណជនគ្រប់ស្រទាប់ ជាន់ថ្នាក់ ដោយមិនប្រកាន់ពណ៌សម្បុរ ភេទ អាយុ ឬនិន្នាការនយោបាយណាមួយឡើយ ។ គេហទំព័រ www.truthcambodia.com នឹងបម្រើដល់សាធារណជន និងដើម្បីជួយជ្រោមជ្រែងស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាគ្រប់រូប ។ គ្រប់លិខិត ឬអត្ថបទ ដែលផ្ញើមកកាន់គេហទំព័រ www.truthcambodia.com សូមដាក់ឈ្មោះ មុខងារ អាសយដ្ឋាន និងលេខទូរសព្ទសម្រាប់ផ្ញើសេចក្តីបញ្ជាក់លើខ្លឹមសារនៃលិខិត ឬអត្ថបទ មុនការចេញផ្សាយ ។*

*គេហទំព័រ www.truthcambodia.com សូមរក្សាសិទ្ធិក្នុងការកែលម្អពាក្យពេចន៍នៃលិខិតទាំងឡាយ ក្នុងន័យថែរក្សានូវអត្ថន័យដើមទាំងស្រុង ។ ប៉ុន្តែ គេទំព័រ www.truthcambodia.com នឹងចុះផ្សាយទាំងស្រុងចំពោះអត្ថបទចូលរួមទាំងឡាយ ។*

# ដើមបណ្តឹងរដ្ឋប្បវេណី និង សាក្សីផ្តល់សក្ខីកម្ម ពីការដឹកនាំបក្សកុម្មុយនីស្តកម្ពុជា

*អង្គជំនុំជម្រះស្តាប់ និងសម្រេចការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-223 រួមជាមួយនឹងសាក្សី តូច ស៊ីថាន ។ ដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់សញ្ញាណអំពីតួនាទីរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ។ លោកស្រី តូច ស៊ីថាន ផ្តល់ព័ត៌មានអំពីការចែកចាយឱសថ ក៏ដូចជាតួនាទីរបស់ជនជាប់ចោទដែរ ។*

## ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-223

*អង្គជំនុំជម្រះបានផ្តល់វេទិកាជូនក្រុមមេធាវីការពារក្តី នួន ជា ។ មេធាវី វីកទ័រ កូប៉េ បានសួរដើមបណ្តឹងរដ្ឋប្បវេណីអំពីចម្លើយសារភាពរបស់គាត់ដែលថា គាត់បានរស់នៅទីក្រុងភ្នំពេញជាមួយ នួន ជា កាលពីដើមទសវត្សរ៍ឆ្នាំ៦០ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានកែថា គាត់មិនបានធ្វើការ និងរស់នៅជាមួយ នួន ជា កាលពីទសវត្សរ៍ឆ្នាំ៦០នោះទេ ។ មេធាវី កូប៉េ បន្តថា កាលពីម្សិលមិញ ដើមបណ្តឹងរដ្ឋប្បវេណីបានប្រាប់អង្គតុលាការថា ខ្លួនបានរស់នៅជាមួយ នួន ជា នៅក្នុងទសវត្សរ៍ឆ្នាំ៦០ ដែលពេលនោះដើមបណ្តឹងរដ្ឋប្បវេណីនៅតូចនៅឡើយ ។ ដើមបណ្តឹងរដ្ឋប្បវេណីបដិសេធមិនធ្លាប់បានរស់នៅជាមួយ នួន ជា នោះទេ ។ ម្តាយរបស់ដើមបណ្តឹងរដ្ឋប្បវេណីធ្លាប់រស់នៅ និងធ្វើការជាមួយ នួន ជា កាលពីឆ្នាំ១៩៥០ ហើយ នួន ជា ធ្លាប់លេងជាមួយគាត់កាលពីពេលដែលគាត់នៅតូច ។ ដើមបណ្តឹងរដ្ឋប្បវេណីបានដឹងរឿងទាំងនេះពីម្តាយរបស់គាត់ ។*

*មេធាវី កូប៉េ បានបង្ហាញឯកសារមួយដល់ដើមបណ្តឹងរដ្ឋប្បវេណី និងបានសួរគាត់ថា តើនេះគឺជាឈ្មោះម្តាយរបស់គាត់ឬមិនមែន? (ឈ្មោះរបស់ម្តាយដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានបង្ហាញជាសាធារណៈនោះទេ ដោយសារតែការរក្សាការសម្ងាត់) ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថានេះពិតជាឈ្មោះម្តាយរបស់គាត់មែន ប៉ុន្តែគាត់បានស្លាប់ ៤-៥ ខែទៅហើយ ។*

*ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា មុនពេលដែល ទូ សាមុត បាត់ខ្លួន ទូ សាមុត គឺជាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ។ សាយ ជាជីតារបស់ដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកធ្វើការឲ្យ ទូ សាមុត ។ ថ្ងៃមួយ ទូ សាមុត ក៏បានបាត់ខ្លួន ។ មេធាវី កូប៉េ បានសួរបន្តថា ក្រោយឆ្នាំ១៩៧៥ តើ នួន ជា ធ្លាប់និយាយថា សាយ ជា «មេដឹកនាំបះបោរ» ដែលឬយ៉ាងណា? ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា នួន ជា មិនធ្លាប់និយាយថា សាយ ជាមេដឹកនាំរបស់ក្រុមក្បត់នោះទេ ប៉ុន្តែ នួន ជា ធ្លាប់និយាយថា សាយ ជាជនក្បត់ ។ នួន ជា ក៏បាននិយាយទៀតថា សាយ ជានីសាររបស់ ទូ សាមុត ហើយ សាយ ក៏ជាអ្នកផ្តល់ដំណឹងដល់ឃាតករដែលបានសម្លាប់ ទូ សាមុត ផងដែរ ។ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានដឹងថា សាយ បានសាងកំហុសអ្វីនោះទេ ។ «នួន ជា គ្រាន់តែនិយាយថា សាយ គឺជាជនក្បត់» ។ សាយ ធ្វើការនៅភូមិភាគ៥៦០ នៅពេលដែលគាត់ត្រូវបានគេចាប់ខ្លួន ។ មេធាវី កូប៉េ បានបន្តថា តើ សាយ គឺជាសមាជិកនៃគណៈកម្មាធិការភូមិភាគពាយ័ព្យ ជាមួយនឹង រស់ ញឹម មែនដែរឬទេ? ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយបញ្ជាក់ថា «ពិត» ។ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានបញ្ជាក់ដែរថា សាយ ត្រូវបានគេស្គាល់ថាជា តាប៉ែន ទៀតផង ។*

*ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា គាត់មិនធ្លាប់ធ្វើការជាមួយ នួន ជា នោះទេ ប៉ុន្តែឪពុករបស់គាត់ធ្លាប់ ។*

## ភាពជាអ្នកដឹកនាំ

*មេធាវី កូប៉េ បានសួរបន្តអំពីមនុស្សម្នាក់ដែលមានឈ្មោះថា សាន ។ ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា សាន ត្រូវបានចាប់*

ខ្លួន ។ មេធាវី កូប៉េ បានបង្ហាញពីរចនាសម្ព័ន្ធមួយដែលមានកម្មាភិបាលភូមិភាគពាយ័ព្យ ញ៉ូវ និង ឆន ។ ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា គាត់ធ្លាប់ឮឈ្មោះ នឿ និងធ្លាប់បានស្គាល់ ឆន ។ គាត់ក៏ស្គាល់សមាជិកខ្លះរបស់កងពលធំលេខ១ ដូចជា កាំង, ខ្ញុយ និង រឿង ដែរ ។ ដើមបណ្តឹងរដ្ឋប្បវេណីបន្តថា គាត់ស្គាល់ ឆន នៅឆ្នាំ១៩៧៤ និងផ្ញើសារទូរលេខទៅ ឆន អំពីព័ត៌មានដែលទាក់ទងនឹងសមរភូមិ ។ ក្រោយឆ្នាំ១៩៧៥ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានជួប ឆន ទៀតនោះទេ ។ មេធាវី កូប៉េ បានសួរបន្តថា តើដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងជាមួយ រ៉េន លេខាកងពលធំ លេខ៣ ញឹកញាប់ប៉ុនណា? ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា ប្រពន្ធ រ៉េន រស់នៅជាមួយគាត់ ដូច្នេះពួកគាត់មានទំនាក់ទំនងការងារជិតស្និទ្ធ ។ រ៉េនឈរជើងនៅត្រែង ។

មេធាវី កូប៉េ បន្តថា តើដើមបណ្តឹងរដ្ឋប្បវេណីមានដឹងថាអ្នកណាជាមេភ័ស្តុភាររបស់ភូមិភាគពាយ័ព្យដែរឬទេ? ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា គាត់មិនបានដឹងនោះទេ ហើយគាត់ក៏មិនដឹងពីគម្រោងផ្តួលរំលំ ប៉ុល ពត នៅថ្ងៃ១៧ មេសា ឬថ្ងៃក្រោយមកទៀតដែរ ។

ដើមបណ្តឹងរដ្ឋប្បវេណីក៏មិនធ្លាប់បានឮ នួន ជា និយាយពីសុខ ដែរ ។ សាយ គឺជាមនុស្សតែម្នាក់គត់ដែលត្រូវបានគេចាត់ទុកជាជនក្បត់ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា វណ្ណៈ៣រួមមាន ពួកសក្តិភូមិ មូលធននិយម និង គហបតី ត្រូវបានគេកម្ទេចចោល ។ អ្នកដែលបានចូលរួមក្នុងក្រុមនោះក៏ត្រូវបានគេប្រហារជីវិតដូចគ្នាដែរ ។ មេធាវី កូប៉េ បានសំដៅទៅសៀវភៅរបស់ ថេត សម្បត្តិ ដែលបានលើកឡើងពីឈ្មោះ ចាន់ សាវុធ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា គាត់ពុំចាំឈ្មោះនេះទេ ។ ការភ្លេចនេះជំរុញឲ្យមេធាវី កូប៉េ អានសម្រង់មួយដែលលើកឡើងពីការកម្ទេចស្ពាន ។ ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា គាត់មិនដឹងរឿងនេះទេ ។ មេធាវី កូប៉េ នៅតែបន្តសួរអំពីការចោទប្រកាន់ចំពោះការធ្វើរដ្ឋប្រហារ ។ ត្រង់ចំណុចនេះ ជំនួយការជាន់ខ្ពស់សហព្រះរាជអាជ្ញា ដេល ឡៃសាក់ បានបដិសេធ និងបន្តថា សំណួរនេះគឺជាសំណួរនាំមុខ ។ បន្ថែមលើនេះទៀត គ្មានភ័ស្តុតាងដែលទាក់ទងនឹងការប៉ុនប៉ងធ្វើរដ្ឋប្រហារនៅថ្ងៃ១៧ មេសា ១៩៧៧ នោះទេ ។ មេធាវី កូប៉េ ផ្តល់ប្រភពនិទ្ទន័យនៅពេលក្រោយ ។ ដើមបណ្តឹងរដ្ឋប្បវេណីក៏ពុំបានដឹងពីអាវុធដែលគេបានរក្សាទុកដែរ ។

មេធាវី កូប៉េ បានសួរបន្តថា តើហេតុអ្វីបានជាពួកគេមានការសង្ស័យថាដើមបណ្តឹងរដ្ឋប្បវេណីគឺជាជនក្បត់? ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា អ្នកដែលនាំគាត់ចេញពីការិយាល័យ៥៦០ ប្រាប់គាត់ ។ «ពួកគេនិយាយថា ខ្ញុំគឺជាជនក្បត់ដែលប្រឆាំងនឹងបដិវត្តន៍» ។ អ្នកដែលប្រាប់គាត់នោះគឺធ្វើការនៅក្នុងការិយាល័យដែលនៅជិតស្ពាន ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបាននាំមកភ្នំពេញតាមរថភ្លើង ។

មេធាវី កូប៉េ បានបន្តថា រ៉ូប៊ឺត លីមគិន *(Robert Lemkin)* បានប្រាប់ដល់តុលាការថា ដាល ជឿន មិនមែនជាឈ្មោះពិតនៅក្នុងសៀវភៅនោះទេ ។ (ពិនិត្យមើលការពិភាក្សានៅថ្ងៃទី១៧ តុលា២០១៦) ។

## ការចាប់ខ្លួន «ទណ្ឌិតសំខាន់ៗ»

បន្ទាប់ពីការសម្រាកលើកទីមួយត្រូវបានបញ្ចប់ មេធាវី កូប៉េ បានលើកឡើងថា ថន ធ្លាប់បាននិយាយពី ភាន ហៅ សាយ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា គាត់មិនធ្លាប់ឮឈ្មោះនេះទេ ។ សាក្សីម្នាក់បាននិយាយថា តាភាង ហៅ សាយ គឺលេខាតំបន់ ១ និងជាអនុរដ្ឋលេខាធិការនៃក្រសួងវប្បធម៌ក្នុងសម័យសម្តេចសីហនុ ថែមទៀតផង ។ ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា គាត់ពុំបានដឹងរឿងទាំងនេះនោះទេ ។ ដើមបណ្តឹងរដ្ឋប្បវេណីធ្លាប់បានឮពីគុកព្រៃស ប៉ុន្តែគាត់ពុំបានដឹងថា គុកនេះមានរូបរាងយ៉ាងម៉េចនោះទេ ។ ស-២១ ត្រូវបានស្គាល់ថាជាមន្ទីរសន្តិសុខ-២១ ។ ដើមបណ្តឹងរដ្ឋប្បវេណីស្គាល់ ហម ដែលធ្វើការនៅមន្ទីរភ័ស្តុភារ ប៉ុន្តែគាត់ពុំបានដឹងពីទំនាក់ទំនងរវាង ហម និង សាយ ទេ ។ គាត់ក៏មិនដឹងថា ស-២១ ត្រូវបានបង្កើតឡើងនៅឆ្នាំណាដែរ ប៉ុន្តែគាត់បានដឹងថាមាន ស-២១ នៅក្រោយឆ្នាំ១៩៧៩ ។ នៅពេលដែលគាត់ធ្វើការនៅការិយាល័យ៥៦០ គាត់មិនធ្លាប់បានឮពីស-២១ នោះទេ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា «ពួកសក្តិភូមិ មូលធននិយម និងគហបតី គឺមិនអាចជៀសផុតពីការប្រហារជីវិតទេ ។ ខ្ញុំចង់មានន័យថា អ្នកដែលមានចំណេះដឹង ។ ពួកគេទុកតែអ្នកដែលមិនចេះតែប៉ុណ្ណោះ» ។

ដើមបណ្តឹងរដ្ឋប្បវេណីមិនស្គាល់ឈ្មោះអ្នកណាម្នាក់ ក្រៅពីមនុស្សដែលបានមកទស្សនាទីក្រុងភ្នំពេញនោះទេ ។ គាត់ក៏ពុំបានស្គាល់គណៈប្រតិភូចិនដែលទៅបាត់ដំបងដែរ ។ ដើមបណ្តឹងរដ្ឋប្បវេណីក៏ពុំបានដឹងថា មន្ត្រីជាន់ខ្ពស់ចិនបានទៅត្រពាំងថ្មជាមួយ វស់ ញឹម ឬក៏អត់ដែរ ។

ត្រែង មានទីតាំងនៅផ្លូវលេខ១០ ពីខេត្តបាត់ដំបង និងមានចម្ងាយប្រហែល ៣០ ទៅ ៤០ គីឡូម៉ែត្រពីទីរួមខេត្ត ។ ត្រែង ធ្លាប់ជាមូលដ្ឋានយោធាដែរ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា កាលពីមុននៅទីនេះគ្មានផ្សារទេ ។ ទីស្នាក់ការកណ្តាល និង ស្ពោ ក៏នៅមិនឆ្ងាយពីផ្សារនេះប៉ុន្មានដែរ ។ ដើមបណ្តឹងរដ្ឋប្បវេណីពុំបានដឹងថា រ៉ែន នៅកងពលធំមួយណានោះទេ ហើយគាត់ក៏ពុំដឹងថាកងពលមួយណាដែលមានមូលដ្ឋាននៅស្ពោដែរ ។ ជាមួយគ្នានេះ មេធាវី កូប៉េ បានបញ្ចប់ការសាកសួរ ហើយផ្តល់វេទិកាបន្តជូនដល់ក្រុមមេធាវីការពារក្តី ខៀវ សំផន វិញម្តង ។

### ការទទួលភ្ញៀវ

មេធាវីការពារក្តី ខៀវ សំផន លោកស្រី អានតា ហ្គីស្សេ បានសួរថា តើដើមបណ្តឹងរដ្ឋប្បវេណីដឹងដោយរបៀបណាថា ឪពុករបស់ដើមបណ្តឹងរដ្ឋប្បវេណីបានស្គាល់មនុស្សដែលគាត់បានលើកឡើងខាងលើនេះ? ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា ឪពុករបស់គាត់ស្គាល់ ហ៊ូ យន់, ហ៊ូ នឹម, ខៀវ សំផន និងអ្នកដទៃទៀត ពីព្រោះពួកគេ "មាននៅក្នុងបញ្ជីឈ្មោះ" ហើយគាត់រស់នៅទីក្រុងភ្នំពេញ ។ ពួកគេយកសៀវភៅឲ្យគាត់បោះពុម្ព ដើម្បីឲ្យក្មេងទាំងនោះមានសម្ភារ និងសៀវភៅសម្រាប់រៀនសូត្រ ។ លោកស្រី ហ្គីស្សេ បានសំដៅទៅបទសម្ភាសរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលគាត់បាននិយាយថា គាត់គឺជានីរសារ និង ជាអ្នកទទួលភ្ញៀវ ។ ដូច្នេះ គាត់បានស្គាល់ ហ៊ូ នឹម និង ខៀវ សំផន មុនឆ្នាំ១៩៧៥ ដោយសារឪពុករបស់គាត់ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា គាត់បានធ្វើការនៅក្នុងព្រៃចាប់ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ។ ពូ និងឪពុករបស់ដើមបណ្តឹងរដ្ឋប្បវេណីធ្វើការជាមួយគ្នានៅទីនោះ ។ ពួកគាត់បានស្នាក់នៅ ការពារ បោសសម្អាត និងបម្រើភ្ញៀវនៅទីនោះ ។ ពួកគាត់ទាំងនោះគឺជាសាច់ថ្លៃ និងបងប្អូនរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

### ញាតិសន្តាន

ខឿន បានចូលមកជំនួស សាយ ។ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានផ្ទេរចេញ សាយ ក៏ត្រូវបានផ្ទេរចេញដូចគ្នាដែរ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានដឹងអំពីគោលនយោបាយដើម្បីសម្រេចផែនការការងារដែលបានកំណត់តាមរយៈ "ឯកសារដែលខ្ញុំបានអាន" ប៉ុន្តែគាត់បានបន្តថា តាមពិតផែនការការងារនេះមិនអាចម្រេចបាននោះទេ ។ "របាយការណ៍មានលក្ខណៈបោកប្រាស់" អ្នកដែលមិនអាចសម្រេចតាមផែនការដែលបានកំណត់ និងត្រូវបាត់ខ្លួន ។ គាត់មិនអាចបែងចែករវាងគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍បាននោះទេ ។ តាមការយល់ដឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ការិយាល័យ៨៧០ គឺជាការិយាល័យរបស់បក្ស ។ ដើមបណ្តឹងរដ្ឋប្បវេណីបានដឹងអំពីការចាប់ខ្លួនឪពុករបស់គាត់នៅពេលដែលគាត់បានជួបក្មួយរបស់គាត់ឈ្មោះ សារុង ។ គាត់បានដឹងរឿងនេះនៅក្រោយរបបខ្មែរក្រហម ដោយសារតែនៅក្នុងរបបខ្មែរក្រហមគាត់គ្មានទំនាក់ទំនងជាមួយសាច់ញាតិ ។

នៅពេលដែល នួន ជា នាំពួកគាត់មកទីក្រុងភ្នំពេញ នួន ជា បានប្រាប់ពួកគាត់ថា គេនាំពួកគាត់មកភ្នំពេញ "ដើម្បីគេចពីការកាត់ទោសរបស់ពួកជនក្បត់" ។ នៅក្នុងក្រុមរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានគ្នាពី៥០០ ទៅ ៦០០នាក់ ប៉ុន្តែគាត់ពុំបានដឹងថាអ្នកទាំងនោះមកពីកងពលធំ ឬ កងពលតូចមួយណានោះទេ ។ ពួកគាត់ទាំងនោះត្រូវបានបំបែកជាក្រុម ហើយដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបញ្ជូនទៅវត្តគាកែវ ។ មនុស្សមួយចំនួនដែលនៅក្នុងក្រុមរបស់គាត់បានបាត់ខ្លួន ។

### ការប្រជុំជាមួយ អៀង ធីរិទ្ធ

អ្នកស្រី ហ្គីស្សេ បានសំដៅទៅដល់អង្គប្រជុំជាមួយលោកស្រី អៀង ធីរិទ្ធ ដែលសាក្សីបានលើកឡើងកាលពីម្សិលមិញ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា លោកស្រី អៀង ធីរិទ្ធ បានបង្កើតអង្គប្រជុំមួយនៅទីស្តីការគណៈរដ្ឋមន្ត្រីនៅក្នុងខែធ្នូ ឆ្នាំ១៩៧៨ ។ នៅពេលនោះ ដើមបណ្តឹងរដ្ឋប្បវេណី គឺជាកម្មករសំណង់នៅមជ្ឈមណ្ឌលផលិតឱសថដែលមានទីតាំងស្ថិតនៅជិតទីស្តីការគណៈរដ្ឋមន្ត្រីសព្វថ្ងៃ ។ នៅក្នុងកិច្ចប្រជុំនោះ គេនិយាយអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ អ្នកជំងឺ និងត្រូវ

បានបញ្ជូនតាមរថភ្លើងមកខេត្តបាត់ដំបង ។ ជាមួយគ្នានេះ លោកស្រី ហ្គីស្សេ បានបញ្ចប់ការសាកសួររបស់គាត់ ។

## ការថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី

បន្ទាប់មក ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានផ្តល់ឱកាសឲ្យធ្វើការថ្លែងការណ៍ និងចោទជាសំណួរទៅកាន់ជនជាប់ចោទ ។

ខ្ញុំមានសំណួរមួយចោទសួរទៅកាន់ នួន ជា ។ គិតអំពីការសម្លាប់ និងការធ្វើទុក្ខបុកម្នេញទៅលើប្រជាជន៧លាននាក់ តើអ្វីទៅជាការទទួលខុសត្រូវរបស់ នួន ជា ? ឬមួយក៏ នួន ជា គិតថា ជនបរទេសគួរមកទទួលខុសត្រូវចំពោះរឿងនេះ?

អ្វីៗគ្រប់យ៉ាងគឺហួសពីការនិយាយទៅទៀត ខ្ញុំមិនដឹងថា តើខ្ញុំត្រូវពណ៌នាពីទុក្ខលំបាករបស់ខ្ញុំដោយរបៀបណាទេ ។ វាលើសពីការស្រមើស្រមៃ ហើយខ្ញុំមិនអាចទទួលយកបាននោះទេ ។ ខ្ញុំរស់នៅក្នុងស្ថានភាពដ៏លំបាក ដែលត្រូវបានពង្រាត់ចេញពីឪពុកម្តាយ បងប្អូន រួមទាំងសាច់ញាតិ ។ ខ្ញុំគ្មានកន្លែងស្នាក់នៅ និងគ្មានអ្វីទាំងអស់នាពេលនោះ ។ ខ្ញុំមិនបានទទួលការអប់រំ ហើយក៏គ្មានដីស្រែមួយដុំដែរ ។ ខ្ញុំមិនដែលនិយាយប្រាប់នរណាម្នាក់ពីរឿងរ៉ាវនៅក្នុងចិត្តរបស់ខ្ញុំនោះទេ ។ ខ្ញុំគ្មានអ្វីនិយាយតទៀតទេ ដោយសារតែការឈឺចាប់ទាំងនោះមិនអាចរៀបរាប់អស់តាមរយៈពាក្យពេចន៍ ។ បច្ចុប្បន្ន ខ្ញុំមិនស្មើនឹងសត្វផង ដែលនេះជាលទ្ធផលនៃអ្វីដែលបានកើតឡើងកាលពីសម័យនោះ ។ ខ្ញុំអរគុណចំពោះការអនុញ្ញាតឲ្យខ្ញុំធ្វើការថ្លែងការណ៍ពីអំពើអាក្រក់ និងការឈឺចាប់ទាំងនោះ ។

លោកប្រធានបានប្រាប់ទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីថា ជនជាប់ចោទមានសិទ្ធិក្នុងការរក្សាភាពស្ងៀមស្ងាត់ ។

## ការផ្តល់សក្ខីកម្មរបស់ តួច ស៊ីថាន

បន្ទាប់ពីសម្រាក សវនាការបន្តត្រូវបានផ្តល់ជូនសាក្សីអ្នកស្រី តួច ស៊ីថាន ដើម្បីផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីប្រទេសបារាំង ។ សាក្សីមានប្រសាសន៍ថា សាក្សីបានជួបប្តីរបស់សាក្សី នៅក្នុងឆ្នាំ១៩៧៨ ។ សាក្សីត្រូវបានចាត់តាំងឲ្យធ្វើការខាងផ្នែកឱសថ ។ ពីរឬបីខែក្រោយមក គេបានជម្លៀសប្តីរបស់សាក្សីចេញ ។ សាក្សីបានបំពេញពាក្យមួយដែលត្រូវទទួលដោយមនុស្សម្នាក់ផ្សេងទៀត ។ សហព្រះរាជអាជ្ញា ដឺវ៉ាល់ បានអានសម្រង់នៃបទសម្ភាសន៍របស់សាក្សី ដែលសាក្សីបាននិយាយអំពីកិច្ចប្រជុំនៅក្រសួងពាណិជ្ជកម្ម ។ សាក្សីបានបន្តថា បងប្រុសរបស់សាក្សីមិនបានទទួលការងារនយោបាយទេ ។ បងប្រុសរបស់សាក្សី ក៏មិនធ្លាប់បាននិយាយអំពីរឿងនយោបាយ ហើយគាត់ក៏មិនបានពិភាក្សាជាមួយ ខៀវ សំផន ដែរ ។ ពួកគេបានព្យាយាមជម្លៀសបងប្រុសរបស់គាត់ចេញ ដែលនេះជាមូលហេតុនាំឲ្យបងប្រុសរបស់គាត់ត្រូវបានបញ្ជូនទៅប្រទេសក្រៅ ។ គេបានផ្តល់ឯកសារមួយឲ្យសាក្សីអាន ប៉ុន្តែឯកសារនោះ «ពិបាកយល់ខ្លាំងណាស់» ។ សាក្សីត្រូវបានប្រាប់មិនឲ្យសួរសំណួរដែលទាក់ទងនឹងប្តីរបស់គាត់នោះទេ ប៉ុន្តែគាត់ក៏ត្រូវបានគេប្រាប់ដែរថា ប្តីរបស់គាត់ប្រហែលជាស្លាប់បាត់ហើយ ។ សាក្សីបានសួររកបទចោទប្រកាន់ប្តីគាត់ និងភ័ស្តុតាង ប៉ុន្តែត្រូវបានគេព្រមាន និងប្រាប់ថាគាត់មិនជឿជាក់លើអង្គការ ។ សហព្រះរាជអាជ្ញា ដឺវ៉ាល់ បានបង្ហាញចម្លើយសារភាពមួយទៅកាន់សាក្សី ។ សាក្សីបានឆ្លើយថា គាត់មិនបានដឹងថា នរណាខ្លះបានបាត់ខ្លួននោះទេ ។ សហព្រះរាជអាជ្ញា ដឺវ៉ាល់ បានសួរថា តើសាក្សីមានដឹងថាទន្តពេទ្យ ឌី ផុន បានបាត់ខ្លួនដែរឬយ៉ាងណា? សាក្សីបានឆ្លើយថា ដឹង ។ សហព្រះរាជអាជ្ញាបន្តថា ឈ្មោះរបស់លោកទន្តពេទ្យ និងភរិយាមាននៅក្នុងបញ្ជីឈ្មោះអ្នកទោសដែលត្រូវបានចាប់ខ្លួននៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ១៩៧៨ ។ បន្ទាប់មក សាក្សីត្រូវបានផ្ទេរចេញពីផ្នែកឱសថ ។ សហព្រះរាជអាជ្ញា ដឺវ៉ាល់ បានបន្តថា តើសាក្សីមានស្គាល់ប្តីប្រពន្ធពីរគូផ្សេងទៀតដែរឬទេ? សាក្សីបានឆ្លើយថា គាត់ស្គាល់ បងហ៊ិ និង បងហា ប៉ុន្តែក្រោយពីពេលដែលគាត់ត្រូវបានផ្ទេរចេញពីមន្ទីរពេទ្យ គាត់មិនបានទាក់ទងនឹងអ្នកទាំងនោះទេ ។ លោកប្រធានបានរម្លឹកដល់ជំនួយការជាន់ខ្ពស់សហព្រះរាជអាជ្ញា ដឺវ៉ាល់ ថា គាត់បានអស់ម៉ោងក្នុងការសាកសួរ និងត្រូវផ្តល់វេទិកានេះទៅឲ្យក្រុមមេធាវីការពារក្តី នួន ជា វិញម្តង ។

មេធាវី កូប៉េ បានសួរថា តើសាក្សីនៅចាំមនុស្សម្នាក់ឈ្មោះ ដួន ជឿន ដែលសាក្សីបានលើកឡើងនៅក្នុងបទសម្ភាសន៍របស់សាក្សីដែរឬទេ? សាក្សីបានឆ្លើយថា ជឿន ធ្វើការនៅមន្ទីរពេទ្យ ។ នៅឆ្នាំ១៩៧០ សាក្សីនៅជាសិស្សនៅឡើយ ហើយគាត់មិនទាន់បានចូលក្នុងផ្នែកឱសថនោះទេ ។ បន្ទាប់មក សាក្សី

បានស្គាល់ប្អូនប្រុសរបស់ ជឿន ។ មេធាវី កូប៉េ បានបន្តថា តើសាក្សីស្គាល់បងប្រុសរបស់ ជឿន ឈ្មោះ ជួន មុំ នៅចន្លោះឆ្នាំ ១៩៧០ និង ១៩៧៥ មែនឬទេ? សាក្សីបានឆ្លើយថា គាត់មិនធ្លាប់បានជួប មុំ នៅចន្លោះឆ្នាំ១៩៧០ និង១៩៧៥ នោះទេ ។ គាត់បានជួប មុំ នៅបារាំង ។ ឥឡូវនេះ មុំ មានវ័យជរាណាស់ទៅហើយ ។ សំណួរចុងក្រោយរបស់មេធាវី កូប៉េ ទាក់ទងនឹងប្រធានបទនេះគឺគាត់ចង់ដឹងថា តើសាក្សីមានដឹងទេថា តើ ជួន ប្រាសិទ្ធ នៅមានជីវិត ឬយ៉ាងណា? សាក្សីបានឆ្លើយបញ្ជាក់ថា ប្រាសិទ្ធ នៅមានជីវិត ។

## ការចែកចាយឱសថ

បន្ទាប់មក មេធាវី កូប៉េ បានបង្ហាញឯកសារបញ្ជីឈ្មោះទៅសាក្សី ។ សាក្សីមិនអាចអានឯកសារនោះបានទេ ដោយសារតែឯកសារនោះមានលក្ខណៈមិនច្បាស់នៅពេលដែលបង្ហាញនៅលើអេក្រង់ ។ មេធាវី កូប៉េ បានបន្តថា ឯកសារនេះមានរាយឈ្មោះឱសថជាច្រើន ។ សាក្សីមិនបានដឹងអ្វីទាក់ទងមនុស្សរបួសនោះទេ ។

សាក្សីបានបន្តថា គាត់មិនជាប់ទាក់ទងនឹងការទិញឱសថនោះទេ ពីព្រោះភារកិច្ចរបស់គាត់គឺ ចែកចាយឱសថទាំងនោះ ។ លោកមេធាវី កូប៉េ សួរបន្តថា តើសាក្សីធ្លាប់បានចូលរួមក្នុងការចែកចាយឱសថចិនទៅតាមភូមិភាគដែរឬទេ? សាក្សីបន្តថា គាត់បានចូលរួមក្នុងការចែកចាយទាំងឱសថចាស់ និង ឱសថថ្មី ប៉ុន្តែគាត់មិនមានទំនាក់ទំនងជាមួយក្រសួងពាណិជ្ជកម្ម ឬ ក្រុមជនជាតិចិននោះទេ ។ សាក្សីបានបន្តថា គាត់ទទួលការណែនាំពីបង សួរ ហើយបន្ទាប់មកគាត់នឹងចែកចាយឱសថទាំងនោះទៅតាមតំបន់ជាច្រើន ។

សាក្សីមិនបានដឹងថា ឱសថទាំងនោះទៅដល់កន្លែងឬក៏យ៉ាងណានោះទេ ដោយសារតែសាក្សីមិនធ្លាប់បានទៅដល់ខេត្តនោះ ។ សាក្សីក៏មិនបានដឹងលម្អិតអំពីការចែកចាយនោះដែរ ពីព្រោះតែមានមនុស្សមកយកឱសថទាំងនោះ ។ មេធាវី កូប៉េ បានសួរបន្តថា តើសាក្សីមានជាប់ទាក់ទងនឹងស្ថានភាពរស់នៅ និងសុខភាពរបស់ប្រជាជនកម្ពុជាដែរឬយ៉ាងណា? សាក្សីបានបដិសេធចំពោះសំណួរនេះ ។ «ខ្ញុំមិនមែនជាបក្ខជនទេ ហើយខ្ញុំក៏គ្មានមុខតំណែងក្នុងក្រសួងសង្គមកិច្ចដែរ» ។

នៅក្នុងរបបនោះ ពួកបក្ខជនដឹងរឿងច្រើនជាងប្រជាជនធម្មតា ។ ដូច្នេះសាក្សីពុំបានដឹងពីការពិភាក្សាក្នុងអង្គប្រជុំរបស់ពួកបក្ខជននោះទេ ។

មេធាវី កូប៉េ បានបង្ហាញពីកំណត់ហេតុនៃកិច្ចប្រជុំទាក់ទងនឹងសុខភាព រួមជាមួយកិច្ចការសាធារណៈដែលមានការចូលរួមពីនួន ជា, អៀង ធីរិទ្ធ និងកម្មាភិបាលជាន់ខ្ពស់ដទៃទៀត រួមទាំង សួរ ថ្នាក់លើរបស់សាក្សីផងដែរ ។ មេធាវី កូប៉េ មានប្រសាសន៍ថា ពួកគេបានពិភាក្សាអំពីការបរិច្ចាគឈាមសម្រាប់ជួយដល់អ្នកតស៊ូ ។ តើសាក្សីធ្លាប់បានដឹងពីគោលនយោបាយនេះដែរឬទេ? សាក្សីបានឆ្លើយថា គាត់មិនយល់ថា តើលោកមេធាវីចង់មានន័យដូចម្តេចចំពោះ «ការបរិច្ចាគឈាម» នេះទេ ។ សាក្សីបានបន្តទៀតថា គាត់ពុំបានដឹងអំពីបញ្ហានេះទេ ។

អង្គជំនុំជម្រះត្រូវបានផ្តល់ឲ្យមេធាវីការពារក្តី ខៀវ សំផន ។ លោកស្រី ហ្គីសេ្ស បានសួរបន្តថា តើពិតទេដែលថា សាក្សីមិនបានរក្សាទំនាក់ទំនងជាមួយអតីតសហការីរបស់គាត់ បន្ទាប់ពីគាត់បានចាកចេញពីមន្ទីរពេទ្យ? សាក្សីបានឆ្លើយបញ្ជាក់ថាពិត ។ ការងារថ្មីរបស់សាក្សីនៅមិនឆ្ងាយប៉ុន្មានពីមន្ទីរពេទ្យនោះទេ ប៉ុន្តែគេត្រូវធ្វើដំណើរដោយកង់ប្រមាណ១ម៉ោងកន្លះ តាមមហាវិថីកម្ពុជាក្រោម ។ កិច្ចប្រជុំមួយបានធ្វើឡើងដោយមានការចូលរួមពីបុគ្គលិកពេទ្យ ប៉ុន្តែពួកគេទាំងនោះមិនបាននិយាយជាមួយគ្នានោះទេ ។ សួរ បានជួប និងណែនាំសាក្សីឲ្យទិញឱសថ ។ មួយសប្តាហ៍ក្រោយមក សួរ បានមកប្រមូលយកឱសថទាំងនោះ ។ បន្ទាប់ពីប្តីរបស់សាក្សីត្រូវបានជម្លៀសចេញ «សាក្សីគ្មានអ្វីធ្វើនោះទេ» ប៉ុន្តែពួកគេត្រូវការមនុស្សដើម្បីធ្វើការជំនួសប្តីសាក្សី ។ មនុស្សមកពីផ្នែកផ្សេងៗគ្នា ហើយសាក្សីពុំបានដឹងថាមានមនុស្សប៉ុន្មាននាក់ដែលមកពីកងជាមួយគាត់នោះទេ ។ ដោយសារតែប្តីរបស់សាក្សីត្រូវបានជម្លៀសចេញ សាក្សីមិនចង់ទៅទិញឱសថនោះទេ ។ «ខ្ញុំគ្មានចំណាប់អារម្មណ៍នឹងធ្វើវាទេ» សាក្សីត្រូវបានគេនាំយកទៅកន្លែងដាច់ស្រយាលដែលឆ្ងាយពីគេឯង ។

អ្នកស្រី ហ្គីសេ្ស បានបង្ហាញពីបទសម្ភាសន៍ដែលសាក្សីបាននិយាយថា គាត់បានឃើញ ខៀវ សំផន និងបានប្រគល់ឯកសារគម្រោងទៅឲ្យពួកគេ ។ សាក្សីបានឆ្លើយថា ម្នាក់នោះជា

អ្នកដែលទទួលបន្ទុកទិញឱសថពីបរទេស ។ ក្រសួងពាណិជ្ជកម្ម គឺនៅជាប់នឹងក្រសួងសង្គមកិច្ច ។

មកដល់ត្រង់ចំណុចនេះ លោកប្រធានបានផ្អាកអង្គជំនុំជម្រះដើម្បីសម្រាក ។

## *ក្រសួង*

បន្ទាប់ពីសម្រាក លោកស្រី ហ្គីស្សេ បានសួរអំពីក្រសួង ។ សាក្សីបានឆ្លើយថា គ្មានស្លាកសញ្ញាសម្រាប់បញ្ជាក់ថា នេះជាក្រសួងពាណិជ្ជកម្ម ឬក្រសួងសង្គមកិច្ចនោះទេ ។ កិច្ចប្រជុំគឺធ្វើឡើងនៅកន្លែងផ្សេង មិនមែននៅជាប់ក្រសួងពាណិជ្ជកម្មទេ ។ ក្រសួងពាណិជ្ជកម្មស្ថិតនៅម្ខាងទៀតនៃផ្លូវ ។ សាក្សីបានជួប ខៀវ សំផន នៅក្រសួងសង្គមកិច្ច ឬ ក្រសួងពាណិជ្ជកម្មផងក៏មិនដឹង ។ លោកស្រី ហ្គីស្សេ បានសួរបន្តថា តើសាក្សីស្គាល់មន្ទីរពិសោធន៍ដែរឬទេ? សាក្សីបានឆ្លើយថា ស្គាល់ ។ តាមគោលនយោបាយឱសថធម្មជាតិត្រូវផលិតនៅកម្ពុជា ដោយផ្អែកលើថ្នាំបុរាណខ្មែរ ហេតុដូចនេះ ទើបយើងមិនត្រូវការឱសថពីបរទេស ។ សាក្សីមិនបានចែកចាយឱសថបុរាណខ្មែរទាំងនោះទេ ដោយពួកគាត់បានប្រមូលឱសថដែលនៅសល់ទៅចែកចាយជំនួសវិញ ។ បន្ទាប់ពីប្តីរបស់សាក្សីត្រូវបានចាប់ខ្លួន និងផ្ទេរចេញ សាក្សីមិនត្រូវបានគេជឿទុកចិត្តទៀតនោះទេ ហើយគាត់ត្រូវធ្វើការតែឯងនៅស្រុកចម្ការលើ ។

ក្រោមការសួរកាត់របស់លោកស្រីចៅក្រម ក្លោឌៀ ហ្វិន សាក្សីបានឆ្លើយថាគាត់ទទួលបានឱសថទាំងនោះពីប្រទេសចិន ។

## *ការរៀបអាពាហ៍ពិពាហ៍*

សាក្សីបានបន្តថា បងស្ងួរ ជាអ្នករៀបចំការរៀបការនេះឡើង ហើយប្រពន្ធអនុប្រធានរបស់ បងស្ងួរ ជាអ្នកប្រាប់គាត់អំពីការរៀបចំនេះ ។ អង្គការមានន័យថា "អ្នកដែលមានទំនួលខុសត្រូវខ្ពស់ និងជាអ្នកដែលអាចធ្វើការសម្រេចចិត្តជំនួសឪពុកម្តាយរបស់យើង" ។ សាក្សីបានពន្យល់ថា អង្គការ "មានការទទួលខុសត្រូវខ្ពស់" ។ សាក្សីមិនត្រូវបានចាត់ទុកជាអង្គការនោះទេ ដោយសារតែគាត់គ្មានសិទ្ធិក្នុងការធ្វើការសម្រេចចិត្ត ។ ពួកគេត្រូវបានបែងចែកជាពីរក្រុមគឺ បក្សជន និងមិនមែនបក្សជន ។ សាក្សីបានបដិសេធចំពោះភារកិច្ចខាងផ្នែកនយោបាយ ។

ចូលទៅកាន់ប្រធានបទបន្ទាប់ លោកស្រី ហ្គីស្សេ បានសួរទៅកាន់សាក្សីថា តើសាក្សីបានដឹងអំពីការប៉ុនប៉ងធ្វើរដ្ឋប្រហារប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដែរឬយ៉ាងណា? សាក្សីបានឆ្លើយថា គាត់មិនបានដឹងពីការប៉ុនប៉ងសម្លាប់មេដឹកនាំនោះទេ ។

សាក្សីបានយកប្រអប់មួយឲ្យ ភា ដែល ភា បានប្រាប់ឲ្យសាក្សីរក្សាវាទុក ។ នៅក្នុងប្រអប់នោះមាន "របស់តូចៗខ្ទិចខ្ទីជាច្រើន" ហើយសាក្សីបានបោះប្រអប់នោះចោលដោយមិនប្រាប់នរណាម្នាក់ពីរឿងនេះនោះទេ ។ សាក្សីបន្តថា បន្ទាប់មកគាត់បានដឹងថា "មានរឿងកើតឡើង" ។ សាក្សីបានដឹងថាមានវិវាទផ្ទៃក្នុងកើតឡើង ។ អៀង ធីរិទ្ធ និងមនុស្សម្នាក់មិនត្រូវគ្នានោះទេ ហើយប្រអប់នេះជា "ផ្នែកតូចប៉ុណ្ណោះ" ។ នៅបារាំង សាក្សីត្រូវបានគេប្រាប់ថា អៀង ធីរិទ្ធ "មិនត្រូវគ្នាជាមួយក្រុមរបស់ សុន សេន ទេ ។ លើសពីនេះទៅទៀត "អៀង ធីរិទ្ធ តែងតែខឹងប្រពន្ធ សុន សេន" ។ សាក្សីមិនបានដឹងថា ពេលនោះ អៀង ធីរិទ្ធ ខឹងនឹងគាត់ដោយសារតែ ខៀវ សំផន តែងតែមកជួបគាត់ ដោយមិនទៅជួប អៀង ធីរិទ្ធ ឬមួយក៏យ៉ាងណានោះទេ ។

សាក្សីត្រូវបានណែនាំឲ្យទិញឱសថពី "បរទេស" ប៉ុន្តែគាត់ពុំទាន់បានធ្វើឯកសារទាំងនោះរួចរាល់ឲ្យ ភា នោះទេ ។ សាក្សីត្រូវបានគេប្រាប់ថា ម៉េង "ខឹង" គាត់ខ្លាំងណាស់ ហើយ ភា មិនសប្បាយចិត្តជាមួយនឹងគាត់នោះទេ ពីព្រោះ ខៀវ សំផន មកជួបគាត់ដោយផ្ទាល់ ។ "ប្រហែលនេះ ជាទម្លាប់របស់គាត់" ។

លោកស្រី ហ្គីស្សេ បានសួរបន្តថា តើសាក្សីធ្លាប់បានឮពីការប៉ុនប៉ងរបស់នរណាម្នាក់ ក្នុងអំឡុងដំណើរទស្សនកិច្ចរបស់គណៈប្រតិភូឡាវដែរឬយ៉ាងណា? សាក្សីបានឆ្លើយបដិសេធចំពោះសំណួរនេះ ។

លោកស្រី ហ្គីស្សេ បានបន្តថា អេលីហ្សាប៊ែត បេកឃើរ (Elizabeth Becker) ធ្លាប់បានសម្ភាស អៀង ធីរិទ្ធ អំពីហេតុការណ៍នេះ ។ សាក្សីបានឆ្លើយថា គាត់មិនបានដឹងអំពីហេតុការណ៍ទាំងនេះទេ ។ ជាមួយគ្នានេះដែរ ការផ្តល់សក្ខីកម្មរបស់លោកស្រី ស៊ីថាន ត្រូវបានបញ្ចប់ ។

**លីអូនី គីវេស្តី**

# សក្ខីកម្មរបស់សាក្សី ស៊ីន អ៊ីង

បន្ទាប់ពីសម្រាក សាក្សី *2-TCW-2069* បានបង្ហាញខ្លួនក្នុងតុលាការ ។ ក្រុមមេធាវីការពារក្តី នួន ជា មេធាវី វីកទ័រ កូប៉េ បានស្នើសុំអង្គជំនុំជម្រះឲ្យបន្ថែមពេលវេលាសម្រាប់ផ្តល់សក្ខីកម្ម ពីព្រោះសាក្សីហាក់បីដូចជាដឹងរឿងច្រើនទាក់ទងនឹងសវនាការនេះ ។ លោកមេធាវីក៏បានស្នើសុំឲ្យធ្វើការស្តាប់សក្ខីកម្មសាក្សី *2-TCW-2069* និង *2-TCW-2070* យ៉ាងហោចណាស់ មួយថ្ងៃកន្លះ ទៅពីរថ្ងៃ ។ សហចៅក្រមអន្តរជាតិ មានប្រសាសន៍ថា លោកមិនជំទាស់ចំពោះសំណើនេះទេ ប៉ុន្តែលោកមិនឃើញពីភាពចាំបាច់ក្នុងការចំណាយពេលស្តាប់សក្ខីកម្មរបស់សាក្សីយូរដូច្នេះដែរ ។

សាក្សី ស៊ីន អ៊ីង កើតនៅថ្ងៃទី ៨ មីនា ១៩៥៧ ។ បន្ទាប់ពីប្រាប់សាក្សីអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន រួមនឹងបញ្ជាក់សមាសភាពរបស់សាក្សីរួច លោកប្រធានបានផ្អាកអង្គជំនុំជម្រះដើម្បីសម្រាក ។

បន្ទាប់ពីសម្រាកថ្ងៃត្រង់ អង្គជំនុំជម្រះបានបង្ហាញពីសក្ខីកម្មពីមុនរបស់ *2-TCW-920* ជាមួយ *DC-Cam* ។ សាក្សីត្រូវផ្តល់សក្ខីកម្មរយៈពេលមួយថ្ងៃកន្លះ ។ អង្គជំនុំជម្រះបានប្រគល់វេទិកាជូនក្រុមមេធាវីការពារក្តី នួន ជា ។

លោកមេធាវី កូប៉េ បានសួរអំពីទីកន្លែងដែលសាក្សីស្នាក់នៅ និងការងាររបស់គាត់ចាប់ពីថ្ងៃទី១៧ មេសា ១៩៧៥ ។ សាក្សីបានធ្វើការនៅកងចល័តពីថ្ងៃទី១៧ មេសា ១៩៧៥ រហូតដល់ឆ្នាំ១៩៧៦ ។

បន្ទាប់មក គាត់ត្រូវគេបញ្ជូនទៅគណៈភូមិភាគ ដើម្បីធ្វើស្រែ ។ ពេលយប់គាត់ត្រូវគេចាត់ឲ្យធ្វើជាអ្នកការពារ និងក្រោយមកគាត់បានក្លាយទៅជាកងការពាររបស់ សោ ភឹម និងដើរតាមការពារសោ ភឹម គ្រប់ទិសទី ។ នៅពេលយប់ខ្ញុំផ្លាស់ប្តូរវេនការពារជាមួយអ្នកការពារផ្សេងទៀត ។



*សាក្សី ស៊ីន អ៊ីង បានមកផ្តល់សក្ខីកម្មនៅមុខអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា*

សាក្សីបានបញ្ជាក់ថា គាត់បានហាត់ទាហានប្រហែល ៣-៤ ខែ ប៉ុន្តែមិនមានមូលដ្ឋានហាត់ច្បាស់លាស់នោះទេ ហើយពេលខ្លះគាត់ក៏មិនបានទៅហាត់ដែរ ។ មេធាវី កូប៉េ បានបន្តថា សាក្សីបានធ្វើការនៅមន្ទីរការពារ តើនេះជាការពិតដែរឬទេ? សាក្សីបានឆ្លើយបញ្ជាក់ថា «ពិត» ។ អ្នកទាំងនោះត្រូវបានចាត់ឲ្យទៅធ្វើការនៅកន្លែងផ្សេងៗពីគ្នា ។ ប្រាក់ ជឿន គឺជាមេកងការពារ ។

មេធាវី កូប៉េ បានសួបន្តថា តើពិតទេដែលថា សាក្សីមានជាប់ទាក់ទងជាមួយនឹង សោ ភឹម ហើយបើសិនជាពិត តើជាទំនាក់ទំនងរបៀបណាដែរ? សាក្សីបានឆ្លើយថា លោកយាយដែលស្លាប់ទៅរបស់គាត់គឺជាបងប្អូនជីដូនមួយរបស់ សោ ភឹម ។ សោ ភឹម បានដឹងថា សាក្សីជាកូនរបស់សាច់ញាតិខ្លួន ។ ឯសាក្សីនាពេលនោះមិនបានដឹងថាគាត់មានជាប់ទាក់ទងអ្វីជាមួយ សោ ភឹម ឲ្យប្រាកដនោះទេ ។

មេធាវី កូប៉េ បានបង្ហាញរូបថតបីសន្លឹកដល់សាក្សី ។ លោកមេធាវីបានសួរទៅកាន់សាក្សីថា តើគាត់ស្គាល់នរណាម្នាក់ក្នុងរូបនេះដែរឬទេ? សាក្សីបានឆ្លើយថាគាត់អាចចំណាំ សោ ភឹម បាន ។ សោ ភឹម ចាស់ជាងក្នុងរូបនេះទៅទៀតនៅពេលដែលសាក្សីធ្វើការឲ្យគាត់ ។ រាប់ពីឆ្វេងមកស្តាំ សោ ភឹម នៅទីបី ។ សាក្សីពុំស្គាល់មនុស្សទីពីរក្នុងរូបនេះទេ ។ មេធាវីបានបន្តថា តើសាក្សីចំណាំ នួន ជា បានដែរឬទេ? សាក្សីបានតបថា គាត់ស្គាល់ នួន ជា មិនច្បាស់នោះទេ ។ លោកមេធាវីបានដកស្រង់សម្តីរបស់សាក្សីដែលបាននិយាយថា នួន ជា ធ្លាប់មកសម្រាកនៅមន្ទីររបស់ខ្លួន ៣-៤ដង ។ សាក្សីបានឆ្លើយថា គាត់ស្គាល់មេដឹកនាំទាំងនោះមិនច្បាស់នោះទេ ដូច្នេះហើយទើបគាត់ចំណាំអ្នកទាំងនោះមិនបាន ។ « ខ្ញុំប្រហែលជាភ្លេចខ្លះហើយ » ។

មេធាវី កូប៉េ បានបង្ហាញរូបថតទីពីរដល់សាក្សី និងបានពន្យល់ប្រាប់សាក្សីថា ប៉ុល ពត ឈរនៅជិត នួន ជា, សោ ភឹម, វន វេត និង កុយ ធួន ។ លោកចៅក្រម ហ្សង់ម៉ាក ឡាវែញ បានមានប្រសាសន៍ថា មេធាវី កូប៉េ ហាក់បីដូចជាកំពុងផ្តល់សក្ខីកម្មដោយខ្លួនឯង ។ លោកមេធាវីគួតែសួរសាក្សីទើបត្រូវ ។ មេធាវី កូប៉េ បានឆ្លើយថា គាត់គ្រាន់តែចង់ដឹងពីមនុស្សតូចតាចនៅខាងឆ្វេងដៃដែលបង់កក្រមាតែប៉ុណ្ណោះ ។ សាក្សីបានឆ្លើយបដិសេធមិនស្គាល់អ្នកនៅក្នុងរូបនេះទេ ។ មេធាវីបានសួរបន្តថា តើសាក្សីស្គាល់ ភួង ប្រធានចម្ការកៅស៊ូនៅភូមិភាគបូព៌ាដែរឬទេ? សាក្សីបានឆ្លើយថា គាត់មិនធ្លាប់បានជួបម្នាក់នេះទេ ពីព្រោះគ្មាននរណាប្រាប់ខ្ញុំពីម្នាក់នេះទេ ។

មេធាវី កូប៉េ បានបង្ហាញរូបថតទីបី ដែលជារូបចុងក្រោយដល់សាក្សី ។ សាក្សីបានឆ្លើយថា គាត់មិនស្គាល់មនុស្សនៅក្នុងរូបនេះទេ ប៉ុន្តែគាត់ប្រហែលជាធ្លាប់បានជួបម្នាក់នេះ ។ មេធាវី កូប៉េ បានបន្តថា នេះជា ហេង សំរិន ដែលសាក្សីបានផ្តល់សក្ខីកម្មយ៉ាងក្បោះក្បាយក្នុងបទសម្ភាសន៍របស់សាក្សីនោះ តើមែនឬទេ? សាក្សីបានឆ្លើយថា «ឥឡូវគាត់ចាស់ហើយ នៅក្នុងរូបនេះគាត់ក្មេងណាស់ ។ កាលពីពេលដែលខ្ញុំបានជួបគាត់ គាត់ក្មេងខ្លាំងណាស់ប៉ុន្តែចាស់ជាងនៅក្នុងរូបនេះ» ។ សាក្សីបន្តថា គាត់មិនចាំមនុស្សនៅក្នុងរូបនេះទេប៉ុន្តែគាត់ក៏មិនបដិសេធជាមួយមេធាវីដែរ ។

មេធាវី កូប៉េ បានបន្តថា សាក្សីធ្លាប់ផ្តល់សាក្ខីកម្មថា ហេង សំរិន ជាមេបញ្ជាការកងពលធំលេខ៤ នៅមេមត់ ។ សាក្សីបានតបឆ្លើយថា គាត់គ្រាន់តែចាំថា ហេង សំរិន ទទួលខុសត្រូវកងពលធំនៅមេមត់ប៉ុណ្ណោះ ។

### សោ ភឹម

មេធាវី កូប៉េ សួរបន្តថា តើសាក្សីបានដឹងអ្វីខ្លះទាក់ទងនឹងយាយ ការ៉ូ ប្រពន្ធរបស់ សោ ភឹម? សាក្សីបានឆ្លើយថា គាត់ស្គាល់ និងអាចចំណាំយាយ ការ៉ូ បាន ។ សាក្សីបានស្គាល់យាយ ការ៉ូ នៅមន្ទីរកសិកម្ម ។ យាយ ការ៉ូ តែងតែនៅទីនោះជានិច្ច ។ ដូច្នេះសាក្សីបានសន្និតថា យាយ ការ៉ូ ជាអ្នកទទួលបន្ទុកមើលការខុសត្រូវនៅការដ្ឋាន ។ មនុស្សគ្រប់គ្នានៅទីនោះគោរពគាត់ណាស់ ។

មេធាវី កូប៉េ បានសួរបន្តថា តើយាយ ការ៉ូ មានជាប់ទាក់ទងនឹង ជា ស៊ីម ដែរឬយ៉ាងណា? សាក្សីបានឆ្លើយថា គាត់មិនដឹងនោះទេ ប៉ុន្តែគាត់គ្រាន់តែដឹងថា ជា ស៊ីម និងយាយ ការ៉ូ មកពីស្រុកជាមួយគ្នា ។

នៅពេលធ្វើជាអ្នកការពារ សោ ភឹម សាក្សីបានជួប ជា ស៊ីម បីដង ។ នៅស៊ីងមានផ្ទះសង់ថ្មី១ ។ សាក្សីបានបន្តថា សោ ភឹម តែងតែទៅជួប ជា ស៊ីម ។ ជួនកាលទៀត តាស៊ីម មកដល់មន្ទីរ

តែម្តង ។ សាក្សីមិនបានដឹងអំពីគោលបំណងនៃការជួបគ្នានោះទេ ដោយសារតែសាក្សីត្រូវយាមនៅខាងក្រៅ ។ មេធាវី កូប៉េ បានសួរបន្តថា តើពិតទេដែលថា ជា ស៊ីម ជាគណៈស្រុកពញាក្រែក ។ សាក្សីបានឆ្លើយថា ពិត ។ សាក្សីមិនបានស្គាល់ ជា ស៊ីម ជិតស្និទ្ធនោះទេ គាត់គ្រាន់តែធ្លាប់បានឃើញ ជា ស៊ីម ដោយសារតែគាត់នៅជាមួយ សោ ភឹម ប៉ុណ្ណោះ ។

សាក្សីបានរៀបរាប់បន្តថា សោ ភឹម មានកូនប្រុសពីរ និងស្រីពីរ ដែលមានឈ្មោះដូចជា ណាត, ស៊ី, គ្គេវ និង ទូច ជាដើម ។ មេធាវី កូប៉េ បានសួរបន្តថា តើពិតទេដែលថា ណាត ជាប្រធានមន្ទីរពេទ្យ ព-២? សាក្សីបានឆ្លើយបញ្ជាក់ថា ពិត ។ សាក្សីបានបន្តថា ស៊ី បានរៀបការមុនគាត់១០ថ្ងៃ ដូច្នេះហើយគាត់មិនដែលបានឃើញ ស៊ី នោះទេ ។ ស៊ី រៀបការជាមួយកូនរបស់គណៈភូមិភាគពាយ័ព្យ រស់ ញឹម ។ មេធាវីបានសួរបន្តថា តើកូនរបស់រស់ ញឹម ឈ្មោះ ដាល មែនទេ? សាក្សីបានតបថា ឈ្មោះនេះដូចជាមិនស្រដៀងសោះ ។ ស៊ី និងសាក្សីរៀបការនៅក្នុងឆ្នាំតែមួយ ហើយប្រពន្ធរបស់សាក្សីនៅរស់នៅឡើយ ។ សាក្សីត្រូវបានសួរបន្តថា គាត់ប្រហែលជាច្រឡំ ស៊ី ជាមួយនឹង គ្គេវ ឬយ៉ាងណា? សាក្សីបានឆ្លើយថា គ្គេវ បានបាត់ខ្លួន ហើយគាត់មិនដឹងថា គ្គេវ នៅមានជីវិត ឬយ៉ាងណានោះទេ ។ គ្គេវ រស់នៅជាមួយឪពុកម្តាយរបស់នាងនៅទួលសំរោង ។ សាក្សីមិនបានស្គាល់ឈ្មោះហៅក្រៅរបស់ គ្គេវ នោះទេ ។ សាក្សីបានព្រឹពីទំនាក់ទំនងសាច់ថ្លៃនៅពេលដែលគាត់ទៅដល់ ។ មានការរៀបចំមង្គលការធំមួយ ប៉ុន្តែសាក្សីមិនបានដឹងថា មង្គលការរបស់អ្នកណានោះទេ ។

មេធាវី កូប៉េ បានសួរបន្តថា តើ រស់ ញឹម ធ្លាប់ទៅជួប សោ ភឹម នៅភូមិភាគបូព៌ាដែរឬទេ? សាក្សីបានឆ្លើយថា គាត់ធ្លាប់ឃើញ រស់ ញឹម បីដង ។ សាក្សីមិនបានដឹងអំពីខ្លឹមសារនៃការពិភាក្សាគ្នានោះទេ ពីព្រោះគាត់នៅខាងក្រៅផ្ទះ ។ ផ្ទះនោះជាផ្ទះបែបបុរាណខ្មែរ ដែលស្ថិតនៅខាងជើងស្ពាន ។ រស់ ញឹម គ្មានអ្នកការពារនោះទេ គាត់មកតែម្នាក់ឯងទេ ប៉ុន្តែពេលខ្លះគាត់នាំក្មេងប្រុសម្នាក់មកជាមួយ ។ គាត់មកតែ ២-៣ម៉ោងប៉ុណ្ណោះ ពីព្រោះគាត់ត្រូវត្រឡប់ទៅវិញនៅថ្ងៃដដែលនោះ ។ ពេលដែលសាក្សីធ្វើជាអ្នកការពារឲ្យ សោ ភឹម សាក្សីមិនដែលបានទៅភូមិភាគពាយ័ព្យនោះទេ ។

លោកសហព្រះរាជអាជ្ញាអន្តរជាតិគាំចាន់ មានប្រសាសន៍ថា *2-TCW-1070* បានបញ្ជាក់ពីចំនួនជួបគ្នារវាង សោ ភឹម និង រស់ ញឹម ហើយថា ពួកគេជួបគ្នា មួយទៅពីរដងក្នុងមួយឆ្នាំ ។ មេធាវី កូប៉េ បានបន្តទៀតថា តើ សោ ភឹម និង រស់ ញឹម តែងតែនិយាយកំប្លែងដាក់គ្នានៅពេលជួបគ្នាមែនឬយ៉ាងណា? សាក្សីបានឆ្លើយថា គាត់មិនបានឮការសន្ទនារបស់អ្នកទាំងពីរនោះទេ ។ តាមពិតទៅ ខ្ញុំការពារនៅបរិវេណខាងក្រៅ ។ មេធាវីបានបន្តថា រស់ ញឹម ហៅ សោ ភឹម ថា អាថៃ ហើយ សោ ភឹម ហៅ រស់ ញឹម វិញថា អាយួន ។ សាក្សីបានឆ្លើយថា គាត់មិនធ្លាប់បានឮពាក្យទាំងនេះទេ ។ មេធាវី កូប៉េ បានបន្តទៀតថា សាក្សីដទៃទៀតបានឆ្លើយថា ពួកគេទាំងពីរនាក់បានរៀបចំកម្លាំង និង រៀបគម្រោងបះបោរ ។ តើសាក្សីធ្លាប់បានដឹងរឿងទាំងនេះទេ? សាក្សីបានឆ្លើយថា គាត់មិនធ្លាប់បានឮរឿងទាំងនេះនោះទេ ។ ខ្ញុំខ្លាចថា ខ្ញុំនឹងត្រូវគេចាប់ខ្លួន ។ ខ្ញុំមិនបានដឹងរឿងក្នុងបក្សនោះទេ ។ ត្រង់ចំណុចនេះ លោកប្រធានបានផ្អាកសវនាការដើម្បីសម្រាក ។

## សមាជិកគ្រួសាររបស់ សោ ភឹម

សាក្សីមិនបានដឹងថា ស៊ី រៀបការនៅថ្ងៃណានោះទេពីព្រោះគាត់មិនធ្លាប់បានឃើញពិធីមង្គលការ ។ សោ ភឹម ជឿលើតែឈូកម្នាក់គត់ ។ មេធាវី កូប៉េ បានបន្តសួរពីឈ្មោះ ប្រាក់ ចាម ។ សាក្សីបានឆ្លើយថា គាត់ធ្លាប់បានឮថាពីដំបូងឡើយ សោ ភឹម ឈ្មោះ ប្រាក់ ចាម ។ សាក្សីមិនបានដឹងពីប្អូនស្រី សោ ភឹម ឈ្មោះ ប្រាក់ ឈុន នោះទេ មានតែចាស់ៗទេដែលស្គាល់ឈ្មោះកំណើតរបស់ពួកគេ ។ ប្អូនស្រីរបស់ សោ ភឹម ទទួលខុសត្រូវសហករណ៍គគីរសោម ។ សាក្សីស្គាល់ ឌុល ហៅ ប្រាក់ ទិត្យ ដែលជាមេភូមិក្រូចឆ្មារ ។ មនុស្សទាំងអស់ត្រូវបានបំបែកចេញពីគ្នា ហើយសាក្សីត្រូវបានគេបញ្ជូនទៅស្អាង ។

មេធាវី កូប៉េ បានសួរបន្តថា តើសាក្សីមានដឹងអំពីការប៉ះទង្គិចការបះបោររបស់ជនជាតិចាមនៅក្រូចឆ្មារដែរឬយ៉ាងណា? សាក្សីបានឆ្លើយបដិសេធ ។ សាក្សីមិននៅទីនោះក្នុងឆ្នាំ១៩៧៤ នោះទេ ។ មេធាវី កូប៉េ បានបន្តទៀតថា ប៉ែនឃៀរនិន *(Kiernan)* ធ្លាប់បានសម្ភាសន៍ជាមួយ ហែម សាមីន ដែល ប៉ែនឃៀរនិន បាន

ហៅថា អ្នកហ៊ីកហាត់ក្រុមកុម្មុយនីស្ត ។ ហែម សាមីន នេះបាន ទម្លាក់កំហុសទៅលើ សោ ភឹម ចំពោះការប៉ះទង្គិចជាមួយជនជាតិចាម និងការសម្លាប់ជនជាតិចាម ។ សាក្សីបានឆ្លើយថា មិនធ្លាប់ដឹងរឿងទាំងនេះទេ ។

មេធាវី កូប៉េ សួរបន្តថា តើ ម៉ៅ ភោគ ជានរណា? សាក្សីបានឆ្លើយថា គាត់មិនដឹងថា ម៉ៅ ភោគ គេចខ្លួនពីពេលណានោះទេ ពីព្រោះពួកគេត្រូវបានបំបែកចេញពីគ្នា ។ សាក្សីគ្រាន់តែដឹងថា ម៉ៅ ភោគ នៅកងទី៩ ។

សាក្សីមិនបានចូលរួមក្នុងការបះបោរនៅភូមិភាគបូព៌ានោះទេ ។ គាត់ត្រូវបានចាប់ខ្លួន ប៉ុន្តែគាត់អាចរត់គេចខ្លួនបាន ។ ទោះបីជាយ៉ាងណាក៏ដោយ ការប្រយុទ្ធគ្នាបានកើតឡើងមុនពេលដែលគាត់អាចគេចខ្លួនបាន ហើយមានអង្គប្រជុំជាច្រើន ប៉ុន្តែគាត់មិនបានដឹងពីខ្លឹមសារនៃអង្គប្រជុំទាំងនោះទេ ដោយសារតែគាត់មិនធ្លាប់បានចូលរួមប្រជុំ ។

មេធាវី កូប៉េ បានសួរអំពី ហេង សំរិន ។ សាក្សីបានឆ្លើយថា ហេង សំរិន ជាមនុស្សចាស់ម្នាក់ ។ ដែលចេះលេងឧបករណ៍តន្ត្រី ។ សាក្សីមិនដែលបាននិយាយជាមួយ ហេង សំរិន ទេ ប៉ុន្តែគាត់ធ្លាប់និយាយជាមួយអ្នកការពាររបស់ ហេង សំរិន ។ មេធាវី កូប៉េ បានសួរបន្តថា តើសាក្សីដឹងពីតួនាទីរបស់ ហេង សំរិន ក្រោយឆ្នាំ១៩៧៩ដែរឬទេ? សាក្សីបានឆ្លើយថា ហេង សំរិន គឺជាអភិបាលខេត្តស្វាយរៀង ប៉ុន្តែសាក្សីមិនបានដឹងពីតួនាទីរបស់គាត់ក្នុងរដ្ឋសភាជាតិនោះទេ ។

## សាក្សី ស៊ីន អ៊ីង

មេធាវី កូប៉េ បានសួរបន្តថា តើពិតទេដែលថា ប្អូនប្រុសរបស់ ហេង សំរិន ឈ្មោះ តាល់ ជាមេបញ្ជាការកងពលធំលេខ៤ ។ សាក្សីបានឆ្លើយថា គាត់មិនដឹងនោះទេ ។ សាក្សីគ្រាន់តែដឹងថា ហេង សំរិន នៅកងពលធំលេខ៤ប៉ុណ្ណោះ ។

មេធាវី កូប៉េ បានសួរអំពីកងពលធំលេខ៥ និងថា តើ ហេង គីម ជាសាច់ញាតិរបស់ ហេង សំរិន ឬយ៉ាងណា? សាក្សីបានឆ្លើយថា គាត់មិនបានស្គាល់ឈ្មោះមេបញ្ជាការកងពលធំទាំងអស់នោះទេ ។

## រដ្ឋប្រហារ

មេធាវី កូប៉េ បានសួរអំពី ប្រាក់ ឈូក ដែលសាក្សីបានលើកឡើងមុននេះបន្តិច និងគិតថាគាត់បានស្លាប់បាត់ហើយ ។ បន្ទាប់មកមេធាវី កូប៉េ បានសួរអំពីរដ្ឋប្រហារវិញម្តង ។ សាក្សីបានឆ្លើយថា គាត់ពុំដឹងអំពីនិយមន័យរដ្ឋប្រហារនោះទេ ។ សម្រាប់គាត់ រដ្ឋប្រហារកើតឡើងនៅពេលដែលមានវិវាទនៅក្នុងរដ្ឋាភិបាលតែមួយ ។ សាក្សីបានបន្តទៀតថា មនុស្សនៅបូព៌ាមិនបានដឹងអំពីគម្រោងការចាប់ខ្លួននោះទេ ។ សាក្សីបានឮថា ប៉ុល ពត ព្យាយាមបង្កើតរដ្ឋប្រហារនេះឡើង ប៉ុន្តែសាក្សីមិនច្បាស់ថា អ្នកណាជាអ្នកផ្តើមបង្កើតវានោះទេ ។ គាត់គ្រាន់តែដឹងថា មជ្ឈិមផ្ញើសន្រ្គាមដើម្បីចាប់ខ្លួនអ្នកបូព៌ា ។ មេធាវី កូប៉េ បានដកស្រង់សម្តីរបស់សាក្សីដែលថា សោ ភឹម បាននិយាយប្រាប់ ហេង សំរិន ថាពួកគេនឹងប្រយុទ្ធម្តងទៀត ។ សាក្សីបានតបថា ជិតដល់ទីបញ្ចប់ទៅហើយដែលពួកគេត្រូវបានបំបែកចេញពីគ្នា និងទៅកន្លែងផ្សេងៗគ្នា ។ មេធាវី កូប៉េ បានបន្តថា តើ សោ ភឹម ចង់មានន័យយ៉ាងដូចម្តេចនៅពេលដែលគាត់និយាយថា ពួកគេនឹងប្រមូលគ្នីគ្នាឡើងវិញ ។ សាក្សីតបថា មេបញ្ជាការ និងអនុបញ្ជាការផកងពលធំគឺឈរជើងនៅទីតាំងនៅឡើយ ។

សាក្សីបានបន្តថា ពួកគេបាននិយាយគ្នាពីការប្តូរទីលំនៅនៅពេលដែលសាក្សីទៅយកវ៉ែនតា ។ សាក្សីបានពន្យល់ថា ពួកគេកំពុងអង្គុយនៅតុមួយ ហើយគាត់ត្រូវសម្អាតតុរបស់គាត់ ។ មេធាវី កូប៉េ បានបន្តថា តើមុនពេល សោ ភឹម ស្លាប់ប៉ុន្មានថ្ងៃដែលគាត់បានប្រាប់ ហេង សំរិន ឲ្យប្រមូលកម្លាំងវាយ ប៉ុល ពត? សាក្សីបានឆ្លើយថា ប្រហែល១០ថ្ងៃ ។ ពួកគេផឹកស្រានៅពេលនិយាយពីរឿងនេះ ។ សហព្រះរាជអាជ្ញាអន្តរជាតិ គាំចាន់ បានបដិសេធ ហើយបន្តថា សោ ភឹម និយាយថា គាត់មកភ្នំពេញដើម្បីដោះស្រាយបញ្ហា ។ បើសិនជាគាត់បាត់ខ្លួន ហេង សំរិន គួរតែលាក់ខ្លួននៅក្នុងព្រៃ ។ សាក្សីបាននិយាយថា គាត់មិនសូវស្គាល់ ហែម សាមីន នោះទេ ។

ក្នុងពេលនោះដែល មានខិតបណ្ណជាច្រើនត្រូវបានទម្លាក់ពីលើយន្តហោះ ។ ខិតបណ្ណទាំងនោះបានសរសេរថា សោ ភឹម សហការជាមួយនឹងយួន ។

**លីអូនី គីះជេស្គី**

# ពិនិត្យលលាដ៏ក្បាលៈ ការវិភាគឆ្អឹងសាកសពនៅជើងឯក

នាពេលរសៀល សាក្សី វឿន វុទ្ធី បានចូលបំភ្លឺ និងជម្រាបអង្គជំនុំជម្រះសាលាដំបូងអំពីព័ត៌មានទាក់ទងលលាដ៏ក្បាលដែលលោក និងក្រុមការងារបានវិភាគនៅជើងឯក ។ លោកក៏បានបកស្រាយអំពីវិធីសាស្ត្រ ដែលក្រុមលោកបានប្រើប្រាស់ដើម្បីកំណត់ភេទ ហើយមូលហេតុស្លាប់ដោយអំពើហិង្សាត្រូវបានរកឃើញលើឆ្អឹងសាកសព ។

**សក្ខីកម្មសាក្សីជាអ្នកជំនាញ៖ លោក វឿន វុទ្ធី**

ក្រោយពីសម្រាកអាហារថ្ងៃត្រង់ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសផ្តើមការស្តាប់អ្នកជំនាញ 2-TCE-1062 ។

លោក វឿន វុទ្ធី កើតនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៧៣ ។ សព្វថ្ងៃលោកធ្វើការនៅក្រសួងវប្បធម៌ ។ លោកបានសិក្សាផ្នែកនរៈវិទ្យានៅសាកលវិទ្យាល័យវិចិត្រសិល្បៈ ។ បន្ទាប់មក លោកបន្តការសិក្សានៅប្រទេសជប៉ុន នៅទីក្រុងបូឡូណា ប្រទេសអ៊ីតាលី និងនៅសាកលវិទ្យាល័យហាវ៉ៃ ផ្នែកអភិរក្សឆ្អឹង និងសាកសព ។ កម្រិតសិក្សាខ្ពស់បំផុតរបស់លោកគឺ បរិញ្ញាប័ត្រអនុបណ្ឌិត ។ លោកបានចូលរួមក្នុងការស្រាវជ្រាវទាក់ទងនឹងបុរាណវត្ថុវិទ្យាក្នុងឆ្នាំ១៩៨៨ ។ លោកក៏បានធ្វើការស្រាវជ្រាវទាក់ទងនឹងការប្រមូលសាកសព និងសំណល់បន្សល់ទុកពីសម័យបុរេប្រវត្តិ ។ លោកបានចូលរួមក្នុងការស្រាវជ្រាវប្រវត្តិសាស្ត្រក្នុងឆ្នាំ១៩៩៩ ។ ក្នុងឆ្នាំ១៩៩០ លោកបានចូលរួមក្នុងគម្រោងស្រាវជ្រាវ នាប៉ែកខាងកើតនៃប្រទេសកម្ពុជាទាក់ទងបុរេប្រវត្តិ ។ ពីឆ្នាំ២០០៦ ដល់ ឆ្នាំ២០០៧ លោកបានចូលរួមក្នុងការសិក្សាអំពីសម័យអង្គរ ។ ក្រោយមក លោកបានធ្វើការស្រាជ្រាវទាក់ទងនឹងការផ្លាស់ប្តូរពីរាជធានីមួយទៅរាជធានីមួយទៀត ។ ក្នុងឆ្នាំ២០១០ លោកបានធ្វើការស្រាវជ្រាវទាក់ទងនឹងឆ្អឹងមនុស្សនៅទីក្រុងហាវ៉ៃ ។ ថ្មីៗនេះ លោកបានធ្វើការស្រាវជ្រាវទាក់ទងនឹងឆ្អឹងសាកសពនៅមជ្ឈមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជើងឯក មជ្ឈមណ្ឌលឧក្រិដ្ឋកម្មក្រាំងតាចាន់ ក៏ដូចជានៅគោកព្រេច និងវត្តប្រាសាទបតី ។ លោកគឺជាប្រធានគម្រោងនាំមុខផ្នែកអភិរក្សឆ្អឹងជនរងគ្រោះ ។ គោលបំណងទីពីរនៃការវិភាគ គឺដើម្បីចងក្រងឯកសារប្រវត្តិសាស្ត្រសម្រាប់ក្មេងជំនាន់ក្រោយដើម្បីជៀសវាងកុំឲ្យមានរបបបែបនេះម្តងទៀត ។ គោលបំណងទីបីគឺដើម្បីធ្វើឯកសារទាក់ទងនឹងទារុណកម្មលើជនរងគ្រោះ ។ គម្រោងទាំងបួនរបស់លោកនឹងត្រូវធ្វើការបញ្ចប់នៅចុងខែនេះ ។ ការចាប់អារម្មណ៍របស់លោកដែលសិក្សាស្រាវជ្រាវនេះ ក៏ព្រោះតែលោកជាជនរងគ្រោះម្នាក់ដែលបាត់បង់ឪពុកជាគ្រូបង្រៀនសមាជិកគ្រួសារ៦នាក់ផ្សេងទៀត ។



សាក្សីជំនាញ វឿន វុទ្ធី បានផ្តល់សក្ខីកម្មនៅមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

សាក្សីបានប្រទះឃើញឆ្អឹងនៅមជ្ឈមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជើងឯក មានសភាពពុកផុយ ហើយអាចប្រឈមនឹងការបាត់បង់

ប្រសិនបើមិនបានថែទាំត្រឹមត្រូវ ។ ក្រុមអ្នកស្រាវជ្រាវមានការចូលរួមពីអ្នកជំនាញមកពី កូសូវ៉ូ សហរដ្ឋអាមេរិក ញូវហ្សឺឡែន និងអង់គ្លេស បានសហការក្នុងការវិភាគឆ្អឹងសាកសព ។ ពួកគេបានចាប់ផ្តើមក្នុងឆ្នាំ២០១៣ ហើយបានបន្តរហូតដល់ឆ្នាំ២០១៥ ។ ក្នុងឯកសារ ពួកគេចងក្រងបីផ្នែក ១) ទិន្នន័យ *database* ២) សៀវភៅ ៣) ទិន្នន័យក្នុងទម្រង់ឌីជីថល ។ ពួកគេបានថតរូបភាពនៃឆ្អឹងសាកសពមុនពេលពួកគេធ្វើការសម្អាតឆ្អឹងទាំងនោះ ។ ក្រោយពីការសម្អាត ពួកគេបានប្រៀបធៀបរូបភាពនៃឆ្អឹងសាកសពដែលពួកគេបានថត ។ ពួកគេបានវិភាគ ភេទ អាយុ និងមូលហេតុស្លាប់ ។ ពួកគេក៏ត្រូវតែវិភាគស្លាកស្នាមលើលលាដ៍ក្បាល ។ បន្ទាប់មកពួកគេបានវិភាគប្រភេទសម្ភារដែលបានវាយទៅលើជនរងគ្រោះ ថាតើវាជាកាំបិត ដំបង ព្រនង់ ឬ ពូថៅ ។

ក្រោយពីការវិភាគបែបនេះ ពួកគេបន្តទៅជំហានបន្ទាប់ដែលជាការអភិរក្សស្លាកស្នាមមិនឲ្យបាត់បង់ ។ បន្ទាប់មក ពួកគេនឹងធ្វើការអភិរក្សឆ្អឹងសាកសពទាំងនោះ ហើយពួកគេនឹងធ្វើឯកសារគ្រប់ជំហានដែលពួកគេបានឆ្លងកាត់ ។ ពួកគេបានធ្វើការសម្ភាសន៍សាក្សីបីវគ្គ ៖ អ្នកដែលបានទៅកាន់ទីតាំង និងសាក្សីដែលបានឃើញសាកសពជនរងគ្រោះ ដើម្បីអាចឲ្យអ្នកស្រាវជ្រាវអាចវាយតម្លៃរណ្តៅសាកសពបាន ។ វគ្គទីពីរ អ្នកដែលបានចូលរួមប្រព្រឹត្តក្នុងទីតាំងសម័យ ប៉ុល ពត ដូចជា ហ៊ឹម ហ៊ុយ ជាដើម ។ សម្រាប់វគ្គទីបី ពួកគេបានសម្ភាសសាក្សីដែលបានឃើញទាហានដឹកជនរងគ្រោះចូលទីតាំងឧក្រិដ្ឋកម្ម ។

បន្ទាប់មក ពួកគេបានគូរ និងថតរូប ។ លោកបានបង្ហាញរូបគូរ និងរូបលលាដ៍ខ្លះដែលបានវិភាគរួចរាល់ ។ ត្រង់ចំណុចនេះ លោកស្រីមេធាវី ហ្គីស្សេ បានកាត់ប្រសាសន៍ហើយថ្លែងថា រូបទាំងនោះគួរតែត្រូវភ្ជាប់ជាមួយប្រតិចារឹក ។

## មូលហេតុស្លាប់

សាក្សីបានឆ្លើយថា លោកមានសៀវភៅចំនួន ៣២ ក្បាល និងបានធ្វើការវិភាគលលាដ៍ក្បាលចំនួន ៦.៤២៦ ។ ការស្រាវជ្រាវដែលពួកលោកបានធ្វើ គឺផ្តោតទៅលើតែជនរងគ្រោះនៅជើងឯក ។ មានឆ្អឹងសាកសពចំនួន ៦.៤២៦ នៅទីនោះ ។ ពួកគេបានរកឃើញស្នាមចំនួន ២៨.០៨៣ លើជនរងគ្រោះ ។ “ពួកគេខ្លះ (ជនរងគ្រោះ) ត្រូវបានសម្លាប់ដោយដំបងឫស្សី” ។

៤.៨០៣ ករណីបានបង្ហាញពីស្នាមរបួសបង្កដោយដែកថ្នាំងអំពៅ ។ ៥.០៨៦ ករណីបានបង្ហាញស្នាមដោយឧបករណ៍ដែកផ្សេងទៀត ហើយ ៣.៥៦៣ ករណីផ្សេងទៀតបានបង្ហាញពីស្នាមចបជីក ។ ៥៤១ ករណីបង្ហាញថាពួកគេ (ជនរងគ្រោះ) ត្រូវបានគេយកខ្នងចបជីកវាយ ។ ១០១ ករណីត្រូវបានគេយកពូថៅវាយ ។ ១៦៥ ករណីបានបង្ហាញពីស្នាមគ្រាប់កាំភ្លើង ហើយ ៩៩០ ករណីទៀតបង្ហាញពីស្នាមកាំបិត ។ ៤៨ ករណីត្រូវបានសម្លាប់ដោយវាយនឹងកញ្ចឹងក ។ ២៨៦ លលាដ៍បានបង្ហាញស្នាមសារធាតុគីមី ហើយឆ្អឹងសាកសពចំនួន៣៨ទៀត បានបង្ហាញថាជនរងគ្រោះត្រូវបានគេធ្វើទារុណកម្ម ។ សាក្សីបានមានប្រសាសន៍ថា ៧៥៨ ករណី បានបង្ហាញថា គេបានយកដែកចាក់ចូលត្រចៀកជនរងគ្រោះ (ប្រហែលជាមានបញ្ហាបកប្រែ ហើយលោកប្រធានក៏បានសួរអំពីការកាត់ស្លឹកត្រចៀក) ។

លោកស្រីមេធាវី ហ្គីស្សេ បានស្នើសុំឯកសារយោង ។ មេធាវី កូប៉េ បានមានប្រសាសន៍ថា សាក្សីជំនាញកំពុងតែប្រើប្រាស់ឯកសារនៅក្នុងសំណុំបណ្តឹង ប៉ុន្តែសាក្សីគួរប្រើចំនួនសរុបជំនួសវិញ ។ លោក ឡៃសាក់ បានមានប្រសាសន៍ថា ចំនួនសរុបត្រូវបានរកឃើញក្នុងឯកសារពីរដែលស្ថិតក្នុងសំណុំបណ្តឹងដែរ ។

## វិធីសាស្ត្រ

លោកប្រធានបានជម្រាបសាក្សីថា លោកគួរតែសង្ខេបការរកឃើញរបស់ខ្លួន ។ នាថ្ងៃស្អែក តុលាការនឹងសួរសំណួរលម្អិតទៅកាន់សាក្សី ។ ពួកគេបានប្រើប្រាស់ឯកសារជាក់លាក់ ហើយពិនិត្យឆ្អឹងសាកសព ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះដែលបានស្លាប់ក្នុងរបបនោះ ។ ដំបូងពួកគេពិនិត្យទីតាំង បន្ទាប់មកពួកគេពិនិត្យឆ្អឹងសាកសព ។ ពួកគេចាំបាច់ត្រូវតែពិនិត្យឆ្អឹងសាកសពឲ្យបានហ្មត់ចត់ដើម្បីជាសម្អាងថា (ជនរងគ្រោះ) ស្លាប់ក្នុងរណ្តៅសាកសពក្នុងសម័យខ្មែរក្រហម ។ ពួកគេក៏បានវិភាគឆ្អឹងសាកសព ២.៥០០ ឆ្នាំមុនដែរ ។ សាក្សីបានថ្លែងថា វាពិតជាមានភាពលំបាកក្នុងការពន្យល់ទាក់ទងនឹងជំនាញនៃការវិភាគ ។

ពួកគេមិនបានធ្វើការវិភាគ *DNA* ឬ *C14* (ជាមធ្យោបាយប្រើប្រាស់សារធាតុវិទ្យុកាបោន) ។ ដូច្នេះ ពួកគេអាចវិភាគត្រឹម

ភេទជនរងគ្រោះតែប៉ុណ្ណោះ ។ ពួកគេរកឃើញរណ្ដៅសាកសព ចំនួន ១២៩ កន្លែង ប៉ុន្តែពួកគេអាចវិភាគត្រឹម ៨៦ កន្លែងតែប៉ុណ្ណោះ ។

លោកប្រធានបានសួរដេញដោលថា ក្រុមអ្នកស្រាវជ្រាវអាចកំណត់ថាជនរងគ្រោះស្លាប់នៅក្រាំងតាចាន់ដោយរបៀបណា ។ សាក្សី វុទ្ធី បានតបថា ពួកគេបានវិភាគភក់ដែលបានជីកមកជាមួយជនរងគ្រោះ ។ លោកបានបន្តថា ពេលខ្លះឆ្អឹងសាកសពមិនជាប់ជាមួយភក់ទេ ។

នៅមជ្ឈមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជើងឯក ក្នុងចំណោមលលាដ៍ក្បាល៦.៨២៦ ដែលពួកគេរកឃើញ មានលលាដ៍ក្បាលតែមួយប៉ុណ្ណោះដែលមិនបានបង្ហាញថា ស្លាប់ដោយការវាយដំដោយឧបករណ៍ ឬធ្វើទារុណកម្ម ។ លោកប្រធានបានសាកសួរថា ពួកគេរកឃើញថា ឆ្អឹងសាកសពបានទទួលរងទារុណកម្មដោយវិធីណា ។ សាក្សីបានឆ្លើយថា ពួកគេពិនិត្យមើលឆ្អឹងសាកសពទាំងនោះ ។ លោកបានបង្ហាញឧទាហរណ៍នៃលលាដ៏ដែលបានរងការប៉ះទង្គិចខ្លាំងដោយដែកច្បូកចាក់អន្ទង់ ។ ពួកគេបានប្រើប្រាស់មីក្រូស្កុប (Microscope) ដើម្បីពិនិត្យលលាដ៍ក្បាល ។ ចំពោះសារធាតុគីមី លោក វុទ្ធី បានបកស្រាយថា ជាតិពុលនឹងបំលែងពណ៌ឆ្អឹង ។ ឆ្អឹងត្រង់ក្រអូមមាត់ក៏ប្រែពណ៌ដែរ ។ បន្ថែមពីនេះទៀត ពួកគេនឹងផ្ញើឆ្អឹងសាកសពទៅសហការីក្រៅប្រទេសដើម្បីឲ្យធ្វើការបញ្ជាក់បន្ថែមទៀត ។

លោកប្រធានបានមានប្រសាសន៍ថា «យើងមិនមែនជាអ្នកជំនាញក្នុងផ្នែកនេះទេ ហើយយើងត្រូវការការពន្យល់» ។ លោកចង់ដឹងថា តើសាក្សីជំនាញអាចដឹងដោយរបៀបណាថា ស្លឹកត្រចៀកត្រូវបានកាត់ចេញពីឆ្អឹងលលាដ៏ក្បាល ។ អ្នកជំនាញបានបកឆ្លើយតបថា ស្លឹកត្រចៀកមិនជាប់នឹងលលាដ៏ក្បាលឡើយ ប៉ុន្តែស្នាមលើឆ្អឹងជិតត្រចៀកបានបង្ហាញយ៉ាងដូច្នោះ ។ «ជាធម្មតានៅពេលដែលត្រចៀកត្រូវបានកាត់ផ្ដាច់ គឺមានស្នាមច្រើនណាស់» ។

ពួកគេបានរកឃើញថា មានជនរងគ្រោះជាច្រើនបានស្លាប់ពេលកំពុងជាប់ខ្នោះ ឬ ចំណង ។ ពួកគេអាចកំណត់បានដូចនេះដោយសារតែមានស្នាម និងដោយសារតែខ្សែចំណងនៅជាប់ជាមួយនឹងឆ្អឹងនៅឡើយ ។ ពួកគេបានរកឃើញអាវុធដែលបានប្រើប្រាស់ចំនួន១០ប្រភេទដូចជា ៖ ពូថៅ ដែកថ្នាំងអំពៅ កាំបិត ដែកច្បូកចាក់អន្ទង់ និង ឈើជ្រុង ជាដើម ។

***ភេទ***

បន្ទាប់មក លោកប្រធានចង់ដឹងថាតើសាក្សីអាចដឹងពីអាយុ និងភេទរបស់ជនរងគ្រោះតាមវិធីណា ។ លោក វុទ្ធី បានបកស្រាយថាក្រុមការងារលោកបានប្រើប្រាស់វិធីសម្គាល់ជាអន្តរជាតិ ។ ជាឧទាហរណ៍ ដំបូងពួកគេពិនិត្យមើលចិញ្ចើមដែលមានលក្ខណៈខុសគ្នា ។ ទងត្រចៀកក៏ខុសគ្នាដែរ ។ មានវិធីសន្និដ្ឋានសរុបចំនួន៧ ។ លើសពីនេះទៀត ខ្សែលើលលាដ៏ក្បាលអាចបង្ហាញពីអាយុ ។ ពួកគេរកឃើញសាកសពជាស្ត្រីចំនួន ១.៦១១ និងបុរសចំនួន ៨.៧៩៨ (បូករួមទាំងសាកសពចំនួន១៧ទៀតដែលមិនអាចកំណត់ភេទបាន) ពួកគេបានបែងចែកជនរងគ្រោះទៅជា៦ផ្នែក ៖ ១) អាយុ ៣ ទៅ ៨ឆ្នាំ ៖ ពួកគេបានរកឃើញលលាដ៏ក្បាលក្មេងប្រុស ២ នាក់ និងក្មេងស្រី ១១ នាក់ ២) អាយុ ៨ ទៅ ១៩ឆ្នាំ ៖ ពួកគេបានរកឃើញលលាដ៏ក្បាលសរុប ២៤១ប្រុស ៧៤នាក់ និងស្រី ១៦៧នាក់ ៣) អាយុពី២០ ទៅ ៣៤ឆ្នាំ ៖ ពួកគេបានរកឃើញលលាដ៏ក្បាលសរុប ៣.៩៨៤ ប្រុស ២.៨៤៥នាក់ ស្រី ១.១២៧នាក់ និងលលាដ៏ក្បាលចំនួន ១២ មិនអាចកំណត់ភេទបាន ៤) អាយុ ៣៥ ទៅ ៤៩ឆ្នាំ ៖ ពួកគេបានរកឃើញលលាដ៏ក្បាលសរុបចំនួន១.៨៩៤ ប្រុស១.៣១៨នាក់ និង ស្រី៥៧៥នាក់ (អ្នកបកប្រែថាមានចំនួន ២.០៧៥នាក់ ។ នេះជាកំហុសនៃការបកប្រែ) ៥) អាយុ៥០ ទៅ ៦៩ឆ្នាំ ៖ ពួកគេរកឃើញលលាដ៏ក្បាលសរុបចំនួន២៧៣ ប្រុស ២៤៥នាក់ និង ស្រី ២៧នាក់ ៦) អាយុ ៧០ឆ្នាំឡើងទៅ ៖ ពួកគេរកឃើញលលាដ៏ក្បាលសរុបចំនួន១៨ ប្រុស១៤នាក់ និងស្រី៤នាក់ ។ ឆ្អឹងលលាដ៏ចំនួនបីមិនអាចកំណត់ភេទបាន (ចំណាំ ៖ មិនត្រូវបន្ថែមតួរលេខ ។ វាពុំមានភាពច្បាស់លាស់ថានេះជាកំហុសនៃការបកប្រែ ឬកំហុសពីខាងអ្នកជំនាញ) ។

ត្រង់ចំណុចនេះ លោកប្រធានបានមានប្រសាសន៍ថា លោកពុំមានសំណួរអ្វីចោទសួរទៅអ្នកជំនាញទៀតឡើយ ។ ដោយសារតែចៅក្រមផ្សេងទៀតក៏ពុំមានសំណួរសួរទៅកាន់សាក្សី លោកប្រធានបានប្រកាសឈប់សម្រាក ។ **លីអូនី គីវេស្តី**

# ចំណាប់អារម្មណ៍របស់សិស្សវិទ្យាល័យព្រះយុគន្ធរ ចំពោះប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជានៃវិទ្យាស្ថានស្លឹករឹត សហការជាមួយនឹងក្រសួងអប់រំ យុវជន និង កីឡា បានធ្វើវេទិកាថ្នាក់រៀនមួយស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដល់សិស្សថ្នាក់ទី១២ ចំនួនជាង៦០នាក់ នៅក្នុងបរិវេណវិទ្យាល័យព្រះយុគន្ធរនាថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ ។

វេទិកានេះ ស្ថិតក្នុងផ្នែកមួយនៃកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា បង្កើតឡើងក្នុងគោលបំណងផ្តល់ឲ្យសិស្សានុសិស្សនូវចំណេះដឹងពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងដើម្បីផ្សព្វផ្សាយពីការផ្សះផ្សារបួសផ្លូវចិត្ត ការអត់ឱន អធ្យាស្រ័យក្នុងសង្គម តម្លៃនៃសន្តិភាពក៏ដូចជាការទប់ស្កាត់មិនឲ្យប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតបែបនេះ កើតមានឡើងម្តងទៀតជាដាច់ខាត ។

វេទិកានេះ បានចាប់ដំណើរការក្នុងរយៈពេលពីរម៉ោងពេញ និងបានប្រើប្រាស់វិធីសាស្ត្រ ចម្បងចំនួន៦ ដូចជាៈ ១) ការបំពេញតារាងសួរបស្ទង់មតិមុនពេលធ្វើវេទិកា ២) ការបំពេញតារាងអ្វីដែលខ្លួនបានដឹង និងអ្វីដែលខ្លួនចង់ដឹងពីរបបខ្មែរក្រហម ៣) ការធ្វើបទបង្ហាញយ៉ាងសង្ខេបពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ៤) វិធីសាស្ត្រក្នុងការធ្វើបទសម្ភាសន៍ពីអ្នកជំនាញរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ៥) ការចែកចាយសៀវភៅ "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)" ៦) ការតាំងពិពណ៌ចល័តស្តីពីការជម្លៀសដោយបង្ខំជាដើម ។



សិស្សវិទ្យាល័យព្រះយុគន្ធរ ចូលរួមវេទិកាថ្នាក់រៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ (១៩៧៥-៧៩) ដែលរៀបចំដោយគម្រោងអប់រំពីអំពើប្រល័យពូជសាសន៍ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

បន្ទាប់ពីវេទិកាថ្នាក់រៀនត្រូវបានបញ្ចប់ទៅសិស្សានុសិស្ស ដែលបានចូលរួមមួយចំនួនបានថ្លែងពីចំណាប់អារម្មណ៍របស់ពួកគេដូចខាងក្រោមៈ

យុវសិស្ស សុវត្ថិ យល់ថា កម្មវិធីបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះពិតជាល្អខ្លាំងណាស់ ជាពិសេសសម្រាប់សិស្សដែលចូលចិត្តរៀនប្រវត្តិសាស្ត្រដូចជាប្អូន ។ ម្យ៉ាងទៀត កម្មវិធីនេះ ជួយបណ្ដុះគំនិតកូនខ្មែរឲ្យចង់ចេះចង់ដឹងអំពីប្រវត្តិសាស្ត្ររបស់ខ្លួនឯងថែមទៀតផង ។ សុវត្ថិ បានបន្តថា «របបខ្មែរក្រហម គឺជារបបដ៏ព្រៃផ្សៃមួយដែលមានការសម្លាប់យ៉ាងរង្គាល និងបន្សល់ទុកនូវសោកនាសកម្មរួមទាំងផលអវិជ្ជមានជាច្រើនដល់ប្រជាជន និងសង្គមជាតិយើងទាំងមូល» ។

ចំណែកឯយុវតីមួយរូបទៀតឈ្មោះ រូ សុជាតា បានបញ្ចេញចំណាប់អាម្មណ៍របស់ប្អូនថា កម្មវិធីនេះ បានជួយឲ្យប្អូន យល់ដឹងអំពីទុក្ខវេទនា និងការឈឺចាប់ដែលអ្នកជំនាន់មុនធ្លាប់បានឆ្លងកាត់ ។ ប្អូនស្រីបានបន្តថា «ប្រទេសយើងធ្លាប់ឆ្លងកាត់សង្គ្រាម និងទទួលរងនូវការឈឺចាប់រាប់មិនអស់ ដែលនេះជាបទពិសោធន៍ និងជាមេរៀនដ៏ល្អសម្រាប់ក្មេងជំនាន់ក្រោយក្នុងការពង្រឹងខ្លួនឲ្យរឹងមាំដើម្បីកសាងប្រទេសជាតិយើងឡើងវិញ» ។ មានចំណុចមួយដែលប្អូនស្រីនៅតែមិនយល់នោះគឺថា ប្រទេសកម្ពុជាគោរពព្រះពុទ្ធសាសនា ប៉ុន្តែហេតុអ្វីបានជាខ្មែរក្រហមលុបបំបាត់សាសនាចោល និងចាប់ផ្សឹកព្រះសង្ឃទៅវិញ?

ដោយឡែក យុវតី ស្រីមុំ បានរ៉ាយរ៉ាប់ប្រាប់ថា ការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះ មានសារសំខាន់ណាស់ចំពោះប្រជាជនកម្ពុជាទាំងមូល ក៏ដូចជាសិស្សានុសិស្ស ដូចជារូបប្អូន ពីព្រោះប្អូនអាចបង្កើនចំណេះដឹងបន្ថែមពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍នានាដែលបានកើតឡើងនាសម័យនោះ ។ ម្យ៉ាងវេទិកានេះក៏បានផ្ដល់ឱកាសដល់ប្អូនធ្វើការចោទសួរដល់លោកគ្រូ និងអ្នកជំនាញដោយផ្ទាល់ដើម្បីស្រាយចម្ងល់នានាដែលប្អូនមាន ។

ស្របពេលជាមួយគ្នានេះ យុវតី បូណ៌មី និងយុវតី ខែហុង បានឲ្យដឹងថា ប្អូនទាំងពីរមានការចាប់អារម្មណ៍លើប្រវត្តិសាស្ត្រខ្មែរក្រហមយ៉ាងខ្លាំង ។ កន្លងមកប្អូនបានដឹង និងឮអំពីរបបកាប់សម្លាប់នេះ តាមរយៈការបកស្រាយពីលោកគ្រូ-អ្នកគ្រូ និងឪពុកម្ដាយរបស់ប្អូន និងតាមរយៈការអានសៀវភៅ ។ សម្រាប់ថ្ងៃនេះផ្ទាល់ ប្អូនទាំងពីរមានអារម្មណ៍ថាខ្លួនកាន់តែមានសំណាងខ្លាំង ដោយសារតែខ្លួនមានឱកាសទទួលបានការអប់រំក្នុងសាលារៀន គ្មានការជិះជាន់សិទ្ធិ ដែលផ្ទុយស្រលះពីអ្វីដែលឪពុកម្ដាយរបស់ប្អូនធ្លាប់បានឆ្លងកាត់ក្នុងរបបនោះ ។

វេទិកានេះ ជំនួយស្មារតីដល់សិស្សានុសិស្ស និងប្រជាជនទាំងឡាយឲ្យថែរក្សាការពារសន្តិភាពរបស់ប្រទេសជាតិ ។ វេទិកានៃការបង្រៀននេះនឹងបន្តធ្វើនៅតាមសាលានានាទូទាំងរាជធានី ខេត្ត ដើម្បីអប់រំបណ្ដុះបណ្ដាលសិស្សានុសិស្សឲ្យយល់ដឹងពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងដើម្បីជាជំនួយដល់សិស្សថ្នាក់ទី១២ក្នុងការប្រលងថ្នាក់ជាតិនាពេលខាងមុខទៀតផង ។

**ឯម សីលា និង ឈឹម អមរ័ត្ន**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន នឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthbunthorn.s@dccam.org*

*Home page: www.d.dccam.org*

# កេរដំណែលផេះផង់សល់ពីរបបខ្មែរក្រហម

**(តពីលេខមុន)**

នៅពេលចល័តប្តូរការដ្ឋាន គេបត់ថែបពីរផ្ទាំងនេះចូលគ្នា ដាក់បញ្ឈរបានជាច្រើននៅលើរទេះមួយគ្រឿងៗ ប្តូរទៅកាន់កន្លែងថ្មីទៀត ។ គឺនៅក្រោមដំបូលថែបនេះហើយ ដែលនៅយប់មួយនោះ មានភ្លៀងធ្លាក់មកយ៉ាងខ្លាំង ហើយគេចាប់ជនរងគ្រោះអ្នក ១៧ មេសា ចំនួនបីនាក់នៅឆ្ងាយពីកន្លែងខ្ញុំដេកប្រហែល២០ ម៉ែត្រយកទៅសម្លាប់ចោលទាំងយប់ ។ ថ្ងៃស្អែកឡើង ទើបបានដឹងពីរឿងនេះ លុះយប់ឡើងភ័យខ្លាំងពេក ខ្ញុំដេកមិនលក់ស៊ើរទល់ភ្លឺ ព្រោះរូបខ្ញុំក៏ជា អ្នក១៧ មេសា ដែរ ។ យប់ក្រោយៗមកទៀត ពិសេសគឺនៅពេលដែលមានភ្លៀងធ្លាក់មកខ្លាំង ក៏ខ្ញុំបញ្ឈរភ្នែកស៊ើរទល់ភ្លឺដែរ ព្រោះតែបាក់ទឹកចិត្តពុំមានភាពកក់ក្តៅនៅក្នុងខ្លួនបន្តិចសោះ ។ ជាញឹកញាប់យុវជនដែលរស់នៅជិតខាងគ្នា តែងមកពឹងពាក់ឲ្យខ្ញុំវាយបំពង់ប៉ុយយកភ្លើងឲ្យពួកគេអុជបារីជក់ មិនថាយប់ឬថ្ងៃឡើយ ។ ប្អូនស្រីបន្ទាប់ខ្ញុំពីរនាក់ ព្រមទាំងរូបខ្ញុំផងទាំងបីនាក់ត្រូវបានម្តាយឲ្យស្បែកសត្វផ្សោតទន្លេសាប ម្នាក់ៗមួយចំណិតទុកជាប់នឹងខ្លួន ដើម្បីការពារកុំឲ្យអារក្ស អ្នកតាព្រៃភ្នំមកបៀតបៀនបាន ។ យប់ឡើងនៅស្នាក់ការកណ្តាលរបស់ខ្មែរក្រហម មានបំភ្លឺដោយភ្លើងអំពូលតភ្ជាប់គ្នាទៅដល់កន្លែងវែកដី និងមានឧបករណ៍បំពងសំឡេងចាក់ផ្សាយចម្រៀងបដិវត្តន៍ មហាលោតផ្លោះមហាអស្ចារ្យ ។ នៅពេលដែលយើងជីកប្រឡាយ លើកទំនប់ចប់តាមផែនការចាស់ គេក៏វាស់ដីចែកឲ្យយើងតាមផែនការថ្មីបន្តបន្ទាប់គ្នាទៀតជារៀងរហូតគ្មានទីបញ្ចប់ ។ ដូច្នេះ ការធ្វើរោងស្នាក់នៅក៏ធ្វើ ការរុះរើយកឈើទៅធ្វើរោងថ្មីទៀតក៏ធ្វើដែរ ដោយគ្មានពេលទំនេរ ។ នៅកន្លែងធ្វើការខ្លះ យើងបានជួបប្រទះបញ្ហាខ្លះដោយដើរទៅដួតទឹកឆ្ងាយ លុះដើរមកដល់កន្លែងស្នាក់នៅវិញត្រូវចេញញើសជោគខ្លួនម្តងទៀត ។ យប់មួយ ខ្ញុំកំពុងឈរកាន់ដងវែករង់ចាំឲ្យគេចូកដីដាក់នៅក្នុងបង្គីឲ្យ ស្រាប់តែមានគេគប់ដុំដីមកចំគ្រាប់ភ្នែកខ្ញុំខាងស្តាំដោយពុំដឹងខ្លួន បណ្តាលឲ្យបែកអំពិលអំពែករងការឈឺចុកចាប់យ៉ាងខ្លាំង ។ នៅពេលយប់ខ្លះ ក្រោយពេលវែកដីបញ្ចប់នៅម៉ោង១១យប់ ពេលដើរមកដល់កន្លែងស្នាក់នៅវិញ គេហៅយើងទាំងអស់គ្នាធ្វើការប្រជុំប្រមាណពីរម៉ោងបន្ថែមទៀត ។ មានយប់ខ្លះទៀត មិត្តនារីខ្មែរក្រហមមានសម្បុរខ្មៅស្រអែមឈ្មោះ មិត្តណាន ចូលចិត្តប្រជុំម្តងម្កាលជាមួយយើងដោយលើកឡើងថា សុំឲ្យបងប្អូនទាំងអស់គ្នាខិតខំធ្វើការឲ្យសកម្មខ្លាំងឡើង ព្រោះអង្គការស្រឡាញ់បងប្អូនណាស់គឺឧបត្ថម្ភគ្រប់បែបយ៉ាងកន្លងមក នៅថ្ងៃណាមួយ អង្គការនឹងលើកបងប្អូនដាក់នៅលើចង្កេះពដូចកូនក្មេងពុំខានឡើយ ។ ខ្ញុំចំណាំមុខមិត្តនារីណាន នេះបានច្បាស់ណាស់ លុះក្រោយឆ្នាំ១៩៧៩ មិត្តណាន បានក្លាយទៅជាភរិយាមិត្តរួមថ្នាក់ខ្ញុំម្នាក់នៅស្រុកកំណើតជាមួយគ្នា ហើយក៏ជាអតីតខ្មែរក្រហមម្នាក់ដែរ គេមានឈ្មោះថា អាំង កាដរ ។ ខ្ញុំឃើញប្តីប្រពន្ធពីរនាក់នេះរស់នៅក្នុងភូមិអន្លង់វិល ឃុំគោកធ្លកក្រោម ។ ក្រោយមក នៅឆ្នាំ១៩៨៧ សម្លាញ់ អាំង កាដរ ឈឺស្លាប់ដោយជំងឺឈាមសស៊ីឈាមក្រហម ។ ជនដែលអែបអបមានមុខមានមាត់តួយ៉ាងដូចជាប្រធានក្រុមខ្លះនោះ គេឈរកាន់ចបកាយដីតម្រង់នេះតម្រង់នោះនៅលើខ្នងទំនប់ បង្កក្រមាយ៉ាងរំភើយ ។ នារីម្នាក់មានសម្បុរសទាប ឈ្មោះ ហា រស់នៅក្នុងភូមិ មានបាតដៃគ្រើមៗ (ចៅយាយយួនចាំជាតិ) និយាយខ្មែរពុំសូវច្បាស់ នៅពេលលើកទំនប់មិនទាន់ហើយ គេនិយាយថា លើកទំនប់នេះ "យូរពិនដន់ហើ" ។ បងប្រុសរបស់អាហ៊ាម្នាក់ គេមានឈ្មោះថា ឌឿក កម្ពស់ក៏ទាបដែរ ពេលឃើញយុវជនក្នុងភូមិ ប្រឡែងគ្នាលេង ស្រែកឡូឡា គេក៏ស្រែកឃាត់ដែរថា ពួកនេះ "កុំឡូឡាពេកមើ៍" ។ ឪពុករបស់ពួកគេឈ្មោះ យិនធ្លាប់រកស៊ីដើរចាក់ថ្នាំនៅភូមិមាត់ខ្លា ឃុំអន្លង់សំណរ ក្នុងស្រុកជីក្រែង ហើយគាត់ចូលចិត្តនិយាយស្តីទាំងមិនច្បាស់ប្រកបដោយកាយវិការកំប្លុកកំប្លែងលេងដើម្បីឲ្យយើងសើច ព្រោះផ្ទះគាត់នៅ

ឆ្ងាយពីផ្ទះយើងមិនដល់១០០ម៉ែត្រផង ។ នៅថ្ងៃមួយ អង្គការខ្មែរក្រហម ធ្វើមិទ្ទីញយ៉ាងធំមួយនៅភូមិថ្នល់តាសិត ដោយមានមនុស្សក្នុងស្រុកជីក្រែងចូលរួមដើម្បីបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ដែលមានបក្ខជនឈរឈ្មោះឲ្យគេបោះឆ្នោត មានតែម្នាក់ឯងគត់ឈ្មោះ សមមិត្តស៊ុនឬអ៊ឹស៊ុន ។ យុវជននិងយុវនារីភូមិថ្នល់តាសិតក៏ទៅចូលរួមដែរ ដោយដើរពីទំនប់ម្កាក់ទៅទាំងយប់ លុះភ្លឺច្បាស់ទើបទៅដល់គោលដៅដែលដើរក្នុងចម្ងាយផ្លូវតែ១០គីឡូម៉ែត្រតែប៉ុណ្ណោះ ព្រោះអ្នកនាំផ្លូវដើរនាយប់នោះវង្វេងនៅក្នុងព្រៃ គឺដើរឆ្វេលចុះឆ្វេលឡើងតែកន្លែងដដែលៗ ។ គេធ្វើ មិទ្ទីញនៅកណ្តាលវាលស្រែ ជាប់ខាងជើងផ្លូវជាតិលេខ៦ កណ្តាលភូមិថ្នល់តាសិត ដោយមានមនុស្សមកពីគ្រប់ទិសទីក្នុងស្រុកជីក្រែងចូលរួមយ៉ាងច្រើនកុះករ ។ លោកគ្រូ ហ៊ួត ថាន់ (អ្នកស្រុកពួក) មានប្រពន្ធឈ្មោះ អ្នកគ្រូ អាំង បូរ៉ុម (អ្នកឃុំកំពង់ឃ្លាំង) ត្រូវបានគេជម្លៀសចេញពីក្រុងសៀមរាប ឲ្យមករស់នៅភូមិសន្ទុងព្រៃវាំងក្នុង ឃុំពង្រលើ ស្រុកជីក្រែង ។ លោកគ្រូ ហ៊ួត ថាន់ ក៏បានចូលរួមធ្វើមិទ្ទីញនេះដែរ ព្រោះនៅល្ងាចថ្ងៃនោះ មុននឹងត្រឡប់ទៅវែកដីវិញ ខ្ញុំបានឃើញគាត់ពាក់អាវយឺតក្នុង (អាវសង្រែកពណ៌ស) អង្គុយក្នុងផ្ទះសំណេះសំណាល សួរសុខទុក្ខគ្នាទៅវិញទៅមកជាមួយឪពុកម្តាយខ្ញុំដោយក្តីនឹករព្ញក ហើយឃើញគាត់រកម្ជុលដេសដើម្បីដេរ ស្រេះឡេវអាវដោយខ្លួនឯង និងនៅក្រោយឆ្នាំ ១៩៧៩ លោកគ្រូ ហ៊ួត ថាន់ ត្រូវបានបាត់ខ្លួន ។ នៅក្នុងពិធីធ្វើមិទ្ទីញនោះ ទាំងអស់គ្នាត្រូវបានគេឲ្យតម្រង់ជួរ ពិសេសពួកយើងជាអ្នកភូមិថ្នល់តាសិត ក៏បានតម្រង់ជាជួរដែរ តែម្នាក់ៗឈរធ្មេចភ្នែក អង្គុយធ្មេចភ្នែក ព្រោះងងុយដេកខ្លាំងពេក ។ ក្រោយពីឮសូរសំឡេងមេក្រូប្រកាសឲ្យស្រែកព្រមៗគ្នាថា យើងទាំងអស់គ្នាបោះឆ្នោតឲ្យ អ៊ឹស៊ុន! រួចមកក៏ស្រែកតាមគេតាមឯងទាំងបិទភ្នែកដែរ ។

ឪពុកខ្ញុំនៅធ្វើការក្នុងភូមិមិនសូវជាប់បានយូរទេ គឺក្រោយនេះបន្តិច គេតម្រូវឲ្យគាត់ទៅធ្វើការនៅឡូតិ៍នេសាទ ស៊ឹងជ្រៅទៀត ហើយគាត់បានណាត់ថ្ងៃឲ្យ បងណូ ទៅចាំផ្លូវគាត់ផង ។ ជំនាន់ខ្មែរក្រហមមិនមានសាសនានោះ គឺថ្ងៃនីមួយៗពុំមានឈ្មោះ ឬពុំមានទីប៉ុន្មាននោះឡើយ ព្រោះយើងពុំមានប្រតិទិនសម្រាប់មើល ឬធ្វើការកត់សម្គាល់ឡើយ ។ តែទោះបីជាយ៉ាងនេះក៏ដោយចាស់ៗទាំងឡាយដូចជាម្តាយខ្ញុំជាដើម ពូកែគួរឲ្យកោតសសើរណាស់ គឺពួកគាត់រួមគ្នារាប់ដឹងថ្ងៃសីល ឬថ្ងៃខែតាមរនោច តាមខ្នើតឥតមានខុះចន្លោះឡើយ ។ លុះដល់ថ្ងៃកំណត់ បងណូ បររទេះគោម្នាក់ឯងចុះតាមដងផ្លូវស៊ឹងជីក្រែង ខាងកើតស៊ឹងទៅក្រោម (ខាងត្បូង) លុះផុតភូមិចូលជ្រៅទៅក្នុងព្រៃនាមបានបន្តិច ទើបយប់ចូលមកដល់ ។ យប់ជ្រៅបន្តិចទៅហើយ គាត់បានបររទេះមកដល់កន្លែងមួយ គឺសត្វគោទាំងពីរក្បាលម្ខាងអាទែក និងម្ខាងទៀតអាត្នោតកញ្ជ្រោលឡើង ដោយក្រាញមិនព្រមបន្តដំណើរទៅមុខទៀត ។ ស្របពេលជាមួយគ្នានោះ បងណូ បានរំពៃមើលសភាពទាំងឡាយនៅជុំវិញខ្លួនគាត់ តែពុំមានអ្វីគួរឲ្យកត់សម្គាល់ឡើយ លុះដាក់ភ្នែកមកវិញក៏ប្រទះមនុស្សប្រុសម្នាក់ដេកស្នៀមផ្ងារពោះនៅជិតបង្កើយក្បែរកង់រទេះ ដោយមានកំណាត់សំពត់ពណ៌សពានាពាក់ឆៀងខ្លួនរបស់គាត់ទៀតផង ។ ឃើញយ៉ាងដូច្នេះ បងណូ បានប្រញាប់ប្រញាល់ដេញគោឲ្យចេញដំណើរយ៉ាងលឿនទៅមុខទៀត ដើម្បីចាកចេញឲ្យផុតពីទីនេះ ។ រដូវបង្កបង្កើនផលស្រូវបានឈានមកដល់ នៅតាមភូមិទាំងឡាយ បានចាប់ផ្តើមធ្វើការភ្ជួររាស់ដី និងសាបដំណាប តម្រូវទៅនឹងផ្ទៃដីរបស់ភូមិដែលមានស្រាប់ ។ ដោយឡែកស្រូវឡើងទឹក ឬស្រូវវារត្រូវបានចាប់ផ្តើមភ្ជួរ ព្រោះពីខែមេសា ឬខែចែត្រ និងត្រូវបញ្ចប់នៅថ្ងៃទី១៥ ខែមិថុនា ជារៀងរាល់ឆ្នាំ ។ ចំណែកស្រូវវស្សា ឬស្រូវស្រុក ការសាបព្រោះគឺមានដោយកម្រ ព្រោះវាផ្ទុយទៅនឹងទិសរបស់បក្សយើង ។ ការប្រើប្រាស់ដីលើដំណាំស្រូវ និងដំណាំបន្លែផ្សេងៗ គឺជាកត្តាចម្បងដែលទទួលបានមកពីបណ្តាប្រភពផ្សេងដែលក្នុងនោះរួមមាន៖

**១)** កងចល័តកុមារ បានដើររើសអាចម៍គោនៅតាមវាលស្រែកាលពីរដូវប្រាំង និងកាប់ដើមទន្ទ្រានខែត្រ ចិញ្ច្រាំធ្វើជាជី ។

**២)** អ្នកបររទេះគោ និងរទេះក្របីត្រូវមានបំពង់ឫស្សីយកជាប់តាមខ្លួន សម្រាប់មនុស្សនោមដាក់ផង និងត្រងយកទឹកនោមគោ និងទឹកនោមក្របី មិនឲ្យខាតក្នុងការបន្ទោរបង់ចោលនោះឡើយ ។

**៣)** កងចល័តយុវជន យុវនារី បានពិនិត្យមើលឃើញនៅរដូវប្រាំងក្នុងពេលលើកប្រព័ន្ធភ្លឺស្រែថ្មី ដែលធ្វើការតាំងទឹកន្លែង

ស្នាក់នៅឆ្ងាយពីភូមិ គឺគេតម្រូវឲ្យមនុស្សទាំងអស់នៅទីនោះធ្វើការបន្ទោបង់ដាក់នៅក្នុងសម្បកធុងសាំងដែលគេកាត់ជាពីរកំណាត់ចេញពីគ្នា ។ មានក្រុមមនុស្ស២-៣នាក់ ជាអ្នកធ្វើដីពីលាមកមនុស្សលាយជាមួយដីដំបូក យកមកពង្រាបលើដីដោយពុះកាត់ជាដុំៗ ហាលថ្ងៃមានសណ្ឋានដូចជាឥដ្ឋតាន់ ងាយស្រួលក្នុងការដឹកជញ្ជូនលើកដាក់ និងបំបែក ដើម្បីបាចដាក់ស្រែ ។ ពួកគេនិយាយពីមាត់មួយទៅមាត់មួយថា ដើម្បីឲ្យដឹងពីល្បាយលាមកលាយដីដំបូកនោះសាបប្រៃ ឬល្មមបាននោះ គេត្រូវមានមនុស្សម្នាក់ជាអ្នកភ្លក់មើល ។ កាលនោះ អ្នកភ្លក់គឺប្រហែលជាមិត្តក្នុងជួរខ្មែរក្រហមម្នាក់ សម្បុរខ្មៅ ទាប ដើរតាមកងចល័តរបស់យើងមានឈ្មោះថា មិត្ត ធឿន នោះហើយមើលទៅ ដែលគេនាំគ្នាលួចហៅក្រៅថា តាម៉ាក់សាល ។

នៅព្រឹកមួយ ខ្ញុំបានស្តាប់ឮផ្ទាល់នឹងត្រចៀក ព្រមទាំងឃើញតាម៉ាក់សាល ដើរស្ទោះទឹកមាត់ផង ព្រមទាំងពោលនូវពាក្យមួយឃ្លាផងថា យើ! ព្រឹកនេះមានកូនសត្វអន្ទង់ពណ៌ស (សត្វព្រូន) ផងវើយអាដែង អ្ហា! ។ លុះដល់សំណាប លូតលាស់គ្រប់អាយុនឹងអាចធ្វើការដកស្ទូងបាននោះ កងចល័តដែលបាននឹងកំពុងដឹកប្រឡាយ លើកទំនប់ឯឃុំគោកធ្លកលើត្រូវបានរំសាយឲ្យមកធ្វើការដកស្ទូងស្រូវនៅក្នុងឃុំគោកធ្លកក្រោមវិញម្តង ។ បើធ្វើការដកស្ទូងនៅភូមិណា គឺភូមិនោះជាអ្នកភ្ជួររាស់ និងដឹកសំណាបសម្រាប់ឲ្យកងចល័តស្ទូងជួនខាងលើ និងជួនខាងក្រោមថ្នល់ជាតិ ។ នៅពេលកងចល័តដើរដក ឬស្ទូងស្រូវដោយបានដើរឆ្លងកាត់ថ្នល់ជាតិលេខ៦ម្តងៗ ខ្ញុំតែងដើររើសដុំគ្រួសនៅមាត់ផ្លូវជាតិ ដែលមានចំណាំងចាំងព្រិចៗដូចថ្មក្រានីតសម្រាប់ដំបំពង់ប៉ុយយកភ្លើងអុជបារីជក់ ឬបំណែកចានថ្មកណ្តាប់ មាស ក៏អាចដំចេញជាផ្កាភ្លើងបានដែរ ។ គោ ក្របី នៅតាមភូមិនីមួយៗ ត្រូវបានយកទៅដាក់ក្នុងក្រោលរួមតាមភូមិរៀងៗខ្លួន លើកលែងតែគោ ក្របី កំពុងប្រើប្រាស់នៅតាមគ្រួសារទាំងឡាយ គឺម្ចាស់ផ្ទាល់ជាអ្នកប្រើ និងថែទាំដោយខ្លួនឯង ។ ការប្រើប្រាស់សត្វក្របីនៅក្នុងភូមិថ្នល់តាសិត គឺមានប្រើខ្លះដែរ ដូចជាម្ចាស់ឈ្មោះ តាហឿន និងតាភោគ ជាដើម ហើយមានចំនួនតិចតួចបំផុត ។ គោ ក្របី ដែលស្ថិតនៅក្នុងក្រោលរួមមានមនុស្សចាស់-ក្មេងប្រហែល៤-៥នាក់ ឃ្វាលនិងមើលថែទាំ ។ នៅឆ្នាំណាដែលមានទឹកធំ ឬខែវស្សា គេយកសត្វគោក្របីរួមទាំងនោះ ទៅចងនៅលើទួលពាក់យាម ហើយក៏គ្មានវ៉ាក់សាំងចាក់ការពារជំងឺគោក្របី និងថ្នាំព្យាបាលក៏គ្មានដែរ ។ នៅរដូវវស្សាឆ្នាំ១៩៧៨ ទឹកទន្លេឡើងធំខុសពីធម្មតា បណ្តាលឲ្យលិចស្រូវវារផង និងស្រូវស្រុកផងនៅក្នុងឃុំដីក្រែង ព្រមទាំងឃុំអន្លង់សំណរអស់គ្មានសល់ នាំឲ្យបណ្តាភូមិទាំងឡាយឡើងទៅសុំដីស្រែពីភូមិប៉ែកខាងលើៗនៅក្បែរគ្នា ដើម្បីដាំស្រូវសារឡើងវិញ ។ សត្វគោរាប់រយក្បាលត្រូវបានដឹកចេញយកទៅឃ្វាលនៅតាមព្រៃប៉ែកខាងក្រោមថ្នល់ជាតិលេខ៦ យ៉ាងអាណាធិបតេយ្យ ។ សត្វពាហនៈនាឱកាសនោះត្រូវរងគ្រោះដោយជំងឺផង ដាច់ពោះងើយក្បាលគោងស៊ីតែស្លឹកឈើផង បណ្តាលឲ្យស្លាប់ជាច្រើនសិបក្បាលនៅក្នុងព្រៃជាបន្តបន្ទាប់ ។ ឪពុកយើងរួមជាមួយអ៊ំប្រុសម្នាក់ទៀតឈ្មោះ ម៉ុម ពួកគាត់ទាំងពីរនាក់នេះកើតនៅឆ្នាំ១៩២៧ ត្រូវនឹងឆ្នាំងរោងដូចគ្នា ត្រូវបានសហករណ៍ចាត់តាំងឲ្យទៅបោចដើមរំពាក់ក្នុងព្រៃយកមកវិញធ្វើជាខ្សែគោ ។ នាល្ងាចថ្ងៃមួយ ក្រោយពេលបោចដើមរំពាក់បានហើយ នៅពេលដើរត្រឡប់មកភូមិវិញបានជួបប្រទះគោឈ្មោលជំទង់មួយក្បាលស្លាប់ថ្មីៗនៅក្នុងព្រៃ ។ នាឱកាសដ៏ស្ងាត់នោះ ពួកគាត់ទាំងពីរនាក់បានយកកាំបិតពន្លះសាច់គោនោះ ដើម្បីចែកគ្នាយកទៅឲ្យកូនចៅនៅឯផ្ទះបរិភោគដើម្បីឲ្យបានឆ្ងាញ់មាត់ម្តង ។ ទើបតែពន្លះបានសាច់បន្តិច ក៏ស្រាប់តែមានមនុស្សម្នាក់ ស្ថិតក្នុងវ័យ៣០ឆ្នាំ បានដើរមកដល់ ព្រមទាំងនិយាយថា អ៊ំប្រុសទាំងពីរនាក់អត់ដឹងទេថា គោស្លាប់មួយក្បាលនេះ វាមានស្នែងអាចដល់បានដែរឬទេ? ឮពាក្យគំរាមយ៉ាងដូច្នេះ ពួកគាត់ទាំងពីរនាក់នៅស្ងៀមពុំនិយាយស្តីអ្វីមួយម៉ាត់តបតវិញឡើយ ព្រមទាំងក្រោកដើរចេញម្តងម្នាក់ៗ លីដើមរំពាក់យកទៅដោយទុកសាច់គោដែលពន្លះបានខ្លះហើយ ចោលនៅទីនោះទាំងអស់ ។ ពេលដើរបានឆ្ងាយបន្តិច ពួកគាត់ក៏នាំគ្នារត់សំដៅភូមិថ្នល់តាសិតវិញទាំងក្តីភិតភ័យ ព្រោះតែពាក្យសម្តីមុសារបស់បុរសម្នាក់នោះ ។ ថ្វីបើសត្វគោគេប្រើប្រាស់ជាសមូហភាពនៅក្នុងភូមិក៏ពិតមែនតែចំពោះអ្នកមានគោ គេនៅតែស្រឡាញ់កម្លាំងអូសទាញ ពោលគឺមានការដោះដូរគោគ្នាទៅវិញទៅមក ដោយធ្វើការថែមថយជាសម្ភារ ដូចជា ចង្ក្រងសម្រាប់ពាក់កគោជាដើម ។

បើពុំនោះទេ គេស្កាត់រកគ្នាដើម្បីដូរគោនៅពេលយប់ ដោយពុំមានប្រើភ្លើងដើម្បីបំភ្លឺមើលភិនភាគរបស់សត្វគោឡើយ ។ បងណូមានពួកម៉ាកម្នាក់នៅរំលងគ្នាមួយផ្ទះមានឈ្មោះ នោង ស៊ីង់ ប្រពន្ធមានឈ្មោះថា ធិន សាវត ហើយមានស្រុកកំណើតនៅឃុំកំពង់ឃ្លាំងជាមួយគ្នា និងត្រូវជាបងប្អូនគ្នា ទៀតផង ។ បងណូ ហៅបង នោង ស៊ីង់ ថា អាបន្ទែៗ ព្រោះនាមត្រកូលគាត់ឈ្មោះ នោង គឺផ្ទែននោងនាម ជាបន្ទែ ។

ចំណែកបង នោង ស៊ីង់ ហៅ បងណូ វិញថា អាមនោៗ គឺហៅឈ្មោះដូចនេះទៅវិញទៅមកជាប្រចាំ ពុំដែលមានលោះថ្ងៃណា ។ បងស៊ីង់ គាត់មានសម្បុរស ប្រកបដោយសំឡេងធំគ្រលរ និយាយពូបានឆ្ងាយ និងធ្លាប់បានដើរដូរគោពេលយប់នៅតាមភូមិដែលនៅក្បែរខាងគ្នានោះ ។ យប់មួយប្រជាជនចូលដេកស្ងាត់អស់ហើយ បងស៊ីង់ ចុះដើរពីថ្នល់ជាតិដឹកសត្វគោពូសូរសម្លេងលុយទឹកគ្រាំៗតម្រង់មកផ្ទះ ។ ក្រោយពេលប្រពន្ធយកភ្លើងមកឲ្យបំភ្លឺមើលសត្វគោដែលទើបដូរបានមកថ្មីៗរួចមក ស្រាប់តែស្តាប់ពូ បងស៊ីង់ ខ្សឹបប្រាប់ប្រពន្ធថា ម៉ែខ្ញុំ! កុំប្រាប់អ្នកណាឲ្យសោះ ព្រោះគោយើងដែលទើបនឹងដូរបានមកនេះ បាយភ្នែកម្ខាងហើយវើយ! ។ ក្នុងរដូវដកស្ទូងនេះ ដើម្បីគ្រប់គ្រងកងចល័តឲ្យកាន់តែល្អ កុំឲ្យដើរទៅផ្ទះរហេតរហូតបាននោះ គឺអង្គការយកទួលចាស់ធំមួយឈ្មោះថា ទួលឆ្អេះ ធ្វើជាទីស្នាក់ការកណ្តាលរបស់កងចល័តសង្កាត់ ។ ទួលនេះស្ថិតនៅខាងជើងថ្នល់ជាតិលេខ៦ ប្រមាណជាកន្លះគីឡូម៉ែត្រនៅកណ្តាលវាលស្រែក្នុងភូមិសាស្ត្ររបស់ភូមិដូនរាជ ក្នុងឃុំគោកធ្លកក្រោម ។ នៅខាងជើងឆៀងខាងកើត ចម្រាក់ទួលបន្តិច មានអណ្តូងទឹកចាស់មួយដែលមានទឹកខ្ទបប្រាំងខ្ទបវស្សាមិនចេះរីងស្ងួត ហើយអ្នកភូមិដូចរាជតែងនាំគ្នាមកដងទឹកនេះយកទៅប្រើប្រាស់តាំងពីយូរលង់ណាស់មកហើយនៅរដូវប្រាំងហួតហែង ។ ឃើញមានសត្វមាន់ព្រៃពី៥ ទៅ៦ក្បាលដែលគេចិញ្ចឹម ហើរឡើងទៅលើដើមឈើធំៗ ខ្ពស់ៗ ដែលដុះនៅលើទួលនោះ និងមានដើមពីងពង់ជាច្រើន ហើយឈ្មោះរបស់ទួលនេះត្រូវបានយកតាមឈ្មោះអណ្តូងចាស់មួយនេះ គឺអណ្តូងឆ្អេះនេះឯង ។ អណ្តូងឆ្អេះ មានជម្រៅប្រហែល៤ម៉ែត្រ នៅក្នុងអណ្តូងមានឫសឈើ និងមានក្អេងរឹកធំដូចក្អមទឹក ព្រោះខ្ញុំធ្លាប់ចុះនៅពេលយប់ទឹកត្រជាក់ស្រឹប ដើម្បីយកធុងទឹកឲ្យប្អូនស្រីខ្ញុំម្នាក់ឈ្មោះ សៀវ សុវត្ថា ដែលដងទឹកធ្លាក់ចូលក្នុងអណ្តូងនេះ ។ នៅលើទួលអង្គការសាងសង់ជារោងវែងៗ ប្រក់ស្បូវចំនួនពី៤-៥រោង ហើយមានទីបញ្ជាការរបស់សង្កាត់គោកធ្លកក្រោម មានចាក់មេក្រូ និងឃើញមានពួកមិត្តមួយចំនួនស្នាក់នៅទីនោះដែរ ។ រោងស្បូវមួយខ្នងនៅបណ្តោយថ្ងៃ គឺផ្ទះបាយរួមរបស់សង្កាត់ដោយផ្ទាល់ដែលមានលោក ជា ប៊ុនថា និងរូបខ្ញុំពីរនាក់ជាអ្នកអារខសដុត និងបម្រើការងារផ្សេងៗនៅទីនោះជាប្រចាំរយៈពេលជិតមួយឆ្នាំ ទើបបានគេដកខ្ញុំម្នាក់ឯងឲ្យទៅរស់នៅនេសាទត្រីឯឃុំកំពង់ឃ្លាំង ។ ប៊ុនថា ស្គាល់អ្នកតូចអ្នកធំមួយចំនួននៅក្នុងឃុំគោកធ្លកក្រោម រាប់ចាប់តាំងពីប្រធានកងចល័តរហូតមិត្តខ្មែរក្រហមខ្លះទៀត ដែលបម្រើការងារនៅក្នុងសង្កាត់ ។ តាមរយៈនេះ ប៊ុនថា មានលទ្ធភាពសុំយកខ្ញុំចេញពីកងចល័តផ្ទេរឲ្យមកនៅបម្រើការងារពីរនាក់គាត់វិញនៅលើទួលឆ្អេះនេះ ហើយការហូបចុកបានស្រួលជាងនៅក្នុងកងចល័ត ។ នៅលើទួលឆ្អេះនេះ ពីរនាក់ ប៊ុនថា បានធ្វើរោងដេកជាមួយគ្នាដោយយកដំបូលរទេះគោមួយគ្របពីលើ ។ នៅឆៀងខាងមុខទីជម្រកដែលយើងដេកនៅបន្តិចនោះ មានដើមពីងពង់ខ្ពស់ៗ មួយគុម្ពដែលខ្ញុំតែងចងអង្រឹងដេកលេងនៅក្បាលព្រលប់ពីរនាក់យុវជនម្នាក់ឈ្មោះ ឡុង ដែលត្រូវជាបងប្អូនជីដូនមួយខាងឪពុកជាមួយ ប៊ុនថា ដែរ ។

នៅរដូវដកស្ទូងនេះ កងចល័តទាំងអស់ អង្គការឲ្យហូបតែបបរទេ និងចំណែកផ្ទះបាយរបស់សង្កាត់ គឺហូបបបរដែរ តែបបរខាប់បន្តិច ។ នៅយប់ខ្លះ យើងទាំងពីរនាក់នាំគ្នាលួចដាំបាយហូបដោយបងប្រុស ជា សូវេត ផ្តល់អង្ករឲ្យ ព្រោះគាត់ជាអ្នកដឹកអង្ករចល័តតាមរទេះគោនៅក្នុងសង្កាត់គោកធ្លកក្រោម ។ នៅទីនោះក៏មានក្រុមដឹកជញ្ជូនត្រីមានដូចជាឈ្មោះ ស្ងួន ឆាយ និង ញ៉ក់ ជាដើមដោយជិះកង់តួប្រុសពណ៌ខ្មៅ ខ្នងកង់វែង៧០០ ផលិតនៅប្រទេសចិនដឹកត្រីពីឃុំកំពង់ឃ្លាំងយកមកទួលឆ្អេះ ។ លោក ជា ប៊ុនថា និងខ្ញុំក្រៅពីអារខស អង្គការឲ្យដើររកដកព្រលឹតនៅស្ពានឫស្សីលកឬតាមត្រពាំងបឹងបួរនានា ព្រមទាំងឲ្យដើរបិទទឹកស្រែនៅក្បែរខាងទួលឆ្អេះនេះផងដែរ ។ ព្រឹកថ្ងៃមួយ អង្គការឲ្យយើងទាំងពីរនាក់បិទទឹកស្រែនៅខាងកើតទួលឆ្អេះ ខ្ញុំឱនលើកបង្គីដីដែល ប៊ុនថា កាប់ដី

ដាក់ឲ្យ ស្រាប់តែខ្ញុំ ថ្ងោះចង្កេះរហូតងើបមិនរួច ក៏ទម្លាក់ខ្លួនអង្គុយ នៅក្នុងទឹកស្រែនោះតែម្តងទៅ ។ ដំបូងឡើយ ប៊ុនថា ស្មានថា ខ្ញុំធ្វើលេងជាមួយគាត់ តែដល់ឃើញខ្ញុំក្រោកពុំរួចពីក្នុងទឹកស្រែនោះ ពិតមែនទៅ ទើបគេចុះទឹកមកក្រាយកខ្ញុំទៅកាន់កន្លែងស្នាក់នៅ វិញ ។

ថ្ងៃនោះដដែល ពេលរសៀលស្ងាត់មនុស្សបន្តិច ប៊ុនថា ទៅយកកង់ប្រុសរបស់មិត្ត មួយគ្រឿងដែលបញ្ឈរចោលនៅក្នុង រោងស្បៀងមួយខ្នង រួចហើយទ្រាប់នៅរានក្រោយកុំឲ្យរលាក់ ដើម្បី ដឹកយកខ្ញុំទៅឲ្យយាយ ម៉ប ចាប់សសៃឲ្យនៅភូមិថ្នល់តាសិត ។ យើង ជិះកង់ឌុបគ្នាចេញដំណើរពីទួលឆ្អេះ បានចម្ងាយប្រមាណជា៣០០ ម៉ែត្រ មិនទាន់ដល់ថ្នល់ជាតិផង ស្រាប់តែកង់យើងដាច់ដុំខាង ក្រោយទៅមុខលែងរួច ។ ភ្លាមៗនោះ ប៊ុនថា ចុះទៅក្នុងស្រែរើស បានកំណាត់ឈើមួយឲ្យខ្ញុំច្រត់ដើរត្រឹកៗត្រឡប់ក្រោយវិញហើយ ចំណែកគាត់លើកកង់ផ្នែកខាងក្រោយឲ្យខ្ពស់ផុតពីដីបណ្តើរបក ក្រោយដែរ ដោយលបយកទៅដាក់នៅកន្លែងដើមវិញស្ងាត់ៗ ដើម្បីគេចចេញពីការទទួលខុសត្រូវ ។ ចាប់ពីពេលនោះ រហូតមក ដល់សព្វថ្ងៃខ្ញុំមានជំងឺប្រចាំកាយមួយគឺថ្ងោះចង្កេះជាញឹកញាប់ ។

យប់មួយខ្ញុំដើរម្នាក់ឯងទៅលេងផ្ទះឯភូមិថ្នល់តាសិត ហើយនៅចន្លោះ ភូមិដូនរាជ និងភូមិថ្នល់តាសិតមានគម្លាតពីគ្នា ប្រហែលជា៥០០ម៉ែត្រ ស្ងាត់គ្មានផ្ទះទេ មានតែដើមឈើធំៗដុះ នៅសងខាងផ្លូវ និងមានស្ពានថ្មពីរនៅជិតគ្នា ស្ពានថ្មខាងលិចគឺជា ស្ពានបុស្សរីលក ។ មួយសន្ទុះធំក្រោយមក ទើបខ្ញុំដើរត្រឡប់មក វិញ (ដើរពីលិចមកកើត) ផុតភូមិថ្នល់តាសិតប្រហែល២០០ម៉ែត្រ គឺនៅខាងស្តាំដៃខាងត្បូង ថ្នល់ជាតិ មានដើមចំបក់ធំខ្ពស់មួយដើម ដុះនៅក្បែរផ្លូវលើចិញ្ចើមថ្នល់ជាតិ ហើយមែកឈើមួយចំហៀង ដើមខាងផ្នែកដែលខ្ញុំដើរ ស្រាប់តែមានសភាពរង់រីយ៉ាងខ្លាំងភ្លាមៗ មួយរំពេច បីដូចជាមានមនុស្ស២-៣នាក់អង្រួនយ៉ាងដូច្នោះដែរ ។ តែចំណែកមែកឈើមួយចំហៀងដើមនៅខាងឯណោះវិញ មាន សភាពស្ងប់ស្ងាត់ដូចធម្មតា ព្រោះក្នុងខណៈនោះពុំមានខ្យល់បកមក ឡើយ ។ រំពេចនោះ ខ្ញុំភ័យព្រឺក្បាលឡើយសំពោងប៉ុនអង្រ្គែត តែ ខិតខំប្រមូលស្មារតីឡើងវិញដោយតាំងចិត្តធ្វើហាក់បីដូចជាជួប រឿងធម្មតា គឺបានខិនរើសដុំថ្មចោលផង ដើរសំដៅទៅដើមឈើនោះ មែកឈើដែលបានរង់រីយ៉ាងខ្លាំងអម្បាញ់មិញ ស្រាប់តែបែរ ជាស្ងប់ស្ងាត់មួយរំពេចទៅវិញ ។ មានចាស់ទុំខ្លះបាននិយាយថា បើឃើញដូច្នេះ គឺជាពួកអមនុស្សគេស្រែកសួរនាំយើង ដោយ ចង់បាននូវចម្លើយឆ្លើយប្រាប់គេទៅវិញអំពីការធ្វើដំណើររបស់ យើង តើមកពីណា? ឬទៅណា? តែប៉ុណ្ណោះ ។ ខ្ញុំបន្តដំណើរទៅ មុខទៀតជិតដល់ស្ពានបុស្សរីលក ទើបជួបយុវជនម្នាក់នៅភូមិជា មួយស្គាល់គ្នាមានឈ្មោះ សុខ ហៅ អា អួងស្មងពុក ដើរប្រាស់ទិស គ្នាមកកាន់ភូមិថ្នល់តាសិតវិញ ។ ពេលខ្ញុំដើរទៅដល់ទួលឆ្អេះ ក្រោយ ពេលប្រាប់រឿង ហេតុទាំងអស់នោះ ប៊ុនថា បានប្រាប់មកវិញថា មិត្តឃើយ ឯងត្រូវបានខ្មោចលងហើយ ដូច្នេះកុំដើរទៅណាពេល យប់ម្នាក់ឯងទៀតរើយ ។

ចរិតពីកំណើតមក លោក ជា ប៊ុនថា មានអកប្បកិរិយា និង សំដីសំដៅមួយៗ ទន់ភ្លន់ គោរពចាស់ទុំ ព្រមទាំងមានចិត្តស្រឡាញ់ ហើយស្មោះស្ម័គ្រចំពោះបងប្អូនជីដូនមួយ ក៏ដូចជាបងប្អូនបង្កើតរបស់ គាត់ដែរ ។ ជាមួយគ្នានោះ កាលដែលយើងស្ថិតនៅក្នុងរបបកម្ពុជា ប្រជាធិបតេយ្យ ថ្វីត្បិតតែខ្ញុំ ជាប្រជាជនថ្មីអ្នក១៧មេសាក្តី តែ ប៊ុនថា មិនដែលមានការរើសអើងចំពោះរូបខ្ញុំម្តងណាឡើយ គឺគេ ហៅឲ្យមកធ្វើការជាមួយគ្នាពីរនាក់ទៀតផង ។ លើសពីនេះទៅ ទៀត ប៊ុនថា មានសន្តានចិត្តល្អជួយយកអាសាអ្នកដទៃដោយមិន ប្រកាន់ពណ៌សម្បុរ គឺពុំខុសគ្នាពីបងប្រុសបង្កើតរបស់គាត់ម្នាក់ ឈ្មោះ លោក ជា សូវេត នោះប៉ុន្មានទេ ។ រាល់ពេលដែលខ្ញុំនឹកឃើញ ពី ប៊ុនថា ម្តងៗ គឺនៅពេលនោះឯងហើយ ដែលខ្ញុំស្ទាក់ស្ទើរនៅក្នុង ចិត្ត ដោយមិនទាន់ជឿស៊ប់ថា ប៊ុនថា គេបានលាចាកលោកយើង នេះទៅហើយនោះទេ ។ គាត់គួរតែរស់នៅឲ្យបានយូរឆ្នាំជាងនេះ តទៅមុខទៀតទើបស័ក្តិសម ។

ប៊ុនថា កើតនៅឆ្នាំ១៩៥៥ ត្រូវនឹងឆ្នាំវក នៅភូមិរទាំង ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប ។ សោកស្តាយ ណាស់ ប៊ុនថា គេបានទទួលអនិច្ចកម្មទាំងមិនទាន់បានមើលឲ្យអស់ ចិត្តពីក្រុមគ្រួសាររបស់គាត់ផង នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៤ វេលាម៉ោង៤ល្ងាច ក្នុងជន្មាយុ៥៩ឆ្នាំ ដោយជម្ងឺលើសឈាម ។

**(តទៅលេខក្រោយ)**

**សៀង សុផុន**

# «សល់មួយគ្រាប់»

## រឿងរ៉ាវ គ្រួសារខ្ញុំ ក្នុងរបបដឹកនាំខ្មៅងងឹត

**(តពីលេខមុន)**

នៅក្នុងរបបខ្មែរក្រហម ថ្ងៃចាកចេញនោះ ខ្ញុំពាក់អាវពណ៌សដៃខ្លី និងខោជើងខ្លីពណ៌គគីរ ។ ជាឯកសណ្ឋានសិស្សសាលាក្នុងសម័យ លន់ នល់ ។ ខ្ញុំបានរៀបចំកាបូបស្ពាយ មានសៀវភៅ និងសម្ភារសិក្សាផ្សេងៗទៀត ។ ខ្ញុំបានដាក់សៀវភៅ ខ្មៅដៃ ប៊ិចចូលនៅក្នុងកាបូបស្ពាយនោះ ហើយខ្ញុំបានយកត្រីវិស័យ ពីបន្ទប់ឪពុករបស់ខ្ញុំដាក់តាមខ្លួន ដើម្បីការពារកុំឲ្យវង្វេងផ្លូវ ។ បើទោះបីខ្ញុំមិនចេះប្រើត្រីវិស័យក៏ដោយ ។ ខ្ញុំបានរុញរទេះតាមបណ្ដោយផ្លូវជាមួយហ្វូងមនុស្សជាច្រើន តាន់តាប់សំដៅទៅភូមិកំណើតរបស់ឪពុក ។ បងប្អូនរបស់ខ្ញុំទាំងអស់ រុញ និងដើរសងខាងរទេះ ។

កាបូបរបស់ខ្ញុំជាកាបូបស្ពាយចំហៀង មានពណ៌បៃតងចាស់ស្រដៀងទៅនឹងពណ៌ឯកសណ្ឋានរបស់ទាហានលន់ នល់ ។ ខ្មែរក្រហមបានសួរខ្ញុំថា តើខ្ញុំជាកូននាយទាហានមែនឬក៏មិនមែន? ។ ពួកគេបានរុះរើកាបូបខ្ញុំ ។ ត្រីវិស័យដែលមានពណ៌ដូចនឹងឯកសណ្ឋានទាហាន ជាឧបករណ៍របស់ទាហាន ។ ពួកគេបានយកត្រីវិស័យខ្ញុំទុក ហើយគ្រវែងសៀវភៅ និងរបស់របរក្នុងកាបូបខ្ញុំចោលទាំងអស់ ។ ម្ដាយខ្ញុំហាមមិនឲ្យតបត ។ វាជាលើកទីមួយហើយដែលខ្មែរក្រហមបានធ្វើឲ្យខ្ញុំឈឺចាប់ ។ ខ្ញុំស្រក់ទឹកភ្នែក ខ្ញុំមិនដែលធ្លាប់ជួបប្រទះរឿងអាក្រក់ គ្មានសីលធម៌ ដូចនេះទេពីមុនមកៗ ។ ពួកគេយកកាបូបរបស់ខ្ញុំ រួចបោះអីវ៉ាន់សម្ភារសិក្សាខ្ញុំចោលទាំងអស់ ហើយខ្ញុំមិនអាចធ្វើអ្វីតបតអ្វីទាំងអស់ ។ ខ្ញុំយំ ខ្ញុំស្ដាយសៀវភៅរបស់ខ្ញុំ តែម្ដាយគាត់អង្អែលខ្នងខ្ញុំ ។ តាមអ្វីដែលខ្មែរក្រហមបានបញ្ជាឲ្យចាកចេញ ពួកគេប្រាប់ពួកយើងថា យើងអាចត្រលប់មកវិញក្នុងរយៈពេលប៉ុន្មានថ្ងៃខាងមុខ ខ្ញុំក៏បានយកសម្ភារសិក្សារបស់ខ្ញុំមកតាមជាមួយ ដោយគិតថានឹងអាចឆ្លៀតពេលរៀនបានខ្លះ ។

បើតាមអ្វីដែលខ្ញុំចាំបាន ពួកយើងបានស្នាក់នៅតាមផ្លូវអស់រយៈពេលមួយយប់ មុននឹងទៅដល់ភូមិកំណើតរបស់ឪពុកខ្ញុំដែលមានឈ្មោះថា ភូមិព្រះម្លូ ស្ថិតនៅក្នុងឃុំបឹងខ្នារ ស្រុកបាកាន ។ យើងដើរតាមបណ្ដោយដងផ្លូវរហូត ។ បងប្អូនប្រុសស្រីរបស់ខ្ញុំនៅតូចៗនៅឡើយ ។ ពេលខ្លះម្ដាយខ្ញុំត្រូវពបី ពួកគេ និងជូនកាលដាក់ឲ្យជិះលើរទេះរុញម្ដាយខ្ញុំមិនដែលធ្លាប់ជួបនឹងការលំបាកនឿយហត់ និងការដើរផ្លូវឆ្ងាយរាប់សិបគីឡូម៉ែត្របែបនេះទេ វាជារឿងមួយលំបាកជាខ្លាំងសម្រាប់គាត់ ។ យើងត្រូវដើរដោយបន្ទំ ហើយត្រូវរុញរទេះអីវ៉ាន់ទៀតផង ក្រោមកំដៅថ្ងៃនាខែមេសា ។

យើងបានទៅដល់ភូមិកំណើតរបស់ឪពុកប្រហែលជិតល្ងាច ប៉ុន្តែយើងទាំងអស់គ្នាមិនត្រូវបានអនុញ្ញាតឲ្យស្នាក់នៅក្នុងភូមិនោះរយៈពេលយូរជាមួយក្រុមគ្រួសារឪពុកខ្ញុំទេ ។ ដោយសារភូមិនេះត្រូវបានខ្មែរក្រហមចាត់ទុកថាជា «តំបន់រំដោះ» មានន័យថាជាតំបន់សម្រាប់តែប្រជាជនចាស់រស់នៅប៉ុណ្ណោះ ។ យើងត្រូវបានខ្មែរក្រហមឲ្យទៅរស់នៅភូមិមួយទៀតចម្ងាយប្រហែលជា ៨ ឬ ១០គីឡូម៉ែត្រ ពីភូមិកំណើតឪពុកខ្ញុំ ជិតដៃបឹងទន្លេសាប ។ ជាភូមិរៀបចំថ្មីសម្រាប់ប្រជាជនថ្មីដែលមានឈ្មោះថា ភូមិបឹងត្រាង ឬសហករណ៍ត្រាង ។

ពេលដែលយើងបានធ្វើដំណើរឆ្លងកាត់ភូមិកំណើតឪពុកខ្ញុំ យើងមិនបានដឹងសោះឡើយថាពួកយើងត្រូវបានខ្មែរក្រហមចាត់ទុកថាជា «ប្រជាជនថ្មី» ។ យើងគ្រាន់តែចង់ស្វែងរកសាច់ញាតិរបស់យើងតែប៉ុណ្ណោះ ។ សាច់ញាតិយើងប្រហែលជាបានដឹងរឿងនេះហើយក៏មិនដឹង អ្នកខ្លះបាននិយាយមកកាន់យើង ប៉ុន្តែអ្នកខ្លះទៀតគេចមិននិយាយរកយើងទេ ។ អាចនឹងថាពួកគេបានដឹងពីអ្វីៗដែលគេហៅថាការបែងចែករវាងប្រជាជនថ្មី និងប្រជាជនចាស់ហើយមើលទៅ ។ ខ្ញុំបានឮសូរក្មេងៗហៅយើងថា «ពួកអាកូនអ្នកមានៗ» ដែលជាពាក្យបែងចែកដោយកំហឹង រួចជាស្រេចរវាងផារ

ជាអ្នកចាស់ និងអ្នកថ្មី ។ "កូនពួកអ្នកមាន អ្នកផ្សារ ពួកចក្រពត្តិ ។ល ។" ប្រជាជនចាស់ទាំងនោះប្រើប្រាស់ពាក្យពេចន៍របៀបនេះរួចស្រេចបាត់ទៅហើយ ។

គ្រួសាររបស់ខ្ញុំ បានកត់សម្គាល់ឃើញថាអត្តចរិតសាច់ញាតិខាងឪពុករបស់យើង មិនដូចកាលពីមុនដែលធ្លាប់បានដឹងនោះទេ ។ បែបទំនងជាគាត់ទាំងអស់មិនចង់ប្រដូចខ្លួនមក យើងដែលការណ៍នេះអាចនឹងធ្វើឲ្យប៉ះពាល់ដល់ប្រវត្តិរូបរបស់គាត់ដែលជាប្រជាជនចាស់ ក៏ថាបាន ឬអាចថាមានការប្រណែនដោយសារតែយើងធ្លាប់មានធនធានស្រណុកស្រួលពីមុនក៏មិនដឹង ។ដូច្នេះ គឺនៅក្នុងភូមិនេះឯងហើយដែលខ្ញុំបានឮសូរការប្រើប្រាស់ពាក្យបែកចែក តិះដៀលឈ្នានីស ថា "ប្រជាជនថ្មី និងប្រជាជនចាស់" ជាលើកទីមួយ ។

ខ្ញុំចាប់អារម្មណ៍ឃើញថាប្រជាជនចាស់ទាំងអស់ ស្លៀកពាក់ខោអាវពណ៌ខ្មៅដូចៗគ្នា ។ ស្រីៗទុកសក់ខ្លីៗ បែបសក់កូរ៉េ ។ ចំណែកយើងទៅដល់ក្នុងភូមិ ដោយមានសំលៀកបំពាក់ពណ៌ចម្រុះ និងប្រើទ្រនាប់ជើងខុសគេផង ។ ភាពខុសគ្នា គឺលេចឡើងយ៉ាងច្បាស់ ។ អ្នកភូមិមើលមកយើងដោយការមើលងាយ ឈ្នាសនីស ហើយចាត់ទុកយើងដូចជាសត្រូវរបស់ពួកគេពីយូរណាស់មកហើយ ។

ម្តាយខ្ញុំក៏បានឲ្យយើងយកសំលៀកបំពាក់ពណ៌ចម្រុះទាំងអស់ ទៅជ្រលក់ពណ៌ ដើម្បីឲ្យខោអាវយើងក្លាយទៅជាពណ៌ខ្មៅស្រដៀងនឹងគេ ។ ដើម្បីធ្វើយ៉ាងនេះ យើងបានបេះផ្លែឈើ និងសំបកដើមមាក្លឿ ដំវាឲ្យបែក រួចយកទៅដាំក្នុងទឹកឲ្យពុះ បន្ទាប់មកយើងយកខោអាវពណ៌ទៅត្រាំ ជ្រលក់ ក្នុងទឹកពុះនោះមួយសន្ទុះ ។ បន្ទាប់មកស្រង់ខោអាវចេញ ហើយដាក់ត្រាំទឹកត្រជាក់ និងជាន់នៅក្នុងភក់ ។ សំអាតឲ្យស្អាតភក់ រួចយកមកហាលថ្ងៃ ។ វាមិនបានជាពណ៌ខ្មៅល្អ ដូចគេទេ ប៉ុន្តែអាចស្រដៀងនឹងសំលៀកបំពាក់ប្រជាជនចាស់ដែរ ។

ខ្ញុំត្រូវបង្ខំចិត្តបោះស្បែកជើងប៉ាតាថ្មីដែលខ្ញុំធ្លាប់ពាក់វាទៅសាលានោះចោល ។ ខ្ញុំសុំស្បែកជើងធ្វើពីកង់ឡានចាស់ៗ ពីក្មេងៗដទៃទៀតដែលគេឈប់ប្រើ ។ ហេតុដូច្នេះហើយ បានជាយើងឃើញឡានដែលត្រូវគេបោះបង់ចោលនៅតាមផ្លូវទាំងនោះ ឥតមានកង់ទេ ។ ដោយសារតែគេដោះយកកង់ឡានទាំងនោះ ទៅកាត់ធ្វើជាស្បែកជើងអស់ហើយ ។ រថយន្ត លុយកាក់ គ្មានតម្លៃអ្វីទាំងអស់សម័យនោះ ។ លើកលែងតែមាស ថ្នាំពេទ្យ ពេលខ្លះអាចដូរជាត្រី អង្ករ ពីប្រជាជនចាស់ ។ អង្ករមានតម្លៃជាងមាស ។

យើងស្នាក់នៅភូមិព្រះម្លូបានប្រហែលតែប៉ុន្មានថ្ងៃប៉ុណ្ណោះ រួចហើយក៏ខ្មែរក្រហមបញ្ជូនឲ្យទៅភូមិត្រាង ។ ខ្ញុំមិនប្រាកដដឹងថានរណាទេដែលបានប្រាប់មកយើងថា យើងទាំងអស់គ្នាមិនត្រូវអនុញ្ញាតឲ្យស្នាក់នៅបន្តក្នុងភូមិព្រះម្លូទៀតទេ ។ ខ្ញុំគ្រាន់តែចងចាំថាយើងមិនអាចបន្តស្នាក់នៅទីកន្លែងនោះទៀតបាន ។ ខ្មែរក្រហមមិនចង់ឲ្យប្រជាជនថ្មីដែលជម្លៀសពីក្រុងពោធិ៍សាត់ រស់នៅលាយឡំគ្នាជាមួយនឹងអ្នកភូមិចាស់នោះទេ ដូច្នេះហើយ បានជាខ្មែរក្រហមដេញយើងឲ្យចេញទៅកាន់តែឆ្ងាយៗ ។ នេះប្រហែលជាគោលនយោបាយមួយរបស់ខ្មែរក្រហមហើយ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងមនុស្ស និងរុញកម្លាំងមនុស្សឲ្យទៅដល់កន្លែងធ្វើកសិកម្ម ។

ខ្ញុំក៏មិនបានដឹងឲ្យប្រាកដផងទេថា តើនរណាជាអ្នកដេញយើងឲ្យទៅភូមិបន្ទាប់ទៀត ។ ខ្មែរក្រហមបានយករទេះគោដើម្បីដឹកជញ្ជូនប្រជាជនថ្មី ។ យើងមិនអាចរុញរទេះរបស់យើងទៅមុខបានទៀតដែរ ដោយសារតែស្ថានភាពផ្លូវមានការលំបាក ។ អ្នកដែលជូនយើងអាចមិនមែនជាយោធាខ្មែរក្រហមទេ អ្នកទាំងនោះអាចជាប្រជាជនចាស់ដែលត្រូវបាន ខ្មែរក្រហមចាត់ឲ្យដឹកជញ្ជូនយើង ។ ប្រជាជនចាស់ទាំងនោះ មិននិយាយអ្វីច្រើនជាមួយប្រជាជនថ្មីទេ ។

ប្រមាណជាមួយឆ្នាំក្រោយមក នៅក្នុងរបបខ្មែរក្រហម ខ្ញុំជឿជាក់ថា ឪពុកខ្ញុំត្រូវបានសម្លាប់យ៉ាងពិតប្រាកដណាស់ ។ នោះដោយសារមូលហេតុថា ក្នុងរបបខ្មែរក្រហម នៅគ្រប់កិច្ចប្រជុំផ្សេងៗ អង្គការបាននិយាយថា "អង្គការឈ្នះដោយចុងអាវុធ" ហើយខ្មែរក្រហមប្រើប្រាស់ពាក្យប្លែកៗ ដោយចងគំនុំគួយ៉ាងដូចជាពាក្យថា "បដិវត្តន៍កម្ទេចខ្មាំងវណ្ណៈ កម្ទេចខ្មាំងសត្រូវ ពួកជនក្បត់ លន់ នល់ សិរិមតៈ ចេង ហេង និងបរិវារ" ជាដើម ។ សឹងតែរាល់ថ្ងៃមានសកម្មភាពចាប់ចង អ្នកបេះដូង អ្នកធ្លាប់រស់នៅទីក្រុងរួមមានគ្រូបង្រៀន និស្សិត ពេទ្យ មន្ត្រីរាជការ ជាដើម ជាពិសេស អង្គការតាមដានរកអតីតទាហានយកទៅកម្ទេចចោល ។ ដំបូងអង្គការសំដៅមករកប្រជាជនថ្មីទាំងអស់ ។ នៅពេលនោះហើយ ដែលខ្ញុំបានចាប់ផ្តើមយល់ច្បាស់នូវនយោបាយបោសសំអាតរបបចាស់ ។ កម្មាភិបាលខ្មែរក្រហមតាមសហករណ៍ បានប្រើប្រាស់ល្បិច ពាក្យបោក

បញ្ឆោត ជំនួស ពាក្យ កម្ទេច ជំនួសពាក្យ សម្លាប់ ដូចជាថា អង្គការស្នើយកបងប្អូនទៅកាប់ពោត ទៅវាយថ្ម ទៅរៀនសូត្រ ទៅកសាងខ្លួនជាដើម ។ មានប្រជាជនថ្មីខ្លះ បានដឹងពីការបោកបញ្ឆោតនោះដែរ តែខ្លះមិនទាន់ដឹង ។

## នៅភូមិត្រាង ឬសហករណ៍ត្រាង

ភូមិត្រាងប្រហែលជាមិនមែនជាភូមិរដ្ឋបាលពីមុននោះទេ តែគ្រាន់តែជាកន្លែងដែលមានខ្ទមតូចៗ ដែលព័ទ្ធទៅដោយវាលស្រែវាលល្វឹងល្វើយ តែប៉ុណ្ណោះ ។ ខ្ញុំគិតថាឈ្មោះ“ត្រាង” នេះអាចនឹងប្រហែលជាមកពីឈ្មោះរុក្ខជាតិម៉្យាងឈ្មោះត្រាង ។

ខ្ញុំបានស្នាក់នៅក្នុងភូមិនេះប្រហែលចំនួនពីរខែដែរ ។ ពីដំបូង ខ្ញុំនៅជាមួយម្ដាយខ្ញុំ ក្រោយមកខ្ញុំក៏បែកពីគាត់ ។ គ្រប់សមាជិកគ្រួសារទាំងអស់ត្រូវកម្មាភិបាល និងគណៈសហករណ៍គ្រប់ជាន់ថ្នាក់ចាប់ផ្ដើមបំបែកចេញក្នុងរយៈពេលត្រឹមតែប៉ុន្មានខែប៉ុណ្ណោះបន្ទាប់ពីយើងទៅដល់ ។

យើងត្រូវស្នាក់នៅក្នុងកូនខ្ទមតូចមួយប្រក់អំពីស្បូវ ។ ដំបូងអង្គការចែកអង្ករឲ្យយើងដោយសារយើងគ្មានសេសសល់អង្ករទៀតទេ ។ ប្រធានសហករណ៍បានបើកអង្ករឲ្យយើង ហើយបានកត់ឈ្មោះគ្រប់សមាជិកគ្រួសារទាំងអស់ ។ ប៉ុន្តែ អង្ករដែលចែកចាយនោះ មានបរិមាណយ៉ាងតិចតួចបំផុត ។ យើងត្រូវហូបបបរលាយជាមួយបន្លែផ្សេងៗ ដែលបេះបានពីវាលស្រែ និងពីក្នុងព្រៃហូបជំនួសបាយ ។ បើមិនដូច្នោះទេ យើងមិនអាចហូបអង្ករដែលអង្គការចែកនោះឲ្យបានយូរទេ ។ ម្ដាយខ្ញុំដាំជាបបរ ម្ដងលាយជាមួយដំឡូង ម្ដងលាយជាមួយដើមជ្រៃ ម្ដងលាយគល់ចេក ឬលាយត្រកួន ។ យើងហូបបបរលាយបន្លែទាំងនោះ ជាមួយអំបិល ឬប្រហុក ហើយម្ដងម្កាលអាចជាមួយត្រីប្រលាក់ ។ ទោះបីជាយើងរស់នៅក្នុងតំបន់ សម្បូរត្រី សម្បូរស្រូវក៏ដោយ ។ សូម្បីតែអំបិលក៏ខ្វះខាតដែរ ។

ត្រឹមតែពេលមួយខែ ពីរខែប៉ុណ្ណោះ យើងបានឃើញមនុស្សឈឺស្លាប់បន្តបន្ទាប់គ្នាអស់ជាច្រើន ។ អ្នកទាំងនោះស្លាប់ដោយគ្មានអ្វីហូប ឬស្លាប់ដោយសារជំងឺ ។ យើងបរិភោគទឹកដែលយើងអាចរកបាន ទោះបីជាហូរមកពីទីណាក៏ដោយ តួយ៉ាងដូចជាទឹកដែលគោក្របីផឹក ឬដេកជាដើម ឬពីអណ្ដូងរាក់ៗមិនមានអនាម័យ ។ អ្នកខ្លះទៀតស្លាប់ដោយសារជំងឺរាករូស គ្រុនចាញ់ ឬជំងឺហើម ។ ប្រជាជនចាស់បាននិយាយថា ប្រជាជនថ្មី ស្មោកគ្រោកណាស់ ស៊ីអាក្រក់អីចឹងហើយបានពួកវាឈឺស្លាប់រាល់ថ្ងៃ ។

ការងារដំបូងរបស់ខ្ញុំ គឺត្រូវចេញទៅឃ្វាលគោនៅជិតៗ ភូមិយ៉ាងទៀងទាត់រាល់ថ្ងៃ ។ ដូច្នេះ ខ្ញុំបានឃើញសាកសពមនុស្សដែលទើបកប់ថ្មីៗ ។ ខ្ញុំមិនដឹងថាសាកសពទាំងនោះជាសាកសពអ្នកណានោះទេ ហើយសាកសពខ្លះមិនទាំងបានកប់ ឬក៏កប់មិនត្រឹមត្រូវផង ។ សាកសពទាំងនោះមាននៅក្រៅភូមិក្បែរៗព្រៃ ឬតាមទួលកប់សព ហើយធុំក្លិនស្អុយអសោច ។ គ្មានការរៀបចំធ្វើបុណ្យសពទេ ។

នៅក្នុងរបបខ្មែរក្រហម យើងត្រូវបានបញ្ជូនឲ្យទៅធ្វើស្រែចម្ការ នៅតាមវាលស្រែឆ្ងាយៗពីភូមិ ។ ពេលឃើញរណ្ដៅធំៗយើងបានដឹងច្បាស់ថា នោះគឺជារណ្ដៅដែលបង្កឡើងដោយសំណល់ពីការទម្លាក់គ្រាប់បែក បេ-៥២ ឬ គ្រាប់ផ្លោងធំៗ ។ រណ្ដៅបែបនេះមានចំនួនច្រើនគួរសមដែរ រាយតាមវាលស្រែ ។ ជាញយៗយើងថែមទាំងអាចចាប់ត្រីពីរណ្ដៅទាំងនោះទៀតផង ដើម្បីយកមកដុតហូប ពេលដែលយើងទៅឃ្វាលគោ ។ នៅថ្ងៃមួយ មិត្តភក្តិរបស់ខ្ញុំម្នាក់បានចុះទៅក្នុងរណ្ដៅមួយដើម្បីចាប់ត្រី ហើយវាក៏បានឃើញលលាដ៍ក្បាលខ្មោចមនុស្សនៅក្នុងរណ្ដៅនោះ យើងក៏ត្រលប់ក្រោយវិញ ។ មិនច្បាស់ថា មានលលាដ៍ក្បាលខ្មោចមនុស្សក្នុងរណ្ដៅនោះប៉ុន្មានទៀតទេ ។

ពេលយប់ យើងត្រូវយកបាវប្រេកអង្ករ ដើម្បីធ្វើជាភួយដណ្ដប់កុំឲ្យរងា និងការពារកុំឲ្យមូសខាំ ។ គ្រួសារខ្លះបានយកភួយមកដែរ ប៉ុន្តែត្រូវប្ដូរយកជាអង្ករជាមួយនឹងប្រជាជនអ្នកមូលដ្ឋានចាស់ ។ គ្រួសារខ្លះទៀតបានយកគ្រឿងអលង្ការដូរជាមួយនឹងអង្ករ និងស្ករ ។ ខ្មែរក្រហមបានលុបបំបាត់រូបិយប័ណ្ណ ដូច្នេះនៅពេលដែលអង្គការរកឃើញលុយនៅក្នុងកាបូបយើង វាគ្រវាត់ចោលយ៉ាងឆ្ងាយ ឬដុតចោល ទោះបីជារូបិយប័ណ្ណប្រទេសណាក៏ដោយ ។ នេះគឺជាការផ្លាស់ប្ដូររបៀបរស់នៅទាំងស្រុងតែម្ដង ។

ប្រជាជនថ្មីមិនហ៊ានរក្សាទុកមាស និងរូបិយប័ណ្ណរបស់ខ្លួននោះឡើយ ។ ខ្លះបានយកទៅឲ្យគណៈសហករណ៍ ព្រោះថាបើក្រុមកម្មាភិបាលខ្មែរក្រហម តាមសហករណ៍រកឃើញលាក់ទុក នៅតាមកូនខ្ទមអ្នកណាម្នាក់ ។ កម្មាភិបាល ឬប្រជាជនចាស់ ដែលមានឥទ្ធិពល

នឹងរាយការណ៍ ហើយមានសិទ្ធិចាប់ប្រជាជនថ្មីទាំងនោះទៅកសាង ទៅពិន័យ ឬអាចយកទៅសម្លាប់ចោលបានដោយងាយស្រួល ។

ការរស់នៅរបស់ប្រជាជនថ្មី ខុសប្លែកពីប្រជាជនចាស់ ដោយសារតែប្រជាជនចាស់មានផ្ទះផ្ទាល់ មានសម្ភារប្រើប្រាស់ជាកម្មសិទ្ធិ ។ គ្មានអ្នកណាមានសិទ្ធិ ឆែកឆេរផ្ទះផ្ទាល់ ឬ សួរនាំបានឡើយ ។ បើប្រជាជនចាស់ទាំងនោះឃើញប្រជាជនថ្មី ទៅជិតផ្ទះរបស់ខ្លួន គេអាចចោទទម្លាក់កំហុសបានគ្រប់យ៉ាង ។ "គំលាតការរស់នៅ ខុសគ្នាហាក់ដូចជាមេឃ និងដី" ។ ចំណែកយើងជាប្រជាជនថ្មីវិញមានតែរបស់របរដែលយើងអាចយកមកតាមខ្លួនបានតែប៉ុណ្ណោះ ។

មានគ្រួសារអ្នកមូលដ្ឋានចាស់ប្រហែលជាដប់គ្រួសារដែររស់នៅក្នុងភូមិត្រាង ។ អ្នកទាំងអស់ សុទ្ធតែមានតួនាទីនៅក្នុងភូមិ ជាកម្មាភិបាល ។ ប្រជាជនចាស់ទាំងនោះ ជាអ្នកគ្រប់គ្រងសហករណ៍ ជាប្រធានកង ប្រធានចុងភៅ ប្រធានសេដ្ឋកិច្ច ឬប្រធានសង្គមកិច្ច ។ កូនៗរបស់ពួកគេទាំងនោះ ក៏មានតួនាទីដឹកនាំកងកុមារដែរ ។ ខ្លះជាគ្រូបង្រៀន ខ្លះជាកងឈ្លប ឬខ្លះទៀតជាអ្នកដឹកនាំការងារដទៃទៀត ។ អ្នកទាំងនោះស្លៀកពាក់ខោអាវពណ៌ខ្មៅដូចប្រជាជនថ្មីយើងដែរ ។ ប៉ុន្តែសំពត់ខោអាវរបស់ពួកគេសុទ្ធតែថ្មីៗ និងប្រើប្រាស់ក្រមាពណ៌ឆ្នូត ស-ក្រហម ឬ ឆ្នូត ស-ខៀវ ហើយពាក់មួកកន្ទឹបដូចកងទ័ពចិន កុម្មុយនីស្ត ។

នៅពេលប្រជុំម្តងៗ កម្មាភិបាល និងគណៈដឹកនាំការងារទាំងនោះ និយាយថា កម្មាភិបាល ប្រជាជនចាស់ ទទួលបញ្ជាពីគណៈតំបន់ ហើយគណៈតំបន់ ទទួលបញ្ជាពីប្រធានគណៈភូមិភាគពាយ័ព្យ ។ ទាំងអស់គ្នាទទួលបញ្ជាពីអង្គការថ្នាក់លើ ។ អង្គការជាភ្នែកម្នាស់ អង្គការដឹងអ្វីៗទាំងអស់ អង្គការជាអ្នកកំណត់ជោគវាសនារបស់ប្រជាជន ។ អង្គការ តំណាងឲ្យវណ្ណៈកម្មករ និងកសិករ ។ ខ្ញុំមិនយល់ពាក្យ អង្គការ នោះឲ្យស៊ីជម្រៅទេនៅពេលនោះ ។

កាលពីដំបូង ប្រជាជនថ្មីអាចដាំស្លហូបចុក ជាគ្រួសារនៅក្នុងខ្ទមបាន ។ ប៉ុន្តែក្រោយមកទៀតប្រជាជនថ្មីទាំងអស់ត្រូវបានគេប្រមូលផ្តុំឲ្យហូបបាយរួមគ្នា នៅកន្លែងហូបរួមមួយក្នុងភូមិ ។ ចានឆ្នាំង និងសម្ភារផ្ទះបាយផ្សេងៗត្រូវបានអង្គការរឹបអូស ។ ប្រសិនបើប្រជាជនចាស់ណាម្នាក់ ឃើញមានផ្សែងហុយចេញពីខ្ទមណាមួយនៃប្រជាជនថ្មី កងឈ្លបនឹងមកមើលភ្លាមថាយើងកំពុងធ្វើអ្វី ។ ភូមិនីមួយៗមាន "ឈ្លប" ជាអ្នកតាមដានគ្រប់សកម្មភាពរបស់ប្រជាជនថ្មីទាំងយប់ទាំងថ្ងៃ ។ ឈ្លបទាំងនោះភាគច្រើនជាក្មេងៗ ដែលជាកូនចៅរបស់ប្រជាជនចាស់ ។ ឈ្លបទាំងនោះ ក៏ប្រហែលជាអ្នកមានសិទ្ធិកំណត់ថា អ្នកណាខុស ឬត្រូវ ។ ប្រជាជនថ្មីទាំងអស់ខ្លាចឈ្លបគ្រប់ៗគ្នា ។

ទាំងអស់គ្នាត្រូវតែចុះធ្វើស្រែ ក្រោមការដឹកនាំដោយប្រជាជនចាស់ទាំងនោះ ដែលជាគណៈសហករណ៍ ជាប្រធានកង ជាប្រធានក្រុម ។ល ។ ផលស្រូវដែលប្រមូលបានត្រូវស្តុកទុកនៅក្នុងទីកន្លែងរួមមួយ ឬអាចដាក់តាមផ្ទះប្រជាជនចាស់ ដែលអ្នកគ្រប់គ្រងសហករណ៍ទុកចិត្ត ។ នៅពេលដែលទីកន្លែងនោះពេញ អង្គការនឹងផ្ទេរទៅកាន់ជង្រុកតូចៗ នៅតាមផ្ទះកម្មាភិបាលជាប្រជាជនចាស់ ។ កម្មាភិបាលខ្មែរក្រហមក៏ធ្វើជាហូបបបរដូច យើងអ្នកថ្មីដែរ ។ ប៉ុន្តែគេហូបដោយឡែក តាមក្រោយនៅផ្ទះរបស់គេ ។ អ្នកចាស់ទាំងនោះមានអង្ករ និងម្ហូបសម្រាប់បម្រុងទុកតាមផ្ទះ ។ អង្គការហាមប្រជាជនថ្មី មិនឲ្យទៅជិតកន្លែងស្តុកស្រូវ ឬកន្លែងស្តុកស្បៀងផ្សេងៗទៀតទេ ។

ប្រជាជនថ្មី ទាំងក្មេងទាំងចាស់ ស្លាប់ជារៀងរាល់ថ្ងៃដោយសារតែធ្វើការហត់ហួសកម្លាំង និងគ្មានអ្វីហូបគ្រប់គ្រាន់ ។ ប្រជាជនចាស់ក៏មិនមានទម្លាប់ជាមួយនឹងលក្ខខណ្ឌរស់នៅនឹងការងារធ្ងន់បែបនេះដែរ ប៉ុន្តែពួកគេមានអាហារហូបគ្រប់គ្រាន់ ហើយពួកគេមិនសូវធ្វើការជាប់លាប់ឡើយ ។ ពួកគេមានរបបប្រជុំជីវភាពដោយឡែក ដែលប្រជាជនថ្មីមិនបានឲ្យចូលរួមទេ ។ ខ្ញុំធ្លាប់បានឃើញគេសែងមនុស្សស្លាប់ចេញពីភូមិញឹកញាប់ ដើម្បីយកទៅកប់នៅក្រៅភូមិ ។ សាកសពទាំងនោះ ត្រូវបានរុំនឹងកន្ទេលចាស់ៗតែប៉ុណ្ណោះ ។ រយៈពេលខ្ញុំរស់នៅក្នុងភូមិត្រាងនោះមិនដែលឃើញប្រជាជនចាស់ស្លាប់ទេ ។

## ការបែងចែកក្រុម

នៅពេលដែលយើងទៅដល់ភូមិត្រាង គណៈគ្រប់គ្រងសហករណ៍ បានធ្វើការបែងចែកប្រជាជនថ្មីទាំងក្មេងទាំងចាស់ និងអ្នកជម្លៀសថ្មីៗទៀត ទៅតាមប្រភេទការងារផ្សេងៗ និងជាក្រុមៗ ។ គណៈសហករណ៍បែងចែក ម្តាយខ្ញុំឲ្យទៅធ្វើការជាមួយអ្នកដទៃ

ទៀត ដែលហៅថាជា ក្រុមមនុស្សវ័យកណ្តាល ។ ក្រុមនេះ មានភារកិច្ចធ្វើស្រែ និងការងារកសិកម្មដទៃទៀត ។ ជាក្រុមស្នូលមានភារកិច្ចសំខាន់ផលិតស្បៀងសម្រាប់បម្រើសមរភូមិមុខ ។ ចំណែកក្មេងៗ ត្រូវបានអង្គការបែងចែកជាក្រុមៗដែរ ។

របៀបបែងចែកក្រុមកុមារា-កុមារី ។ ដំបូង គណៈសហករណ៍ ឬប្រធានកង ឬប្រធានក្រុម ឲ្យក្មេងៗឈរជាជួរ ហើយពិនិត្យមើល បើកុមារា កុមារីណា មានកម្ពស់ខ្ពស់ល្មម នឹងឲ្យចូលក្នុងក្រុមកងចល័ត ហើយបន្ទាប់មក ត្រូវបានបញ្ជូនឲ្យទៅធ្វើការឆ្ងាយពីភូមិ ។ បងស្រីខ្ញុំពីរនាក់ត្រូវបានដាក់ឲ្យធ្វើការនៅក្នុងក្រុមកងចល័ត ដោយសារមានកម្ពស់ខ្ពស់ល្មម ។ ទោះបីជាគាត់ទាំងពីរមានអាយុតិចក៏ដោយ ។ បើមានកម្ពស់មិនសូវខ្ពស់ អង្គការឲ្យចូលក្នុងក្រុមកងកុមារដែលត្រូវឲ្យទៅធ្វើការក្នុងភូមិ ឬភូមិជិតៗ ។ អង្គការបានចាត់ខ្ញុំចូលក្នុងកងកុមារ ។ កុមារតូចៗមិនទាន់អាចធ្វើការបាន ត្រូវបានគេដាក់ឲ្យនៅមួយក្រុម សម្រាប់ជួយធ្វើការក្នុងភូមិតិចតួច ។

ក្រុមកងយុវជន ចល័តជាក្រុមទី១ ជាក្រុមសំខាន់បំផុត ។ ក្មេងៗ និងយុវជនអាចមានអាយុចន្លោះពី១៤ ទៅ២០ឆ្នាំ ហើយត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅក្រៅភូមិ សមរភូមិមុខ ដូចជា ជីកប្រឡាយ ធ្វើទំនប់ទឹកជាដើម ។ ក្រុមកងកុមារ ជាក្រុមទី២ មានក្រុមក្មេងៗ ដែលមានអាយុពី៩ ដល់១៣ឆ្នាំ ។ កុមារទាំងនេះក៏ត្រូវបានបញ្ជូនឲ្យចេញទៅធ្វើការនៅក្រៅភូមិដែរ ប៉ុន្តែនៅជិតភូមិជាងក្រុមយុវជនចល័ត ដោយមិនឲ្យទៅណាឆ្ងាយពីភូមិទេ ។ ការងាររបស់កងកុមារ គឺត្រូវសំអាតអាចម៍គោតាមក្រោល រើសអាចម៍គោតាមស្រែ ដើម្បីយកមកធ្វើជី ឃ្វាលគោ និងជួយកិច្ចការដកស្ទូងពេលថ្ងៃ និងបោកស្រូវ ពេលយប់ ហើយក៏បានរៀនសូត្រខ្លះៗដែរ និងហាត់សិល្បះ ។

ក្រុមទីបីជាកុមារតូចៗ មានអាយុតិចជាង៩ឆ្នាំ ។ កុមារទាំងនេះអាចនៅជាមួយឪពុកម្តាយរបស់គេបាន ហើយអាចទៅសាលាបានច្រើន ។ ប៉ុន្តែមិនមែនជាសាលាដូចនៅសម័យមុនទេ ។ វាគ្រាន់តែជាកន្លែងជម្រកមួយ ដែលមានតុវែងវាយភ្ជាប់នឹងកៅអី ហើយតុនេះទៀតសោតគឺគ្មានអ្វីក្រៅពីក្តារពីរបន្ទះវែងនោះទេ វាដូចជាតុ កន្លែងហូបបាយរួមដែរ និងចុងក្រោយជាក្រុមទីបួនមានអាយុក្រោម៥ឆ្នាំ ។ ពួកគេត្រូវបានដាក់ផ្តុំគ្នានៅក្នុងភូមិ ដែលមានយាយចាស់ៗជាអ្នកមើលការខុសត្រូវ ។ ប៉ុន្តែ វាក៏មិនមែនជាទីកន្លែងសមរម្យសម្រាប់ទារកដែលមានអាយុស្របារនោះសម្រាកដែរ ពីព្រោះនៅពេលយប់វាគឺជាកន្លែងរោងគោដេកតែប៉ុណ្ណោះ ។

ខ្ញុំបានទៅរៀនពីរ ឬបីដងក្នុងមួយអាទិត្យ រយៈពេល២ម៉ោង ពេលព្រឹក ឬពេលល្ងាច ក្រោមរោងប្រក់ស្លឹកត្នោតចាស់មួយ ។ មួយអាទិត្យ យើងធ្វើការ៧ថ្ងៃ ។ ភាគច្រើន អង្គការឲ្យយើងរៀនទ្រឹស្តីបដិវត្តន៍ ។ អង្គការបានបង្រៀនយើងជាអាទិ៍ថាកងទ័ពខ្មែរក្រហមមានចិត្តក្លាហាន លះបង់ជីវិត ហ៊ានប្រយុទ្ធតតាំងនឹង «ខ្មាំងសត្រូវ ជាមហាអំណាចជាចក្រពត្តិ» ដើម្បីរំដោះទឹកដី ធ្វើឲ្យប្រជាជនរស់នៅស្មើភាពគ្នា គ្មានអ្នកមាន គ្មានអ្នកក្រ ។ យើងក៏រៀនដែរ អំពីកិច្ចការ នៅក្នុងផ្នែកកសិកម្ម ដូចជារបៀបធ្វើស្រែ ធ្វើជីជាដើម និងគណនាលេខបន្តិចបន្តួច ។ តាមពិត ការរៀនសូត្រទាំងនេះ គ្មានអ្វីលំបាកសម្រាប់ខ្ញុំឡើយ ពីព្រោះក្នុងរបប លន់ នល់ ខ្ញុំបានរៀនជិតចប់ថ្នាក់បឋមសិក្សាហើយ ។ គ្មានសៀវភៅសរសេរសម្រាប់កត់ត្រាអ្វីទេ ។ យើងយកដីឥដ្ឋមកលុញ ដើម្បីសរសេរលើផ្ទាំងក្តារលាបពណ៌ខ្មៅ ។ សមមិត្តគ្រូ គាត់ជាអតីតយោធាសមរភូមិមុខ តែគាត់ពិការដៃម្ខាង របួសពេលប្រយុទ្ធគ្នា ។ សមមិត្តគ្រូ មានអាយុប្រហែល ២៥ ឬ២៦ឆ្នាំ ។ គាត់មានចំណេះដឹងច្រើនជាងសមមិត្តគ្រូៗដទៃទៀត ។ ចប់ពីរៀន យើងត្រូវបន្តការងារភ្លាម ។ មេកងរបស់យើង រង់ចាំជិតៗនោះ ជូនកាលមេកង ក៏បង្រៀនដែរ ។

**(តទៅលេខក្រោយ)**

**ហ៊ែម សុខណ្ណារិទ្ធិ**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm ។ ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម




មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ វ៉ាន់ថាន់ ពៅដារ៉ា ទូរសព្ទលេខ ០១២ ៨៤៦ ៥២៦ ឬ អ៊ីម៉ែល ៖ truthpdara@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។




***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។




***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 206, 2017 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.